ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ




# ច្បាប់ស្តីពីហិរញ្ញវត្ថុ

## សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

## ច្បាប់ និងបទប្បញ្ញត្តិ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មករា ២០១៨

# មាតិកា


**ផ្នែកទី១៖ បទឧទ្ទេសនាមរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងឱកាសពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

**ផ្នែកទី២៖ ក្របខ័ណ្ឌនៃការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- សារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០
- សារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៧ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- កំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់លេខ ០០៥ សហវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់លេខ ១៧ សជណ.កបច ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

**ផ្នែកទី៣៖ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- ព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
  - ✓ តារាង “ក១” ស្តីពីចំណូលថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
  - ✓ តារាង “ក២” ស្តីពីចំណូលថវិការាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
  - ✓ តារាង “ខ១” ស្តីពីចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
  - ✓ តារាង “ខ២” ស្តីពីចំណាយថវិការដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
  - ✓ តារាង “គ១” ស្តីពីចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស
  - ✓ តារាង “គ២” ស្តីពីចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស (គម្រោងឥណទាន និងឥណទានភ្ជាប់សន្យា)
  - ✓ តារាង “ឃ” ស្តីពីចំណាយមូលធននៃថវិកាថ្នាក់ជាតិ (ឥណទានភ្ជាប់សន្យា និងឥណទានទូទាត់)

**ផ្នែកទី៤៖ អនុក្រឹត្យអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- អនុក្រឹត្យលេខ ២៣៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកចំណូលថវិកាថ្នាក់ជាតិតាមជំពូក
- អនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក
- អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការផ្ទេរឥណទានថវិកា

**ផ្នែកទី៥៖ ប្រកាសអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- ប្រកាសលេខ ១៤៥២ សហវ.អថ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- ប្រកាសលេខ ១៤៥៣ សហវ.អថ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្នែកក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី នៃមាតិកាថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- ប្រកាសលេខ ១៤៥៤ សហវ.អថ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការផ្ទេរឥណទានថវិកា
- ប្រកាសលេខ ១៤៥៥ សហវ.អថ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- ប្រកាសលេខ ១៤៥៦ សហវ.អថ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកឥណទានចំណាយថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

**ផ្នែកទី៦៖ ចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- ចំណូលថវិកាថ្នាក់ជាតិ
- ចំណាយថវិកាថ្នាក់ជាតិ

**ផ្នែកទី៧៖ ចំណូល-ចំណាយថវិកាថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨**

- ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

# បទឧទ្ទេសនាម

## របស់

## បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី,

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ក្នុងឱកាសពិភាក្សា

## សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

*រដ្ឋសភា, ថ្ងៃទី ១៧ ខែ ឥច្ឆិកា ឆ្នាំ ២០១៧*

**ខ្ញុំបាទសូមគោរព ៖**

**-សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;**

**-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;**

**-ឯកឧត្តមបណ្ឌិតអនុប្រធានទី ២ នៃរដ្ឋសភា;**

**-សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា, នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!**

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨** ចូលក្នុងរបៀបវារៈរបស់ខ្លួន ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍លម្អិតបន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះដែរ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង; ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ ។

## I - អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៨

ជាបរិការណ៍ទូទៅ, ឆ្នាំ ២០១៨ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ៤ ផង និង ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ ផង ។ ដូចនេះ, រាជរដ្ឋាភិបាលត្រូវធានាឱ្យការបោះឆ្នោតទាំងពីរនេះ ប្រព្រឹត្តទៅដោយរលូន, មានសណ្តាប់ធ្នាប់ និង ប្រកបដោយតម្លាភាព; ទន្ទឹមនឹងការធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទូទៅ ជាពិសេស ការធានារក្សាការពារឱ្យបានដាច់ខាត នូវសុខសន្តិភាព និងស្ថិរភាពសង្គម, ដែលសម្រេចបានមកដោយលំបាក, ឱ្យស្ថិតស្ថេរគង់វង្សចីរកាល ។ ម៉្យាងទៀត, និន្នាការនៃការផ្លាស់ប្តូរថ្មីនៅក្នុងបរិការណ៍ពិភពលោក, ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយ ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រសេដ្ឋកិច្ច និង ទាំងក្នុងទិដ្ឋភាពចរន្តនយោបាយ-សង្គម រួមទាំងបញ្ហាសន្តិសុខនៅក្នុងតំបន់ និងពិភពលោក, អាចនឹងបង្កើនកម្រិតហានិភ័យដល់សេដ្ឋកិច្ចពិភពលោក ឱ្យកាន់តែខ្ពស់ថែមទៀត ទោះបីស្ថានភាពសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្នកំពុងមានលក្ខណៈប្រសើរជាងបណ្តាឆ្នាំកន្លងទៅក្តី ។ ហេតុនេះ, កម្ពុជាត្រូវខិតខំទ្វេរដងថែមទៀត ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ហើយត្រូវមានភាពហ្មត់ចត់ និងភាពប្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងហានិភ័យផ្សេងៗជាប់ជាប្រចាំ ។

## II- អំពីសមិទ្ធិផលសំខាន់របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា និងគោលដៅនៃថវិកាឆ្នាំ ២០១៨

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញអនុវត្តឱ្យបានជោគជ័យនូវវិធានការគោលនយោបាយសំខាន់ៗ នៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ឆ្ពោះទៅរកការសម្រេចឱ្យបានពេញលេញជាអតិបរមានូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលត្រូវបាន និង កំពុងត្រូវបានអនុវត្តយ៉ាងសស្រាក់-សស្រាំ, តាំងពីដើមនីតិកាលមក, ដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរដ៏រាចរនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍ថ្មី, ទាំងកម្រិតជាតិ និង អន្តរជាតិ ។

ជារួម, រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរបស់ខ្លួនរហូតមក, ធានាបានជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេស ធានា និង រក្សាបាននូវសន្តិភាព, សន្តិសុខ, អធិបតេយ្យភាព, ការអភិវឌ្ឍ និង កំណើន សេដ្ឋកិច្ច ព្រមទាំងលំនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន; ទោះបីត្រូវប្រឈមនឹងបញ្ហាគ្រប់បែប-យ៉ាង, ទាំងក្នុង និង ក្រៅប្រទេសក៏ដោយ ។

អាស្រ័យដោយខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុ បានគូសរំលេចរួចហើយ អំពីសមិទ្ធផលសំខាន់ៗនៃនីតិកាលទី ៥ នេះ ទាំងការគ្រប់គ្រងល្អខាងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងល្អខាងផ្នែកហិរញ្ញវត្ថុសាធារណៈ, ដូចនេះ ដើម្បីចំណេញពេល ខ្ញុំបាទសូមធ្វើការគូសបញ្ជាក់ជារួមថា ៖

ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ និង ស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច ក្នុងបរិការណ៍ អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព ព្រមជាមួយនឹងលទ្ធផលល្អប្រសើរនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់នៅទូទាំងប្រទេស កាន់តែមានឱកាសក្នុងការស្វែងរកការងារ និង ក្នុងការបង្កើនប្រាក់ចំណូល ដោយក្នុងនោះ មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ទទួលបាននូវប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់បៀវត្សក្នុងគោលដៅជាង **១ លានរៀល** ឱ្យបាននៅត្រឹមឆ្នាំ ២០១៨ ហើយនិវត្តជនក៏បានទទួលនូវការបង្កើនប្រាក់សោធននិវត្តន៍ និង របបតាវកាលិកផ្សេងទៀត ជាបន្តបន្ទាប់ផងដែរ ។ ដូចគ្នានេះដែរ, កម្មករ-និយោជិតរាប់សែននាក់ទៀតដែលកំពុងតែម្រើការងារក្នុងវិស័យឯកជន ក៏ទទួលបាននូវឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួន តាមរយៈគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករ-និយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និង ផលិតស្បែកជើងជារៀងរាល់ឆ្នាំ, ដែលនៅឆ្នាំ ២០១៨ ប្រាក់ឈ្នួលអប្បបរមានេះ នឹងត្រូវកើនឡើងដល់ចំនួន ១៧០ ដុល្លារអាមេរិក ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀត ពីការអនុវត្តគោលនយោ-បាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ។ ក្រៅពីនេះ, រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធាន-ការគោលនយោបាយចាំបាច់នានា ជាបន្តបន្ទាប់ ក្នុងគោលដៅដោះស្រាយការលំបាក, ក្តីកង្វល់, និង បំណងប្រាថ្នារបស់ប្រជាជន, ដូចជា ការលុបចោលមិនយកកម្រៃពីសេវាសាធារណៈចាំបាច់មួយចំនួន, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, រួមមាន ការលុបប័ណ្ណបើកបរទោចក្រយានយន្ត, ការលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តកម្លាំងក្រោម ១៥០សេសេ, កម្រៃសេវាសាធារណៈលើលិខិតបញ្ជាក់កំណើត, អាពាហ៍ពិពាហ៍, លើការផ្តល់អត្តសញ្ញាណប័ណ្ណ ជាដើម; ការបញ្ចុះថ្លៃថាមពលអគ្គិសនី និងទឹកស្អាត; ការលុបចោលរបបពន្ធម៉ៅការ; ការដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់-ពន្ធ; ការលើកលែងពន្ធប្រថាប់ត្រាក្នុងរង្វង់សាច់ញាតិ; ការលុបចោលការបង់ភាសុី និង ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង, កញ្ជើ, ល្អី; ការអនុញ្ញាតឱ្យអាជីវករដែលមានតូប, រាន, ស្តង់ ឬកន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ប្រើប្រាស់ និង អាស្រ័យផល ហើយអាចផ្ទេរសិទ្ធិនេះបាន; ព្រមទាំងការលុបចោលពន្ធសត្តឃាត និង

ការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្មសត្តឃាតដ្ឋាន ជាដើម, បាន និងកំពុងតែផ្តល់ជាគុណ-ប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេស អ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ, គ្រូបង្រៀន, គ្រូពេទ្យ និង កម្មករ-និយោជិត ក៏ដូចជាដល់អ្នកប្រកបអាជីវកម្មតូចតាចផងដែរ ។

ជាមួយគ្នានេះ, ការគ្រប់គ្រងបានល្អ រឹងមាំ និង ដោយចីរភាពនៃថវិកាជាតិ, ទាំងនៅក្នុងផ្នែកចំណូល និងទាំងនៅក្នុងផ្នែកចំណាយ ជាពិសេស ការសម្រេចបាននូវកំណើនចំណូលដ៏ខ្ពស់ និង មិនធ្លាប់មាននៅក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ, បាននាំកម្ពុជា ដែលធ្លាប់មានចំណូលថវិកាជាតិធៀបនឹង ផសស ទាបជាងគេក្នុងតំបន់, ឱ្យឈានឡើងដល់កម្រិតកណ្តាលធៀបនឹងគេវិញ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ក៏បានផ្តល់ការវាយតម្លៃខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា **មិនធ្លាប់មានពីមុនមកនៅក្នុងបណ្តាប្រទេសក្នុងតំបន់** ។ បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨, ចំណូលចរន្ត-ថវិការដ្ឋកើនឡើងជាងពីរដង, ពីប្រមាណ ២ ២៦៤ លានដុល្លារអាមេរិក ដល់ប្រមាណ ៤ ៥៦០ លានដុល្លារអាមេរិក ។ ជាលទ្ធផល, ការកើនឡើងនៃទំហំចំណូលនេះ បានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលបង្កើនចំណាយយ៉ាងច្រើនទៅលើការលើកកម្ពស់គុណភាព និង ការពង្រីកវិសាលភាពនៃសេវាសាធារណៈ, ទាំងតាមរយៈចំណាយចរន្តថវិកាជាតិ និង ទាំងតាមរយៈចំណាយវិនិយោគសាធារណៈ, ដើម្បីធ្វើឱ្យការផ្តល់សេវាសាធារណៈមានភាពកាន់តែប្រសើរឡើង និង កាន់តែខិតជិតនឹងប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់ ។ បើគិតពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨, ចំណាយសរុបថវិការដ្ឋត្រូវបានបង្កើនជិតពីរដង; ក្នុងនោះ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានបង្កើនជាងបីដង, ចំណាយសរុបរបស់ក្រសួងសុខាភិបាលត្រូវបានបង្កើនជិតពីរដងកន្លះ, ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទត្រូវបានបង្កើនជិតបីដង ហើយចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្កើនជិតពីរដងកន្លះ ។ មួយវិញទៀត, សមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេសក្នុងចំណែកថវិកាជាតិ បានថយចុះ ពីប្រមាណជិត ៧០% នៅក្នុងឆ្នាំ ១៩៩៥ មកនៅត្រឹមតែប្រមាណ ២១,៤% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៧ ហើយនឹងបន្តថយចុះថែមទៀតនៅមិនដល់ ២០% ផងទេ នៅឆ្នាំ ២០១៨ ។ **ប្រការនេះ គឺជាការសបញ្ជាក់ឱ្យឃើញថា កម្ពុជាកាន់តែមានឯករាជ្យភាពខាងថវិកាជាងមុន និង កាន់តែមានភាពជាម្ចាស់ជាងមុន ដែលនេះគឺជាផលផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្ត, ក្នុងឆន្ទៈប្តូរផ្តាច់ឥតងាករេ, នូវវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលត្រូវបានចាប់ផ្តើមតាំងពីនីតិកាលមុនមក** ។

ឈរលើមូលដ្ឋានខាងលើនេះ, ថវិកាឆ្នាំ ២០១៨ **គឺជាគោលនយោបាយវិស្តារកម្មថវិកាប្រយ័ត្នប្រយែង** ក្នុងគោលដៅថែរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់កំណើនក្នុងរយៈពេលខ្លី ព្រមទាំងបង្កើតលក្ខខណ្ឌចាំបាច់ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង ជាពិសេសដើម្បីធានាចលនការនៃការកែទម្រង់ ដែលរាជរដ្ឋាភិបាលបាន និង កំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំ តាំងពីដើមនីតិកាលមក ហើយក៏កំពុងបន្តតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និង អាទិភាពគោលនយោបាយសំខាន់ៗ ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគិតគូរផងដែរ ទៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៤ និង ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ និង ការត្រៀមខ្លួនទប់ទល់នឹងវិបត្តិ ដែលអាចកើតមានឡើងដាយថាហេតុ ក៏ដូចជាផ្តល់ការឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា, ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស, ទាំងក្នុងក្របខ័ណ្ឌតំបន់ និង ពិភពលោក, ជាពិសេស ដើម្បីសម្រេចឱ្យបានជាអតិបរមានូវ គោលដៅជាយុទ្ធសាស្ត្រទាំង ៤ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ។

## III - អំពីគោលការណ៍នៃការរៀបចំថវិកាឆ្នាំ ២០១៨

ក្នុងគោលដៅខាងលើនេះ, ថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **<u>គោលការណ៍គ្រឹះ</u>** ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៤ ដែលក្នុងនោះរួមមាន ៖

(១)- ធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន, ផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកើនឡើងកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិ;

(២)- ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការគ្រប់គ្រងបាននូវអតិផរណា និង ការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ;

(៣)- បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដោយផ្តោតជាពិសេសលើសកម្មភាពកែទម្រង់ដែលផ្តល់លទ្ធផលភ្លាមៗ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន តាមការសន្យារបស់រាជរដ្ឋាភិបាលនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន ក៏ដូចជាការពង្រឹងគ្រឹះក្នុងការកសាង ស្ថាប័ន និង សមត្ថភាពនៃវិស័យសាធារណៈ; និង

(៤)- ផ្តល់ការលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នណា ដែលអនុវត្តសកម្មភាពការងាររបស់ខ្លួនប្រកបដោយបុរេសកម្ម និង មានសមិទ្ធកម្ម ឬ លទ្ធផលការងារល្អ ។

ឈរលើគោលការណ៍គ្រឹះទាំងនេះ, ថវិកាឆ្នាំ ២០១៨ ត្រូវបានផ្តោតជាពិសេសទៅលើ៖

(១)- ការបន្តដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធឱ្យបានជាង **១ លានរៀល** ដើម្បីបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធឱ្យកាន់តែល្អប្រសើរផង និង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផង;

(២)- ការបន្តវិនិយោគលើធនធានមនុស្ស ព្រមជាមួយនឹងការជំរុញអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៧-២០២៥ របស់រាជរដ្ឋាភិបាល;

(៣)- ការកែទម្រង់សំដៅលើកកម្ពស់ និង កែលម្អប្រសិទ្ធភាព និង គុណភាពសេវាសាធារណៈក្នុងគ្រប់វិស័យ ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការរបស់ប្រជាជន; និង

(៤)- ការផ្តល់អាទិភាពលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវបានកសាងរួច ដើម្បីបន្តជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចទាំងក្នុងរយៈពេលខ្លី មធ្យម និង វែង ក៏ដូចជាដើម្បីដោះស្រាយតម្រូវការប្រចាំថ្ងៃរបស់ប្រជាជន ។

## IV- អំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ ៦,៩% ដូចឆ្នាំ ២០១៧ ដែលធ្វើឱ្យទំហំសេដ្ឋកិច្ចជាតិ (ផសស ថ្លៃបច្ចុប្បន្ន) កើនឡើងដល់ជាង ៩៩, ១ ទ្រីលានរៀល សមមូលនឹងប្រមាណជាង ២៤,៥ ប៊ីលានដុល្លារអាមេរិក, ខណៈដែល ផសស សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៥៦៨ ដុល្លារអាមេរិក ។ និយាយជារួម, ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចបានកំណត់ខាងលើនេះ, យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ, នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, ខណៈដែលបញ្ហាប្រឈម និងហានិភ័យកាន់តែកើនឡើង,ទាំងខាងក្នុង,ទាំងខាងក្រៅ,ដែលតម្រូវឱ្យកម្ពុជាបន្តប្រកាន់ខ្ជាប់នូវអប្បមាទខ្ពស់ ។

## V - អំពីក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨

លើមូលដ្ឋាននៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលការណ៍ ដូចបានគូសរំលេចខាងលើ, ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំឡើងក្រោមការកំណត់ដូចតទៅ៖

**១-ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ចំណូលក្នុងប្រទេសថវិកាជាតិ** ត្រូវបានគ្រោងចំនួន ១៨ ៥៨៧ ០០៣ លានរៀល, សមមូលនឹងប្រមាណ ៤ ៦០៤ លានដុល្លារអាមេរិក, ត្រូវ- ជា ១៨,៧៥% នៃ ផសស, និង មានកំណើន ១១,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ។ ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨ មានគោលដៅបង្កើន **ចំណូលចរន្តថវិការដ្ឋ** ឱ្យបានស្មើនឹង ១៨,៥៧% នៃ ផសស ដែលមានកំណើនចំនួន ០,១៧ ពិន្ទុភាគរយ នៃ ផសស ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ។

**២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៤ ៣៧៥ ១០២ លានរៀល, សមមូលនឹងប្រមាណជាង ៦ ប៊ីលានដុល្លារអាមេរិក, ត្រូវដា ២៤,៥៩% នៃ ផសស, និង មានកំណើន ១៥,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៧; ក្នុងនោះ

**ចំណាយចរន្តថវិការដ្ឋ** ត្រូវបានគ្រោងចំនួន ១៥ ៩៤៥ ៤១៨ លានរៀល, សមមូលនឹង ប្រមាណជាង ៣,៩ ប៊ីលានដុល្លារអាមេរិក, ត្រូវដា ១៦,០៩% នៃ ផសស, និង មានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ។

## VI - អំពីគម្រោងចំណូលចំណាយ-ថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០១៨ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិ ឱ្យមានទំហំស្មើ នឹង ១៧, ៦ ទ្រីលានរៀល, សមមូលនឹងប្រមាណជាង ៤,៣ ប៊ីលានដុល្លារអាមេរិក, ត្រូវដា ១៧,៨០% នៃ ផសស, គឺមានកំណើន ១២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ។ ក្នុង-ក្របខ័ណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះបានរៀបរាប់ រួចហើយ អំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ (ដែលត្រូវ បានដាក់ចេញសម្រាប់ អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានពន្ធដារ ដែលជាអង្គភាពប្រមូលចំណូលធំពីរ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផ្ទាល់) និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងអំពីគោលដៅចំណូលមូលធន, ទាំងចំណូលមូលធន-ក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស ។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលា, ខ្ញុំបាទ សូមការអនុញ្ញាតមិនអធិប្បាយនូវចំណុចទាំងអស់នោះសាជាថ្មីឡើងវិញទេ។

### ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

#### ក-១- <u>អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ</u>

ដូចបានគូសបញ្ជាក់ នៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ នេះ, ថវិកាថ្នាក់ជាតិឆ្នាំ ២០១៨ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុង កម្រិត ចំនួន ១៥ ២១៨ ១៦៦ លានរៀល, សមមូលនឹងប្រមាណជាង ៣, ៧ ប៊ីលានដុល្លារ អាមេរិក, ត្រូវដា ១៥,៣៥% នៃ ផសស, គឺមានកំណើន ១៦,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៧, ដែលក្នុងនោះ ៖

**ក.១.១-<u>ចំណាយលើបន្ទុកបុគ្គលិក:</u>** មានកំណើន ១៦,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៧, ត្រូវដា ៧,៩៩% នៃ ផសស និង មានសមាមាត្រស្មើនឹង ៥២,០% នៃចំណាយចរន្តថវិកា-ថ្នាក់ជាតិ ។ ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា អាទិភាពនៃចំណាយនេះ ត្រូវបានផ្តោតលើការ-គ្រោងសម្រាប់ ៖ (១)-**ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១២,០% ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ២០១៨; និង** (២)-**ការដំឡើងប្រាក់បំណាច់មុខងារដែលនឹងត្រូវអនុវត្ត ចាប់ពីខែ មេសា ដល់ ខែ ធ្នូ ឆ្នាំ ២០១៨** ។ តាមរយៈវិធានការនេះ, ស្ថានភាពបៀវត្សអប្ប-បរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ នឹងកើនឡើងដល់គោលដៅជាង **១ លានរៀល** របស់រាជ-

រដ្ឋាភិបាល ។ ដូច្នេះ, ជារួម, **នៅឆ្នាំ ២០១៨ បៀវត្សអប្បរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានកើនឡើងជិត ៣ ដង ធៀបនឹង ឆ្នាំ ២០១៣** ។

ក្រៅពីការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យដល់ជាង ១ លានរៀល ក្នុងមួយខែ, **រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន ផងដែរ** ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានសម្រេចផ្តល់ និង ដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន ២ មុខទៀត ដោយអនុវត្តចាប់ពីខែ មករា ឆ្នាំ ២០១៨ ដែលរួមមាន ៖

(១)- **ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាព ដល់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី** ដោយបង្កើនពី ៦០ ម៉ឺនរៀល ទៅចំនួន ៨០ ម៉ឺនរៀល សម្រាប់ការសម្រាលបានកូនមួយ និង ចំនួន ១ លាន ៦ សែនរៀល សម្រាប់ការ-សម្រាលបានកូនភ្លោះពីរ និង ចំនួន ២ លាន ៤ សែនរៀល សម្រាប់ការ-សម្រាលបានកូនភ្លោះបី;

(២)- **ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព** ដោយក្នុងម្នាក់ៗ ត្រូវបានដំឡើងពីចំនួន ចំនួន ១ លាន ២ សែនរៀល ទៅ ២ លានរៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និង ដំឡើងពីចំនួន ១ លាន ៥ សែនរៀល ទៅ ៤ លានរៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬ គ្រោះថ្នាក់ការងារ ។

ជាមួយគ្នានេះដែរ, ប្រាក់ឧបត្ថម្ភចំពោះមន្ត្រីជាប់កិច្ចសន្យា និង ចំពោះនិវត្តជន, ទាំងផ្នែកមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ, ក៏ត្រូវបានគ្រោងដំឡើងផងដែរ ស្របតាមគោលនយោបាយកំណត់របស់រាជរដ្ឋាភិបាល ។

**ក.១.២-<u>ចំណាយក្រៅបន្ទុកបុគ្គលិក:</u>** មានកំណើន ១៦,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៧, ត្រូវជា ៧,៣៧% នៃ ផសស និង មានសមាមាត្រស្មើនឹង ៤៨,០% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ។

**ក.២- <u>អំពីទិដ្ឋភាពនៃការបែងចែកចំណាយចរន្តថវិកាថ្នាក់ជាតិតាមវិស័យ</u>**

ជារួម, ចំណាយចរន្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៨ ត្រូវបានវិភាជន៍ដោយផ្អែកលើតម្រូវការ និង អាទិភាពចាំបាច់ រួមទាំងការអនុវត្តនូវកម្មវិធីថ្មីមួយចំនួន ទៅតាមវិស័យនីមួយៗ ស្របតាមគោលការណ៍នៃការរៀបចំថវិកា ដូចបានគូសបញ្ជាក់ពីខាងដើម ។ ប៉ុន្តែដើម្បីចំណេញពេល, ខ្ញុំបាទគ្រាន់តែសូមធ្វើការគូសរំលេចកញ្ចប់ថវិកា ដែលត្រូវបានវិភាជសម្រាប់អនុវត្តគោលនយោបាយថ្មីមួយចំនួនរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានជាអាទិ៍ ៖

- *ការផ្តល់ថវិកាចំនួន ២០ ប៊ីលានរៀល ជា **"មូលនិធិទ្រទ្រង់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា"**, បន្ថែមលើថវិកាជាង ៤០ ប៊ីលានរៀល ដែលត្រូវផ្តល់ជូនមន្ទីរពេទ្យគន្ធបុប្ផា នៅឆ្នាំ ២០១៨, ដើម្បីជានាថាមន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និង ការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល នៅពេលមានការផ្ទេរការគ្រប់គ្រងពីលោកវេជ្ជបណ្ឌិត Beat Richner ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលវិញនោះ;*
- *ការគាំទ្រដល់ **ការពង្រីកមូលនិធិសមធម៌** ដើម្បីផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃជូនដល់កម្មករ-និយោជិត (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) ដែលមិនទាន់ស្ថិតក្រោមបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) ឱ្យទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌ ដោយឥតគិតថ្លៃ ដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ;*
- ***ការគាំទ្រដល់ការឧបត្ថម្ភមាតុភាព ដល់កម្មករ-និយោជិត** ដោយបើកផ្តល់ថវិកាចំនួន ៤០ ម៉ឺនរៀល ចំពោះការសម្រាលកូនមួយ និង ថវិកាចំនួន ៨០ ម៉ឺនរៀល ចំពោះការសម្រាលបានកូនភ្លោះពីរ និង ថវិកាចំនួន ១ លាន ២ សែនរៀល បើសម្រាលបានកូនភ្លោះបី ។*

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

### ខ.១- <u>គម្រោងចំណាយមូលធន</u>

ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោងចំនួន ៨ ២១០ ១៣២ លានរៀល, សមមូលប្រមាណជាង ២ ប៊ីលានដុល្លារអាមេរិក, មានកំណើន ១៥,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៧, មានសមាមាត្រស្មើនឹង ៣៥,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ៨,២៨% នៃ ផសស ដែលក្នុងនោះ ៖

(១)- គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ មានកំណើន ៣៤,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ហើយត្រូវជា ២,៩៥% នៃ ផសស ដែល**ឆ្លុះបញ្ចាំងពីការកើនឡើងនៃសមត្ថភាព និងឯករាជ្យភាពខាងថវិការបស់កម្ពុជា,** ក៏ដូចជាអំពីការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការបង្ហូរទុនវិនិយោគសាធារណៈកាន់តែច្រើន ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និង បង្កើតការងារក្នុងស្រុក ។

(២)- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស មានកំណើនត្រឹម ៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ហើយត្រូវជា ៤,៥៩% នៃ ផសស ។

ខ.២- <u>ការកំណត់ពិតាននៃការខ្វីសម្រាប់ឆ្នាំ ២០១៨</u>

រាជរដ្ឋាភិបាលបានកំណត់ពិតានក្នុងការខ្វីសម្រាប់ឆ្នាំ ២០១៨ ក្នុងកម្រិត **១ ប៊ីលានអេសដេអ៊ែរ** ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និងមានទំហំកាន់តែធំឡើងៗ សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ដែលចេះតែរីកលូតលាស់ពីឆ្នាំមុនៗមក ហើយត្រូវរង់ចាំការចុះហត្ថលេខា ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទសូមគូសបញ្ជាក់ថា ជារួម, ការបង្កើនទំហំនៃការខ្វីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះសមត្ថភាពសងរបស់កម្ពុជាក៏កើនខ្ពស់ជាងមុនដែរ ហើយនៅក្នុងការអនុវត្ត, រាជរដ្ឋាភិបាលនឹងបន្តគោរពឥតងាករេ នូវគោលការណ៍គ្រឹះទាំង ៤ យ៉ាងរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅក្នុងការគ្រប់គ្រងបំណុល ដូច**ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានធ្វើរបាយការណ៍ពីខាងដើម, ពោលគឺ ៖ (**១**)- ត្រូវខ្វីឥណទាន ក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន, (**២**)- ត្រូវខ្វីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់, (**៣**)- ត្រូវខ្វីសម្រាប់តែ វិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និង វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬ ផលិតភាព ផលិតកម្ម, និង (**៤**)- ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និង ស័ក្តិសិទ្ធិភាពខ្ពស់បំផុត ។

## VII - អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៨

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានឱនភាពថវិកាចំនួន ៧៣៧ ៨៧០ លានរៀល, សមមូលនឹងប្រមាណ ១៨៣ លានដុល្លារអាមេរិក, ហើយដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ **ដែលការឧបត្ថម្ភនេះ មានកំណើន ១៥,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៧, ត្រូវជា ០,៧៤% នៃ ផសស** ។ ជារួម, **ពីឆ្នាំ ២០១៣ ដល់ ឆ្នាំ ២០១៨, ចំណាយសរុបនៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនឡើងជាងពីរដងកន្លះ, ពីប្រមាណ ១៦០ លានដុល្លារអាមេរិក ដល់ប្រមាណ ៤១៧ លានដុល្លារអាមេរិក ។**

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្តល់ដល់ការដំឡើងប្រាក់បៀវត្សជូនដល់ ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខ័ណ្ឌ, ឃុំ-សង្កាត់ និង មន្ត្រីភូមិ ផងដែរ ដូចមានគូសរំលេចពិស្តារនៅក្នុងសេចក្តីថ្លែងហេតុ ។

## VIII - អំពីតុល្យភាពរួមនៃថវិកាឆ្នាំ ២០១៨

នៅក្នុងក្របខ័ណ្ឌ<u>ថវិការដ្ឋ</u> ឬ <u>ថវិកាជាតិ</u>ខាងលើ, ទាំង<u>ថវិកាថ្នាក់ជាតិ</u> និង <u>ថវិកាថ្នាក់ក្រោមជាតិ</u>, រាជរដ្ឋាភិបាលអាចរក្សា **អតិរេកថវិកាចរន្ត** ឱ្យបានក្នុងកម្រិតប្រមាណ ២,៤៨%

នៃ ផសស នៅឆ្នាំ ២០១៨, ធៀបនឹង ២,៩៨% នៃ ផសស គ្រោងក្នុងច្បាប់ឆ្នាំ ២០១៧ នេះ ។ ជាលទ្ធផល, **ឱនភាពថវិកាជាតិសរុប** នឹងមានទំហំប្រមាណ -៥,៨៤% នៃ ផសស គឺកើនឡើងពីកម្រិតនៃឱនភាពក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៧ ដែលស្មើនឹង -៥,០៧% នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយ**ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំប្រមាណ ៤,៥៩% នៃ ផសស, **មូលនិធិទ្រទ្រង់ថវិកា**ប្រមាណជា ០,២៥% នៃ ផសស និង **ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល** ប្រមាណ ១,០០% នៃ ផសស ។ ក្នុងន័យនេះ, **ថវិកាឆ្នាំ ២០១៨ ត្រូវបានរៀបចំក្នុងលក្ខណៈវិត្តារកម្ម ដោយមានការប្រយ័ត្នប្រយែង; ប៉ុន្តែ ការវិភាជថវិកា, ជាគោលការណ៍, ត្រូវបានផ្តល់អាទិភាពទៅលើតែមុខចំណាយចាំបាច់ខ្លាំងបំផុតប៉ុណ្ណោះ** ។

## IX - **បទឧប្បញ្ញត្តិស្តីពីពន្ធដារ**

ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរបស់មន្ត្រីរាជការ និងកម្មករ-និយោជិត រួមទាំងប្រជាពលរដ្ឋទូទៅផង ក៏ដូចជាក្នុងគោលបំណងជំរុញកៀរគរចំណូលឆ្នាំ ២០១៨ ឱ្យទទួលបានលទ្ធផលតាមគោលដៅដែលបានគ្រោងទុក ជាពិសេស ដើម្បីធានាបាននូវចីរភាពក្នុងការប្រមូលចំណូលប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ក៏បានបញ្ចូលផងដែរនូវ **បទប្បញ្ញត្តិស្តីពីពន្ធដារ ចំនួន ៣ មាត្រា** ។ ខ្ញុំបាទសូមមិនអធិប្បាយលម្អិតលើបណ្តាសំណើកែសម្រួលបទប្បញ្ញត្តិស្តីពីពន្ធដារនោះទេ ក៏ប៉ុន្តែសូមអនុញ្ញាតគូសរំលេចចំណុចសំខាន់ៗមួយចំនួនដូចតទៅ៖

**ទី១.ធ្វើការលុបចោលពន្ធសត្តឃាត** ដើម្បីសម្រាលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើសាច់សត្វដែលជាអាហារមូលដ្ឋានសម្រាប់ចិញ្ចឹមជីវិត ក៏ដូចជាដើម្បីជួយលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងថែមទៀត និង បន្ទរបន្តយសម្ពាធលើថ្លៃម្ហូបអាហារជារួមផងដែរ ។

**ទី២.ធ្វើការកែសម្រួលមាត្រា ៤៧ ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធ ឱ្យឡើងដល់ ១ លាន ២ សែនរៀល** ដើម្បីផ្តល់ការ-លើកទឹកចិត្ត និង លើកកម្ពស់កម្រិតជីវភាពដល់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ ជាពិសេស គ្រូបង្រៀន និង គ្រូពេទ្យ ព្រមទាំងកម្មករ-និយោជិត ដែលមានប្រាក់បៀវត្សទាប នៅក្នុងបរិការណ៍នៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ឱ្យបានជាង ១ លានរៀល ក្នុងមួយខែ នៅឆ្នាំ ២០១៨ និង ការអនុវត្តគោលនយោបាយដំឡើងប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មករ-និយោជិត ក្នុងវិស័យវាយនភណ្ឌកាត់ដេរ និង ផលិតស្បែកជើង ជារៀងរាល់ឆ្នាំ ហើយដែលប្រាក់ឈ្នួលអប្បបរមានេះ នឹងកើនឡើងដល់ចំនួន ១៧០ ដុល្លារអាមេរិក នៅឆ្នាំ ២០១៨ ។

ខ្ញុំបាទសុំយកឱកាសនេះ គួសបញ្ជាក់បន្ថែមជូនអង្គសភាទាំងមូលជ្រាបថា វិធានការផ្នែកពន្ធដារខាងលើនេះ គឺត្រូវបានរៀបចំឡើងក្រោមការចង្អុលបង្ហាញ និងណែនាំដោយផ្ទាល់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងតែយកចិត្តទុកដាក់ខ្ពស់ដល់ជីវភាពរស់នៅរបស់មន្ត្រីរាជការគ្រប់ប្រភេទ និងជីវភាពរស់នៅ និង សុខមាលភាពរបស់ប្រជាពលរដ្ឋទូទៅគ្រប់ៗគ្នា ។

**ទី៣.ការបញ្ចូលបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និង ធនធានរ៉ែក្នុងច្បាប់ស្តីពីសារពើពន្ធ** ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាចាំបាច់នូវបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និង ធនធានរ៉ែ ជាពិសេស ដើម្បីធានាបាននូវប្រសិទ្ធភាព និង តម្លាភាពនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងប្រេងកាត រវាងរាជរដ្ឋាភិបាលជាមួយនឹងប្រតិបត្តិករធ្វើប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ (A) ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ។

## X- សេចក្តីសន្និដ្ឋាន

ការរៀបចំថវិកាឆ្នាំ ២០១៨ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម ព្រមទាំងហានិភ័យមួយចំនួនយ៉ាងណាក្តី, ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជសម្រាប់អនុវត្តអាទិភាពគោលនយោបាយសំខាន់ៗជាសារវន្ត ដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបន្តសម្រេចបាននូវលទ្ធផលជាក់ស្តែងបន្ថែមទៀតជូនប្រជាជន ពិសេសនៅក្នុងឆ្នាំ ២០១៨ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី ៥ នៃ រដ្ឋសភា ។

សរុបមក, ដោយយោងលើមូលហេតុ និង ឈរលើមូលដ្ឋាននៃការគិតគូរខាងលើនេះ-ហើយ ទើបរាជរដ្ឋាភិបាលប្រសិទ្ធនាមថវិកាឆ្នាំ ២០១៨ ថាជា **"ថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និង ធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព, ស្ថេរភាព, ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និង ចីរភាព តទៅមុខឥតឈប់ឈរ ក្នុងនីតិកាលបន្តបន្ទាប់ទៀត"**។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ, សូមសម្តេចអគ្គមហាពញាចក្រី និង អង្គសភាទាំងមូល មេត្តាពិនិត្យ និង ផ្តល់ការអនុម័តលើ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨** ដោយអនុគ្រោះ។

*សូមអរគុណ !*



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :០៦៣.ស.ណ.៤

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

## ១. សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដើម្បីឱ្យក្រសួង-ស្ថាប័ននីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៨។ នៅជំហានបន្ទាប់នៃដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាលត្រូវដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះ សម្រាប់ជាជំនួយដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិការយៈពេល បីឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំនៅដំណាក់កាលទីមួយ នៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/ ០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-

ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ពន្យល់ និង បង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញ ច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធីយ៉ាងច្បាស់លាស់, អំពី សូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធី សមស្របនឹងទំហំថវិកា និង លទ្ធភាពថវិកាដែលមាន ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ ក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣**" និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង "**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**"។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយ ត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយ ដែល គ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈ រដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ។

ទន្ទឹមនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកា មូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាគន្លឹះមិនអាចខ្វះបាន ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាព និងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការ លើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិសម្រាប់វិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ក្នុងន័យនេះ *ក្រសួង-ស្ថាប័ន នីមួយៗ ចាំបាច់ត្រូវជុំវិញ និងលើកទឹកចិត្តដល់ក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពី នាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង ឱ្យ ដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់*។ **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬ ឆ្លុះបញ្ចាំងនៅ ក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាង ពិតប្រាកដ ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណង គោលនយោបាយ និងរវាងកម្មវិធី ដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

ជារួម ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍មួយយ៉ាងសំខាន់ សម្រាប់ភាពជោគជ័យនៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ គឺ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២០)** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦។ ថ្វីត្បិតការរៀបចំផែនការ យុទ្ធសាស្ត្រថវិកា ត្រូវបានកែលម្អជាលំដាប់ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០០៨ ប៉ុន្តែ គុណភាព និង ប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា មិនទាន់ឈានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយ។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗ ចាំបាច់ត្រូវកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ ស្របតាម គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ព្រមទាំងស្មារតី និង

លទ្ធផលនៃការចរចាថវិកាឆ្នាំ ២០១៧ កន្លងទៅ, និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ ជាពិសេសការគ្រោងវិភាជចំណាយតាមវិស័យនៃចំណាយចរន្តថវិកាថ្នាក់ជាតិ ដូចមានកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (ផ្នែក **២.២**) ខាងក្រោមនេះ។ *ទន្ទឹមនេះ ដើម្បីលើកកម្ពស់គុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ គ្រប់ក្រសួង-ស្ថាប័នចាំបាច់ត្រូវរៀបចំឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងលើកិច្ចការនេះឱ្យបានច្បាស់លាស់បន្ថែមទៀត អំពីតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ ព្រមទាំងអាចដាក់ចេញជាគោលការណ៍ណែនាំផ្ទៃក្នុង ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាគោលការណ៍ណែនាំផ្ទៃក្នុងសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំផងដែរ ជាពិសេស សម្រាប់ក្រសួង-ស្ថាប័នដែលមិនទាន់បានបង្កើតនូវយន្តការនេះ ឬ ក៏បានបង្កើតរួចហើយ តែដំណើរការគ្មានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួង-ស្ថាប័ននីមួយៗ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អទៅវិញទៅមក ដោយអនុញ្ញាតឱ្យ**ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមី មានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្មតាមគម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។*

ស្របតាម **"ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០"** ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗពីការផ្តោតលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង-ស្ថាប័នចំនួន ៣ ចុងក្រោយ រួមមាន÷ ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ នឹងត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និង អង្គភាពថវិកា ចាប់ពីឆ្នាំ២០១៨ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកាកម្មវិធីនៅក្នុងឆ្នាំ២០១៧ ស្របតាមប្រតិទិន នៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចក្រសួង-ស្ថាប័នចំនួន ៣៦ ដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ ២០១៧ នេះ។ ប្រការនេះបានធ្វើឱ្យយុទ្ធសាស្ត្រនៃការពង្រីកការដាក់អនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័នថ្នាក់ជាតិ នៅត្រឹមឆ្នាំ ២០១៨ សម្រេចគោលដៅតាមការគ្រោងទុក។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាឆ្ពោះទៅរកលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់-គ្រងថវិកា និងលើការអនុវត្តថវិកា ត្រូវបានផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នសាមី ចំណែកឯសិទ្ធិអំណាចនៃការទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីអគ្គនាយកដ្ឋាន/នាយកដ្ឋានហិរញ្ញវត្ថុ/គណនេយ្យរបស់ក្រសួង-ស្ថាប័ន ទៅអង្គភាពថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ កាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចខាងក្រោម÷

**២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ:**

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ បានផ្តល់ទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយ ដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបានហើយតាមរយៈនេះ បង្កើតបានជាលំហថវិការួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាចកំណត់អាទិភាពសកម្មភាពការងារសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនេះ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជា អំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។

ក្នុងន័យនេះ ដោយផ្អែកលើមូលដ្ឋាននៃ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូ-សេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម÷

**២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច**

ផ្អែកលើចលនការកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជានៃឆ្នាំកន្លងមក និងភាពនៅតែល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ព្រមទាំងសកម្មភាពសេដ្ឋកិច្ចនៅតែរស់រវើកនៅដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៧ ត្រូវបានព្យាករថា អាចសម្រេចបានក្នុងរង្វង់ ៧% តាមការគ្រោងទុកដូចដែលបានដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ។ ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៨ ខាងមុខនេះវិញ, តាមការព្យាករបឋម សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនរឹងមាំក្នុងរង្វង់ ៧%។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ២,០% និងកំណើនវិស័យឧស្សាហកម្មប្រមាណ ១០,១% ដែលវិស័យនេះគាំទ្រដោយវិស័យកាត់ដេរ, និងសំណង់ ជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ ក្នុងនោះ វិស័យកាត់ដេរអាចមានកំណើនប្រមាណ ៨,០% និងវិស័យសំណង់អាចសម្រេចបានប្រមាណ ១២,៤% ព្រមទាំងកំណើនវិស័យសេវាកម្មដែលអាចនឹងសម្រេចបានក្នុងរង្វង់ ៦,៧%។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ នៅឆ្នាំ ២០១៧ តាមការព្យាករ នឹងស្ថិតក្នុងកម្រិត ៣,៨% គឺខ្ពស់ជាងការព្យាករ ដែលបានដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ប៉ុន្តែ អាចនឹងថយចុះមកត្រឹម ៣,៥% វិញ នៅឆ្នាំ ២០១៨។ អត្រាប្តូរប្រាក់នៅឆ្នាំ ២០១៧ ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានតម្លៃជាមធ្យម ៤ ០៣៧ រៀលក្នុង ១ ដុល្លារអាមេរិក គឺទាបជាងការព្យាករដែលបានដាក់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។ ទន្ទឹមនេះ តាមការព្យាករ នៅឆ្នាំ ២០១៨ អត្រាប្តូរប្រាក់ជាមធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ ៤ ០៣៧ រៀលក្នុង ១ ដុល្លារអាមេរិក ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងប្រសិទ្ធភាពក្នុងការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោល-នយោបាយរូបិយវត្ថុបានល្អ។

ឱនភាពគណនីចរន្តនៅឆ្នាំ ២០១៧ តាមការប៉ាន់ស្មាននឹងមានកម្រិត ៧,៩% នៃ ផ.ស.ស. គឺមានការកើនឡើងបន្តិច បើធៀបនឹងឆ្នាំ ២០១៦ ដែលមានកម្រិត ៧,៦% នៃ ផ.ស.ស.។ ទន្ទឹមនេះ តាមការព្យាករឱនភាពគណនីចរន្ត នឹងកើនឡើងបន្តិចទៀតទៅដល់ ៨,៥% នៃផ.ស.ស. នៅឆ្នាំ ២០១៨។ និន្នាការនៃការកើនឡើងឱនភាពគណនីចរន្ត គឺដោយសារការរំពឹងទុកអំពីកំណើនយឺតបន្តិចនៃការនាំចេញ ខណៈឆ្នាំ ២០១៨ ជាឆ្នាំបោះឆ្នោតសកល ហើយការនាំចូលត្រូវបានរំពឹងថា នឹងនៅតែកើនឡើងស្របគ្នាទៅនឹងនិន្នាការកើនឡើងជាបន្តបន្ទាប់នៃផលិតកម្មក្នុងស្រុកដើម្បីបម្រើឱ្យការប្រើប្រាស់ក្នុងស្រុក ដែលរួមចំណែកកាន់តែធំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ នៅឆ្នាំ ២០១៧ ទុនបម្រុងនឹងមានទំហំ ៧ ៥៣៨ លានដុល្លារអាមេរិក និង នៅឆ្នាំ ២០១៨ អាចកើនឡើងរហូតដល់ ៧ ៨៥៣ លានដុល្លារអាមេរិក ដែលធានាការនាំចូលប្រមាណជាង ៥,៥ ខែ។

**២.២ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ:**

ដើម្បីសម្រេចបានតាមគោលដៅក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨ ដូចខាងក្រោម÷

- ជានាកំណើនចំណូលចរន្ត ដើម្បីឈានទៅសម្រេចឱ្យបាន ១៨,៦០% នៃ ផ.ស.ស. នៅ ២០១៨ (ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រឹមតែ ១៧,៣៥% នៃ ផ.ស.ស. នៅក្នុងឆ្នាំ ២០១៨) ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៧,៦៦% នៃ ផ.ស.ស. និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិគឺ ០,៩៤% នៃ ផ.ស.ស.។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា គ្រោងសម្រេចឱ្យបាន ៨,៤១% នៃផ.ស.ស., ចំណូលពីអគ្គនាយកដ្ឋានពន្ធដារគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃផ.ស.ស. (ក្នុងនោះចំណូលពន្ធដារថ្នាក់ជាតិ គ្រោងសម្រេចឱ្យបាន ៦,៨១% នៃផ.ស.ស. និងចំណូលពន្ធដារថ្នាក់ក្រោមជាតិ គ្រោងសម្រេចឱ្យបាន ០,៨៨% នៃផ.ស.ស.) និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៥០% នៃ ផ.ស.ស.។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ ២០១៨ គ្រោងសម្រេចឱ្យបាន ១៨,៧៨% នៃផ.ស.ស.។

- ចំណាយសរុបថវិការដ្ឋនៅឆ្នាំ ២០១៨ នឹងកំណត់ក្នុងរង្វង់ ២៤,៦៨% នៃ ផ.ស.ស. ដែលក្នុងនោះ គម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិមាន ២៣,៧៤% នៃផ.ស.ស. និងគម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិមាន ១,៦៨% នៃផ.ស.ស. (ដោយគិតបញ្ចូលទាំងឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៧៥% នៃផ.ស.ស.)។ ចំណាយចរន្តថវិការដ្ឋត្រូវគ្រោងក្នុងកម្រិត ១៥,៦៨% នៃផ.ស.ស ដែលគម្រោងចំណាយបន្ទុកបុគ្គលិក មានប្រមាណ ៥៣,៧% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើប្រមាណ ៨,៤២% នៃផ.ស.ស. ដោយផ្តោតអាទិភាពទៅលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈ, គិតគួរដល់ការបង្កើនប្រាក់សោធននិវត្តជូននិវត្តជន និងគិតគួរពីការចូលរួមចំណែករបស់រដ្ឋាភិបាលក្នុងរបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ ចំណាយមិនមែនបុគ្គលិកត្រូវបានគ្រោងប្រមាណ ៤៦,៣% នៃចំណាយចរន្តថវិការដ្ឋ ឬ ស្មើនឹង ៧,២៦% នៃ ផ.ស.ស.។ ចំណាយនេះនឹងត្រូវត្បិតត្បៀតឱ្យមានប្រសិទ្ធភាពបំផុត ព្រមទាំងតម្រង់ទៅលើសកម្មភាពកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ដោយឡែក ចំណាយមូលធន ត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ៩,០% នៃផ.ស.ស. (គ្រោងកើន ២១,២%)។

- ជារួម ចំណាយចរន្តថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៨ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷
    - វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ២,១១% នៃផ.ស.ស. និងមានកំណើន ៤,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
    - វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃផ.ស.ស. និងមានកំណើន ១៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
    - វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៥,៤៥% នៃផ.ស.ស. និងមានកំណើន ១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
    - វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ១,៤៩% នៃផ.ស.ស. និងមានកំណើន ១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧
    - ទន្ទឹមនេះដែរ ចំណាយមូលធន ត្រូវបានគ្រោងប្រមាណ ៩,០០% នៃផ.ស.ស. ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។
- ឈរលើមូលដ្ឋានគម្រោងក្របខ័ណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៨ គ្រោងសម្រេចបានស្មើនឹងប្រមាណ ២,៩២% នៃ ផ.ស.ស. ចំណែកឯឱនភាពថវិកាសរុបត្រូវបានកំណត់ត្រឹម ៥,៩០% នៃ ផ.ស.ស.។ នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើនេះ, ដើម្បីធានាតុល្យភាពថវិកា រាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលចំនួនប្រមាណ ១,០% នៃ ផ.ស.ស. ត្រូវជា ៩៩៤ ៧៣៧ លានរៀល ក្នុងគោលបំណងដើម្បីបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់

ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តាមផែនការដែលបានគ្រោងទុក (សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧-២០២០ មាននៅក្នុងឧបសម្ព័ន្ធ ២ គោរពភ្ជាប់មកជាមួយ)។

ដើម្បីធានាបាននូវការអនុវត្តតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧ ការគ្រោងថវិកាឆ្នាំ ២០១៨ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

**<u>ក. ផ្នែកចំណូល</u>**

**ក.១-ផ្នែកចំណូលពន្ធដារ**

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ៗ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលអាចនឹងកើតមានក្នុងឆ្នាំ ២០១៨ វិធានការផ្នែកចំណូលពន្ធដារសម្រាប់បន្តអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន÷

- *<u>បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្តោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ាតាមរយៈ÷</u>*
  - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី,
  - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្លូវផ្តួងព័ត៌មានជាមួយស្ថាប័នផ្សេងៗ,
  - ការផ្តល់សេវាជូនអ្នកជាប់ពន្ធធំចំនួន ១៥០ សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ,
  - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment)
  - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យ ឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម,
  - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្តានុពលមួយចំនួនដូចជា វិស័យនាំចេញ-នាំចូល វិស័យទេសចរណ៍ និងវិស័យសំណង់,
  - ការបន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរថ្លៃ,
  - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្តីពីការផ្ទេរថ្លៃ (Transfer Pricing) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ,

- ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។

• <u>*បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ÷*</u>

- ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន,
- ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរ ដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ,
- ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single sign-on)។

**ក.២ ផ្នែកចំណូលគយ និងរដ្ឋាករ**

ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈម ដែលនឹងអាចកើត-មានឡើងក្នុងឆ្នាំ ២០១៨ វិធានការជាក់លាក់សម្រាប់ផ្នែកចំណូលគយនិងរដ្ឋាករ ដែលត្រូវអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន÷

• <u>*ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្អែកលើការប្រកាសគយ, ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ តាមរយៈ÷*</u>

- ការបន្តលើកកម្ពស់អនុលោមភាព នៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធត្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេសជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក,
- ការចុះឃ្លាំមើលនិងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនករមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន ជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ,
- ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងពុរជនលើនីតិវិធីគយ ជាពិសេសកាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត,
- ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការ លើជនសង្ស័យឬជនល្មើសដែលមិនរាងចាល,

- ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរួបរួមលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យ និងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរួបរួមដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កែន,
- ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការលើកកម្ពស់កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយជាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វារគយ ឬច្រករបៀងខុសច្បាប់,
- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជនតាមរូបភាពនៃការចូលរួមផ្តល់ព័ត៌មានព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់,
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយតាមរយៈ ការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស,

• *<u>ការបន្តការពង្រឹងយន្តការគាំទ្រ តាមរយៈ÷</u>*

- ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្សៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្ទុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្យដ្ឋានច្បាស់លាស់ទាំងយានយន្តឯកជន, យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្នផ្សេងៗ,
- ការកសាង អនុវត្ត និងវាយតម្លៃការអនុវត្តផែនការសកម្មភាពឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើ (១)-រចនាសម្ព័ន្ធគ្រប់គ្រង, (២)-សមត្ថភាព និងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)-ការបំពាក់មធ្យោបាយការងារទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរួបរួមផ្សេងទៀតឱ្យបានសមស្របដូចជា មធ្យោបាយប្រដេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយមានស្នាដៃ និងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម,
- ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូលដោយបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន

ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល សន្និធិ និងចរាចរចែកចាយផលិតផលតេលសិលា ជាពិសេស ការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,

- ការបន្តពង្រីកភាពគ្របដណ្តប់និងមុខងារប្រព័ន្ធស៊ុយប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិកវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស៊ុយប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ,
- ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានាសំដៅប៉ះប៉ូវចំណូលគយ ដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលា ជាពិសេស (១)-ការបន្តពិនិត្យលទ្ធភាពដំឡើងអត្រាអាករពិសេស (២)-ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស និងការកាត់បន្ថយការលើកទឹកចិត្តពន្ធអាករហួសពីការអនុវត្តល្អក្នុងតំបន់ និង (៣)-ការចាត់វិធានការមុតស្រួចនានាបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

**ក.៣. ផ្លែកចំណូលមិនមែនសារពើពន្ធ**

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមសំខាន់ៗ ដែលនឹងអាចកើត-មានឡើងក្នុងឆ្នាំ ២០១៨ វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៨ (មិនមែនជាវិធានការជាក់លាក់ក្នុងឆ្នាំទេ ប៉ុន្តែជាវិធានការប្រចាំគ្រាសំខាន់ៗ) ដែលត្រូវបន្តអនុវត្ត រួមមាន÷

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ,
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន កត់ត្រា កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវច្បាស់លាស់, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ,
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត,
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល,
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលកំពុងរៀបចំដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ការរៀបចំប្រព័ន្ធ

ព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,

- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិឱ្យគ្រប់ចំនួន និងទាន់ពេលវេលា,
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព,
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដែលបច្ចុប្បន្ន អគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កំពុងសហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីបង្កើតកម្រៃ ៤ ដុល្លារអាមេរិក សម្រាប់អ្នកដំណើរក្នុងប្រទេស និង ៦ ដុល្លារអាមេរិក សម្រាប់អ្នកធ្វើដំណើរក្រៅប្រទេស,
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីជីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល,
- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរចំណូលពីវិស័យកាស៊ីណូ និងឆ្នោតឡូតូ,
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណ៍ល្បែងពាណិជ្ជកម្មឱ្យចេញនៅឆ្នាំ ២០១៨,
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

**<u>ខ. ផ្នែកចំណាយ</u>**

**ខ.១- គោលនយោបាយអាទិភាពផ្នែកចំណាយ**

ស្របតាមគោលដៅនៃសូចនាករហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨-២០២០ ដូចតទៅ÷

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កាកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,

- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមាន: ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ, និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងអត្រាឡើងថ្នាក់របស់សិស្ស,
- ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរជន,
- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែមទាំងអគារមន្ទីពេទ្យ, សម្ភារៈបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល,
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សម្រាប់គាំទ្រដល់កំណើន និងការអភិវឌ្ឍ,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ពិសេសផ្តោតទៅលើការផលិតពូជល្អ, បន្លែ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, ការនាំអង្ករចេញ ព្រមទាំងផលិតកម្មកែច្នៃមួយបអាហារ,
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម និងឱកាសស្មើគ្នា,
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងពង្រីកការទទួលបានការពេញចិត្តពីសេវាទាំងនេះ។

**២.២- វិធានការផ្នែកចំណាយ**

ដោយឈរលើមូលដ្ឋានការអនុវត្តចំណាយសាធារណៈកន្លងមក និងដើម្បីសម្រេចបានប្រសិទ្ធភាព និង

ស័ក្តិសិទ្ធភាពនៃវិតារកម្មគោលនយោបាយចំណាយសាធារណៈ រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និងគោលការណ៍ជាក់លាក់មួយចំនួនក្នុងឆ្នាំ ២០១៨ ដែលរួមមាន÷

- បន្តការគិតគូរពីការរៀបចំថវិកាឱ្យកាន់តែមានលក្ខណៈផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅ ពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា,
- ពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឱ្យបានគ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិពីចំនួន ៣៦ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៧ ឱ្យឡើងដល់ ៣៩ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៨, និង ពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, ចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ច,
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក, កសិកម្ម និងប្រព័ន្ធគាំពារសង្គម,
- បន្តធ្វើវិតារកម្មគោលនយោបាយចំណាយ (រួមជាមួយការបន្តរឹតត្បិតចំណាយមិនចាំបាច់) ក្នុងស្មារតីគាំទ្រដល់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" និងគាំទ្រដល់ការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនការចំណាយវិនិយោគសាធារណៈលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គីសនី។ល។ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន។ បង្កើនការយកចិត្តទុកដាក់លើចំណាយថែទាំឱ្យមានប្រសិទ្ធភាព ក្នុងទិសដៅកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត,
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម វិស័យចំណីអាហារ និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញការកែច្នៃកសិផលសម្រាប់ការនាំចេញ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈវិចារណកម្មគោលនយោបាយចំណាយក្នុងទិសដៅទទួលបានប្រសិទ្ធភាពខ្ពស់,
- បន្តជំរុញអនុវត្ត**កម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work)** ដែលជាកម្មវិធីដែលជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើត

ការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជន នៅទីជនបទ,

- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយក-ចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត (ចំណាយបុគ្គលិក និងមិនមែនបុគ្គលិក) និងចំណាយមូលធន,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងដំហានបន្ទាប់ផ្សេងៗទៀត,
- គិតគួរឱ្យមានកញ្ចប់ថវិការត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ,
- លើកកម្ពស់ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងពីប្រភពថវិកា រដ្ឋ ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងពីប្រភពថវិការបស់ដៃគូឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដោយត្រូវ÷
  - ការរៀបចំក្របខ័ណ្ឌ និងគោលការណ៍រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅមុនដំណាច់ឆ្នាំ២០១៧,
  - ការរៀបចំគោលការណ៍ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីប្រភពថវិកាជាតិ ដែលគ្រោងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨,
  - ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធីរួមសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨, និង
  - ការរៀបចំក្របខ័ណ្ឌគតិយុត្ត យន្តការស្ថាប័ន និងនីតិវិធីប្រតិបត្តិការរួម សម្រាប់គ្រប់គ្រងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាពស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុល។

## ៣. ទេសានសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់

គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោលនយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំតាមទម្រង់ដូចខាងក្រោម÷

- **ផ្នែកទី១: អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ត្រូវចាប់ផ្តើមដោយគូសរំលេចអំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៦-២០១៨ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០១៧ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរអំពីវិធានការគោលនយោបាយសំខាន់ៗដែលក្រសួង-ស្ថាប័ន បានដាក់ចេញស្របតាមទិសដៅនៃ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** រួមទាំង គោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី២: អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យ និងអន្តរវិស័យ ដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗមិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ អាចត្រូតពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ របស់ខ្លួនបានដើម្បីធានាថា គោលនយោបាយដែលបានកំណត់មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ឆ្លើយតបបានកាន់តែច្បាស់លាស់ ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះសូមបញ្ជាក់ ផងដែរថា *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពីពីរទេ*។ **សូមរៀបចំខ្លឹមសារ នៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

• **ផ្នែកទី៣: អំពីកម្មវិធី**

ការរៀបចំកម្មវិធី (ក្រសួង-ស្ថាប័ន ដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធី និង ក្រសួង-ស្ថាប័ន ដែលនឹងត្រូវអនុវត្តថវិកាកម្មវិធីចាប់ពីឆ្នាំ២០១៨) ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយដែលបានកំណត់ខាងលើ និងត្រូវបញ្ជាក់អំពីគោលបំណងនៃកម្មវិធីឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធីទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលបានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង-ស្ថាប័នដែលនឹងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំដំបូង ត្រូវបង្កើតឈ្មោះកម្មវិធី ព្រមជាមួយការរៀបរាប់និងពន្យល់អំពីគោលបំណងនៃកម្មវិធីទាំងនោះ។ ចំពោះក្រសួង-ស្ថាប័នដែលបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវធ្វើការពិនិត្យ និងកែលម្អឈ្មោះកម្មវិធីឱ្យកាន់តែល្អប្រសើរ ដោយឡែកក្រសួង-ស្ថាប័នដែលត្រៀមអនុវត្តថវិកាកម្មវិធីនៅឆ្នាំ ២០១៨ ត្រូវពិនិត្យ និង កែលម្អ យុទ្ធសាស្ត្រអាទិភាពឱ្យបានច្បាស់លាស់ ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរផងដែរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើម។ សូមបញ្ជាក់ផងដែរថា ***ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធីមិនឱ្យលើសពី ៥ ឡើយ*** ប៉ុន្តែចំពោះអនុកម្មវិធីអាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង-ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និងចង្កោមសកម្មភាព ព្រមទាំងជាមូលដ្ឋានសម្រាប់ការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាព សំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតជាតុចេញ(Output) សម្រាប់ចង្កោមសកម្មភាពនោះ ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់គ្នាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្ម ដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្ត ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬ ខ្សែបណ្តោយរបស់ក្រសួង នៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ **ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញរបស់ខ្លួននៅរាជធានី-ខេត្ត អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយ ឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្ត របស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់។ ជាទូទៅ មន្ទីរជំនាញមួយ អាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ អាស្រ័យទៅតាមតួនាទី និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ**។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយ សារាចរណែនាំនេះ**។

- **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬ លទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មនីមួយៗ ត្រូវមានសូចនាករ (Indicator) សម្រាប់វាស់វែងលទ្ធផល ឬ សមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅ (Target) សូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាន នៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែង ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ (Output) និងសូចនាករលទ្ធផល ឬ លទ្ធផលចុងក្រោយ (Outcome)។

សូចនាករធាតុចេញ ឬ លទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/ សមិទ្ធកម្ម នៃការអនុវត្ត កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផល ឬ លទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់ លទ្ធផល/ សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាកនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៦ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៧ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស

និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត កម្មវិធីនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេល មធ្យមនិងវែង (លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបាន ទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមាន ភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

- **ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល ២០១៨-២០២០។

**ក-ការគ្រោងចំណូល**

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៨-២០២០ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្តាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង ប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ តាមរយៈការដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្តុយទៅវិញ ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការវិតត្បិតចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល*។

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៨-២០២០ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

ទី១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និង ចំណាយមូលធន ឬ ហៅថាចំណាយវិនិយោគ,

ទី២- ការវាយតម្លៃលើសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៧ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗបាននិងកំពុងអនុវត្ត,

ទី៣- ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី ÷

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង

- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០១៨-២០២០ តាមគោលការណ៍នៃការកំណត់ពិដានកញ្ចប់ថវិកា ដូចខាងក្រោម÷

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤) សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៨ ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៧ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្ស នៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១៧ **ដោយដំឡើងបៀវត្សមូលដ្ឋានចំនួន ១២% ក្នុងមួយឆ្នាំ (គិតពីខែមករា ដល់ ធ្នូ)** ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។ **ចំពោះការតម្លើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ឆ្នាំ ២០១៨ នឹងត្រូវបានផ្តល់ទឹកប្រាក់បន្ថែមគិតពីខែ មេសា** ដោយផ្អែកលើកម្រិតនៃប្រាក់បំណាច់មុខងារនីមួយៗ ដោយកម្រិតក្រោម ៣០០ ០០០ រៀល ក្នុង ១ខែ បន្ថែមចំនួន ១០០ ០០០ រៀល និងបង្កើនរហូតដល់កម្រិតចាប់ពី ៨០០ ០០០រៀល ក្នុង ១ខែ បន្ថែមត្រឹម ៤០ ០០០ រៀល ។ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងចេញគោលការណ៍លម្អិតបន្ថែមសម្រាប់ការបន្ថែមជូនសម្រាប់កម្រិតចន្លោះពី ៣០០ ០០០រៀល ទៅ ៨០០ ០០០រៀល ក្នុងមួយខែ សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនាពេលខាងមុខ។
- ដោយឡែក សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៩ និង ២០២០ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។
- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភកធន) ជាសរុបសម្រាប់ឆ្នាំ ២០១៨ ត្រូវគ្រោងស្មើនឹងកម្រិតឥណទានអតិបរមានៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ព្រោះអាទិភាពចំណាយឆ្នាំ ២០១៨ ដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺផ្តោតជាសំខាន់លើការដំឡើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ***ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ ២០១៨ នឹងទទួលបានស្មើឆ្នាំ ២០១៧ ដោយស្វ័យប្រវត្តិដែរ*** ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ហើយថវិកាដែលបានកាត់ចេញនោះមិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញនោះទេ លុះត្រាតែផ្តល់ការពន្យល់ និងផ្តល់អំណះអំណាង

ឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី។ ដោយឡែកសម្រាប់ឆ្នាំ ២០១៩ និង ២០២០ ការគ្រោងចំណាយចរន្តអាចបង្កើន ក្នុងរង្វង់នៃកម្រិតអតិផរណា ធៀបនឹងកញ្ចប់ដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ រៀងៗគ្នា។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ ថ្មី និង/ឬ ខ្ពស់ជាងគោលការណ៍ដែលបានចែងនេះ គឺត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា និងអំណះអំណាងឱ្យបានត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់ នៅក្នុងដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះឱ្យហើយ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ ជារួម គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្ត ចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ សម្រាប់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១) សម្រាប់ក្រសួងសាធារណៈការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ក្នុងការកំណត់អាទិភាពគម្រោង និងទំហំថវិកាសម្រាប់ឆ្នាំ ២០១៨ ដែលមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ ២០១៧។ ដោយឡែក ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគ ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំអាទិភាពភាវូបនីយកម្មគោរពសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ទៅតាមលទ្ធភាពថវិកាក្នុងទំហំដ៏សមស្រប ប៉ុន្តែជាក់ស្តែង គឺអាស្រ័យលើលទ្ធភាពនៃថវិកាក្នុងដំណាក់កាលរៀបចំថវិកាប្រចាំឆ្នាំ។
- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍ** ក្រសួង-ស្ថាប័នដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទានស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០១៨-២០២០) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬ អនុស្សារណៈនៃការយោគយល់គ្នា ឬ ការសន្យាតាមរយៈយន្តការផ្សេងៗ។

- **ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និង មានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយ របស់ក្រសួង-ស្ថាប័នរៀងៗខ្លួន និងដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាគឺជាដំណាក់កាលទី ១ នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង-ស្ថាប័ននីមួយៗមានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធី ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹង គោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ ឱ្យបានសមស្រប ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៣-២០១៥ របស់ខ្លួន ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៨-២០២០ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៧* ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ដើម្បីសម្រួលដល់ដំណើរការ ពិនិត្យនិងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមពេលវេលា ដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកា តាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៧។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤.សរណនស

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

## ១. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាល រួមមាន **ដំណាក់កាលទី១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែមីនា ដល់ ខែឧសភា, **ដំណាក់កាលទី២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែមិថុនា ដល់ខែកញ្ញា និង**ដំណាក់កាលទី៣** គឺការអនុម័តថវិកា ចាប់ពីខែតុលា ដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ ផ្អែកលើក្របខណ្ឌគោលនយោបាយនេះ រាជរដ្ឋាភិបាល ក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨ ដើម្បីឱ្យគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននីមួយៗ ធ្វើការពន្យល់និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូលនិងបង្ហាញអំពីតម្រូវការចំណាយរយៈពេល ៣ ឆ្នាំ (២០១៨-២០២០) សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ដែលជាការរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**" ។ នៅដំណាក់កាលទី២ នេះ រាជរដ្ឋាភិបាល ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៨ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ។ ដូច្នេះ សារាចរនេះបានដាក់ចេញនូវក្របខណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។ ដោយឡែកចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១

ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការរិះគាជថ្មីកា ដើម្បីចូលរួមបង្កើនប្រសិទ្ធភាពនិងស័ក្តសិទ្ធភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការរិះគាជថ្មីកា និងស័ក្តសិទ្ធភាពនៃការអនុវត្តចំណាយទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

២- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ គឺស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសុខសន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយ, ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស, ព្រមទាំងសម្រេចបាននូវការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យ ជាពិសេសការប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាបចាប់តាំងពីឆ្នាំ ២០១៥ ។ សមិទ្ធផលដ៏ធំធេងនេះបានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំ និងបង្កលក្ខខណ្ឌកាន់តែអំណោយផល និងស្ថានភាពអនុគ្រោះសម្រាប់ការកសាងអនាគតកម្ពុជាមួយដ៏រុងរឿង និងត្រចះត្រចង់ ព្រមទាំងបានផ្តល់នូវឱកាស និងភាពងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាផង និងដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរដោយរចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជាផង ក៏ដូចជាការប្រែប្រួលនិមាបនកម្មសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ទាំងក្នុងកម្រិតតំបន់ និងពិភពលោកផង។

៣-ការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកក្នុងពេលថ្មីៗនេះ បានបង្ហាញថាកំណើនរឹងមាំជាងការរំពឹងទុកនៃសេដ្ឋកិច្ចរបស់ប្រទេសអាមេរិក និងចិន ព្រមទាំងសន្ទុះកំណើនខ្ពស់នៃប្រទេសដែលមានសេដ្ឋកិច្ចកំពុងលូតលាស់ និងប្រទេសក្នុងតំបន់អាស៊ាន កំពុងជំរុញឱ្យមានភាពប្រសើរឡើងនៃសេដ្ឋកិច្ចពិភពលោក។ ទោះជាយ៉ាងនេះក្តី ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក គឺនៅតែមាននៅឡើយដោយសារការលេចឡើងនូវចរន្តប្រឆាំងសកលភាវូបនីយកម្ម, ការការពារនិយមដែលរាំងខ្ទប់ការធ្វើពាណិជ្ជកម្មសេរី, ការកើនឡើងនូវការប្រើប្រាស់គោលនយោបាយប្រជាភិថុតិនិយមនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ និងការប្រឆាំងនឹងការធ្វើអន្តោប្រវេសន៍ ដែលនិន្នាការបែបជាតិនិយមទាំងនេះ បានជះឥទ្ធិពលអវិជ្ជមាន (Negative Spillovers) ដល់ប្រទេសដទៃទៀត និងកំពុងបង្កើតភាពស្មុគស្មាញ និងភាពមិន-ប្រាកដប្រជាកាន់តែខ្លាំងដល់ស្ថានភាពភូមិសាស្ត្រនយោបាយ និងបញ្ហាសន្តិសុខពិភពលោក ក៏ដូចជាបង្កើនហានិភ័យកាន់តែខ្ពស់ដល់សេដ្ឋកិច្ច ពាណិជ្ជកម្ម និងហិរញ្ញវត្ថុសកលលោក តំបន់ និងប្រទេស។ លើសពីនេះ ការតឹបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក, ការចាកចេញរបស់ប្រទេសអង់គ្លេស និងភាពមិនច្បាស់លាស់នៃតំបន់អឺរ៉ុប, ការថមថយនៃកំណើនរបស់សេដ្ឋកិច្ចចិន, ភាពមិនច្បាស់លាស់នៃគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក, ការងើបឡើងវិញនូវតម្លៃប្រេង និងទំនិញលើទីផ្សារអន្តរជាតិ អាចបង្កើតជាហានិភ័យសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ។

ចំពោះហានិភ័យក្នុងប្រទេស, ការវិភាគបានបង្ហាញថា សេដ្ឋកិច្ចកម្ពុជាបានឈានដល់ចំណុចមួយដែលចាំបាច់ត្រូវជំរុញអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការមុតស្រួច និងយុទ្ធសាស្ត្រចាំបាច់បន្ថែមនៅក្នុងវិស័យមួយចំនួន ព្រោះកំណើនខ្ពស់ប្រកបដោយចិរភាព, ក្នុងរយៈពេលជាងពីរទសវត្សរ៍មកនេះ, បានពឹងផ្អែកលើវិស័យកសិកម្ម វិស័យកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍ ដែលវិស័យទាំងនេះបាននិងកំពុង

បង្ហាញនូវសញ្ញាថមថយមួយចំនួន។ ទន្ទឹមនេះ កម្ពុជាក៏កំពុងបន្តប្រឈមនឹងបញ្ហាសេដ្ឋកិច្ចផ្ទៃក្នុងមួយចំនួនទៀត រួមមាន តម្លៃអគ្គិសនីនៅខ្ពស់សម្រាប់វិនិយោគិន ធៀបជាមួយនឹងប្រទេសជិតខាង បើទោះជាតម្លៃនេះបានធ្លាក់ចុះហើយក្តី, ការកើនឡើងជាលំដាប់នៃបៀវត្សអប្បបរមា ដែលធ្វើឱ្យសឹករិចរិលនូវភាពប្រកួតប្រជែងរបស់កម្ពុជាធៀបនឹងប្រទេសមួយចំនួនទៀត ដែលមានស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលនឹងកម្ពុជា, ភាពមិនទាន់ឆ្លើយឆ្លងស៊ីសង្វាក់គ្នាពេញលេញរវាងសមត្ថភាពជំនាញ និងផលិតភាពរបស់ពលកររកម្ពុជាជាមួយនឹងសេចក្តីត្រូវការនៃទីផ្សារ និងតម្រូវការនៃការអភិវឌ្ឍ និងសម្ភាធនៃថ្លៃម្ហូបអាហារ ជាដើម ។

៤- ជារួម ទោះបីកម្ពុជាត្រូវជួបប្រទះនូវបញ្ហាប្រឈមគ្រប់បែបយ៉ាងទាំងក្នុង និងក្រៅប្រទេសក៏ដោយ ក៏រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរហូតមក, នៅតែអាចតស៊ូពុះពារ និងជំនះបាននូវរាល់ឧបសគ្គ និង ការលំបាកផងទាំងពួង ហើយជានាបាននូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាជានាបានល្អប្រសើរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបសមរម្យ, ជានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងពង្រឹងឡើងថែមទៀតនូវសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញការអនុវត្តវិធានការនានា សំដៅពន្លឿនពិពិធកម្មសេដ្ឋកិច្ច រួមមានជាអាទិ៍ ការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ និងការធ្វើឱ្យកាន់តែល្អប្រសើរនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជាជនកម្ពុជា, ពិសេសយុវជន ជាច្រើនសែននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០១៦, ប្រទេសកម្ពុជាត្រូវបានធនាគារពិភពលោកចាត់ចូលក្នុងក្រុមប្រទេស **ឯកទគ្គកអំណើន** ទាំងប្រាំបីនៅក្នុងពិភពលោក (Olympians of Growth) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់និងរឹងមាំ ហើយជាងនេះទៅទៀត ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ក៏បានកោតសរសើរយ៉ាងខ្លាំងចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា ដែលបានផ្លាស់ប្តូរពីប្រទេសក្រីក្រ និងមានជម្លោះផ្ទៃក្នុងរ៉ាំរ៉ៃ ទៅជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ហើយបានប្រសិទ្ធនាមប្រទេសកម្ពុជា ជា "**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**" ទៀតផង។

ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យដូចបានគិតគូរខាងលើ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ត្រូវបានកំណត់ឈរលើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## ២. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៨

### ២.១- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨

៥- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៦ កន្លងមកនេះ នៅបន្តរក្សាភាពរឹងមាំក្នុងអត្រាកំណើន ៧,០% ដូចការប៉ាន់ស្មានកាលពីដើមឆ្នាំ ជាមួយនឹងអតិផរណាមធ្យមប្រចាំឆ្នាំក្នុងអត្រា ៣,០% និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៥៦ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ ការបន្តមានកំណើនខ្ពស់បែបនេះបានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗកើនឡើងដល់១ ៣០២ ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាត្រូវបានចាត់ទុកថា សម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៦- នៅក្នុងឆ្នាំ ២០១៧ និង ឆ្នាំ២០១៨ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ហើយ ផ.ស.ស តាមថ្លៃចរន្តឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន ៨៩ ៤៧៨ ប៊ីលានរៀល និង ផ.ស.ស តាមថ្លៃចរន្តឆ្នាំ ២០១៨ ត្រូវបានគ្រោងចំនួន ៩៩ ០២៣ ប៊ីលានរៀល។ កំណើននេះបានមកពី៖

-វិស័យកសិកម្ម ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងរង្វង់ ២,០% នៅឆ្នាំ២០១៧ និង ២០១៨ ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ដែលបានព្យាករដោយក្រសួងធនធានទឹក និងឧត្តុនិយម, គោលនយោបាយវិស្តារកម្មរបស់រាជរដ្ឋាភិបាល ក្នុងការវិនិយោគបន្ថែមលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច ពូជ ដំណាំ និងការផ្សព្វផ្សាយបច្ចេកទេស, ការចូលរួមកាន់តែសកម្មជាងមុនពីសំណាក់ដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនឯកជន ក្នុងការវិនិយោគលើវិស័យកសិកម្ម គួបផ្សំនឹងការបន្តកើនឡើងនៃតម្លៃកសិផលលើទីផ្សារអន្តរជាតិ។ ផលិតកម្មដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំ ត្រូវបានប៉ាន់ស្មានថានឹងបន្តកំណើនខ្ពស់ ដែលទ្រទ្រង់ដោយការកើនឡើងនៃតម្លៃកៅស៊ូ និងការងើបឡើងវិញនៃតម្លៃកសិផលផ្សេងៗ ព្រមទាំងការកើនឡើងនៃការវិនិយោគលើវិស័យកសិឧស្សាហកម្ម ដូចជាការផលិតចំណីសត្វ, ប្រេងអេតាណុល និងស្ករសជាដើម។ អនុវិស័យកសិកម្មផ្សេងទៀត ដែលរួមមាន ជលផល និងការចិញ្ចឹមសត្វ ក៏ត្រូវបានព្យាករថានឹងបន្តកំណើនល្អ ដោយសារតែការរំពឹងទុកនៃការបន្តកើនឡើងការវិនិយោគលើវិស័យវារីវប្បកម្ម និងការចិញ្ចឹមមាន់ និងជ្រូក ដោយក្រុមហ៊ុនឯកជនក្នុងទម្រង់ជាកសិកម្មបែបកិច្ចសន្យា។ ដូចនេះ រាជរដ្ឋាភិបាលនឹងផ្តោតការផ្តល់អាទិភាពខ្ពស់ចំពោះការបង្កើតឱ្យមានផែនការរយៈពេលវែងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម ដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ពីផ្នែកសាធារណៈ, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដែលបាននិងកំពុងជួបប្រទះ៖ ផលិតភាពទាប, កង្វះការធ្វើពិពិធកម្មកសិកម្ម, កង្វះការវិនិយោគលើវិស័យកសិឧស្សាហកម្ម, ការចិញ្ចឹមសត្វ និងវារីវប្បកម្មបែបពាណិជ្ជកម្ម ព្រមទាំងភាពមានកម្រិតនៃការធ្វើពាណិជ្ជូបនីយកម្មនៃផលិតផលកសិកម្ម។

-វិស័យឧស្សាហកម្ម ត្រូវបានព្យាករថានឹងបន្តកំណើនរឹងមាំក្នុងអត្រា ១០,៧% នៅឆ្នាំ២០១៧ និង ១០,១% ក្នុងឆ្នាំ ២០១៨ ដែលគាំទ្រដោយវិស័យកាត់ដេរ និងសំណង់ ជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ។ វិស័យកាត់ដេរ រំពឹងថានឹងនៅបន្តកំណើនខ្ពស់ក្នុងអត្រា ៨,៥% ក្នុងឆ្នាំ ២០១៧ ដោយសារភាពល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចសកល ជាពិសេសប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗ ដូចជាសហរដ្ឋអាមេរិក និងអ៊ឺរ៉ុបជាដើម, ការងើបឡើងវិញនៃពាណិជ្ជកម្មអន្តរជាតិ និងការលុបចោលកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរប៉ាស៊ីហ្វិកជាដើម។ ដោយឡែក, វិស័យកាត់ដេរឆ្នាំ ២០១៨ អាចនឹងថមថយកំណើនបន្តិចដែលអាចបណ្តាលមកពីស្ថានភាពមិនច្បាស់លាស់នៃការវិនិយោគក្នុងឆ្នាំបោះឆ្នោតសកល និងការប្រកួត-ប្រជែងកាន់តែខ្លាំងពីប្រទេសមីយ៉ាន់ម៉ា និងវៀតណាម ជាពិសេសនៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងវៀតណាម និងសហភាពអឺរ៉ុបចូលជាធរមាន។ ក្នុងន័យនេះ, កម្ពុជាត្រូវផ្តោតសំខាន់លើការពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីរក្សានិន្នភាពកំណើននៃវិស័យកាត់ដេរ ក៏ដូចជាការត្រៀមខ្លួនជាស្រេចដើម្បីចាប់យកឱកាសនៃបម្លាស់ទីរោងចក្រចេញពីប្រទេសចិន។ វិស័យសំណង់ ត្រូវបានព្យាករថានឹងអាចថមថយកំណើនមកត្រឹម ១៤,១% និង ១២,៤% សម្រាប់ឆ្នាំ ២០១៧ និង ២០១៨ រៀងគ្នា ដោយសារឥរិយាបថ "រង់ចាំមើល" (Wait-and-See) របស់វិនិយោគិនក្នុងការវិនិយោគបន្ថែម និងកំណើននៃការផ្គត់ផ្គង់ដ៏ច្រើនលើសលប់ ធៀបនឹងតម្រូវការជាក់ស្តែង ចំពោះប្រភេទសំណង់លំនៅដ្ឋានដែលមានតម្លៃខ្ពស់។ ជានិន្នាការ ការសាងសង់ខុនដូរ និងបុរីដែលមានតម្លៃខ្ពស់មានសភាពនៅទ្រឹង ប៉ុន្តែ បានប៉ះប៉ូវដោយ

គម្រោងលំនៅដ្ឋានដែលមានតំលៃសមរម្យ, ការបន្តកើនឡើងនៃការសាងសង់សំណង់ការិយាល័យ និង សំណង់ផ្សេងៗទៀត, និន្នាការនៃការលូតលាស់យ៉ាងឆាប់រហ័សផ្នែកនគរូបនីយកម្មនៅរាជធានីភ្នំពេញ និង តាមខេត្តធំៗមួយចំនួន ក៏ដូចជាការកើនឡើងនៃវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។ ទោះជា យ៉ាងនេះក្តី ការថមថយនៃវិស័យសំណង់ ត្រូវបានបំពេញបន្ថែមដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម ផ្សេងៗ ដូចជា អាហារ និង ភេសជ្ជៈ, គ្រឿងបង្គុំអេឡិចត្រូនិច, គ្រឿងបន្លាស់, វិស័យថាមពល និងវិស័យ ផលិតកៅស៊ូក្រែបជាដើម។ គម្រោងបង្កើនការផលិតអាហារ និងភេសជ្ជៈក្នុងស្រុកបន្ថែមទៀតនាឆ្នាំ ២០១៧ និង២០១៨ ជំនួសឱ្យការនាំចូល នឹងធ្វើឱ្យវិស័យនេះរួមចំណែកកាន់តែធំជាងមុននៅក្នុងសេដ្ឋកិច្ចជាតិ។ វិស័យគ្រឿងបង្គុំអេឡិចត្រូនិច និង គ្រឿងបន្លាស់រថយន្តក៏នឹងមានសន្ទុះខ្លាំងផងដែរ ដោយសារវិនិយោគិន ជប៉ុនបានបន្តបង្កើតរោងចក្រថ្មីបន្ថែមទៀតក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងប៉ោយប៉ែត សម្រាប់បម្រើការ នាំចេញទៅក្រៅប្រទេស។ កំណើននៃវិស័យថាមពល ដោយសារកំណើននៃការផ្គត់ផ្គង់អគ្គិសនីពីទំនប់ វារីអគ្គិសនីក្នុងស្រុកមួយចំនួន នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយបរិមាណអគ្គិសនីដែលនាំចូល ពីប្រទេសជិតខាង និងធ្វើឱ្យតម្លៃអគ្គិសនីនៅកម្ពុជាកាន់តែមានកម្រិតសមរម្យជាងមុន។ ការអនុវត្តយុទ្ធសាស្ត្រ ចិនបួក ១ និងថៃបួក ១ ក៏នឹងចូលរួមពង្រឹងភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មផលិតកម្មក្នុងស្រុកឱ្យ បានកាន់តែប្រសើរផងដែរ។ ដើម្បីជំរុញឱ្យវិស័យឧស្សាហកម្មរួមចំណែកកាន់តែប្រសើរឡើងក្នុងសេដ្ឋកិច្ច ជាតិ, រាជរដ្ឋាភិបាលនឹងត្រូវខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដើម្បីបំពេញនូវ ការថមថយការវិនិយោគក្នុងស្រុក ដោយសារភាពមិនប្រាកដប្រជានាឆ្នាំ ២០១៨ ខាងមុខ; ជំរុញការអនុវត្ត គោលនយោបាយឧស្សាហកម្ម ដែលជាយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិឱ្យមានសន្ទុះខ្លាំងក្លាឡើង សំដៅ ជំរុញល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មឱ្យកាន់តែឆាប់រហ័ស ដើម្បីបង្កើនភាពប្រកួតប្រជែង បង្កើនតម្លៃបន្ថែមឱ្យកាន់តែខ្ពស់ក្នុងខ្សែចង្វាក់ផលិតកម្មក្នុងស្រុក និងចាត់វិធានការមុតស្រួចដើម្បីកាត់ បន្ថយចំណាយធុរៈកិច្ចដែលនៅខ្ពស់ និងសម្រួលនីតិវិធីក្នុងការធ្វើធុរកិច្ចឱ្យកាន់តែរលូនជាងមុន។

-វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងបន្តនូវកំណើនខ្ពស់ប្រហាក់ប្រហែលនឹងឆ្នាំ ២០១៦ ក្នុងរង្វង់ ៦,៥% សម្រាប់ឆ្នាំ ២០១៧ និង ៦,៧% នាឆ្នាំ ២០១៨ ដោយសារកំណើនរឹងមាំនៃវិស័យលក់ដុំ និង លក់រាយ និងវិស័យគមនាគមន៍ ទោះបីវិស័យវិស័យទេសចរណ៍នៅបន្តកំណើនយឺត និងការថមថយនៃ កំណើនក្នុងវិស័យអចលនទ្រព្យ និងដឹកជញ្ជូន។ កំណើននៃវិស័យទេសចរណ៍ ត្រូវបានព្យាករថានៅទ្រឹង ប្រមាណ ២,៣% ក្នុងឆ្នាំ២០១៧ និង២០១៨ ដោយសារតែកង្វះការធ្វើពិពិធកម្មទាំងលើផលិតផល សេវាកម្ម ទិសដៅទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ព្រមទាំងការបន្តកើនឡើងនៃប្រាក់ដុល្លារ អាមេរិក។ វិស័យអចលនទ្រព្យ ក៏ត្រូវបានព្យាករថានឹងបន្តថមថយកំណើនមកត្រឹម ៨,៣% និង ៧,៩% សម្រាប់ឆ្នាំ ២០១៧ និង២០១៨ រៀងគ្នា ដែលនិន្នាការនេះស្របគ្នានឹងការថមថយកំណើននៃវិស័យសំណង់ និងដែលឆ្លុះបញ្ចាំងតាមរយៈការថមថយឥណទានផ្តល់ឱ្យទៅវិស័យនេះ ការថមថយនៃតម្រូវការធៀបនឹងការ ផ្គត់ផ្គង់ ព្រមទាំងបរិបទនៃភាពមិនច្បាស់លាស់នៃស្ថានភាពវិនិយោគនាឆ្នាំខាងមុខ។ វិស័យដឹកជញ្ជូន និង ទំនាក់ទំនង ត្រូវបានព្យាករថានឹងបន្តកំណើនយឺតជាងមុនបន្តិចមកត្រឹម ៧,៥% និង ៧,៤% រៀងគ្នា ដោយ សារកំណើនយឺតនៃវិស័យផ្សេងៗទៀតដូចជាកាត់ដេរ, សំណង់, និងទេសចរណ៍ជាដើម ទោះបីជាវិស័យ ទំនាក់ទំនងនឹងមានសន្ទុះកំណើនខ្ពស់នាឆ្នាំខាងមុខ។ ដោយឡែក កំណើនខ្ពស់នៃវិស័យលក់ដុំ និងរាយ នឹងអាចប៉ះប៉ូវដល់ការថមថយទាំងនេះ ពោលគឺវិស័យនេះត្រូវបានព្យាករថានឹងកើនឡើងជាបន្តបន្ទាប់ក្នុង

អត្រា ៧,៨% និង៨,៣% រៀងគ្នា ស្របនឹងកំណើននៃតម្រូវការក្នុងស្រុក ដែលឆ្លុះបញ្ចាំងអំពីនិន្នាការនៃការផ្លាស់ប្តូររបៀបរបបរស់នៅរបស់យុវវ័យ ព្រមទាំងការកើនឡើងនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដោយសារគោលនយោបាយវិស្តារកម្មថវិការបស់រាជរដ្ឋាភិបាលក្នុងការបង្កើនបៀវត្សជូនមន្ត្រីរាជការ និងការកើនឡើងនៃបៀវត្សអប្បបរមានៃវិស័យឯកជន។ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ តែខិតខំជំរុញការអភិវឌ្ឍលំនៅស្ថានដែលមានតម្លៃសមរម្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិនិយោគបន្ថែមលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗផ្សេងទៀត ដោយផ្អែកលើផែនការមេមួយច្បាស់លាស់ ជាពិសេសចំពោះវិស័យទូរគមនាគមន៍ និងដឹកជញ្ជូន និងវិស័យថាមពល ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃចំណាយទាំងនេះ។ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ, ទ្រទ្រង់កំណើនឥណទានឱ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម, បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតសម្រាប់វិស័យឯកជន ជាពិសេសការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ (Bond Market) និងទីផ្សាររូបិយប័ណ្ណ (Money Market) និងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងបន្តពិនិត្យលទ្ធភាពបញ្ចុះថែមទៀតនូវអត្រាការប្រាក់ក្នុងវិស័យទាំងនេះ។

- អតិផរណាត្រូវបានប៉ាន់ស្មានថានឹងបន្តស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ទោះបីតម្លៃប្រេងត្រូវបានព្យាករថានឹងបន្តកើនឡើង គួបផ្សំនឹងសម្ពាធនៃតម្លៃម្ហូបអាហារ។ អត្រាអតិផរណាជាមធ្យមនៅឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៣,៨% និង ៣,៥% រៀងគ្នា។ អត្រាប្តូរប្រាក់ត្រូវបានរំពឹងថានឹងមានស្ថិរភាព ដែលមានអត្រាជាមធ្យមគឺ ៤ ០៣៧ រៀលក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ ២០១៧ និង២០១៨ខាងមុខ ដោយសារការបន្តរក្សាបាន កំណើនសេដ្ឋកិច្ចខ្ពស់ និងជំនឿទុកចិត្តពីសាធារណជន ពិសេសការបន្តអនុវត្តបានល្អប្រសើរ និងសមស្រប នៃគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ និងគោល-នយោបាយរូបិយវត្ថុក្នុងវិស័យហិរញ្ញវត្ថុសាធារណៈរបស់ ធនាគារជាតិនៃកម្ពុជា។

- ឱនភាពគណនីចរន្តត្រូវបានព្យាករថានឹងបន្តប្រសើរឡើង ក្នុងអត្រា ៧,៩% នៃ ផ.ស.ស នា ឆ្នាំ ២០១៧ និង ៨,៥% នៃ ផ.ស.ស នៅឆ្នាំ ២០១៨។ ភាពប្រសើរឡើងនេះ ស្តែងចេញតាមរយៈការកើនឡើងជាលំដាប់នៃសមត្ថភាពនាំចេញរបស់កម្ពុជា ស្របពេលដែលផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៧ ទុនបម្រុងនឹងមានទំហំ ៧ ៥៣៨ លានដុល្លារអាមេរិក ហើយនឹងអាចកើនឡើងដល់ ៧ ៨៥៣ លានដុល្លារអាមេរិក នាឆ្នាំ ២០១៨ ដែលអាចធានាបានជាមធ្យមប្រមាណជា ៥,៦ ខែ នៃការនាំចូលទំនិញ និងសេវាទាំងអស់។

- ជារួម ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ចតាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព, ស្ថិរភាពតម្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅកំណើន ផ.ស.ស ឱ្យ សម្រេចបានប្រមាណ ៧,០% សម្រាប់ឆ្នាំ ២០១៧ និងឆ្នាំ ២០១៨។ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាជាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ ៣,៥% ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងបន្តធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយខិតខំជំរុញលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងរយៈពេលមធ្យម និង រយៈពេលវែង។

## ២.២- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៨

៨- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ដោយមានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តជានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន,
- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងជានាការពារអធិបតេយ្យ និងបូរណភាពទឹកដី,
- បន្តជានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ព្រមទាំងជានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព,
- បន្តផ្តល់អាទិភាពដល់ការដំឡើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានដាង ១ លានរៀលនៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ, ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨), ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,
- បន្តខិតខំប្រឹងប្រែងខ្លាំងក្លាជាងមុនក្នុងការប្រមូលចំណូល ដើម្បីបន្តសម្រេចបានតាមទិសដៅដាក់ចេញក្នុង**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៤-២០១៨)** ជាពិសេស គឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក,
- ខិតខំរក្សាឱ្យបាននូវលំហថវិកាសមស្រប រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដាយថាហេតុ, ទន្ទឹមនឹងការបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹង-ផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស,
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព,
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល អាហារូបត្ថម្ភ និងសេវាសន្តិសុខសង្គម,
- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធជាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យ ។ល។ *ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងសកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ដែល*

*មានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជំងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះ-មហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច,*

- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេស ផ្លូវថ្នល់ និង ប្រព័ន្ធជាតិសាស្ត្រស្រោចស្រព,
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្មនិងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញ ការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ,
- ជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥,
- បន្តអនុវត្តកំណែទម្រង់សំខាន់ៗ រួមទាំង ការពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច,
- លើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានានូវកិច្ចដំណើរការដោយរលូន និងដោយជោគជ័យនៃការបោះឆ្នោតសកលឆ្នាំ២០១៨។

៩- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៨ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ២០១៨ ដូចខាងក្រោម៖

### ២.២.១- ក្របខណ្ឌចំណូលថវិកាឆ្នាំ២០១៨

១០- គម្រោងចំណូលថវិកាឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម៖

- ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ២០១៨ គ្រោងសម្រេចឱ្យបាន ១៨,៧៨% នៃផ.ស.ស. គឺមានកំណើន ០,២១ ពិន្ទុភាគរយនៃផ.ស.ស. ឬ កើនឡើង ១១,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ២០១៧) ក្នុងនោះ ៖

• ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ១៨,៦០% នៃផ.ស.ស. គឺមានកំណើន ០,១៩ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ចំណូលពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៨,៤១% នៃផ.ស.ស. គឺមានកំណើន ០,២៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៦,៨១% នៃផ.ស.ស. គឺមានកំណើន ០,២២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៤,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,៥០% នៃផ.ស.ស. គឺថយចុះ ០,១១ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។

• **ចំណូលមូលធន**ក្នុងប្រទេស ត្រូវសម្រេចឱ្យបាន០,១៨% នៃផ.ស.ស. គឺមានកំណើន ០,០២ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ២១,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។

• ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៥៩%នៃផ.ស.ស. គឺថយចុះ ០,២០ ពិន្ទុភាគរយ នៃផ.ស.ស.

ឬកើនឡើង ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ហើយ**មូលនិធិទ្រទ្រង់ថវិកា** គ្រោងសម្រេចឱ្យបាន ០,៣០%នៃផ.ស.ស.។

១១- ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយសម្រាប់រយៈពេលខ្លី និងមធ្យម ស្របតាម **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តប្រឹងប្រែងខ្លាំងក្លាជាងមុន ក្នុងការលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការកែសម្រួលនិងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធដល់អ្នកបង់ពន្ធដើម្បីលើកកម្ពស់អនុលោមភាព, បន្តពង្រឹងការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឬសគល់ និងការពង្រឹងការកៀរគរបន្ថែមនូវចំណូលមិនមែនសារពើពន្ធតាមបណ្តាក្រសួង ស្ថាប័ននានា។

**ក.១- ផ្នែកចំណូលពន្ធដារ**

១២- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន៖

- <u>បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្តោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា</u> តាមរយៈ ៖
    - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី,
    - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្លូវផ្តេងព័ត៌មានជាមួយស្ថាប័នផ្សេងៗ,
    - ការផ្តល់សេវាជូនអ្នកជាប់ពន្ធធំចំនួន ១៥០ សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ,
    - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment)
    - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យ ឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម,
    - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្តានុពលមួយចំនួនដូចជា វិស័យនាំចេញ-នាំចូល វិស័យទេសចរណ៍ និងវិស័យសំណង់,
    - ការបន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរថ្លៃ,
    - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្តីពីការផ្ទេរថ្លៃ (Transfer Pricing) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ,

- ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។

- <u>បន្តការពង្រឹងមុខងារគាំទ្រ</u> តាមរយៈ៖
  - ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន,
  - ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរ ដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ,
  - ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single sign-on)។

**ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ**

១៣- វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ២០១៨ រួមមាន៖

- <u>ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្អែកលើការប្រកាសគយ, ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ</u> តាមរយៈ ៖
  - ការបន្តលើកកម្ពស់អនុលោមភាព នៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយ ទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយ ដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធអត្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេសជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក,
  - ការចុះឃ្លាំមើលនិងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនករមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ,
  - ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងធុរជនលើនីតិវិធីគយជាពិសេស កាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត,
  - ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការ លើជនសង្ស័យឬជនល្មើសដែលមិនរាងចាល,
  - ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរូបវន្តលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យនិងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរូបវន្តដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កែន,

- ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការលើកកម្ពស់ កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយដាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វេភាគី ឬច្រករបៀងខុសច្បាប់,
- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជនតាមរូបភាពនៃការចូលរួម ផ្តល់ព័ត៌មាន ព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់,
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយតាមរយៈ ការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស,

- <u>ការបន្តការពង្រឹងយន្តការគាំទ្រ</u> តាមរយៈ៖
  - ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្សៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្ទុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្យដ្ឋានច្បាស់លាស់ ទាំងយានយន្តឯកជន, យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្ន ផ្សេងៗ,
  - ការកសាង អនុវត្ត និងវាយតម្លៃការអនុវត្តផែនការសកម្មភាពឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើ (១)-រចនាសម្ព័ន្ធគ្រប់គ្រង, (២)-សមត្ថភាពនិងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)-ការបំពាក់មធ្យោបាយការងារទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរូបវន្តផ្សេងទៀតឱ្យបានសមស្រប ដូចជា មធ្យោបាយប្រដេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយមានស្នាដៃ និងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម,
  - ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូលដោយបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល សន្និធិ និងចរាចរចែកចាយផលិតផលតេលសិលា ជាពិសេសការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,
  - ការបន្តពង្រីកភាពគ្របដណ្តប់និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិករវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ,

- ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានាសំដៅប៉ះប៉ូវចំណូលគយ ដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលា ជាពិសេស (១)-ការបន្តពិនិត្យលទ្ធភាពដំឡើងអត្រាអាករពិសេស (២)-ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស និងការកាត់បន្ថយការលើកទឹកចិត្តពន្ធអាករហួសពីការអនុវត្តល្អក្នុងតំបន់ និង (៣)-ការចាត់វិធានការមុតស្រួចនានាបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៤- វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ២០១៧ រួមមាន៖

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ,
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន កត់ត្រា កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធ ឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវច្បាស់លាស់, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធ ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ,
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត,
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល,
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យាកំពុងរៀបចំដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,
- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិឱ្យគ្រប់ចំនួន និងទាន់ពេលវេលា,
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព,
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដែលបច្ចុប្បន្នអគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធកំពុងសហការជាមួយរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍

ស៊ីវិល ដើម្បីបង្កើតកម្រៃ ៤ ដុល្លារអាមេរិក សម្រាប់អ្នកដំណើរក្នុងប្រទេស និង ៦ ដុល្លារ អាមេរិក សម្រាប់អ្នកធ្វើដំណើរក្រៅប្រទេស,

- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល,
- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរចំណូលពីវិស័យកាស៊ីណូ និងឆ្នោតឡូតូ,
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online,
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណកម្មឱ្យចេញនៅឆ្នាំ ២០១៨,
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

## ២.២.២- ក្របខណ្ឌចំណាយថវិកាឆ្នាំ២០១៨

១៥- គម្រោងចំណាយថវិកាឆ្នាំ ២០១៨ ត្រូវបានកំណត់ និងវិភាជ ដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋ** សម្រាប់ឆ្នាំ២០១៨ ត្រូវបានគ្រោងស្មើនឹង ២៤,៦៨% នៃផ.ស.ស. គឺមានកំណើន ១,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០១៧)។ ក្នុងនោះ **ចំណាយចរន្តថវិការដ្ឋ**នឹងកម្រិតត្រឹម ១៥,៦៨% នៃផ.ស.ស. គឺមានកំណើន ០,២៦ ពិន្ទុភាគរយ នៃផ.ស.ស. ឬកើនឡើង ១២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដោយផ្តោតអាទិភាពជាពិសេសលើការបង្កើន**ចំណាយបៀវត្ស** សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលនឹងធ្វើឱ្យចំណាយនេះឡើងដល់ ៥៣,៦៩% នៃ ចំណាយចរន្តសរុប ឬស្មើប្រមាណ ៨,៤២% នៃផ.ស.ស.។ **ចំណាយមូលធន** ត្រូវបានគ្រោងស្មើនឹង ៩,០០% នៃផ.ស.ស.គឺមានកំណើន ០,៧៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ២១,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស** ត្រូវបានគ្រោង ក្នុងកម្រិត ៣,៦៦% នៃផ.ស.ស. គឺមានកំណើន ០,៩៨ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៥១,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ និង**ចំណាយសម្រាប់ការទូទាត់ប្រាក់ខ្ចី** ត្រូវបានគ្រោងក្នុងកម្រិត ០,៧៤% នៃផ.ស.ស. កើនឡើង ១០,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។ ទន្ទឹមនេះ **ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងក្នុងកម្រិត ៤,៥៩% នៃផ.ស.ស. គឺថយចុះ ០,២០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៦,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។
- **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ លើមូលដ្ឋាននៃការបន្តខិតខំបង្កើនប្រសិទ្ធភាពចំណាយ (ទាំងប្រសិទ្ធភាពក្នុងការវិភាជ, ទាំងប្រសិទ្ធភាពក្នុងផ្នែកប្រតិបត្តិការ) ក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ក៏ដូចជាលើមូលដ្ឋាននៃការធានាឱ្យបាននូវកិច្ចដំណើរការដោយរលូន និងដោយជៀគជ័យនៃការបោះឆ្នោតឆ្នាំ ២០១៨ ដូចខាងក្រោម៖
  - **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត ៥,៤៥% នៃផ.ស.ស គឺមានកំណើន ០,០៤ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១១.៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,

- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងក្នុងកម្រិត១,៤៩% នៃផ.ស.ស. គឺមានកំណើន ០,០៣ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១២,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,
- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងក្នុងកម្រិត ២,១១% នៃផ.ស.ស គឺថយចុះ ០,១២ ពិន្ទុភាគរយនៃផ.ស.ស. ប៉ុន្តែមានកំណើន ៤,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧,
- **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងក្នុងកម្រិត ៣,៨៩% នៃផ.ស.ស គឺមានកំណើន ០,១៦ ពិន្ទុភាគរយនៃផ.ស.ស. ឬកើនឡើង ១៥,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧។

- **ចំណាយចរន្តថវិការាជធានី ខេត្ត, មូលនិធិក្រុង ស្រុក ខណ្ឌ និង មូលនិធិឃុំ-សង្កាត់** ត្រូវកំណត់ត្រឹម ១,៤៧% នៃផ.ស.ស កើនឡើង ៤,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ ដែលក្នុងនោះ ថវិកាផ្ទាល់របស់ រាជធានី ខេត្ត សរុបមានប្រមាណ ០,៧២% នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ រាជធានី ខេត្ត ស្មើនឹង ០,១៥% នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិក្រុង ស្រុក ខណ្ឌ ស្មើនឹង ០,១៦% នៃផ.ស.ស. ឬស្មើនឹង ១,០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧,និង ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ ២០១៨ ស្មើនឹង០,៤៤% នៃផ.ស.ស. ឬស្មើនឹង ២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧។

## **វិធានការដើម្បីបង្កើនប្រសិទ្ធភាពចំណាយ**

១៦-ក្នុងក្របខណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តយុទ្ធសាស្ត្រ និង ក្របខណ្ឌនៃវិធានការដើម្បី *បង្កើនប្រសិទ្ធភាពចំណាយ* ដូចខាងក្រោម៖

- បន្តការគិតគូរពីការរៀបចំថវិកាឱ្យកាន់តែមានលក្ខណៈផ្សារភ្ជាប់ទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការរិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅ ពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា,
- ពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឱ្យបានគ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិពីចំនួន ៣៦ ក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០១៧ ឱ្យឡើងដល់គ្រប់ក្រសួង-ស្ថាប័នទាំង ៣៩ ក្នុងឆ្នាំ ២០១៨, និង ពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, ចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ច,
- បន្តក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះ-បណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក, កសិកម្ម និងប្រព័ន្ធគាំពារសង្គម,
- បន្តធ្វើវិស្តារកម្មគោលនយោបាយចំណាយ (រួមជាមួយការបន្តរឹតត្បិតចំណាយមិនចាំបាច់) ក្នុងស្មារតីគាំទ្រដល់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" និងគាំទ្រដល់ការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគ

សាធារណៈលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គីសនី។ល។ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន។ បង្កើនការយកចិត្តទុកដាក់លើចំណាយថែទាំឱ្យមានប្រសិទ្ធភាព ក្នុងទិសដៅកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត,

- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម វិស័យចំណីអាហារ និងវិស័យ គាំទ្រដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញការកែច្នៃកសិផលសម្រាប់ការនាំចេញ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម តាមរយៈវិចារណកម្មគោលនយោបាយចំណាយក្នុងទិសដៅទទួលបានប្រសិទ្ធភាពខ្ពស់,
- បន្តជំរុញអនុវត្ត**កម្មវិធីសាច់ប្រាក់ពលកម្ម** (Cash For Work) ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពប្រជាជន នៅទីជនបទ,
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេល នៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត (ចំណាយបុគ្គលិក និងមិនមែនបុគ្គលិក) និងចំណាយមូលធន,
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងដំហានបន្ទាប់ផ្សេងៗទៀត,
- គិតគូរឱ្យមានកញ្ចប់ថវិការត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានសក្តិ,
- លើកកម្ពស់ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងពីប្រភពថវិការដ្ឋ ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងពីប្រភពថវិការបស់ដៃគូឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន តាមរយៈ ៖
    - ការរៀបចំក្របខណ្ឌ និងគោលការណ៍រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅមុនដំណាច់ឆ្នាំ២០១៧,

- ការរៀបចំគោលការណ៍ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានពីប្រភពថវិកាជាតិ ដែលគ្រោងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យ នៅក្នុងឆ្នាំ២០១៨,
- ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធីរួមសម្រាប់គ្រប់គ្រង និងអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុង ឆ្នាំ២០១៨,
- ការរៀបចំក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងនីតិវិធីប្រតិបត្តិការរួមសម្រាប់គ្រប់គ្រង ការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨;

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាព ស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុល។

### ២.២.៣-ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ២០១៨

១៧- ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និង ផ្នែកចំណាយខាងលើ នឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ២,៩២% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,៩០% នៃផ.ស.ស. នៅក្នុងឆ្នាំ២០១៨។ ដូច្នេះ ដើម្បីធានាបាននូវតុល្យភាពថវិកា រាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ប្រាក់បញ្ញើរបស់រាជ្ជាភិបាលចំនួនប្រមាណ១,០% នៃផ.ស.ស ត្រូវជាប្រមាណ ៩៩៤ ៧៣៧ លានរៀល។ ប្រការនេះ នឹងផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ តាមផែនការដែលបានគ្រោងទុក ទន្ទឹមនឹងការបន្តធានារក្សាបាននូវលំហថវិកាក្នុងទំហំមួយសមស្របសម្រាប់ត្រៀមទប់ទល់នឹងវិបត្តិ ក៏ដូចជាហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ។

## ៣. គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០១៨

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ២០១៨

១៨- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងល័ក្ខខ័ណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ២០១៧),
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ,

- ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
- ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ

• ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

## ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ២០១៨

១៩- **ក្រសួង-ស្ថាប័ន** មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ដែលបាននិងកំពុង**អនុវត្តថវិកាកម្មវិធី** និង ក្រសួង-ស្ថាប័នដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០១៨ ត្រូវបន្ត និងយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព និង ជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬជាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ដែលមានបទពិសោធន៍ក្នុងការរៀបចំ ក៏ដូចជាក្នុងការអនុវត្តថវិកាកម្មវិធីរួចហើយ ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ និងស៊ីសង្វាក់គ្នា ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២០- គ្រប់**ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និង ចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០១៦ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០១៧ និងដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២១- ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ២០១៨-២០២០, ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០១៨ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តទាំងអស់ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួន ដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួលនិងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតទៅតាមគោលការណ៍នៃ

ការដំឡើងបៀវត្សរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា គឺចៀសវាងការគ្រោងបៀវត្ស ឬ បន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោលមិនប្រើប្រាស់ដូចឆ្នាំកន្លងមក។ គោលការណ៍សម្រាប់ការគ្រោងបន្ទុកបុគ្គលិកឆ្នាំ២០១៨ រួមមាន៖

- ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៧ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៧ ដោយ**ដំឡើងបៀវត្សមូលដ្ឋាន** តាមតម្លៃឯកតាសន្ទស្សន៍ ២ ១៣០ រៀល ដោយគិតចាប់ពីខែ មករា ដល់ ខែធ្នូ គឺមានកំណើនស្មើនឹង ១២% ក្នុងមួយឆ្នាំ,
- **ចំនួនក្របខណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើន ស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ដែលត្រូវកាត់ចេញពីអង្គភាពសាមី ហើយត្រូវបញ្ជាក់ពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័ន អាចស្នើប្រើប្រាស់ថវិកានោះ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន។*
- ការដំឡើង**ប្រាក់បំណាច់មុខងារ**ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នឹងត្រូវបានអនុវត្តគិតចាប់ពីខែ មេសា ដល់ ខែ ធ្នូ ឆ្នាំ ២០១៨ ទៅតាមកម្រិតនៃប្រាក់បំណាច់មុខងារដូចតទៅ៖
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យរដ្ឋបាល, ការទូត, បច្ចេកទេស និងផ្សេងៗ៖**
    - ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៣៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល
    - ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៥០០ ០០០ រៀល ឡើងទៅ។
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យអប់រំ៖**
    - ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៤៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥៤០ ០០០ រៀល,
    - ផ្តល់បន្ថែម ៩០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៥៤០ ០០០ រៀល ទៅដល់កម្រិតក្រោម ៧៥០ ០០០ រៀល,
    - ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារចាប់ពី ៧៥០ ០០០ រៀល ឡើងទៅ។
  - **សម្រាប់មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យសុខាភិបាល៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥៩០ ០០០ រៀល,
- ផ្តល់បន្ថែម ៩០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៩០ ០០០ រៀល ទៅដល់កម្រិតក្រោម ៧០០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧០០ ០០០ រៀល ឡើងទៅ។

▪ **សម្រាប់យោធិន៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល,
- ផ្តល់បន្ថែម ៨០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០ រៀល ទៅដល់កម្រិតក្រោម ៦៥០ ០០០ រៀល,
- ផ្តល់បន្ថែម ៦០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ១ ៣៤០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៣៤០ ០០០ រៀល ឡើងទៅ។

▪ **សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារ៖**

- ផ្តល់បន្ថែម ១០០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល,
- ផ្តល់បន្ថែម ៨០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០ រៀល ទៅដល់កម្រិតក្រោម ៦៥០ ០០០ រៀល,
- ផ្តល់បន្ថែម ៦០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០ រៀល ទៅដល់កម្រិតក្រោម ១ ៤៤០ ០០០ រៀល,
- ផ្តល់បន្ថែម ៤០ ០០០ រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៤៤០ ០០០ រៀល ឡើងទៅ។

- ចំនួនមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងមិនឱ្យលើសចំនួនដែលក្រសួងមុខងារសាធារណៈផ្តល់ជូន ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវ ស្របតាមគោលការណ៍ ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងដំឡើងពី ៥០០ ០០០ រៀល ក្នុងឆ្នាំ ២០១៧ ទៅដល់ ៦០០ ០០០ រៀល សម្រាប់រយៈពេល ១២ ខែ ដោយគ្រោងអនុវត្តចាប់ពីខែ មករា ដល់ ខែធ្នូ ឆ្នាំ ២០១៨។
- ជាមួយគ្នានេះដែរ របបសន្តិសុខសង្គមអប្បបរមាប្រចាំខែ ត្រូវគ្រោងដំឡើងពី ៤២០ ០០០ រៀល ក្នុងឆ្នាំ ២០១៧ ទៅដល់ ៤៨០ ០០០ រៀល។ និវត្តជនដែលជាអតីតមន្ត្រីរាជការ

ស៊ីវិល និងអតីតយុទ្ធជន ត្រូវគ្រោងផ្តល់បន្ថែម ៤០ ០០០ រៀល និង ២០ ០០០ រៀល ដោយផ្អែកលើកម្រិតរបបសន្តិសុខសង្គមប្រចាំខែ ដោយគ្រោងអនុវត្តចាប់ពីខែ មេសា ឆ្នាំ ២០១៨ ។

ខ- **ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន)** ជាសរុបសម្រាប់ឆ្នាំ២០១៨ ត្រូវគ្រោងក្នុងកម្រិតអតិបរមាត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ព្រោះអាទិភាពចំណាយឆ្នាំ២០១៨ ត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺ "ថវិកាឆ្នាំ២០១៨ ត្រូវផ្តោតជាសំខាន់លើការដំឡើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច"។ *ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ ២០១៨ នឹងទទួលបានស្មើឆ្នាំ២០១៧ ដោយស្វ័យប្រវត្តិនោះដែរ* គឺត្រូវទាមទារឱ្យក្រសួង-ស្ថាប័ននីមួយៗ បង្កើនប្រសិទ្ធភាពនៃការធ្វើអាទិភាវូបនីយកម្មមុខចំណាយផង និងប្រសិទ្ធភាពប្រតិបត្តិការចំណាយផង។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ដែលមានសមិទ្ធិកម្មល្អលើការងារកែទម្រង់ដែលទទួលស្គាល់ជាសាធារណៈ នឹងត្រូវទទួលបានការលើកទឹកចិត្ត។ ដូច្នេះ *គ្រប់ក្រសួង-ស្ថាប័ន ត្រូវធ្វើអាទិភាវូបនីយកម្មនៃអាទិភាពគោលនយោបាយ និងថ្លឹងថ្លែងបែងចែកថវិការវាងកម្មវិធីនីមួយៗ ជាពិសេសកម្មវិធីស្នូលរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយ ទៅកម្មវិធីមួយទៀត ឬ ពីអង្គភាពថវិកាមួយ ទៅអង្គភាពថវិកាមួយទៀត នៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាច ទៅតាមនិងរវាងអង្គភាពថវិកានីមួយៗក្នុងក្របខណ្ឌពិដានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី*។ ក្នុងន័យនេះដែរ ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវគ្រោងដោយឈរលើគោលការណ៍ ដូចខាងក្រោម៖

- **ការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ** ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូល ដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៦ កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០១៧ នេះ និង ដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូល លើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយ លើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិពណ៌។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកា ត្រូវបង្ហាញពីភាពចាំបាច់ ភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ ២០១៧ ហើយលែងត្រូវការនៅក្នុងឆ្នាំ២០១៨ ឬសកម្មភាពការងារ ដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៧,
- **ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះឡើយ គឺមានន័យថាលុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី** ដែលត្រូវអនុវត្ត ហើយដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ និងមានយុត្តិការអំពីភាពចាំបាច់ និងបន្ទាន់ ដោយត្រូវផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មី ហើយត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបអាចចាត់ទុកជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចា។
- ការគ្រោង និងវិភាជថវិកា ត្រូវបង្កើនវិមជ្ឈការការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និង សោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។
- ចំពោះតម្រូវការចំណាយបន្ថែមលើសពីពិដានកញ្ចប់ថវិកា ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានីខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែម សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការវាយតម្លៃ ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

**គ. ចំណាយមូលធន/វិនិយោគផ្តាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក២១)** ត្រូវអនុវត្តតាមក្របខណ្ឌនៃការវិភាជដោយឡែក ដោយអនុលោមតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។ សម្រាប់ក្រសួង-ស្ថាប័នដែលត្រូវទទួលបានការវិភាជថវិកាជាទៀងទាត់ ទំហំថវិកានឹងត្រូវបានវិភាជស្របតាមគោល-នយោបាយ ស្របជាមួយនឹងដំណើរការនៃការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។ ចំពោះគម្រោងអាទិភាពលម្អិត គឺជាកម្មវត្ថុនៃកិច្ចពិភាក្សាក្រោមយន្តការអន្តរក្រសួងដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើង។ ដោយឡែកសម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលជាកម្មវត្ថុទទួលបានថវិកាពីកញ្ចប់ឥណទានមិនទាន់បែងចែក ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាពការបូនីយកម្មគម្រោង ស្នើសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ទៅតាមលទ្ធភាពថវិកា។

ទន្ទឹមនេះ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមលក្ខខ័ណ្ឌ ដូចខាងក្រោម៖

- ត្រូវតែជាគម្រោងដែលមានក្នុងក្របខណ្ឌគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង-ស្ថាប័នសាមី,
- ជាគម្រោងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់,
- ជាគម្រោងដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម,
- ចំពោះគម្រោងធំៗ ត្រូវមានការសិក្សាសមិទ្ធិច្បាស់លាស់។

២២- ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃឥណទានថវិកាឆ្នាំ២០១៧ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់យ៉ាងច្រើនត្រឹមកម្រិតឆ្នាំ២០១៧។ ប៉ុន្តែ ការរៀបចំគម្រោងចំណាយលម្អិតតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោង និងវិភាជថវិកា ព្រោះ *ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយតភាពឥណទានថវិកាផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២ សម្រាប់ក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធីទាំងអស់ ហើយត្រូវផ្អែកលើហេតុផល និងលទ្ធផលការងារដែលសម្រេចបាន។*

២៣- ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវធ្វើការ**គណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ ជំពូក៦៣ និងជំពូក៦៥ ដោយផ្អែកលើមូលដ្ឋានពីរបន្ថែមទៀត ដូចខាងក្រោម៖

- *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ពការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋាន សម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើ អគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់**។
- *កំណត់ចំណាយមិនប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយ ជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារឹម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញ

ប្រចាំឆ្នាំព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និង បេសកកម្ម មួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៤- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំ ផ្នែកក្នុង** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ។ ទំហំឥណទានដែលនៅសល់ក្នុងក្របខណ្ឌពិដាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុង**ក្រសួង-ស្ថាប័នដដែល ឬ ទៅ ក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញនៃក្រសួងមួយ ទៅមន្ទីរជំនាញនៃក្រសួងមួយទៀតបាន** ក្នុងក្របខណ្ឌនៃវិស័យចំណាយតែមួយ។

២៥-ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬ ការកាត់បន្ថយគម្រោងចំណាយឆ្នាំ២០១៨ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ២០១៦ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ២០១៧ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ២០១៨*។

២៦- ទន្ទឹមនេះដែរ ត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៧ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ក្នុងការរៀបចំថវិកាឆ្នាំ២០១៨ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្នែកក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្នែកក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល,

- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៧- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួងស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់-

ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

### ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៨

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សានិងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងធ្វើការបូកសរុបចំណូល-ចំណាយ រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៧ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧**។

២៩- **ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៨** ដែលក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់**ការចរចាថវិកាកម្រិតបច្ចេកទេស/ ជំនាញ** និង **ការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង** ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ **ការចរចាថវិកា កម្រិតបច្ចេកទេស និង កម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និង អនុគណនី) និង/ឬ តាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)** លើមូលដ្ឋាននៃ គោលការណ៍និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីជានាប្រសិទ្ធភាពនៃការវិភាជថវិកា ក្នុងកម្រិតនៃពិដានកញ្ចប់ថវិកាឆ្នាំ២០១៨ ដែលបានកំណត់និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលណាមួយ មិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃឥណទាន ថវិកាឆ្នាំ២០១៧ ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមដំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ រាជធានី ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល។

## ៤. សេចក្តីសន្និដ្ឋាន

៣០- ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេស ក្នុងការគ្រោងចំណូល និងចំណាយចាំបាច់ សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំ

ឆ្នាំរបស់ខ្លួន សំដៅធ្វើយ៉ាងណាសម្រេចឱ្យបានជោគជ័យនូវគោលបំណងនៃគោលនយោបាយ និងកម្មវិធី ដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល គឺរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែង ប្រកបដោយចីរភាពក្នុងរង្វង់ ៧% និង កាត់បន្ថយភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំៗ ព្រមទាំងបន្ត រក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺភាពសុខដុមរមនាសង្គម និង សុខុមាលភាពប្រជាជន។

៣១- ទោះជាយ៉ាងណាក៏ដោយ ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ពិសេស ត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំ ថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និង បច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បី មិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ដែលជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជា ជន្លល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដោយរួមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣២- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួន សម្រាប់ ការគ្រប់គ្រងឆ្នាំ២០១៨ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស/ជំនាញ និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ទាន់ពេលវេលាកំណត់។ ក្នុង ការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំង គ្រឹះស្ថាន សាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា)។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
## គម្រោងចំណូលថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច

តារាង ១"ក"

ឯកតា៖លានរៀល

| ជំពូក | ក្រុម | អនុក្រុម | ចំណាត់ថ្នាក់ចំណូល (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | ប៉ាន់ស្មានអនុវត្តឆ្នាំ២០១៧ | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិតចំណូល (ដោយបង្ហាញការគណនាក្នុង១ឯកតា) | បរិមាណ | សរុបទឹកប្រាក់ | អនុវត្តជាក់ស្តែងឆមាសទី១ | ប៉ាន់ស្មានឆមាសទី២ | ប៉ាន់ស្មានប្រចាំឆ្នាំ | | មូលដ្ឋានគិតចំណូល (ដោយបង្ហាញការគណនាក្នុង១ឯកតា) | បរិមាណ | សរុបការគ្រោងចំណូល | |
| | | | | | | | | | ទឹកប្រាក់ | %ច្ប.១៧ | | | ទឹកប្រាក់ | %ច្ប.១៧ |
| សរុបរួម | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ក្រសួង.....

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# គម្រោងថវិកាឆ្នាំ២០១៨
## សរុបគម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច

**តារាង ២"ក"**

ឯកតា៖លានរៀល

| ជំពូក | គណនី | អនុគណនី | **ចំណាត់ថ្នាក់ចំណាយ** (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | ប៉ាន់ស្មានអនុវត្តឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ឥណទានដើមឆ្នាំ | ឥណទានប្តី | អនុវត្តជាក់ស្តែង ឆមាសទី១ | ប៉ាន់ស្មាន ឆមាសទី២ | ប៉ាន់ស្មានប្រចាំឆ្នាំ | | | ទឹកប្រាក់ | %ឥ.ដើមឆ្នាំ ២០១៧ | %ឥ.ប្តី ២០១៧ |
| | | | | | | | | ទឹកប្រាក់ | %ឥ.ដើមឆ្នាំ | %ឥ.ប្តី | | | |
| | | | សរុបរួម | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
# គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦០ : ការទិញ

តារាង ២.១"ក"

| ជំពូក | គណៈ | អនុគណៈ | ចំណាត់ថ្នាក់ចំណាយ (តាមគោលនយោបាយថវិកា) | សរុបសន្និធិ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | |
| | | | | ប្រភេទសន្និធិ | បរិមាណ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ |
| សរុប | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានឧទ្ធរបន្ទុកហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
## គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦១ : សេវាកម្ម

តារាង ២.២"ក"

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋាន គិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | | មូលដ្ឋាន គិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | |
| | | | | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ |
| សរុប | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
## គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦៤ : បន្ទុកបុគ្គលិក

តារាង ២.៣"ក"

| ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | គម្រោងថវិកាឆ្នាំ២០១៨ | | |
|---|---|---|---|---|---|---|
| | មូលដ្ឋាន គិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋាន គិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) |
| សរុប | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
## គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦២ : អត្ថប្រយោជន៍សង្គម

តារាង ២.៤"ក"

| ជំពូក | គណៈ | អនុគណៈ | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | |
| | | | | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ |
| | | | សរុប | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
# គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦៥ : ឧបត្ថម្ភកធន

តារាង ២.៥"ក"

| ជំពូក | គណៈ | អនុគណៈ | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | |
| | | | | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ |
| សរុប | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានធនធនមនុស្សហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
# គម្រោងចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
## ជំពូក៦៣ : ពន្ធ និងអាករ

តារាង ២.៦"ក"

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ប្រាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | | | | | គម្រោងថវិកាឆ្នាំ២០១៨ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | | មូលដ្ឋានគិតចំណាយ (១ឯកតា) | បរិមាណ | ទឹកប្រាក់ (លានរៀល) | | |
| | | | | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ | | | សរុប | ចំណាយជាប្រចាំ | ចំណាយមិនជាប្រចាំ |
| | | | សរុប | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨
## គម្រោងចំណាយមូលធនថវិការដ្ឋ

តារាង ២.៧"ក"

| ជំពូក | គម្រោង | | | | | ឆ្នាំ២០១៧ | | | | គម្រោងថវិកាឆ្នាំ២០១៨ |
|---|---|---|---|---|---|---|---|---|---|---|
| | ឈ្មោះ | ទីតាំង | បរិមាណ | កម្មវិធីទី... | សរុបទឹកប្រាក់ (លានរៀល) | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែងឆមាសទី១ | ប៉ាន់ស្មានអនុវត្តឆមាសទី២ | ប៉ាន់ស្មានអនុវត្តឆ្នាំ២០១៧ | |
| | សរុប | | | | | | | | | |
| | ឆ្នាំ២០១៨(សំណើគម្រោងថ្មី) | | | | | | | | | |
| | ១/ ..... | | | | | | | | | |
| | ២/ ..... | | | | | | | | | |
| | ..... | | | | | | | | | |
| | ឆ្នាំ២០១៧ | | | | | | | | | |
| | ..... | | | | | | | | | |
| | ..... | | | | | | | | | |
| | ឆ្នាំ ..... | | | | | | | | | |
| | ..... | | | | | | | | | |
| | ..... | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ហត្ថលេខា និងត្រារដ្ឋមន្ត្រី**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ប្រធានទទួលបន្ទុកហិរញ្ញវត្ថុ**

ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**រៀបចំដោយ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....

# គម្រោងថវិកាឆ្នាំ២០១៨

## គម្រោងបន្ទុកបុគ្គលិកក្របខ័ណ្ឌ និងមិនមែនក្របខ័ណ្ឌ

តារាង ៣"ក"

| កាំប្រាក់ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | | | | | |
|---|---|---|---|---|---|---|---|
| | ចំនួនមន្ត្រី (នាក់) | ចំនួនមន្ត្រី (នាក់) | សរុប ទឹកប្រាក់ | បៀវត្ស មូលដ្ឋាន | ប្រាក់បំណាច់ មុខងារ | កូនអាយុ ២០ឆ្នាំចុះ | អ្នកក្នុង បន្ទុក |
| សរុបរួម | | . | . | . | . | . | . |
| បុគ្គលិកអចិន្ត្រៃយ៍ | | . | . | . | . | . | . |
| សរុប ក | | . | . | . | . | . | . |
| ក.១ | | . | . | . | . | . | . |
| ក.១.១ | | | - | | | | |
| ក.១.២ | | | - | | | | |
| ក.១.៣ | | | - | | | | |
| ក.១.៤ | | | - | | | | |
| ក.១.៥ | | | - | | | | |
| ក.១.៦ | | | - | | | | |
| ក.២ | | . | . | . | . | . | . |
| ក.២.១ | | | - | | | | |
| ក.២.២ | | | - | | | | |
| ក.២.៣ | | | - | | | | |
| ក.២.៤ | | | - | | | | |
| ក.៣ | | . | . | . | . | . | . |
| ក.៣.១ | | | - | | | | |
| ក.៣.២ | | | - | | | | |
| ក.៣.៣ | | | - | | | | |
| ក.៣.៤ | | | - | | | | |
| សរុប ខ | | | | | | | |
| ខ.១ | | | | | | | |
| ខ.១.១ | | | | | | | |
| ខ.១.២ | | | | | | | |
| ខ.១.៣ | | | | | | | |
| ខ.១.៤ | | | | | | | |
| ខ.១.៥ | | | | | | | |
| ខ.១.៦ | | | | | | | |
| ខ.២ | | | | | | | |
| ខ.២.១ | | | | | | | |
| ខ.២.២ | | | | | | | |
| ខ.២.៣ | | | | | | | |
| ខ.២.៤ | | | | | | | |
| ខ.៣ | | | | | | | |
| ខ.៣.១ | | | | | | | |
| ខ.៣.២ | | | | | | | |
| ខ.៣.៣ | | | | | | | |
| ខ.៣.៤ | | | | | | | |
| សរុប គ | | | | | | | |
| គ.១ | | | | | | | |
| គ.២ | | | | | | | |
| គ.៣ | | | | | | | |
| គ.៤ | | | | | | | |
| គ.៥ | | | | | | | |
| គ.៦ | | | | | | | |
| គ.៧ | | | | | | | |

| កាំប្រាក់ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | | | | | |
|---|---|---|---|---|---|---|---|
- *ដំណាក់កាលទី៣ (តុលា-ធ្នូ) គឺជាដំណាក់កាលស្នើសុំការអនុម័តសេចក្តីព្រាងច្បាប់*។ ឥឡូវនេះយើងកំពុងស្ថិតក្នុងដំណាក់កាលទី៣ គឺការសុំការអនុម័តពីគណៈរដ្ឋមន្ត្រី ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនដល់រដ្ឋសភាក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៧ ហើយនឹងត្រូវបានអនុម័តទាន់ពេលវេលាដោយស្ថាប័ននីតិប្បញ្ញត្តិ គឺត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ ដូច្នេះ តាមរយៈនៃកិច្ចដំណើរការនេះ បញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាផលិតផលរួមរបស់គ្រប់ក្រសួង-ស្ថាប័ននិងត្រូវប្រើរយៈពេល១០ ខែ ក្នុងការរៀបចំ(៧ខែ) និងអនុម័ត(៣ខែ) ក្រោមការចង្អុលបង្ហាញគ្រប់ជំហានរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**។

### ១.២- <u>ទម្រង់នៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨</u>

**សេចក្តីព្រាងច្បាប់នេះរួមមាន៦ ជំពូក និង១៥ មាត្រា៖**

- **ជំពូកទី១ មាន៦ មាត្រា** (មាត្រា១ ដល់៦) កំណត់អំពីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៨
- **ជំពូកទី២ មាន២ មាត្រា** (មាត្រា៧ ដល់៨) កំណត់អំពីការខ្ចី និងការធានារបស់រដ្ឋសម្រាប់ឆ្នាំ២០១៨
- **ជំពូកទី៣ មាន៣ មាត្រា** (មាត្រា៩ ដល់១១) កំណត់អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ
- **ជំពូកទី៤ មាន១ មាត្រា** (មាត្រា១២) កំណត់អំពីនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- **ជំពូកទី៥ មាន១ មាត្រា** (មាត្រា១៣) កំណត់អំពីចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៨ ដែលរួមមានថវិការបស់រដ្ឋបាលរាជធានី-ខេត្ត ថវិការបស់រដ្ឋបាលក្រុង-ស្រុក និងថវិការបស់រដ្ឋបាលឃុំ-សង្កាត់
- **ជំពូកទី៦ ជាអវសានប្បញ្ញត្តិ មាន២ មាត្រា** (មាត្រា១៤ និង១៥)។

### ១.៣- <u>បរិការណ៍នៃការរៀបចំថវិកាឆ្នាំ២០១៨</u>

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលកើតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** និងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និង

ការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ ព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវការអភិវឌ្ឍ រីកចម្រើនលូតលាស់លើគ្រប់វិស័យគួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ជាពិសេស ការសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺការក្លាយខ្លួនជាប្រទេសចំណូលមធ្យម កម្រិតទាបនៅក្នុងឆ្នាំ២០១៥ កន្លងទៅ ក៏ដូចជាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត។ សមិទ្ធផលខាងលើនេះគឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជា ដោយចាប់ផ្តើមពីបាតដៃទទេ និងក្នុង ដំណើរឆ្លងកាត់ដ៏វែងឆ្ងាយ បត់បែន និងលំបាកជាច្រើនរាប់មិនអស់ ហើយទទួលបាននូវការសាទរ និង ការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើមុខ និងស្មើសិទ្ធិ ជាពិសេសបានផ្តល់នូវក្តីសង្ឃឹម និងភាពជឿជាក់ ចំពោះជោគវាសនាអនាគតរបស់ប្រជាជនគ្រប់រូប និងប្រទេសជាតិទាំងមូល នៅក្នុងដំណើរ ឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីទៀត គឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមាន សមធម៌សង្គម និងការថែរក្សាបរិស្ថានកាន់តែល្អប្រសើរ។

ឈរលើមូលដ្ឋាននេះ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបាន រៀបចំឡើងក្នុងគោលដៅដើម្បីបង្ហាញអំពីលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន ព្រមទាំងវិធានការ គោលនយោបាយសំខាន់ៗ នៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ឆ្ពោះទៅរក ការសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលបាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើម នីតិកាលមកដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក៏ដូចជាដើម្បី ឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរដោយចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍ថ្មី ទាំង កម្រិតជាតិ និងអន្តរជាតិ។

ជាបរិការណ៍ទូទៅ ឆ្នាំ២០១៨ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ផង និងជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ផង។ ដូចនេះ រាជរដ្ឋាភិបាលត្រូវធានាឱ្យការបោះឆ្នោតទាំងពីរនេះ ប្រព្រឹត្តទៅដោយរលូន មានសណ្តាប់ធ្នាប់ និងប្រកបដោយតម្លាភាព ទន្ទឹមនឹងការធានាឱ្យបាននូវស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាទូទៅ ជាពិសេសការធានារក្សាការពារឱ្យបានដាច់ខាតនូវសុខសន្តិភាព និង ស្ថិរភាពសង្គម ដែលសម្រេចបានមកដោយលំបាក ឱ្យស្ថិតស្ថេរគង់វង្សចីរកាល ក៏ដូចជាការបន្តទប់ស្កាត់រាល់ ឧបាយកលនិងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឱ្យប្រទេសជាតិធ្លាក់ទៅក្នុងសភាពវឹកវរ និង អស្ថេរភាព។ ម៉្យាងទៀត និន្នាការនៃការផ្លាស់ប្តូរថ្មីនៅក្នុងបរិការណ៍ពិភពលោក ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រ នយោបាយ ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រសេដ្ឋកិច្ច និងទាំងក្នុងទិដ្ឋភាពចរន្តនយោបាយ-សង្គម រួមទាំង បញ្ហាសន្តិសុខនៅក្នុងតំបន់ និងពិភពលោក អាចនឹងបង្កើនកម្រិតហានិភ័យដល់សេដ្ឋកិច្ចពិភពលោកឱ្យកាន់តែ ខ្ពស់ថែមទៀត ទោះបីស្ថានភាពសេដ្ឋកិច្ចពិភពលោកកំពុងមានលក្ខណៈប្រសើរជាងបណ្តាឆ្នាំកន្លងទៅក្តី។ ទោះបីជាយ៉ាងនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានឹងនៅតែអាចបន្តមានស្ថានភាពល្អប្រសើរ ហើយ នៅតែអាចរក្សាបាននូវចីរភាពនៃកំណើន សម្រាប់រយៈពេលមធ្យមទៅមុខ។ ក៏ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាកំពុងស្ថិតក្នុង របត់ថ្មីមួយ ដែលទាមទារជាចាំបាច់នូវការជំរុញអនុវត្តឱ្យបានខ្លាំងក្លា និងឱ្យកាន់តែមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយទាំងឡាយ ដែលត្រូវបានដាក់ចេញក្នុងពេលកន្លងមក ព្រមពេលជាមួយគ្នានឹង

ការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែលូតលាស់ ហើយកាន់តែស្មុគស្មាញជាងមុន និងការប្រែប្រួលរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ជាពិសេសការចាប់យកកាលានុវត្តភាពពីផលលាភបច្ចេកវិទ្យាឌីជីថល និងផលលាភប្រជាសាស្ត្រ ក្នុងគោលដៅទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យសម្រេចបានក្នុងរង្វង់៧% ក្នុងមួយឆ្នាំប្រកបដោយបរិយាប័ន្ន ដែលជាមូលដ្ឋានមិនអាចខ្វះបាន ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣០ ដើម្បីអាចក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ហើយប្រជាជនកម្ពុជាគ្រប់រូបនឹងទទួលបានឱកាសរកប្រាក់ចំណូលបានកាន់តែច្រើន, ទទួលបានការអប់រំកាន់តែខ្ពស់ និងការងារធ្វើកាន់តែល្អ ព្រមទាំងជីវភាពកាន់តែធូរធា។ ជាមួយគ្នានេះ កម្ពុជាត្រូវខិតខំទ្វេដងថែមទៀតក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ហើយត្រូវមានភាពហ្មត់ចត់និងភាពប្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងហានិភ័យផ្សេងៗជាប់ជាប្រចាំ។ នៅក្នុងក្របខ័ណ្ឌនេះ កម្ពុជាត្រូវបន្តជំរុញការអនុវត្ត **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥"** ដែលជា **យុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ** ឱ្យកាន់តែខ្លាំងក្លា និងការធ្វើទំនើបកម្មវិស័យកសិកម្ម ព្រមទាំងត្រូវជំរុញការអភិវឌ្ឍវិស័យសេវាកម្ម ដូចជា វិស័យទេសចរណ៍ វិស័យដឹកជញ្ជូននិងឡូជីស្ទីក និងវិស័យហិរញ្ញវត្ថុ ព្រមទាំងវិស័យឌីជីថលឱ្យកាន់តែខ្លាំងថែមទៀត ដើម្បីបង្កើតជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចថ្មី បន្ថែមលើកម្លាំងចលករ អូសកំណើនចាស់ប្រពៃណីដូចជា វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងវិស័យកសិកម្មដែលកំពុងប្រឈមនឹងបញ្ហាផលិតភាពទាប និងហានិភ័យនៃការថមថយ ក៏ដូចជាកត្តាវិបត្តិពីខាងក្រៅ។ ទន្ទឹមនេះ កម្ពុជាក៏ត្រូវបន្តកែទម្រង់វិស័យសាធារណៈ និងបន្តលើកកម្ពស់សមត្ថភាពស្ថាប័ន ព្រមទាំងធនធានមនុស្ស ដើម្បីជាមូលដ្ឋាន សម្រាប់ទ្រទ្រង់ដល់ដំណើរឈានឡើងរបស់កម្ពុជាខាងលើ ក៏ដូចជាដើម្បីលើកកម្ពស់បរិស្ថានវិនិយោគ និងធុរកិច្ចឱ្យកាន់តែប្រសើរឡើង។ ក្នុងន័យនេះ **ថវិកាឆ្នាំ២០១៨ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី៥ នៃរដ្ឋសភា ត្រូវតែជាថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព ស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាពតទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត**។

ជារួម រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ចាប់តាំងតែពីដើមនីតិកាលរបស់ខ្លួនរហូតមក ធានាបានជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសការធានា និងរក្សាបាននូវសន្តិភាព សន្តិសុខ អធិបតេយ្យភាព ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ព្រមទាំងលំនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ទោះបីត្រូវប្រឈមនឹងបញ្ហាគ្រប់បែបយ៉ាង ទាំងក្នុង និងក្រៅប្រទេសក៏ដោយ។ ទន្ទឹមនឹងនេះដែរ ការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យរបស់រាជរដ្ឋាភិបាល បាននិងកំពុងចាប់ផ្តើមបង្កើតចេញជាលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់ ទោះបីល្បឿននៃការកែទម្រង់នេះនៅមានកម្រិតខុសៗគ្នាក៏ដោយ។ ប្រការនេះ បានបង្កើនការជឿជាក់មកលើសមត្ថភាពដឹកនាំ និងគ្រប់គ្រងប្រទេសរបស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់។ ជាក់ស្តែង ទំហំសេដ្ឋកិច្ចជាតិ (ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន) បានកើនឡើងពី៦១ ៣២៦ ៩២៨លានរៀល ឬសមមូលនឹងប្រមាណជាង១៥ ២៣៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់៨៩ ៥០៩ ៤២២លានរៀល ឬសមមូលនឹងប្រមាណជាង២២ ១៧២លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់៩៩ ១១៦ ០៤១

លានរៀល ឬសមមូលនឹងប្រមាណជាង២៤ ៥៥២លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ ចំណូលមនុស្ស
ម្នាក់ធៀបនឹង ផ.ស.ស. ក៏បានកើនឡើងពី១ ០៤២ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ១ ៤៣៥
ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ១ ៥៦៨ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ក្នុងខណៈ
ដែលអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់៤ ០៥០រៀល ក្នុងមួយដុល្លារអាមេរិក ហើយអត្រាអតិផរណាជាមធ្យមស្ថិតក្នុង
រង្វង់៣% ដែលជាកម្រិតមួយទាប និងអាចគ្រប់គ្រងបាន នៅក្នុងរយៈពេលដូចគ្នា។ ទន្ទឹមនឹងនេះ ទុនបម្រុង
អន្តរជាតិក៏បានកើនឡើងពី៣ ៦៤៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់៧ ៥៣៩លានដុល្លារអាមេរិក
ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់៧ ៨៥៣លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ តុល្យភាពជញ្ជីងទូទាត់
ក៏មានភាពកាន់តែល្អប្រសើរឡើងជាលំដាប់ ក្នុងខណៈដែលកម្រិតបំណុលសាធារណៈរបស់កម្ពុជា មានអនុបាត
បំណុលទាបបំផុតនៅក្នុងតំបន់ ដែលឆ្លុះបញ្ចាំងពីហានិភ័យទាប និងចីរភាពនៃបំណុលសាធារណៈរបស់កម្ពុជា។
ជាមួយនឹងកំណើនខាងលើនេះ អត្រានៃភាពក្រីក្រដែលបានធ្លាក់ចុះពីប្រមាណ៥៣,៥%ក្នុងឆ្នាំ២០០៤ មក
ត្រឹមតែប្រមាណ១៣,៥%ក្នុងឆ្នាំ២០១៤ នោះនឹងបន្តកាន់តែធ្លាក់ចុះមកថែមទៀតនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ
ហើយមេគុណជីនីដែលបានធ្លាក់ចុះ ពី០,៣៨០ក្នុងឆ្នាំ២០០៤ មកត្រឹម០,២៩៥ក្នុងឆ្នាំ២០១៤ នោះ ក៏ត្រូវបាន
រំពឹងថាកាន់តែមានភាពប្រសើរឡើងថែមទៀតផងដែរ។ ប្រការនេះ បានគូសបញ្ជាក់ថាកម្ពុជាមិនត្រឹមតែ
សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំប៉ុណ្ណោះទេ តែកំណើននេះក៏កាន់តែមានបរិយាប័ន្ន ហើយ
ការបែងចែកផលនៃកំណើនក៏កាន់តែសមធម៌ផងដែរ។ សមិទ្ធផលសង្គម-សេដ្ឋកិច្ចខាងលើនេះ បានធ្វើឱ្យស្ថាប័ន
ហិរញ្ញវត្ថុអន្តរជាតិចាត់ទុកកម្ពុជាជាប្រទេសមួយ នៅក្នុងចំណោមប្រទេសឯតទគ្គកំណើនចំណាត់ថ្នាក់
ទី៦ នៅក្នុងពិភពលោក ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។ ជាងនេះទៅទៀត ធនាគារអភិវឌ្ឍន៍អាស៊ី
ក៏បានចាត់ទុកកម្ពុជាជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ីផងដែរ។ ក្រៅពីនេះ កម្ពុជាក៏ទទួលបាននូវជ័យលាភី
ជាច្រើនទៀត ដូចជាការទទួលបានចំណាត់ថ្នាក់ជាប្រទេសជោគជ័យបំផុតទី៤ លើពិភពលោក ក្នុងការ-
កាត់បន្ថយអត្រាភាពក្រីក្រ និងទទួលបានការវាយតម្លៃខ្ពស់ពីអង្គការសហប្រជាជាតិ ចំពោះការកាត់បន្ថយអត្រានៃ
ភាពអត់ឃ្លានជាងពាក់កណ្តាលមុនពេលកំណត់ និងជាប្រទេសឈានមុខគេទាំង៧ លើពិភពលោក ក្នុង
ការកែលម្អសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស ក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥។

ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិការណ៍អតិផរណាទាប និង
អត្រាប្តូរប្រាក់មានស្ថិរភាពខាងលើនេះ បានធ្វើឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់នៅទូទាំងប្រទេស
កាន់តែមានឱកាសក្នុងការស្វែងរកការងារ និងក្នុងការបង្កើនប្រាក់ចំណូល ដោយក្នុងនោះ មន្ត្រីរាជការ និង
កងកម្លាំងប្រដាប់អាវុធ ទទួលបាននូវប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការអនុវត្តនូវ
គោលនយោបាយដំឡើងប្រាក់បៀវត្សក្នុងគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលចាប់តាំង
ពីដើមនីតិកាលមក។ ដូចគ្នានេះដែរ កម្មករនិយោជិតរាប់សែននាក់ទៀត ដែលកំពុងតែបម្រើការងារក្នុង
វិស័យឯកជន ក៏ទទួលបាននូវឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួនផងដែរ តាមរយៈការអនុវត្តនូវ
គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ
កាត់ដេរ និងផលិតស្បែកជើងជារៀងរាល់ឆ្នាំ ដែលនឹងត្រូវកើនឡើងដល់ចំនួន១៧០ដុល្លារអាមេរិកនៅឆ្នាំ
២០១៨ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀតពីការអនុវត្តគោលនយោបាយ

គាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ក្រៅពីការផ្តល់នូវឱកាសស្វែងរកការងារ និងឱកាសបង្កើនប្រាក់ចំណូលដូនដល់ប្រជាជនរាប់លាននាក់ខាងលើ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់នានាជាបន្តបន្ទាប់ ក្នុងគោលដៅដោះស្រាយការលំបាក ក្តីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាដោះស្រាយបញ្ហាប្រឈមរបស់ជាតិ ទាំងបញ្ហាសង្គម និងទាំងបញ្ហាសេដ្ឋកិច្ច។ ជាក់ស្តែង ការលុបចោលមិនយកកម្រៃពីសេវាសាធារណៈចាំបាច់មួយចំនួន បានជួយសម្រាលបន្ទុកចំណាយ និងលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ លើសពីនេះ ការដាក់ចេញនូវវិធានការបុរេសកម្មចាំបាច់នានា ជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ទាំងក្នុងទិដ្ឋភាពនយោបាយ និងទាំងក្នុងទិដ្ឋភាពគោលនយោបាយពាក់ព័ន្ធនឹងការបញ្ចុះថ្លៃថាមពលអគ្គិសនី និងទឹកស្អាត ការបន្ធូរបន្ថយពន្ធ និងការអនុគ្រោះពន្ធលើប្រភេទពន្ធមួយចំនួន ដូចជា៖ ការលុបចោលរបបពន្ធម៉ៅការ ការដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ការលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តកម្លាំងក្រោម១៥០សេះ និងការលើកលែងពន្ធប្រថាប់ត្រាក្នុងរង្វង់សាច់ញាតិជាដើម បាននិងកំពុងតែផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន និងគ្រូពេទ្យ កម្មករនិយោជិត ក៏ដូចជាដល់ការប្រកបអាជីវកម្មតូចតាចផងដែរ។ ទន្ទឹមនឹងនេះ ការលុបចោលការបង់ភាស៊ី និងថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកន្ត្រែង កញ្ចើ ល្ហុ នៅតាមទីផ្សារទូទាំងប្រទេស និងការអនុញ្ញាតឱ្យអាជីវករ ដែលមានតូប ពន ស្តង់ ឬកន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ហើយអាចផ្ទេរសិទ្ធិបាន ព្រមទាំងការលុបចោលពន្ធសត្តឃាត និងការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្មសត្តឃាតដ្ឋាន បានចូលរួមចំណែកលើកកម្ពស់ជីវភាព និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើម្ហូបអាហារប្រចាំថ្ងៃបានមួយកម្រិតថែមទៀត ក៏ដូចជាបានជួយជំរុញធ្វើឱ្យសេដ្ឋកិច្ចជាតិ ជាពិសេសសេដ្ឋកិច្ចជនបទកាន់តែរីកចម្រើន។ ជារួម ការដាក់ចេញនូវវិធានការគោលនយោបាយពន្ធខាងលើ គឺដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការជួយដោះស្រាយ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ ទោះយ៉ាងណាក្តី រាជរដ្ឋាភិបាលនៅតែអាចរក្សាបាននូវតួនាទីរបស់ប្រព័ន្ធពន្ធជាឃ្នាស់សម្រាប់ការការពារបាននូវការប្រមូលចំណូល។ ម៉្យាងវិញទៀត ការសម្រេចទិញយកមកគ្រប់គ្រងវិញនូវគម្រោងផ្លូវ និងស្ពានមួយចំនួនជាបន្តបន្ទាប់ពីវិស័យឯកជននៅក្នុងក្របខ័ណ្ឌនៃយន្តការភាពជាដៃគូ រវាងរដ្ឋនិងវិស័យឯកជនក៏បានជួយដោះស្រាយការលំបាក និងជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋបន្ថែមទៀតផងដែរ ក្រៅពីការសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានបង្កើនចំណាយយ៉ាងច្រើនទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃសេវាសាធារណៈ ទាំងតាមរយៈចំណាយចរន្តថវិកាជាតិ និងទាំងតាមរយៈចំណាយវិនិយោគសាធារណៈ ដើម្បីធ្វើឱ្យការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង និងកាន់តែខិតជិតដល់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់។

ចាប់តាំងពីចុងឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលក៏បានគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈបានយ៉ាងល្អ ដែលធ្វើឱ្យវិស័យនេះ កាន់តែមានលក្ខណៈរឹងមាំ និងចីរភាព ទាំងនៅក្នុងផ្នែកចំណូល និងទាំងនៅក្នុងផ្នែកចំណាយ ដែលនេះគឺជាការបោះជំហានឆ្ពោះទៅកាន់ជោគជ័យនៅលើវិថីនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាជាជំហានៗ ឱ្យស្របតាមឧត្តមានុវត្ត

ជាអន្តរជាតិ និងបទដ្ឋានអន្តរជាតិ។ ជាក់ស្តែង ខាងផ្នែកចំណូលយើងសម្រេចបាននូវការបង្កើនទំហំចំណូលចរន្តថវិការដ្ឋសរុបពី៩ ១១០ ៨៤៨លានរៀល ឬសមមូលនឹង២ ២៦៤លានដុល្លារអាមេរិកដែលត្រូវជា ១៤,៨៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ កើនឡើងដល់ប្រមាណ១៦ ៤៦៨ ៩៩៧លានរៀល ឬសមមូលនឹង៤ ០៨០លានដុល្លារអាមេរិក ដែលត្រូវជា១៨,៤០%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ហើយនឹងបន្តកើនឡើងដល់១៨ ៤០៦ ៨១០ លានរៀល ឬសមមូលនឹង៤ ៥៦០លានដុល្លារអាមេរិកនៅឆ្នាំ២០១៨ ដែលត្រូវជា១៨,៥៧%នៃ ផ.ស.ស. **ពោលគឺ ចំណូលចរន្តថវិការដ្ឋបានកើនឡើងប្រមាណពីរដង**។ ប្រការនេះ គួសបញ្ជាក់ថា កម្ពុជាសម្រេចបាននូវកំណើននៃចំណូលប្រមាណជិត១ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ពោលគឺ លើសពីគោលដៅ ០,៥០ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមប្រចាំឆ្នាំ និងលើសពីកម្រិត១៧,៣៥%នៃ ផ.ស.ស. សម្រាប់គោលដៅឆ្នាំ ២០១៨ ដូចដែលមានកំណត់ក្នុង**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨**។ ការសម្រេចបាននូវកំណើនចំណូលដ៏ខ្ពស់ និងមិនធ្លាប់មាននៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ បាននាំកម្ពុជាដែលធ្លាប់មានចំណូលថវិកាជាតិធៀបនឹង ផ.ស.ស. ទាបជាងគេក្នុងតំបន់ ឱ្យឡើងដល់កម្រិតកណ្តាលធៀបនឹងគេវិញ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ក៏បានផ្តល់ការវាយតម្លៃខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា **មិនធ្លាប់មានពីមុនមកនៅក្នុងបណ្តាប្រទេសក្នុងតំបន់**ផងដែរ។ គួរគូសបញ្ជាក់ផងដែរថា សមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេសក្នុងចំណែកថវិកាជាតិបានថយចុះពីប្រមាណជិត៧០%នៅក្នុងឆ្នាំ១៩៩៥ មកត្រឹមតែប្រមាណ២១,៤%ប៉ុណ្ណោះ ក្នុងឆ្នាំ ២០១៧ ហើយនឹងបន្តថយចុះមកទៀតមិនដល់២០%ផងនៅឆ្នាំ២០១៨។ **ប្រការនេះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា សេដ្ឋកិច្ចកម្ពុជាកាន់តែមានឯករាជ្យភាពជាងមុន និងកាន់តែមានភាពជាម្ចាស់ជាងមុន ដែលនេះគឺជាផលផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងឆន្ទៈប្តូរផ្តាច់ឥតងាករេនូវវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានចាប់ផ្តើមតាំងពីនីតិកាលមុនមក**។ ទន្ទឹមនឹងនេះដែរ ខាងផ្នែកចំណាយវិញ គឺយើងបានបង្កើនទំហំចំណាយថវិការដ្ឋសរុបពី១៣ ៤៧៥ ៩២៣ លានរៀល ឬសមមូលនឹង៣ ៣៤៨លានដុល្លារអាមេរិក ដែលត្រូវជា២១,៩៧%នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៣ ឡើងដល់២១ ១៥១ ៩៨៥លានរៀល ឬសមមូលនឹង៥ ២៤០លានដុល្លារអាមេរិក ដែលត្រូវជា២៣,៦៣% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តកើនឡើងដល់២៤ ៣៧៥ ១០២លានរៀល ឬសមមូលនឹង៦ ០៣៨ លានដុល្លារអាមេរិក ដែលត្រូវជា២៤,៥៩%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបថវិការដ្ឋត្រូវបានបង្កើនជិតពីរដង** សម្រាប់គាំទ្រដល់ការកែទម្រង់នានា និងសកម្មភាពការងារសំខាន់ៗចាំបាច់មួយចំនួនទៀតរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ ការអប់រំ សុខាភិបាល ព្រមទាំងការវិនិយោគលើការពង្រឹងការតភ្ជាប់ ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ព្រមទាំងការទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យសម្រេចបាន៧%។ ជាក់ស្តែង យើងបានបង្កើនចំណាយយ៉ាងច្រើនចំពោះវិស័យ និងក្រសួងអាទិភាពនានា ដោយក្នុងនោះ **(១)-ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានបង្កើនពីប្រមាណតែ១ ០៨១ ៦៦២លានរៀល ឬសមមូលនឹងប្រមាណ២៦៩លានដុល្លារអាមេរិក ដែលត្រូវជា ១,៧៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ២ ៧៣៩ ៩១៣លានរៀល ឬសមមូលនឹងប្រមាណ ៦៧៩លានដុល្លារអាមេរិក ដែលត្រូវជា៣,០៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ

៣ ៤៣៨ ០០៨លានរៀល ឬសមមូលនឹងប្រមាណ៨៥២លានដុល្លារអាមេរិក ដែលត្រូវជា៣,៤៧%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើនជាង បីដង (២)-ចំណាយសរុបរបស់ក្រសួងសុខាភិបាល**ត្រូវបានបង្កើនពីប្រមាណតែ៨៥៧ ៦៨២លានរៀល ឬសមមូលនឹងប្រមាណ២១៣លានដុល្លារអាមេរិក ដែលត្រូវជា១,៤០%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ១ ៦៩៧ ៦១៥លានរៀល ឬសមមូលនឹងប្រមាណ៤២១លានដុល្លារអាមេរិក ដែលត្រូវជា១,៩០% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ១ ៩៦៧ ៨៥១លានរៀល ឬសមមូលនឹងប្រមាណ៤៨៧លានដុល្លារអាមេរិក ដែលត្រូវជា១,៩៩%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបរបស់ក្រសួងសុខាភិបាលត្រូវបានបង្កើនជិតពីរដងកន្លះ** និង **(៣)-ចំណាយសរុបរបស់វិស័យកសិកម្មទាំងមូល** ត្រូវបានបង្កើនពីប្រមាណ១ ២៤៤ ៤២៧លានរៀល ឬសមមូលនឹងប្រមាណ៣០៩លានដុល្លារអាមេរិក ដែលត្រូវជា២,០៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ១ ៤៥៧ ៩១៥លានរៀល ឬសមមូលនឹងប្រមាណ៣៦១លានដុល្លារអាមេរិក ដែលត្រូវជា១,៦៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ដោយក្នុងនោះ **ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានបង្កើនពីប្រមាណតែ ១៨៣ ៣៤៩លានរៀល ឬសមមូលនឹងប្រមាណ៣៦លានដុល្លារអាមេរិក ដែលត្រូវជា០,២៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ៤៣៩ ៤៨០លានរៀល ឬសមមូលនឹងប្រមាណ១០៩លានដុល្លារអាមេរិក ដែលត្រូវជា០,៤៩%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយទំហំចំណាយនេះនៅឆ្នាំ២០១៨ នឹងនៅបន្តស្ថិតក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៧ **ពោលគឺ ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើនជិតបីដង**។

ក្រៅពីការបង្កើនទំហំនៃចំណាយ យើងក៏បានខិតខំបង្កើនគុណភាពចំណាយថែមទៀត តាមរយៈការបន្តបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា និងការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និងបច្ចេកទេស ដោយបានធ្វើឱ្យកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបាននូវទំនិញ សេវា និងសំណង់ ក្នុងបរិមាណច្រើនជាងមុន គុណភាពល្អជាងមុន និងតម្រង់ចំណាយឱ្យកាន់តែចំទិសដៅ និងអាទិភាពជាងមុន។ លើសពីនេះ យើងក៏សម្រេចបាននូវអតិរេកថវិកាចរន្តជាប់ជាប្រចាំនៅក្នុងឆ្នាំថវិកានីមួយៗ សម្រាប់យកទៅបង្កើនការវិនិយោគសាធារណៈ។ ជាក់ស្តែង ចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានបង្កើនឡើងពីប្រមាណតែ១ ២៥៩ ៧៩៣លានរៀល ឬសមមូលនឹងប្រមាណ៣១៣លានដុល្លារអាមេរិក ដែលត្រូវជា២,០៥%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ២ ១៨៣ ៧០០លានរៀល ឬសមមូលនឹងប្រមាណ៥៤១លានដុល្លារអាមេរិក ដែលត្រូវជា២,៤៤%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ២ ៩២៥ ៨០០លានរៀល ឬសមមូលនឹងប្រមាណ៧២៥លានដុល្លារអាមេរិក ដែលត្រូវជា២,៩៥ %នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៨ **ពោលគឺ ចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានបង្កើនជិតពីរដងកន្លះ**។ ប្រការនេះ គឺជាការឆ្លុះបញ្ចាំងពីសមត្ថភាព និងឯករាជ្យខាងថវិការបស់កម្ពុជា និងជាលទ្ធផលនៃការប្រកាន់ខ្ជាប់នូវវិន័យថវិកា និងនិយាមថវិកា ព្រមទាំងបានផ្តល់លទ្ធភាពដល់ការបង្កើនប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលសម្រាប់ត្រៀមទប់ទល់បញ្ហាប្រឈម វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ។ ជាមួយគ្នានេះដែរ ក្រៅពីបានដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធជារៀងរាល់ឆ្នាំ

ដែលជាអាទិភាពសំខាន់បំផុតរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅ**ជាង១លានរៀលនៅឆ្នាំ២០១៨** និងបានបើកប្រាក់បៀវត្សទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗតាមប្រព័ន្ធធនាគារ រាជរដ្ឋាភិបាលក៏បានផ្តល់នូវការលើកទឹកចិត្ត និងមធ្យោបាយមួយចំនួនទៀត តាមរយៈការអនុវត្តនូវគោលនយោបាយផ្តោតការយកចិត្តទុកដាក់ដល់ធនធានមនុស្ស និងការផ្ទេរថវិកាឱ្យដល់អង្គភាពដែលអនុវត្តការងារផ្ទាល់ បន្ថែមពីលើអត្ថប្រយោជន៍ខាងហិរញ្ញវត្ថុមួយចំនួនទៀត ដូចជា៖ ការដំឡើងរបបប្រាក់បេសកកម្ម និងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជាដើម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបង្កើនប្រាក់សោធននិវត្តន៍ និងរបបតាវកាលិកផ្សេងទៀត ជូននិវត្តជនជាបន្តបន្ទាប់ផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវកម្មវិធីអន្តរាគមន៍ផ្ទាល់របស់រដ្ឋក្នុងគោលដៅសង្គម-សេដ្ឋកិច្ចជាបន្តបន្ទាប់ ដូចជាកិច្ចអន្តរាគមន៍របស់រដ្ឋនៅក្នុងការប្រមូលទិញស្រូវពីកសិករ ដើម្បីទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះហួសពីថ្លៃទីផ្សារខ្លាំងពេក ដោយមិនសមហេតុផលជាដើម។

សមិទ្ធផលខាងលើដែលសម្រេចបានមកនេះ គឺមិនអាចកាត់ផ្តាច់ពីការខិតខំប្រឹងប្រែងជាប់ជាប្រចាំ និងលទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះទេ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលទី២ **គណនេយ្យភាពហិរញ្ញវត្ថុ** និងបានចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ គឺ**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ដែលនៅក្នុងដំណាក់កាលនេះការដាក់អនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញ និងការដាក់ឱ្យអនុវត្តអង្គភាពថវិកា គឺជាស្នូលនៃការកែទម្រង់ប្រព័ន្ធថវិកា ដោយចាប់ផ្តើមជាដំហានៗ ពីឆ្នាំ២០១៥ ស្របតាម **ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៣-២០២០** ក្នុងគោលដៅបោះជំហានឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកាពី**ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ**។ ជាមួយនឹងទិសដៅនៃការពង្រឹង និងពង្រីកប្រព័ន្ធ **ថវិកាកម្មវិធី** ដែលគ្រប់ក្រសួងស្ថាប័ន នឹងអនុវត្តថវិកាកម្មវិធីនៅឆ្នាំ២០១៨ និងជាពិសេសផ្អែកលើបទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធីកន្លងមកនេះ រាជរដ្ឋាភិបាលកំពុងរៀបចំនូវ **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៧-២០២៥** ដើម្បីឈានទៅដាក់អនុវត្ត**ប្រព័ន្ធថវិកាផ្អែកលើពត៌មានសមិទ្ធកម្ម** ឬហៅកាត់ថា **ថវិកាសមិទ្ធកម្ម** នៅឆ្នាំ២០២៥ នៅកម្ពុជា ស្របតាមឧត្តមានុវត្តតំបន់ និងអន្តរជាតិ។

ជារួម មកដល់ពេលនេះ រាជរដ្ឋាភិបាលសម្រេចបាននូវឱ្សនភាពគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន៖

(១)-ការពង្រឹងភាពទុកចិត្តនៃថវិកាសម្រេចបាន តាមរយៈការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ជាពិសេសការផ្តោតលើការពង្រឹងរដ្ឋបាលចំណូល និងការព្យាករណ៍ចំណូល យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធអនុវត្តថវិកា ព្រមទាំងការពង្រីកវិសាលភាពនៃប្រព័ន្ធគណនីទោលរតនាគារ និងការគ្រប់គ្រងសាច់ប្រាក់តាមគេហទំព័រ

(២)-ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ បានផ្តោតជាសំខាន់លើការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំហានទី១ និងឈានទៅអនុវត្តដំហានទី២ ដែលនឹងគ្របដណ្តប់ដល់ក្រសួងអាទិភាពសំខាន់ៗ ស្របនឹងការរៀបចំ និងការដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកា និង

មាតិកាគណនេយ្យថ្មី ដែលរួមចំណែកដល់ការលើកកម្ពស់ប្រព័ន្ធរបាយការណ៍ និងតម្លាភាពនៃការអនុវត្ត ថវិកា និង

(៣)-ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការដាក់អនុវត្តថវិកាកម្មវិធី និងការត្រៀមលក្ខណៈទៅមុខមួយជំហានទៀតឆ្ពោះទៅដាក់អនុវត្តថវិកាសមិទ្ធកម្ម ដែលប្រការនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចធ្វើការវិភាជធនធានកាន់តែមានប្រសិទ្ធភាពខ្ពស់ តម្រង់ឆ្ពោះទៅអាទិភាពគោលនយោបាយសំខាន់ៗ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

ជាលទ្ធផល តាមរយៈការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ការអនុវត្តថវិកាមានភាពប្រសើរឡើង ដោយគម្លាតនៃការអនុវត្តចំណូលនិងចំណាយនៃថវិកាជាតិធៀបនឹងច្បាប់ថវិកាដែលបានអនុម័តកាន់តែតូចទៅៗ លំហូរចំណូលនិងចំណាយកាន់តែមានភាពលូន ដោយជំរុញការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានទាំងស្រុងនូវបំណុលកកស្ទះដ៏រ៉ាំរ៉ៃ។ លើសពីនេះទៀត ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរួមចំណែកដល់ការពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពហិរញ្ញវត្ថុ សំដៅបង្កើនភាពច្បាស់លាស់ សុក្រឹតភាព ភាពទាន់ពេលនៃប្រព័ន្ធកត់ត្រា និងរបាយការណ៍ ជាមួយគ្នានឹងចំណាត់ថ្នាក់ថវិកាទាំង៧ ដែលត្រូវបានរៀបចំរួចរាល់ សម្រាប់ដាក់ចូលក្នុងប្រព័ន្ធ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាបន្តបន្ទាប់ តាមរយៈការរៀបចំនូវលិខិតបទដ្ឋានគតិយុត្ត ដោយបានបញ្ចប់អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌ សារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបន្តបញ្ចប់ការរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។ ក្នុងក្របខ័ណ្ឌនៃការវាយតម្លៃវិញ ស្ថាប័នអន្តរជាតិជាច្រើនបានវាយតម្លៃខ្ពស់ ចំពោះវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ផ្សេងៗ។ ទន្ទឹមនេះ កម្ពុជាក៏មានភាពជាម្ចាស់ក្នុងការរៀបចំវាយតម្លៃដោយខ្លួនឯង តាម**ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ** (PEFA) ដើម្បីវាស់វែងអំពីសុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលឈរលើមូលដ្ឋានគ្រឹះ៣ យ៉ាង គឺការគោរពវិន័យថវិកា ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ។

ឈរលើមូលដ្ឋានខាងលើនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានគិតគូរ និងរៀបចំ ដើម្បីធានាចលនការនៃការកែទម្រង់របស់ខ្លួន ដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំ តាំងពីដើមនីតិកាលមក ហើយក៏កំពុងបន្តតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗ ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគិតគូរផ្លាស់ប្តូរទៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ និងជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិ ដែលអាចកើតមានឡើងដាយថាហេតុ ក៏ដូចជាផ្តល់ការឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក ជាពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវ**គោលដៅជាយុទ្ធសាស្ត្រចាំង៤** ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ដើម្បី**កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ដែលជា **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃ រដ្ឋសភា** គឺ៖

*ទី១.* ជានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព និងបរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ

*ទី២.* បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការវិនិយោគ

*ទី៣.* សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ក៏ដូចគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងទៅលើការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ

*ទី៤.* បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

ទន្ទឹមនឹងនេះដែរ ថវិកាឆ្នាំ២០១៨ ក៏បន្តផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព៤ ដែលមានដូចខាងក្រោម៖

*ទី១.* ការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើយុវជន

*ទី២.* ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា

*ទី៣.* ការបន្តអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនផលិតភាពទំនើបកម្មកសិកម្ម ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម

*ទី៤.* ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ភាពប្រកួតប្រជែងរបស់កម្ពុជា និងការកែលម្អបរិយាកាសវិនិយោគ។

### ១.៤- <u>អភិក្រម និងគោលការណ៍សំខាន់ៗនៃការរៀបចំច្បាប់ថវិកាឆ្នាំ២០១៨</u>

ឆ្នាំ២០១៨ គឺជាឆ្នាំបញ្ចប់អាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា និងជាឆ្នាំបោះឆ្នោតសកល។ ក្នុងន័យនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយផ្អែកលើអភិក្រមសំខាន់ពីរគឺ៖

(ទី១)-ជានានិរន្តភាព និងភាពរលូននៃកិច្ចដំណើរការគ្រប់គ្រងរដ្ឋបាល និងការដឹកនាំរាជរដ្ឋាភិបាលពោលគឺ "មិនឱ្យដល់កំពង់ លង់ទូក"

(ទី២)-អនុវត្តបញ្ចប់ ឬសម្អាតការងារនៅសេសសល់ ដែលក្រសួង-ស្ថាប័នត្រូវបំពេញ ដើម្បីពង្រឹងមូលដ្ឋានគ្រឹះកាន់តែរឹងមាំសម្រាប់បន្តការគ្រប់គ្រងប្រទេស ការបំពេញបំណងប្រាថ្នារបស់ប្រជាជន និងការអភិវឌ្ឍលើគ្រប់វិស័យក្នុងរយៈពេលវែង។

ផ្អែកលើអភិក្រមទាំងពីរខាងលើនេះ គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ចំនួន៤ ក៏ត្រូវបានប្រកាន់យកផងដែរសម្រាប់ការរៀបចំថវិកាឆ្នាំ២០១៨ ដែលក្នុងនោះរួមមាន៖

- ជានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន, ផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកើនឡើងកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិ

• ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ

• បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដោយផ្តោតជាពិសេសលើសកម្មភាពកែទម្រង់ដែលផ្តល់លទ្ធផលភ្លាមៗ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនតាមការសន្យា ក៏ដូចជាការពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ

• ផ្តល់ការលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នណា ដែលអនុវត្តសកម្មភាពការងាររបស់ខ្លួនប្រកបដោយ-បុរេសកម្ម និងមានសមិទ្ធកម្ម ឬលទ្ធផលការងារល្អ។

ក្នុងន័យនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានផ្តោតជាពិសេសទៅលើ៖

-ការបន្តដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានជាង១លានរៀល ដើម្បីបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យកាន់តែល្អប្រសើរផង និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផង

-ការវិនិយោគលើធនធានមនុស្ស ពិសេសការជំរុញអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៧-២០២៥ របស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការផ្តល់ និងបង្កើនប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី ការបង្កើនប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាពសម្រាប់រៀបចំពិធីបុណ្យតាមប្រពៃណី ការផ្តល់ការថែទាំសុខភាពសម្រាប់កម្មករនិយោជិត និងការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់កម្មករនិយោជិត

-ការកែទម្រង់សំដៅលើកកម្ពស់ និងកែលម្អប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈក្នុងគ្រប់វិស័យ ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការរបស់ប្រជាជន និង

-ការផ្តល់អាទិភាពលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ អគ្គិសនី និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព ដើម្បីបន្តជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចទាំងក្នុងរយៈពេលខ្លី មធ្យម និងវែង ក៏ដូចជាដោះស្រាយតម្រូវការប្រចាំថ្ងៃរបស់ប្រជាជន។

លើសពីនេះ ផ្អែកលើអភិក្រម និងគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រខាងលើ ថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយបន្តប្រកាន់យកគោលការណ៍ជាបច្ចេកទេសសំខាន់ៗ ដូចខាងក្រោម៖

***១/-ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល៖*** ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ចំណូលថវិការដ្ឋសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ ដោយមានការកើនឡើងក្នុងសន្ទុះយ៉ាងលឿន ជាពិសេសក្នុងនីតិកាលនេះ។ ប៉ុន្តែចំណូលឆ្នាំ២០១៨ អាចនឹងប្រឈមនឹងការថមថយនៃល្បឿន ដោយសារម្យ៉ាងចំណូលបានឈានមកដល់កម្រិតមួយដែលចង់អស់ខ្យល់កំណើន ព្រោះកំណើនក្នុងរយៈពេលកន្លងមកនេះ គឺជាសំខាន់ទទួលផលពីវិធានការរដ្ឋបាល មិនមានការដាក់ចេញវិធានការគោលនយោបាយ ឬការដំឡើងអត្រាពន្ធនោះទេ លើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ឬបរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងវត្តមានខ្លះនៅឡើយនូវអំពើរត់គេចពន្ធ និង

ម្យ៉ាងទៀត ជាឆ្នាំបោះឆ្នោតសកល ដែលការអនុវត្តចំណូលអាចជួបហានិភ័យនៃការរត់ពន្ធ ការគេចវេះពន្ធ និងការដំអក់អនុវត្តកាតព្វកិច្ចពន្ធ ហើយលើសពីនេះ កំណើនសេដ្ឋកិច្ចក៏អាចមានហានិភ័យខ្លះ ដែលអាចនាំឱ្យប៉ះពាល់ដល់ចំណូលផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយឆ្នាំ២០១៨ អាចចាត់ទុកថាជាឆ្នាំអន្តរការណ៍មួយសម្រាប់ការងារនេះ ដូចនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែន-សារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់លទ្ធភាព ជាពិសេសពង្រឹងមន្ត្រីមានសមត្ថកិច្ចក៏ដូចជាអង្គភាពពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ខ្លួនមិនឱ្យធ្លាក់ដៃ ក្នុងការបំពេញការកិច្ចឡើយ។

*២/-ការកំណត់លំដាប់អាទិភាព៖* តាមរយៈការបន្តនូវភាពម៉ឺងម៉ាត់ និងការសម្រួចលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងទៅលើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ កំណើនថវិកាត្រូវបានផ្តល់អាទិភាពជាសំខាន់ទៅលើកម្មវិធី/អនុកម្មវិធី/សកម្មភាពណា ដែលអាចរំពឹងថានឹងហុចផលក្នុងរយៈពេលខ្លី និងមានប្រសិទ្ធភាពអនុវត្តខ្ពស់ ក្នុងការឆ្លើយតបទៅនឹងបរិការណ៍ឆ្នាំចុងក្រោយនៃអាណត្តិទី៥ របស់រាជរដ្ឋាភិបាល និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០១៨។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជួយសម្របសម្រួល និងស្នើឱ្យក្រសួង ស្ថាប័ន ធ្វើការកែតម្រូវអាទិភាពរបស់ខ្លួនផងដែរ។

*៣/-ការយកចិត្តទុកដាក់លើមនុស្ស៖* ទន្ទឹមនឹងបន្តបង្កើនប្រាក់បៀវត្សអប្បបរមា ជូនមន្ត្រីរាជការគ្រប់ប្រភេទឱ្យដល់កម្រិតជាង១លានរៀល នៅឆ្នាំ២០១៨ ព្រមទាំងរបបតារាកាលិកចាំបាច់ផ្សេងៗ ថវិកាឆ្នាំ២០១៨ ផ្តល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្តល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់ ក៏ដូចជាការពង្រឹងគុណភាពសេវាសាធារណៈដែលផ្តល់ប្រយោជន៍ និងផលប៉ះពាល់ផ្ទាល់ដល់ប្រជាជនទូទៅ។

*៤/-កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព៖* បន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ, និងគុណភាព ក្នុងការអនុវត្តកម្មវិធី/សកម្មភាព ក្នុងគោលដៅជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា ជាពិសេសជួយដល់ក្រសួង-ស្ថាប័នក្នុងការធ្វើវិចារណកម្មថវិកា ដើម្បីតម្រង់ការវិភាជឱ្យចំទិសដៅអាទិភាព ក្នុងពេលដែលលម្ហថវិកាចរន្តមិនមែនបន្ទុកបុគ្គលិកជួបប្រទះនឹងស្ថានភាពតឹងតែង។

*៥/-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត៖* បង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់ដែលនៅក្រោមឱវាទក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ទាំងលើការអនុវត្តចំណាយ ទាំងលើសមិទ្ធកម្មការងារ។

*៦/-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា៖* ផ្សារភ្ជាប់ការវិភាជថវិកា ទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័នដែលកៀរគរចំណូលបានដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់ ហើយបានបង់ចំណូលមួយភាគធំចូលថវិការដ្ឋ ហើយរឹតត្បិតលើការស្នើសុំបង្កើនថវិកា ចំពោះក្រសួង-ស្ថាប័នដែលការប្រមូលចំណូលមិនអាចសម្រេចបានលទ្ធផលសមស្របតាមសក្តានុពលជាក់ស្តែង ឬដែលមានទំហំចំណែកប្រាក់រង្វាន់ធំ។

*៧/-ការរក្សាតុល្យភាព និងចីរភាពថវិកា៖* ស្ថិតក្រោមសម្ពាធនៃតម្រូវការចំណាយដែលចេះតែកើនឡើងក្នុងសន្ទុះថេរ ជាពិសេសសម្ពាធនៃចំណាយបន្ទុកបុគ្គលិក ចំណាយចរន្តមិនមែនបន្ទុកបុគ្គលិកដែលកើតឡើងថ្មីៗ ព្រមទាំងចំណាយវិនិយោគដើម្បីជំរុញការអភិវឌ្ឍ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ហើយនៅក្នុងពេលដំណាលគ្នានេះ ការប្រមូលចំណូលមានការថមថយកំណើន ព្រមទាំងជួបបញ្ហាប្រឈមនិងហានិភ័យកាន់តែធំឡើង ការរៀបចំថវិកាឆ្នាំ២០១៨ ចាំបាច់ត្រូវប្រើប្រាស់ថវិកាសន្សំខ្លះ ដោយឈរលើគោលការណ៍នៃការធានាឱ្យបាននូវតុល្យភាពថវិកាផង ព្រមទាំងធានាចីរភាពភាពថវិកានិងចីរភាពម៉ាក្រូសេដ្ឋកិច្ចផង។ ការប្រើថវិកាសន្សំនាពេលនេះ គឺបានស្ថិតនៅក្នុងសេណារីយ៉ូដែលបានត្រៀមលក្ខណៈតាំងពីដើមនីតិកាលមកម្ល៉េះ។ ម្យ៉ាងទៀត ក្នុងការគ្រោងចំណាយនេះ ក៏មានសមាសធាតុត្រៀមបម្រុងមួយចំនួនដែលជាក់ស្តែងអាចនឹងមិនត្រូវបានអនុវត្ត និងមានការត្រៀមបម្រុងសម្រាប់សេចក្តីត្រូវការមិនបានគ្រោងទុក និងសម្រាប់ការធ្វើ-អន្តរាគមន៍ដាយថាហេតុរបស់រាជរដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំថវិកាក្នុងលក្ខណៈប្រើថវិកាសន្សំដើម្បីបំពេញតុល្យភាពនេះ គឺត្រូវបានរំពឹងថាអនុវត្តតែសម្រាប់ឆ្នាំ២០១៨ ដែលជាឆ្នាំពិសេសប៉ុណ្ណោះ។ ក្នុងន័យនេះ ការរៀបចំថវិកាឆ្នាំបន្តបន្ទាប់ ត្រូវឈរលើមូលដ្ឋាននៃការកែទម្រង់ដ៏មុតស្រួចថែមទៀត ទាំងផ្នែកចំណូល និងទាំងផ្នែកចំណាយ។

## ២. ក្របខ័ណ្ឌនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨

### ២.១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨

តាមការព្យាករ, កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ៦,៩% ដូចឆ្នាំ២០១៧ ដែលធ្វើឱ្យ ផ.ស.ស. ថ្លៃបច្ចុប្បន្នកើនឡើងដល់៩៩ ១១៦ ០៤១លានរៀល សមមូលនឹងប្រមាណ ២៤ ៥៥២លានដុល្លារអាមេរិក ខណៈដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៥៦៨ដុល្លារអាមេរិក ធៀបនឹងត្រឹមតែ១ ០៤២ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣។ កំណើននេះ ត្រូវបានទ្រទ្រង់ដោយ៖ (ទី១)-កំណើននៃវិស័យឧស្សាហកម្មប្រមាណ៨,៦% ដែលគាំទ្រដោយអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ជាពិសេសលើផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិច ម្ហូបអាហារ និងកេសជ្ជៈ ដែលជួយបំពេញបន្ថែមឱ្យការថមថយនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់។ ថ្វីត្បិតតែអនុវិស័យសំណង់មានកំណើនថមថយបន្តិចប៉ុន្តែកំណើននេះនៅតែខ្ពស់ដោយសារសំណង់ប្រភេទពាណិជ្ជកម្ម និងការងាកទៅរកសំណង់លំនៅឋានតម្លៃសមរម្យ ចំណែកឯការបន្តថមថយនៃអនុវិស័យកាត់ដេរ គឺបណ្តាលមកពីការកើនឡើងប្រាក់ឈ្នួលអប្បបរមាដែលធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា និងភាពស្ងាត់ស្ងៀរនៃការបញ្ជាទិញក្នុងអំឡុងឆ្នាំបោះឆ្នោតសកល (ទី២)-វិស័យសេវាកម្មបន្តកំណើនប្រមាណ៧,៦%ដែលគាំទ្រដោយកំណើនខ្ពស់នៃអនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ព្រមទាំងអនុវិស័យសេវាកម្មផ្សេងៗ តាមរយៈការកើនឡើងការប្រើប្រាស់ក្នុងស្រុក ដោយសារការកើនឡើងប្រាក់ឈ្នួលអប្បបរមា និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ ស្របនឹងការបន្តគោលនយោបាយវិស្តារកម្មរបស់រាជរដ្ឋាភិបាលដែលជួយជំរុញដល់សកម្មភាពសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ អនុវិស័យអចលនទ្រព្យនៅតែបន្តកំណើនរឹងមាំ ស្របតាមនិន្នាការនៃអនុវិស័យសំណង់ ខណៈដែលអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបានរំពឹងថា មានកំណើនថមថយបន្តិច និង (ទី៣)-វិស័យកសិកម្មអាចសម្រេចបានកំណើនក្នុងរង្វង់២,០%ទ្រទ្រង់ដោយអនុវិស័យដំណាំ និងជលផល ដោយសារភាពប្រសើរឡើងនៃប្រព័ន្ធស្រោចស្រព និងការរំពឹងទុកលក្ខខណ្ឌអំណោយផលនៃកត្តាអាកាសធាតុ។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថា នឹងមានការកើនឡើងបន្តិច ក្នុងអត្រា៣,៨%ក្នុងឆ្នាំ២០១៧ និង៣,៥% ក្នុងឆ្នាំ២០១៨ ដោយសារការងើបឡើងវិញជាបណ្តើរៗនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងថ្លៃកសិផលមួយចំនួន។ ចំណែកឯអត្រាប្តូរប្រាក់រៀល គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់៤ ០៣៧រៀល ក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង២០១៨ ដែលជាអត្រាមួយអាចរក្សាស្ថិរភាពអតិផរណា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។ ឱនភាពគណនីចរន្តនៃដញ្ជីងទូទាត់ក្រៅប្រទេសត្រូវបានរំពឹងថា នឹងកើនឡើងជាងមុនបន្តិចពី៧,៩% នៃផ.ស.ស. នៅឆ្នាំ២០១៧ មក៨,៤% នៃ ផ.ស.ស. នៅឆ្នាំ២០១៨ ដោយសារការរំពឹងទុកនៃការថយចុះនៃឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណង ក្រោមហេតុផលថាកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ខណៈដែលឱនភាពពាណិជ្ជកម្មបានធ្លាក់ចុះពី ១៥,៤%នៃ ផ.ស.ស. នៅក្នុងឆ្នាំ២០១៧ មកត្រឹម១៥%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៨ ដែលឆ្លុះបញ្ចាំងនូវពិពិធកម្មផលិតផលនាំចេញ។ ដោយឡែកទុនបម្រុងអន្តរជាតិត្រូវបានប៉ាន់ស្មានថានឹងបន្តកើនឡើងពី៦ ៧៣១ លានដុល្លារអាមេរិកនៅឆ្នាំ២០១៦ ដល់៧ ៥៣៨លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៧ និងបន្តឡើងដល់ ៧ ៨៥៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដោយសារការវិនិយោគផ្ទាល់ពីបរទេសនឹងនៅបន្តមានកំណើនល្អ ដែលនឹងធានាបាននូវការនាំចូលប្រមាណ៥,៤ខែក្នុងឆ្នាំ២០១៨ ដែលជាកម្រិតមួយល្អសម្រាប់ការរក្សាបាននូវស្ថិរភាពដញ្ជីងទូទាត់។

ក្នុងន័យនេះ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨ ត្រូវបានកំណត់តាមសូចនាករសំខាន់ៗដូចខាងក្រោម៖

| សូចនាករសេដ្ឋកិច្ច | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|
| | ប៉ាន់ស្មាន | ព្យាករ | ព្យាករ |
| ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន (លានរៀល) | ៨០ ៥៥៨ ៥៣២ | ៨៩ ៥០៩ ៤២២ | ៩៩ ១១៦ ០៤១ |
| កណើននៃ ផ.ស.ស.តាមថ្លៃថេរ (%) | ៧,០ | ៦,៩ | ៦,៩ |
| ផ.ស.ស.សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៣០២ | ១ ៤៣៥ | ១ ៥៦៨ |
| អតិផរណា (អត្រាមធ្យមប្រចាំឆ្នាំ) | ៣,០ | ៣,៨ | ៣,៥ |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៦ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស.) | -៨,៣ | -៧,៩ | -៨,៤ |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៦ ៧៣១ | ៧ ៥៣៩ | ៧ ៨៥៣ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥,៥ | ៥,៧ | ៥,៤ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ២០១៧*

ជារួម ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថាកម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ ខណៈដែលបញ្ហាប្រឈម និងហានិភ័យកាន់តែកើនឡើងទាំងខាងក្នុង ទាំងខាងក្រៅ ដែលអាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើននេះ និងបង្កភាពអាក់អួលដល់កិច្ចអភិវឌ្ឍន៍ ដូចជា៖

**ទី១**-ផ្នែកក្រៅប្រទេស សេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងកំណើនយឺតនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហគមន៍អឺរ៉ុប និងភាពស្រពិចស្រពិលនៃសេដ្ឋកិច្ចអឺរ៉ុប ការថមថយកំណើនសេដ្ឋកិច្ចរបស់ចិន ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ និងភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក ព្រមទាំងស្ថានការណ៍វិវត្តន៍ទៅរកភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចនៅក្នុងពិភពលោក ជាពិសេសការឡើងកម្តៅនៃវិាទនៅតាមតំបន់មួយចំនួន ដែលបញ្ហាទាំងនេះជាហានិភ័យសេដ្ឋកិច្ចសម្រាប់កម្ពុជាដែលមានសេដ្ឋកិច្ចបើកចំហខ្លាំង ជាពិសេសសម្រាប់វិស័យពាណិជ្ជកម្មអន្តរជាតិ និងលំហូរទុនវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងវិស័យទេសចរណ៍។

**ទី២**-ផ្នែកក្នុងស្រុក កម្ពុជាកំពុងប្រឈមនឹងបញ្ហាចម្បងៗមួយចំនួន នៅក្នុងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចដូចជា៖ បញ្ហាថ្លៃអគ្គិសនីនៅខ្ពស់ ប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីកនៅទន់ខ្សោយ និងនិន្នាការនៃកំណើនប្រាក់ឈ្នួលអប្បបរមាលឿនជាងកំណើននៃផលិតភាពការងារ ព្រមទាំងការយកកម្រៃក្រៅផ្លូវការ ដែលនៅមានខ្លះ គួបផ្សំនឹងបែបបទនីតិវិធីមួយចំនួនដែលនៅតែស្មុគស្មាញនៅឡើយ។ បញ្ហាប្រឈមទាំងនេះ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងរបស់កម្ពុជាប៉ុណ្ណោះទេ តែប៉ះពាល់ផងដែរដល់ប្រសិទ្ធភាពនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល ហើយជាឧបសគ្គរារាំងដល់ការបង្កើនសក្តានុពលវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា ជាពិសេសការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅនៃការវិនិយោគលើឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់។

**ទី៣**-និន្នាការកើនឡើងនៃថ្លៃប្រេង ក៏អាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា ដែលជាប្រទេសប្រើប្រាស់ប្រេងនាំចូល១០០%។ ទន្ទឹមនឹងនេះ សម្ពាធនៃការបន្តឡើងថ្លៃម្ហូបអាហារ ក៏នឹងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋផងដែរ ជាពិសេសអ្នកដែលមានចំណូលទាប។ ការកើនឡើងនៃថ្លៃនៃទំនិញទាំងពីរប្រភេទនេះនឹងអាចធ្វើឱ្យអត្រាអតិផរណាមានការកើនឡើង។

**ទី៤**-ជាងនេះទៅទៀត កម្ពុជាកំពុងទទួលសម្ពាធនៃតម្រូវការចំណាយថវិការដ្ឋកាន់តែកើនឡើងឥតឈប់ឈរ ជាពិសេសចំណាយបន្ទុកបុគ្គលិក ក្នុងខណៈដែលកំណើនចំណូលថវិកាបានឈានទៅកៀកនឹងពិដាននៃសក្តានុពលទៅហើយ។ ដូចនេះ កំណើនចំណូលនៅឆ្នាំ២០១៨ និងបណ្តាឆ្នាំខាងមុខ អាចប្រឈមនឹងការថមថយ ទន្ទឹមនឹងឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណងក៏កាន់តែរឹងស្ងួតទៅៗតាមដំណាក់កាលនៃការវិវឌ្ឍរីកចម្រើនខាងសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ។

ក្នុងន័យនេះ កម្ពុជាត្រូវដាក់ចេញនូវវិធានការគោលនយោបាយមុតស្រួចមួយចំនួនឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅជម្នះ និងដោះស្រាយនូវរាល់បញ្ហាប្រឈម និងហានិភ័យខាងលើ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំ និងប្រកបដោយចីរភាពក្នុងរង្វង់៧% ដូចខាងក្រោម៖

**(ក)-ការបន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** តាមរយៈ៖ (១)-ការពង្រឹងបន្ថែមទៀតនូវយន្តការគ្រប់គ្រងរបិត្ត និងហានិភ័យ ទាំងយន្តការបញ្ជៀសរបិត្ត និងទាំងយន្តការដោះស្រាយរបិត្ត ព្រមទាំងត្រូវធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលាក្នុងការរក្សាស្ថិរភាពថ្លៃនៅលើទីផ្សារ (២)-ការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែខ្លាំងក្លា តាមរយៈការជំរុញការអនុវត្ត**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** ដោយបន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀត ជាពិសេសការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ

និងទីផ្សាររូបិយប័ណ្ណ ព្រមទាំងការបន្តពង្រឹងវិស័យមិនមែនធនាគារ រួមមានៈ វិស័យធានារ៉ាប់រង និងទីផ្សារមូលប័ត្រ (៣)-ការបន្តរក្សាស្ថិរភាពនៃកំណើនឥណទានស្របទៅតាមស្ថានភាពនៃសេដ្ឋកិច្ច តែត្រូវជំរុញបន្ថែមទៀតនូវការផ្តល់ឥណទាន ទាំងបរិមាណ និងគុណភាពទៅលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម រួមទាំងសហគ្រាសធុនតូចនិងមធ្យម ជាពិសេស វិស័យស្រូវ-អង្ករ (៤)-ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការប្រើប្រាស់កម្ចីនេះឱ្យមានប្រសិទ្ធភាព និងផលិតភាពខ្ពស់ ទន្ទឹមនឹងការបន្តគ្រប់គ្រងការអនុវត្តគោលនយោបាយកំណត់ពិដានអត្រាការប្រាក់ឱ្យបានរលូន និងមានប្រសិទ្ធភាព និង(៥)-ការបន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យឱ្យកាន់តែល្អ រួមទាំងការឃ្លាំមើលនៃការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**(ខ)-ការបន្តជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព** តាមរយៈ៖ (១)-ការខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ដើម្បីបំពេញបន្ថែមការវិនិយោគក្នុងស្រុក ដែលអាចនឹងថមថយដោយកត្តាចិត្តសាស្ត្រឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោត តាមរយៈការបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ហើយជំរុញការអនុម័ត និងការអនុវត្តច្បាប់នេះ រួមទាំងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍ និងតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗក្នុងប្រទេស ទៅនឹងប្រទេសជិតខាង ក៏ដូចជាដើម្បីបន្តជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ច ទាំងនៅក្នុងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ អាស៊ាន និងពិភពលោក (២)-ការជំរុញអនុវត្ត**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ឱ្យមានសន្ទុះកាន់តែខ្លាំងក្លា ទន្ទឹមនឹងការខិតខំអនុវត្តបញ្ចប់នូវកិច្ចការមួយចំនួនដែលនៅមិនទាន់ចេញជាផ្លែផ្កា សំដៅជំរុញល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មកម្ពុជាឱ្យបានកាន់តែឆាប់រហ័ស ក្នុងគោលដៅបង្កើនភាពប្រកួតប្រជែង ការបង្កើនតម្លៃបន្ថែមឱ្យកាន់តែខ្ពស់ក្នុងខ្សែចង្វាក់ផលិតកម្មនៃឧស្សាហកម្មកាត់ដេរ ការកែច្នៃម្ហូបអាហារ ការដំឡើងគ្រឿងម៉ាស៊ីន និងគ្រឿងអេឡិចត្រូនិច និងគ្រឿងបន្លាស់ ព្រមទាំងឧស្សាហកម្មថ្មីៗផ្សេងទៀត ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និង (៣)-ការបង្កើនចំណាយលើវិស័យអាទិភាពសំខាន់ៗដូចជាៈ ការអប់រំ ការអភិវឌ្ឍជំនាញ សុខាភិបាល កសិកម្ម ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ រួមទាំងការបង្កើនប្រសិទ្ធភាពចំណាយនៅក្នុងវិស័យទាំងនោះ ហើយត្រូវផ្អែកលើផែនការមេមួយច្បាស់លាស់ ជាពិសេសចំពោះវិស័យទូរគមនាគមន៍ ដឹកជញ្ជូន និងវិស័យថាមពល ដើម្បីជំរុញកំណើន លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពនៃសេដ្ឋកិច្ចព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ក៏ដូចជាសម្រាប់ឈានទៅអនុវត្តនូវសេដ្ឋកិច្ចឌីជីថល នៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។

**(គ)-ការពន្លឿនកិច្ចការកែទម្រង់រចនាសម្ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស** តាមរយៈ៖ (១)-ការគិតគូរឡើងវិញនូវគោលនយោបាយរយៈពេលវែង និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីចំពោះវិស័យសំខាន់ៗមួយចំនួននៅក្នុងសេដ្ឋកិច្ច និងធ្វើពិពិធកម្មវិស័យទាំងនោះឱ្យកាន់តែខ្លាំងក្លា ជាពិសេសវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដើម្បីជំរុញសន្ទុះនៃកំណើនផង និងរក្សាចីរភាពនៃកំណើនផង (២)-ការចាត់វិធានការមុតស្រួចមួយចំនួន សំដៅកាត់បន្ថយថ្លៃម្ហូបអាហារផង និងរក្សាស្ថិរភាពថ្លៃម្ហូបអាហារនៅលើទីផ្សារផង (៣)-ការបន្ថោះស្រាយបញ្ហាថ្លៃធ្វើធុរកិច្ចនៅខ្ពស់នៅកម្ពុជា ដោយធ្វើការពិនិត្យទៅលើបញ្ហាបទប្បញ្ញត្តិ និងនីតិវិធីនៃ

ការអនុវត្ត រួមទាំងគុណភាព និងចំណាយលើសេវាសាធារណៈ ដើម្បីកែលម្អបរិស្ថានវិនិយោគនិងធុរកិច្ច ឱ្យកាន់តែប្រសើរឡើង ដើម្បីការទាក់ទាញបន្ថែមទៀតនូវការវិនិយោគថ្មីៗពីបរទេស ក៏ដូចជាដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគក្នុងស្រុក និង (៤)-ការបន្តកែទម្រង់វិស័យសាធារណៈ និងពន្លឿនការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍជំនាញកម្រិតទាប មធ្យម និងខ្ពស់ សំដៅគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មឱ្យកាន់តែខ្លាំងក្លាជាងមុន និងការជំរុញការបែងចែកផ្លែផ្កាពីកំណើនសេដ្ឋកិច្ចប្រកបដោយ-សមធម៌ និងបរិយាប័ន្ន តាមរយៈការអនុវត្ត**គោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥** ដើម្បីឈានទៅកសាងប្រព័ន្ធគាំពារសង្គមមួយដែលមានប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ សម្រាប់បម្រើឱ្យគោលនយោបាយកាត់បន្ថយ និងទប់ស្កាត់ ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សឱ្យកាន់តែរឹងមាំ និងទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## ២.២- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិការឆ្នាំ២០១៨

ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ២០១៨ មានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តពង្រឹងយ៉ាងម៉ឺងម៉ាត់ និងដាច់ខាតនូវសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, នីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យ, វប្បធម៌សន្តិភាព, សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងភាពសុខដុមរមនាក្នុងសង្គម ក៏ដូចជា ភាពសុខក្សេមក្សាន្តរបស់ប្រជាជន,

- បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់,

- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ន និងចីរភាព ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិផងដែរ,

- បន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងឱ្យបាននូវអតិផរណា និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ,

- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីសម្រេចឱ្យបាននូវគោលដៅដាង១លានរៀលនៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨) ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ,

- គាំទ្រដល់ការអនុវត្ត**កម្មវិធីថ្មីមួយចំនួនលើវិស័យសង្គមកិច្ច** ក្នុង**ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥** ឱ្យចេញជាលទ្ធផលផ្លែផ្កាបណ្តើរៗ ជាពិសេសពាក់ព័ន្ធការថែទាំសុខភាព មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ការផ្តល់និងបង្កើនប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាស្ត្រីនៅពេលសម្រាលកូន និងសម្រាកលំហែមាតុភាព ការបង្កើនប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ការផ្តល់ការថែទាំសុខភាពសម្រាប់កម្មករនិយោជិត និង

ការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់កម្មករនិយោជិត ស្របពេលជាមួយគ្នានឹងការអនុវត្តគោលនយោបាយជាតិមនុស្សចាស់ ឆ្នាំ២០១៧-២០៣០

- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល តាមរយៈការជំរុញអនុវត្តវិធានការនៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ជាពិសេសគឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ ដូចសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទន្ទឹមនឹងបន្តការកែសម្រួលនីតិវិធី និងសេវាពាក់ព័ន្ធនឹងការបង់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ និងកាន់តែងាយស្រួល មានយុត្តិធម៌ និងកាន់តែមានអភិបាលកិច្ចខ្ពស់

- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ និងបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស

- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ, ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល និងអាហារូបត្ថម្ភ

- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់ សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេសផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធជារាសាស្ត្រ អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យជាដើម ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ជាពិសេសទូរគមនាគមន៍ សម្រាប់កសាងមូលដ្ឋានគ្រឹះក្នុងការឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា

- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធជារាសាស្ត្រស្រោចស្រព

- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងសកម្មភាពអភិវឌ្ឍវិស័យកសិកម្មដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាទឹកជំនន់, គ្រោះរាំងស្ងួត, ខ្យល់ព្យុះ និងការផ្ទុះជម្ងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច

- បន្តជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

- បន្តអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ ដើម្បីរក្សាចីរភាព នៃបំណុលសាធារណៈផង ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់គាំទ្រដល់កំណើនផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដែលមានទំហំកាន់តែធំ ស្របទៅតាមដំណាក់កាលនៃភាពរីកចម្រើនលូតលាស់របស់សេដ្ឋកិច្ចជាតិ

- គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១៨-២០២០

- គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០

- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងទទួលបានលទ្ធផលផ្លែផ្កាជាក់ស្តែងកាន់តែច្រើនថែមទៀត រួមទាំងការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ជាពិសេសការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជាដើម្បីផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ

- ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។

ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម៖

| **សូចនាករថវិកា** | **២០១៦** | | **២០១៧** | **២០១៨** |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលក្នុងប្រទេសថវិការដ្ឋ (% ផ.ស.ស.) | *១៧,៨២* | *១៨,៨៩* | *១៨,៥៧* | ***១៨,៧៥*** |
| *- ចំណូលចរន្តថវិការដ្ឋ (% ផ.ស.ស.)* | *១៧,៦៦* | *១៨,៧៤* | *១៨,៤០* | ***១៨,៥៧*** |
| ចំណាយសរុបថវិការដ្ឋ (% ផ.ស.ស.) | *២២,៧០* | *២២,០៣* | *២៣,៦៣* | ***២៤,៥៩*** |
| *- ចំណាយចរន្តថវិការដ្ឋ (% ផ.ស.ស.)* | *១៤,៦៨* | *១៤,២៨* | *១៥,៤២* | ***១៦,០៩*** |
| **អតិរេកចរន្ត (% ផ.ស.ស.)** | *២,៩៨* | *៤,៤៦* | *២,៩៨* | ***២,៤៨*** |
| **ឱនភាពសរុប (% ផ.ស.ស.)** | *-៤,៨៧* | *-៣,១៣* | *-៥,០៧* | ***-៥,៨៤*** |

តាមក្របខ័ណ្ឌនេះ ចំណូលក្នុងប្រទេសថវិការដ្ឋ ត្រូវបានគ្រោងចំនួន១៨ ៥៨៧ ០០៣លានរៀល ត្រូវដា១៨,៧៥% នៃ ផ.ស.ស. និងមានកំណើន១១,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ **ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៨ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង១៨,៥៧% នៃ ផ.ស.ស. ដែលមានកំណើនចំនួន០,១៧ ពិន្ទុភាគរយ នៃ ផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៧។** ទន្ទឹមនឹងកំណើនចំណូលមិនកើនទៅដល់គោលដៅដែលកំណត់ឱ្យស្មើនឹង០,៥០ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ, ក៏ទំហំចំណូលឆ្នាំ២០១៨ កើនលើសគោលដៅចំណូល ដែលត្រូវបានកំណត់ត្រឹមតែ១៧,៣៥%នៃ ផ.ស.ស. សម្រាប់ឆ្នាំ២០១៨ នៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨**។ ជាមួយគ្នានេះ គួរកត់សម្គាល់ថា កម្រិតចំណូលឆ្នាំ២០១៨ បានផ្តល់លទ្ធភាពរាជរដ្ឋាភិបាលសម្រេចលុបកម្រៃគ្រប់គ្រងការនាំចេញ (Export Management Fee) ដែលតាមការប៉ាន់ស្មានមានចំនួន៨២ ៥៤២លានរៀល ឬសមមូលសនឹងប្រមាណ២០ លានដុល្លារអាមេរិក។ ការលុបកម្រៃនេះនឹងជួយ (១)-បង្កើនការទាក់ទាញនូវការវិនិយោគថ្មីៗបន្ថែមទៀតនៅកម្ពុជា ដើម្បីរួមចំណែកបន្តលើកស្ទួយកំណើនសេដ្ឋកិច្ច និងបង្កើនការងារកាន់តែច្រើនជូនពលករកម្ពុជា និង (២)-ផ្តល់លទ្ធភាពដល់ក្រុមហ៊ុនវិនិយោគ ដែលកំពុងប្រតិបត្តិការរោងចក្រ/សហគ្រាសនៅកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងនៅឆ្នាំ២០១៨ ដល់ចំនួន១៧០ដុល្លារអាមេរិក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ២.៣.- គម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ២.៣.១- គម្រោងចំណូលថវិកាថ្នាក់ជាតិ

| សូចនាករ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលថវិកាថ្នាក់ជាតិសរុប(% ផ.ស.ស.) | *២១,៨៦* | *២២,៩៨* | *២២,៥៥* | ***២២,៦៤*** |
| ចំណូលក្នុងប្រទេសថ្នាក់ជាតិ(% ផ.ស.ស.) | *១៦,៨១* | *១៧,៨៧* | *១៧,៤៨* | ***១៧,៨០*** |
| ចំណូលចរន្តថវិកាថ្នាក់ជាតិ(% ផ.ស.ស.) | *១៦,៦៤* | *១៧,៧២* | *១៧,៣២* | ***១៧,៦២*** |
| ចំណូលមូលធន(% ផ.ស.ស.) | *៥,២២* | *៥,២៦* | *៥,២៣* | ***៥,០២*** |
| ចំណូលមូលធនក្នុងប្រទេស(% ផ.ស.ស.) | *០,១៦* | *០,១៥* | *០,១៧* | ***០,១៨*** |
| ចំណូលមូលធនក្រៅប្រទេស(% ផ.ស.ស.) | *៥,០៦* | *៥,១១* | *៥,០៧* | ***៤,៨៤*** |

ថវិកាឆ្នាំ២០១៨មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង១៧,៨០%នៃ ផ.ស.ស. គឺស្មើនឹង១៧ ៦៤០ ១៩៩លានរៀល ដែលមានកំណើន១២,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ តាមគោលដៅនេះ៖

ក- **<u>ចំណូលចរន្តថ្នាក់ជាតិ</u>** ត្រូវសម្រេចឱ្យបានចំនួន១៧ ៤៦០ ០០៦លានរៀល ត្រូវជា១៧,៦២%នៃ ផ.ស.ស. គឺមានកំណើន១២,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ដែលក្នុងនោះ៖

- **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន១៥ ០៧៥ ៥៦២លានរៀល ត្រូវជា១៥,២១% នៃ ផ.ស.ស. គឺមានកំណើន១៤,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនេះ៖
  - ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន៨ ៣៣០ ០០៤លានរៀល ត្រូវជា៨,៤០%នៃ ផ.ស.ស. គឺមានកំណើន១៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧
  - ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន៦ ៧៤៥ ៥៥៨លានរៀល ត្រូវជា៦,៨១%នៃ ផ.ស.ស. គឺមានកំណើន១៤,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧
- **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន២ ៣៨៤ ៤៤៤លានរៀល ត្រូវជា២,៤១% នៃ ផ.ស.ស. គឺមានកំណើន៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖
  - ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន២ ១១៦ ១១១លានរៀល មានកំណើន៦,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧
  - ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត អាជ្ញាប័ណ្ណ ត្រូវបានគ្រោងចំនួន២២៤ ៨៧៥ លានរៀល មានកំណើន២៥,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ដោយឡែកកម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ ត្រូវបានគ្រោងចំនួន៤៣ ៤៥៨លានរៀល មានការថយចុះ៦៥,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដោយសារការលុបចោលចំណូលពីកម្រៃគ្រប់គ្រងការនាំចេញ ក្នុងគោលដៅដូចបានគូសបញ្ជាក់ខាងលើ។

ខ- **<u>ចំណូលមូលធន</u>** ត្រូវបានគ្រោងចំនួន៤ ៩៧៧ ១៣២លានរៀល ត្រូវជា៥,០២%នៃ ផ.ស.ស. គឺមានកំណើន៦,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

- **ចំណូលមូលធនក្នុងប្រទេស** ដែលជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវសម្រេចឱ្យបានចំនួន១៨០ ១៩៣លានរៀល ត្រូវជា០,១៨%នៃ ផ.ស.ស. គឺមានកំណើន២១,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧។
- **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន៤ ៧៩៦ ៩៣៩លានរៀល ត្រូវជា ៤,៨៤%នៃ ផ.ស.ស. គឺមានកំណើន៥,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖
  - មូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន២៥០ ០០០លានរៀល ត្រូវជា០,២៥%នៃ ផ.ស.ស. គឺស្មើនឹងច្បាប់ឆ្នាំ២០១៧
  - ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណងនិងពីការខ្ចី ត្រូវបានគ្រោងចំនួន៤ ៥៤៦ ៩៣៩លានរៀល ត្រូវជា ៤,៥៩%នៃ ផ.ស.ស. គឺមានកំណើន៦,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

ជារួម កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានក្រៅប្រទេសមិនមានអ្វីប្រែប្រួលទេ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ទ្វេភាគី មាននិន្នាការថយចុះ ដោយសារម្យ៉ាងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាដៃគូកំពុងជួបការលំបាក និងម្យ៉ាងទៀត ប្រទេសមួយចំនួនទៀត ដូចជាប្រទេសជប៉ុន ប្រទេសបារាំង ជាដើម កំពុងងាកមកបង្កើនការផ្តល់ ឬចាប់ផ្តើមផ្តល់ឥណទានសម្បទានជំនួសវិញ ដោយសារស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជាមានការរីកធំធាត់ជាងមុន។

### ២.៣.២- គម្រោងចំណាយថវិកាថ្នាក់ជាតិ

| សូចនាករ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណាយថវិកាថ្នាក់ជាតិសរុប(% ផ.ស.ស.) | *២១,៦៨* | *២១,០១* | *២២,៥៥* | ***២៣,៦៤*** |
| ចំណាយចរន្តថ្នាក់ជាតិ(% ផ.ស.ស.) | *១៣,៨៥* | *១៣,៥០* | *១៤,៥៨* | ***១៥,៣៥*** |
| ចំណាយមូលធនថវិកាថ្នាក់ជាតិ(% ផ.ស.ស.) | *២,៣៩* | *២,១៨* | *២,៤៤* | ***២,៩៥*** |
| គម្រោងវិនិយោគ | *១,៥២* | *១,៤៤* | *១,៦១* | ***២,០៩*** |
| បដិភាគវិនិយោគ | *០,៥៦* | *០,៥៨* | *០,៥៥* | ***០,៦១*** |
| មូលនិធិទ្រទ្រង់ថវិកា | *០,៣១* | *០,១៧* | *០,២៨* | ***០,២៥*** |
| ការទូទាត់ប្រាក់ខ្ចី | *០,៦៣* | *០,៥៧* | *០,៧៤* | ***០,៧៤*** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | *៤,៨១* | *៤,៧៦* | *៤,៧៩* | ***៤,៥៩*** |

ថវិកាថ្នាក់ជាតិឆ្នាំ២០១៨ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយថវិកាថ្នាក់ជាតិសរុបស្ថិតក្នុងកម្រិតចំនួន២៣ ៤២៨ ២៩៨លានរៀល ត្រូវជា២៣,៦៤% មានកំណើន១៦,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

**ក. <u>ចំណាយចរន្តថវិកាថ្នាក់ជាតិ</u>**

**ក.១ <u>ទិដ្ឋភាពរួមនៃចំណាយចរន្តថ្នាក់ជាតិ</u>**

ចំណាយចរន្តថ្នាក់ជាតិ ត្រូវបានកំណត់ឱ្យស្ថិតក្នុងកម្រិតចំនួន១៥ ២១៨ ១៦៦លានរៀល ត្រូវជា ១៥,៣៥%នៃ ផ.ស.ស. គឺមានកំណើន១៦,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

**ក.១.១- ចំណាយលើបន្ទុកបុគ្គលិក** រួមមាន បៀវត្សមូលដ្ឋាន, ប្រាក់បំណាច់មុខងារ, ប្រាក់ឧបត្ថម្ភ និវត្តជន លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យា ត្រូវបានគ្រោងចំនួន៧ ៩១៤ ៩២៤លានរៀល មានសមាមាត្រស្មើនឹង ៥២,០%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា៧,៩៩%នៃ ផ.ស.ស. គឺមានកំណើន១៦,៣%ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ក្នុងនោះ បានគ្រោងសម្រាប់ (១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា១២,០% ដោយដំឡើងបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍២ ១៣០រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨, (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៨ ទៅតាមកម្រិតនៃប្រាក់បំណាច់មុខងារដូចតទៅ៖

- **មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យរដ្ឋបាល, ការទូត, បច្ចេកទេស និងផ្សេងៗ៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៣៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥០០ ០០០រៀល
  - ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០រៀល ឡើងទៅ។
- **មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យអប់រំ៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥៤០ ០០០រៀល
  - ផ្តល់បន្ថែម៩០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៤០ ០០០រៀល ទៅដល់កម្រិតក្រោម៧៥០ ០០០រៀល
  - ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧៥០ ០០០រៀល ឡើងទៅ។
- **មន្ត្រីរាជការដែលបម្រើការងារក្នុងក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យសុខាភិបាល៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥៩០ ០០០រៀល
  - ផ្តល់បន្ថែម៩០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៩០ ០០០រៀល ទៅដល់កម្រិតក្រោម៧០០ ០០០រៀល
  - ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧០០ ០០០រៀល ឡើងទៅ។
- **យោធិន៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០រៀល ទៅដល់កម្រិតក្រោម ៥០០ ០០០ រៀល

- ផ្តល់បន្ថែម៨០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០រៀល ទៅដល់កម្រិតក្រោម៦៥០ ០០០រៀល
- ផ្តល់បន្ថែម៦០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០ រៀល ទៅដល់កម្រិតក្រោម១ ៣៤០ ០០០រៀល
- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៣៤០ ០០០រៀល ឡើងទៅ។

○ **នគរបាលជាតិ និងអនុរក្សពន្ធនាគារ៖**

- ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី២៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥០០ ០០០រៀល
- ផ្តល់បន្ថែម៨០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី៥០០ ០០០រៀល ទៅដល់កម្រិតក្រោម៦៥០ ០០០រៀល
- ផ្តល់បន្ថែម៦០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី៦៥០ ០០០រៀល ទៅដល់កម្រិតក្រោម១ ៤៤០ ០០០រៀល
- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី១ ៤៤០ ០០០រៀល ឡើងទៅ។

**ដូច្នេះ តាមរយៈការដំឡើងប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារខាងលើនេះ នឹងធ្វើឱ្យរាជរដ្ឋាភិបាលអាចសម្រេចបាននូវអាទិភាពគោលនយោបាយខ្ពស់បំផុតរបស់ខ្លួន ក្នុងការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យបានជាង១លានរៀលនៅឆ្នាំ២០១៨ ទៅតាមការគ្រោងទុកតាំងពីដើមនីតិកាលមក ដោយអាចធានាមិនឱ្យមានបច្ច័យប៉ះពាល់ដល់ចីរភាពថវិកា និងស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ចជារួម។ កំណើនប្រាក់បៀវត្សនេះ មិនត្រឹមតែបានជួយលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធតែមួយមុខទេ តែថែមទាំងបានលើកកម្ពស់ប្រសិទ្ធភាពនៃសេវាធារណៈឱ្យកាន់តែប្រសើរឡើងផងដែរ។ នៅក្នុងក្របខ័ណ្ឌនេះ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៅក្នុងឆ្នាំ២០១៨ នឹងត្រូវបានដំឡើងដូចខាងក្រោម៖**

- បៀវត្សមន្ត្រីរាជការស៊ីវិល នឹងត្រូវដំឡើងពីចំនួន៨៥៣ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ៩១៤ ៤៥០រៀល នៅខែមករា ឆ្នាំ២០១៨, ហើយនឹងត្រូវដំឡើងដល់ប្រមាណ **១ ០១៤ ៤៥០**រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨
- បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ នឹងត្រូវដំឡើងពីចំនួន៩៥៣ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ១ ០១៤ ៤៥០រៀល នៅខែមករា ឆ្នាំ២០១៨, ហើយនឹងត្រូវដំឡើងដល់ប្រមាណ**១ ១១៤ ៤៥០**រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨
- បៀវត្សនគរបាលជាតិ (ពលបាលត្រី) នឹងត្រូវដំឡើងពីចំនួន៩៣៧ ៩៧៧រៀល (ដោយគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ២០១៧ ដល់ប្រមាណ៩៩៨ ៩២៧រៀល (ដោយគិតបញ្ចូល

របបអង្គរ) នៅខែមករា ឆ្នាំ២០១៨, ហើយនឹងត្រូវដំឡើងដល់ប្រមាណ**១ ០៩៨ ៩២៧**រៀល (ដោយគិតបញ្ចូលរបបអង្គរ) ចាប់ពីខែមេសា ឆ្នាំ២០១៨

- បៀវត្សយោធិន (ពលទោ) នឹងត្រូវដំឡើងពីចំនួន៨២២ ៥០០ រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ៨៧៦ ៥៥០រៀល នៅខែមករា ឆ្នាំ២០១៨ (មិនគិតបញ្ចូលរបបអង្គរ), ហើយនឹងត្រូវដំឡើងដល់ប្រមាណ៩៧៦ ៥៥០រៀល (មិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលរបបអង្គរ ត្រូវជាប្រមាណ**១ ០៣៥ ០២៧** រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨ ។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធជាង១លានរៀល **រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន៣០ ០០០លានរៀល សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន**។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន២ទៀត ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៨ ដែលរួមមាន៖

- **ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាព ដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី** ដោយបង្កើនពី៦០០ ០០០រៀលទៅចំនួន៨០០ ០០០រៀល សម្រាប់ការសម្រាលបានកូនមួយ និងចំនួន១ ៦០០ ០០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះពីរ និងចំនួន២ ៤០០ ០០០ រៀល សម្រាប់ការសម្រាលបានកូនភ្លោះបី។
- **ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព** ដោយក្នុងម្នាក់ៗ ត្រូវបានដំឡើងពីចំនួន១ ២០០ ០០០រៀល ទៅ២ ០០០ ០០០រៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និងដំឡើងពីចំនួន១ ៥០០ ០០០រៀល ទៅ៤ ០០០ ០០០រៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណី។

ចំពោះប្រាក់សោធននិវត្តជន ក៏ត្រូវបានគ្រោងថវិកាចំនួន៣៥ ០០០លានរៀលផងដែរ សម្រាប់បន្ថែមជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយដំឡើងរបបសោធនប្រចាំខែទាបបំផុតពី៤២០ ០០០រៀល ឱ្យឡើងដល់៤៨០ ០០០រៀលក្នុងមួយខែ ព្រមទាំងគ្រោងផ្តល់បន្ថែមចន្លោះពី២០ ០០០ រៀល ទៅ៤០ ០០០រៀល ជូននិវត្តជន ដោយផ្អែកលើកម្រិតរបបសោធនប្រចាំខែ ហើយគ្រោងអនុវត្តចាប់ពីខែមេសា ឆ្នាំ២០១៨ ។ ប្រការនេះនឹងជួយកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់។

ក្រៅពីការដំឡើងប្រាក់សោធននិវត្តន៍ជូននិវត្តជន ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា ក៏នឹងត្រូវបានដំឡើងពីចំនួន៥០០ ០០០រៀល នៅឆ្នាំ២០១៧ ដល់ចំនួន៦០០ ០០០រៀល នៅឆ្នាំ២០១៨ផងដែរ។

**ក.១.២-ចំណាយមិនមែនបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន៧ ៣០៣ ២៤៣លានរៀល មានសមាមាត្រស្មើនឹង៤៨,០%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៧,៣៧%នៃ ផ.ស.ស. គឺមានកំណើន១៦,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

ទន្ទឹមនេះ គួរកត់សម្គាល់ថា នៅឆ្នាំ២០១៨ **ការសាកល្បងថវិកាកម្មវិធីពេញលេញ** នឹងត្រូវអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័នចំនួន ៣៩ទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញ ដែលរួមទាំងស្ថាប័នបីចុងក្រោយ គឺ **ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** និង **ក្រសួងការពារជាតិ** ។ ថវិកាកម្មវិធីនេះ គឺជាការរៀបចំថវិកាដោយ

ផ្អែកលើកម្មវិធីជាមូលដ្ឋាន និងមានការកំណត់ជាមុននូវលទ្ធផលរំពឹងទុក ដែលត្រូវវាស់ដោយលទ្ធផល ឬ ជាតុចេញ (outputs), លទ្ធផលចុងក្រោយ (outcomes) និងសូចនាករ (indicators) ទៅតាមកម្មវិធី (programs), អនុកម្មវិធី (sub-programs) និងចង្កោមសកម្មភាព (activities)។ ការអនុវត្តថវិកាកម្មវិធីនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចធ្វើការវិភាជធនធានកាន់តែមានប្រសិទ្ធភាពជាងមុន ហើយចំអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ក.២-<u>ទិដ្ឋភាពនៃការបែងចែកចំណាយចរន្តថវិកាថ្នាក់ជាតិតាមវិស័យ</u>**

ថវិកាចរន្តថ្នាក់ជាតិឆ្នាំ២០១៨ ត្រូវបានបែងចែកទៅតាមវិស័យដូចតទៅ៖

**ក.២.១-វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងថវិកាចំនួន២ ២៦៣ ៣០៤លានរៀល, មានសមាមាត្រស្មើនឹង ១៤,៩% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា២,២៨%នៃ ផ.ស.ស. គឺមានកំណើន១៣,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ ស្ថាប័នដែលមានកំណើនសំខាន់ៗ គួរឱ្យកត់សម្គាល់គឺ៖

- **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** ត្រូវបានគ្រោងថវិកាចំនួន២០៨ ៥២៤ លានរៀល, មានសមាមាត្រស្មើនឹង១,៤% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, មានកំណើន១៥,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន១៨ ៨០៣ លានរៀល មានកំណើនចំនួន ៥,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៩១,០% នៃចំណាយសរុបរបស់ស្ថាប័ន, ត្រូវបានគ្រោងថវិកាចំនួន១៨៩ ៧២២ លានរៀល មានកំណើន១៦,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ និងត្រូវបានផ្តោតជាពិសេសទៅលើការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា និងជាពិសេសសម្រាប់ភ្នាក់ងារ ជាតិជាប់កិច្ចសន្យា និងបុគ្គលិកសមូហភាពសាធារណៈផ្សេងៗ ក្នុងរយៈពេលនៃការចុះឈ្មោះពិនិត្យបញ្ជីឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០១៨។
- **អគ្គលេខាធិការដ្ឋានរដ្ឋសភា** ត្រូវបានគ្រោងថវិកាចំនួន១៨០ ៨៨៨លានរៀល មានសមាមាត្រស្មើនឹង១,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, មានកំណើនចំនួន២១,២% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ថវិកាបន្ទុកបុគ្គលិកមានចំនួន៩១ ៦៤៦លានរៀល មានកំណើនចំនួន១៤,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងចំណាយក្រៅបន្ទុកបុគ្គលិកមានចំនួន៨៩ ២៤២ លានរៀល មានកំណើនចំនួន២៨,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៧ ដែលបានផ្តោតទៅលើ៖
  - ឯកសណ្ឋានជូនសមាជិកសមាជិការដ្ឋសភា៥ ៨០០លានរៀល និងជួសជុលកៅអីសាលប្រជុំតំណាងរាស្ត្រចំនួន១ ១០០លានរៀល
  - ជួសជុល និងបំពាក់ការម៉ោសុវត្ថិភាពនៅតាមបណ្តាចំណុចសំខាន់ៗចំនួន២០០គ្រឿង ដែលមានតម្រូវការថវិកាចំនួន៣ ០០០លានរៀល
  - ការផ្តល់ជូនថវិកាចំនួន៦ ០០០លានរៀល បន្ថែមពីលើឥណទានថវិកាឆ្នាំ២០១៧ សម្រាប់ចំណាយលើការជួសជុលអគារធំ (A) និងការជួសជុលការិយាល័យតំណាងរាស្ត្រនៅតាមខេត្តចំនួន២២០លានរៀល (ខេត្តកែប និងខេត្តកំពត) ព្រមទាំងការជួសជុលតូចតាចផ្សេងទៀត

- ការផ្តល់ថវិកាចំនួន១ ៦៧០លានរៀល ដើម្បីបំពាក់កៅអីថ្មី ក្នុងឆ្នាំ២០១៨ លើគម្រោងថវិកាកែលម្អកៅអីសរុបចំនួន៨ ០០០ លានរៀល ដែលស្មើនឹងចំនួន៤៨៤ កៅអី សម្រាប់បំពាក់កៅអីថ្មី។

- **ទីស្តីការគណៈរដ្ឋមន្ត្រី** ត្រូវបានគ្រោងថវិកាចំនួន៤០៩ ១៣២ លានរៀល មានសមាមាត្រស្មើនឹង ២,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ មានការថយចុះ-១៤,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានចំនួន៦៦ ០៨២លានរៀល មានកំណើនចំនួន១៦ ៧០៧លានរៀល ត្រូវជា៣៣,៨% ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងចំណាយមិនមែនបន្ទុកបុគ្គលិកចំនួន៣៤៣ ០៥០លានរៀល គឺថយចុះចំនួន ៨៤ ៧៥៤លានរៀល ត្រូវជា-១៩,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដោយសារការផ្ទេរអង្គភាពមួយចំនួនទៅក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នជំនាញ ដែលមានដូចជា៖ (១)-សមាគមជាតិកាយរឹទ្ធិជាតិកម្ពុជា, (២)-គណៈកម្មការជាតិយូណេស្កូកម្ពុជា, (៣).គណៈកម្មាធិការជាតិបេតិកភ័ណ្ឌពិភពលោក, (៤).អាជ្ញាធរអប្សរា, (៥).អាជ្ញាធរជាតិព្រះវិហារ និង(៦).គណៈវិស្វករកម្ពុជា។

- **ក្រសួងមុខងារសាធារណៈ** ត្រូវបានគ្រោងថវិកាចំនួន៤៧ ៩៦១លានរៀល មានសមាមាត្រស្មើនឹង ០,៣%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,០៥%នៃ ផ.ស.ស. មានកំណើន៤,៨%ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានចំនួន១៦ ៦៤៣លានរៀល មានកំណើន១២,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៦៥,៣%នៃចំណាយសរុបរបស់ក្រសួង ត្រូវបានគ្រោងថវិកាចំនួន៣១ ៣១៨លានរៀល មានកំណើន១,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ហើយត្រូវបានផ្តោតជាសំខាន់លើការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ កែទម្រង់រដ្ឋបាលសាធារណៈ ដែលមានថវិកាចំនួន៥ ៥៩៩ លានរៀល ជាពិសេសសម្រាប់ការបណ្តុះបណ្តាលមន្ត្រីរាជការដើម្បីកសាងរដ្ឋបាលសាធារណៈ ឱ្យកាន់តែមានភាពឆ្លើយតប, មានប្រសិទ្ធភាព, ប្រសិទ្ធផល, និងជឿទុកចិត្ត ដែលមានថវិកាចំនួន ៣ ៧៧៤ លានរៀល។

- **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ត្រូវបានគ្រោងថវិកាចំនួន៧៧២ ៥៤០លានរៀល មានសមាមាត្រស្មើនឹង ៥,១%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,៧៨%នៃ ផ.ស.ស. មានកំណើន៣៤,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន១០៦ ៣៤៦លានរៀល មានកំណើន ២១,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលមានចំនួន៨៦,២%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៦៦៦ ១៩៤លានរៀល មានកំណើន៣៦,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដោយសារការកត់ត្រាចំណាយព្រម លើមុខសញ្ញាអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារកសិកម្ម និងពន្ធនាំចូលវត្ថុធាតុដើមសម្រាប់ផលិតឱសថចំនួនប្រមាណ២៨៥ ០០០លានរៀល ទន្ទឹមនឹង ការបង្កើនកញ្ចប់ថវិកាសម្រាប់ការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ចំនួន១០០ ០០០លានរៀលផងដែរ។

- **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ត្រូវបានគ្រោងថវិកាចំនួន១៥០ ១០៣លានរៀល មានសមាមាត្រស្មើនឹង១,០%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,១៥%នៃ ផ.ស.ស. មានកំណើន១១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក មានចំនួន៨៧ ៦៤៨លានរៀល មានកំណើន ១៨,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៤១,៦%នៃចំណាយ

សរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៦២ ៤៥៥លានរៀល មានកំណើន២,៩%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៧ និងត្រូវបានផ្តោតជាពិសេសទៅលើការបន្តគាំទ្រដល់ការបែងចែកដីសម្បទានសង្គមកិច្ច ស្របតាមគោលនយោបាយកែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល និងការបន្តគាំទ្រដល់ការដោះស្រាយទំនាស់ដីធ្លី ព្រមទាំងការជំរុញការបន្តចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ និងដីឯកជន។

**ក.២.២-វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងថវិកាចំនួន ៣ ៨៩៤ ៣៧៦លានរៀល, មានសមាមាត្រស្មើនឹង២៥,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា៣,៩៣% នៃ ផ.ស.ស. គឺមានកំណើន១៦,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

- **ក្រសួងការពារជាតិ** ត្រូវបានគ្រោងថវិកាចំនួន២ ១៩៨ ៣៧៨លានរៀល, មានសមាមាត្រស្មើនឹង ១៤,៤% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា២,២២%នៃ ផ.ស.ស. គឺមានកំណើន១៨,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន៨៤,៨%នៃចំណាយសរុបរបស់ក្រសួង ត្រូវបានគ្រោងថវិកាចំនួន១ ៨៦៤ ៩៤៤លានរៀល មានកំណើន២០,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិក ដែលមានតែចំនួន១៥,២%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៣៣៣ ៤៣៤លានរៀលមានកំណើន៦,៣%ធៀបនឹងច្បាប់ឆ្នាំ ២០១៧ និងត្រូវបានផ្តោតទៅលើ៖
  - ការលើកកម្ពស់ជីវភាពរស់នៅរបស់កងទ័ពគ្រប់ប្រភេទ ជាពិសេសកងទ័ពឈរជើងតាមបណ្តោយព្រំដែន តាមរយៈការផ្តត់ផ្តង់ស្បៀងអាហារដល់កងទ័ពគ្រប់ប្រភេទ មានថវិកា៩៤ ៦៦១ លានរៀល
  - ការផ្តត់ផ្តង់ឯកសណ្ឋាន និងសម្លៀកបំពាក់ដែលរួមមាន៖ ខោខ្លី, អាវយឺត, ស្បែកជើង, ខោអាវ៉ាវុី និងសាក់កាដូ មានថវិកាចំនួន៥៩ ២៥០ លានរៀល
  - ការសាងសង់, ជួសជុល និងថែទាំឃ្លាំង ដើម្បីថែរក្សាសម្ភារៈបច្ចេកទេសកងទ័ព និងគ្រឿងចក្រ មានថវិកាចំនួន១៥ ៨៧០លានរៀល ក្នុងនោះ ថវិកាចំនួន១០ ០០០លានរៀល សម្រាប់សាងសង់ទីលានហ្វឹកហ្វឺនបាញ់គ្រាប់ពិតរបស់កងរាជអាវុធហត្ថ និងថវិកាចំនួន១ ២១០លានរៀល សម្រាប់សាងសង់របង និងអគារព្រលានយន្តហោះ នៅខេត្តកំពង់ឆ្នាំង
  - ការថែទាំសុខុមាលភាព និងព្យាបាលជំងឺដល់កងយោធពលខេមរភូមិន្ទ និងគាំទ្របន្ថែមដល់វៈអន្តរាគមន៍ មានថវិកាចំនួន១១ ៩៤១លានរៀល មានកំណើន១ ៦០៦លានរៀល ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ក្នុងនោះ ថវិកាចំនួន១ ០០០លានរៀល សម្រាប់មន្ទីរពេទ្យព្រះកេតុមាលា, ៣០លានរៀលសម្រាប់គិលានដ្ឋានជួរមុខ, និង៥៧៦លានរៀល សម្រាប់វៈអន្តរាគមន៍
  - ការរៀបចំឯកសារយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលលើគោលនយោបាយការពារជាតិ (សៀវភៅសការពារជាតិថ្មី) មានថវិកាចំនួន ១២៥ លានរៀល។

- **ក្រសួងមហាផ្ទៃ** ត្រូវបានគ្រោងថវិកាចំនួន១ ៥៥៧ ៦៧៧លានរៀល មានសមាមាត្រស្មើនឹង ១០,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា១,៥៧%នៃ ផ.ស.ស. និងមានកំណើន១៤,១%ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ក្នុងនោះ៖

• **ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ** ត្រូវបានគ្រោងថវិកាចំនួន១ ៣៩៤ ០៩៥លានរៀល, មានសមាមាត្រស្មើនឹង៩,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា១,៤១%នៃ ផ.ស.ស. គឺមានកំណើន ១២,៥% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន៦៦,៧%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងចំនួន១ ០៣៩ ៧២៦លានរៀល មានកំណើន១១,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន២២,៧%នៃចំណាយសរុបរបស់ក្រសួង ត្រូវបានគ្រោងថវិកាចំនួន៣៥៤ ៣៦៩លានរៀល មានកំណើន១៦,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាពិសេសលើ៖

- ការរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន (Border Control System) ដែលមានរយៈពេលទូទាត់៤ឆ្នាំ (២០១៧-២០២០) មានថវិកាចំនួន ៣៥ ៨៧៣ លានរៀល
- ការបន្តបំពាក់ម៉ាស៊ីនថតល្បឿនយានយន្តស្វ័យប្រវត្តិយប់-ថ្ងៃ ដែលមានថវិកាចំនួន៥ ៩៤០ លានរៀល
- ការបន្តផ្តល់ថវិកាសម្រាប់ការបោះពុម្ពលិខិតឆ្លងដែនថ្មី នៅក្នុងជំហានទី២ (E-Passport) ដែលមានថវិកាចំនួន៣០ ៥២២លានរៀល
- ការរៀបចំមជ្ឈមណ្ឌលប្រព័ន្ធគ្រប់គ្រងទូរស័ព្ទ ដែលមានថវិកាចំនួន១៤ ១០០លានរៀល
- ការបន្តផ្តល់ថវិកាសម្រាប់ការងារផលិតលិខិតឆ្លងដែន មានថវិកាចំនួន២៧ ១២៩លានរៀល និងអត្តសញ្ញាណកម្មជំហានទី៣ មានថវិកាចំនួន៣៥ ៥០៧លានរៀល
- ការផ្តល់ប្រាក់បំប៉នជីវភាពសិក្ខាកាម និងប្រាក់ម៉ោងគ្រូបង្រៀន និងគ្រូឧទ្ទេស មានថវិកាចំនួន ៨ ០០១លានរៀល។

• **ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ** ត្រូវបានគ្រោងថវិកាចំនួន១៦៣ ៥៨២លានរៀល, មានសមាមាត្រស្មើនឹង១,១%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,១៧%នៃ ផ.ស.ស. គឺមានកំណើន២៩,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន៥,៥% នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៨៥ ៤៧២លានរៀល មានកំណើន៤១,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតទៅលើការផ្តល់ប្រាក់បំប៉នជីវភាពដល់ក្របខ័ណ្ឌមន្ត្រីពន្ធនាគារ។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៥,0% នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៧៨ ១១០លានរៀល មានកំណើន១៨,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតលើការគាំទ្រសេវាពន្ធនាគារ ដែលមានចំនួនអ្នកទោសកើនឡើងពីចំនួន២២ ០០០នាក់ ទៅ៣០ ០០០នាក់ ដែលធ្វើឱ្យមានតម្រូវការចំណាយសម្រាប់ស្បៀងអាហារ, ឯកសណ្ឋាន, សម្ភារៈប្រើប្រាស់ ដែលធ្វើឱ្យមានកំណើនថវិកាចំនួន១២ ៣៩១លានរៀល។

- **ក្រសួងយុត្តិធម៌** ត្រូវបានគ្រោងថវិកាចំនួន១៣៨ ៣២១លានរៀល, មានសមាមាត្រស្មើនឹង0,៩%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា0,១៤%នៃ ផ.ស.ស. មានកំណើន១៨,៥%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៤៦,៨%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងចំនួន៦៤ ៧៩៩លានរៀល, មានកំណើន១៣,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតការយកចិត្តទុកដាក់លើការបង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាដម្រះក្តីគ្រប់

ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ ក្នុងគោលដៅធានាឱ្យបាននូវប្រព័ន្ធយុត្តិធម៌មួយ ដែលអាចជឿទុកចិត្តបាន និងមានស្ថិរភាព សម្រាប់ការលើកស្ទួយការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការពង្រឹងគោលការណ៍នីតិរដ្ឋ ក្នុងលទ្ធិប្រជាធិបតេយ្យសេរី ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្តសម្រាប់ទាក់ទាញការវិនិយោគ តាមរយៈ៖

- ការគាំទ្រគម្រោងជួសជុលអគាររដ្ឋបាលទីស្តីការក្រសួងពហុឆ្នាំចំនួន២ ៤២០លានរៀល, ជួសជុលអាគារនៅតុលាការកំពូលចំនួន៦៦១លានរៀល និងសាលាដំបូងរាជធានី-ខេត្តចំនួន ៣ ៤៩២លានរៀល ដើម្បីមានលទ្ធភាពបំពេញការងារប្រកបដោយប្រសិទ្ធភាព និងផលិតភាព
- ការបន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគាត់ តាមផ្លូវតុលាការមានថវិកាចំនួន៩០០លានរៀល។

**ក.២.៣-វិស័យសង្គមកិច្ច** ត្រូវបានគ្រោងថវិកាចំនួន៥ ៦៥៨ ៩៥៩លានរៀល, មានសមាមាត្រស្មើនឹង ៣៧,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវដាច់៥,៧១%នៃ ផ.ស.ស. គឺមានកំណើន១៧,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

- **ក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានគ្រោងថវិកាចំនួន២ ៧០៥ ៤៥៧លានរៀល, មានសមាមាត្រស្មើនឹង១៧,៨%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវដាច់២,៧៣%នៃ ផ.ស.ស. គឺមានកំណើន១៣,៥%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកដែលមានចំនួន៨០,៦%នៃចំណាយសរុបរបស់ក្រសួង មានកំណើន១២,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន ១៩,៤%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៥២៤ ៧១០លានរៀល មានកំណើន ១៧,៣%ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៧ និងត្រូវបានផ្តោតជាសំខាន់លើការបន្តគាំទ្រដល់ការពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ ព្រមទាំងការអប់រំកាយ និងកីឡា ជាពិសេសការកែទម្រង់ក្នុងវិស័យអប់រំ តាមរយៈ៖
  - ការបង្កើនថវិកាដំណើរការសាលារៀនចំនួន១៣ ០០០លានរៀល ដោយបង្កើនថវិកាចំនួន ១,៥លានរៀល ក្នុង១សាលារៀន ដែលធ្វើឱ្យថវិកាដំណើរការសាលារៀនសរុបបានកើនឡើងទៅដល់ចំនួន៨០ ០០០លានរៀល ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងសាលារៀន ឱ្យកាន់តែល្អប្រសើរ
  - ការបន្តផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅកម្រិតបឋមសិក្សាចំនួន១០០៤២២នាក់ ដោយសិស្ស១រូប ទទួលបានថវិកាចំនួន២៤ ម៉ឺនរៀលក្នុង១ឆ្នាំ និងនៅកម្រិតមធ្យមសិក្សាបឋមភូមិចំនួន៧២ ១៨០នាក់ ដោយសិស្ស១រូប ទទួលបានថវិកាចំនួន៣៦ ម៉ឺនរៀលក្នុង១ឆ្នាំ ព្រមទាំងនៅកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១០ ៩៧០នាក់ ដោយសិស្ស១រូប ទទួលបានថវិកា៣៦ ម៉ឺនរៀល ក្នុង១ឆ្នាំ មានតម្រូវការថវិកាសរុបចំនួន៤៥ ៣៧៤លានរៀល ក្នុងគោលបំណងកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សក្រីក្រ និងជួយសម្រាលបន្ទុកចំណាយរបស់

មាតាបិតា និងអាណាព្យាបាលសិស្ស ពិសេសដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រឱ្យទទួលបាននូវការអប់រំដោយស្មើភាព

- ការបន្តជួសជុល និងថែទាំអគារសិក្សា ដែលត្រូវប្រើប្រាស់ជាមណ្ឌលប្រឡង ឱ្យមានគុណភាព និងសោភ័ណភាពកាន់តែល្អ ដែលមានថវិកាចំនួន៤ ២០០លានរៀល
- ការបន្តបំពាក់តុ កៅអី តាមសាលារៀន ដែលមានការខ្វះខាត ឬជំនួសតុ កៅអីដែលមានការបាក់បែក នៅគ្រប់តំបន់ ជាពិសេសតំបន់ជនបទ ដែលមានថវិកាចំនួន៨ ០០០លានរៀល
- ការបន្តគាំទ្រដល់ការសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀនចំនួន ២១៦កន្លែងបន្ថែមទៀត ដើម្បីលើកកម្ពស់អនាម័យរបស់សិស្សានុសិស្សទូទៅ ជាពិសេសជួយសម្រួលដល់ការសិក្សារបស់សិស្សស្រី ដែលមានថវិកាចំណាយចំនួន២ ៩៨០លានរៀល
- ការបន្តពង្រឹងគុណភាពនៃការផ្តល់សេវានៅថ្នាក់មូលដ្ឋាន ដោយបន្តផ្តល់ថវិកាដោយផ្ទាល់ដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌចំនួន២៤លានរៀល ក្នុង១ឆ្នាំ សម្រាប់គាំទ្រដល់ដំណើរការការងារដាប្រចាំ ដែលមានថវិកាចំនួ៤ ៧២៨លានរៀល
- លើកកម្ពស់ប្រសិទ្ធភាពការងាររដ្ឋបាលនៅតាមសាលារៀន ដោយនឹងបន្តរៀបចំបង្កើតបន្ទប់កុំព្យូទ័រដល់សាលារៀនចំនួន២៥ បន្ថែមទៀត មានតម្រូវការថវិកាសរុបចំនួន១ ៣៧៥លានរៀល
- ការលើកកម្ពស់គុណវុឌ្ឍិ និងគុណភាពគ្រូឧទ្ទេស ដោយនឹងបញ្ជូនគ្រូឧទ្ទេសឆ្នើមចំនួន ៣០ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៅប្រទេសសឹង្ហបូរី ដែលមានថវិកាចំនួន ២ ៥០០លានរៀល
- ការបន្តពង្រឹងគុណភាពនៃការប្រឡងនៅគ្រប់កម្រិត ដោយបង្កើនថវិកាសម្រាប់ការរៀបចំប្រឡងចំនួន៥ ១៤៨លានរៀល ដែលធ្វើឱ្យថវិកាសម្រាប់ការរៀបចំប្រឡងកើនឡើងទៅដល់ ៤២ ៣៨០លានរៀល
- ការបន្តបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន៣បន្ថែមទៀត ដើម្បីផ្តល់ជម្រើសដល់សិស្សដែលរៀនចប់មធ្យមសិក្សាបឋមភូមិ ឱ្យមានលទ្ធភាពកាន់តែច្រើនក្នុងការបន្តការសិក្សាជំនាញបច្ចេកទេស ដែលអាចរកការងារធ្វើបានសមរម្យដោយផ្តល់ថវិកាចំនួន៤ ៥០០លានរៀល សម្រាប់ចំណាយលើការបំពាក់បរិក្ខារបច្ចេកទេសក្នុងការបង្រៀន និងពិសោធន៍
- ការបន្តពង្រីកសាលារៀនជំនាន់ថ្មីដោយបានបង្កើនថវិកាចំនួន២ ៦០០លានរៀល សម្រាប់ពង្រីកសាលាជំនាន់ថ្មីចំនួន៣ បន្ថែមទៀត ក្នុងនោះ សាលារៀនជំនាន់ថ្មីនៅកម្រិតបឋមសិក្សា២ សាលារៀន និងសាលារៀនជំនាន់ថ្មីនៅកម្រិតមធ្យមសិក្សាចំនួន១ សាលារៀន ដែលធ្វើឱ្យសាលារៀនជំនាន់ថ្មី ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានចំនួន៨ សាលារៀន ដែលក្នុងនោះ កម្រិតមធ្យមសិក្សា មានចំនួន៦ សាលារៀន និងកម្រិតបឋមសិក្សា មានចំនួន២ សាលារៀន ដែលមានថវិកាចំនួន៧ ៨០០លានរៀល

- ការបន្តលើកកម្ពស់គុណភាពឧត្តមសិក្សា ដោយផ្តោតលើការសិក្សា និងការស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រពិត បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (ជំនាញ STEM) ដែលមានថវិកាចំនួន១ ៤៥០លានរៀល
- ការបន្តបោះពុម្ពសៀវភៅគោលសិក្សា ដើម្បីចែកចាយឱ្យទាន់ពេលវេលា និងចែកចាយសៀវភៅតាមមុខវិជ្ជាដែលសាលារៀននីមួយៗ មានតម្រូវការជាក់ស្តែង ដែលមានថវិកាចំនួន២៦ ០០០ លានរៀល
- ផ្តល់ថវិកាចំនួន៨០លានរៀល សម្រាប់គាំទ្រដល់ដំណើរការរដ្ឋបាល ដោយផ្តល់ថវិកាចំនួន ២០លានរៀល ក្នុង១ឆ្នាំ ក្នុង១សាលារៀន ឱ្យទៅដល់សាលាបឋមសិក្សាដែលអនុវត្តកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃ ដែលមានសាលារៀនចំនួន ៤
- ការផ្តល់ថវិកាចំនួន៧៥០លានរៀលសម្រាប់ការផ្តល់ការសិក្សាដល់សិស្សពិការ (គ, ថ្លង់, ខ្វាក់)
- ផ្តល់ថវិកាចំនួន១ ៣៣៩លានរៀល សម្រាប់ចំណាយលើប្រតិបត្តិការមតេ្តយ្យសហគមន៍ ដើម្បីជំនួសហិរញ្ញប្បទានដែលធ្លាប់ផ្តល់ដោយ UNICEF (ក្រៅពីនេះ នៅមានផ្តល់ប្រាក់ឧបត្ថម្ភគ្រូបង្រៀន មតេ្តយ្យសហគមន៍ចំនួន៤ ៣២០លានរៀល ដែលគ្រូបង្រៀន១នាក់ ទទួលបាន ៦០ម៉ឺនរៀល ក្នុង១ខែ)
- ផ្តល់ថវិកាចំនួន៦ ០០០លានរៀល សម្រាប់ការរៀបចំការប្រកួតកីឡាជាតិលើកទី២
- ការបន្តលើកកម្ពស់ការអប់រំកាយ និងកីឡា ពិសេសការបណ្តុះបណ្តាលកីឡាករសម្រាប់ត្រៀមក្នុងការទទួលធ្វើម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣ការផ្តល់ប្រាក់បំប៉នសម្រាប់កីឡាករជម្រើសជាតិហ្វឹកហាត់ មានថវិកាសរុបចំនួន១៦ ៩២៥លានរៀល។

*ទន្ទឹមនឹងថវិកាចំណាយចរន្ត, ក្រសួងអប់រំ យុវជន និងកីឡាទទួលបានថវិកាវិនិយោគចំនួន៤១០ ០០០ លានរៀល សម្រាប់ការកសាង និងជួសជុលអគារសាលារៀននៅតាមបណ្តាខេត្ត។*

**-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ត្រូវបានគ្រោងចំនួន២០៩ ៣៥៩លានរៀល, មានសមាមាត្រស្មើនឹង១,៤%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,២១%នៃ ផ.ស.ស. គឺមានកំណើន១០,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៥៣,៩%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន១១២ ៨៥៨លានរៀល មានកំណើន៦,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៧ និងត្រូវបានផ្តោតជាសំខាន់លើការអភិវឌ្ឍជំនាញដែលឆ្លើយតបនឹងតម្រូវការទីផ្សារ ជាពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និង ការអភិវឌ្ឍវិស័យការងារ តាមរយៈ៖

- ការបន្តគាំទ្រដល់ការបង្កើនគុណភាព, បរិមាណ និងកញ្ចប់ចំណាយឯកតា សម្រាប់ការបណ្តុះ-បណ្តាលបច្ចេកទេសជំនាញរយៈពេលពី១ឆ្នាំដល់៣ឆ្នាំ(C1, C2, & C3) ជូនដល់យុវជនចំនួន ២៥០០នាក់ សរុបថវិកាចំនួន២ ៥០០លានរៀល និងបានផ្តល់អាហារូបករណ៍ជីវភាពប្រចាំខែក្នុងម្នាក់ចំនួន១៦០ ០០០រៀល ដល់សិស្សចំនួន៤០០នាក់ ដែលសិក្សាមុខជំនាញមួយចំនួន ដូចជា សំណង់(ជាងកំបោរ), ជាងក្រឡឹង, ជាងផ្សារ ជាដើម

- ការបន្តវិនិយោគលើការសាងសង់ និងជួសជុលអគារសិក្សាដែលនឹងត្រូវដាក់ឈ្មោះថាជា អគារ អាយឌីភី (Industrial Development Policy-IDP Building) ដែលត្រូវសាងសង់នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) មានថវិកាចំនួន២៦ ២៥៣លានរៀល
- ការលើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស និងការកែលម្អកម្មវិធីសិក្សា ដែលមានថវិកាចំនួន១ ៥០០លានរៀល
- ការបន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជនលើសកម្មភាពបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្របតាមតម្រូវការទីផ្សារការងារជាក់ស្តែង ដែលមានថវិកាចំនួន១ ២០០លានរៀល
- ការបន្តលើកកម្ពស់ការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការរៀនជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានថវិកាចំនួន១ ២០០លានរៀល
- ការបន្តគាំទ្រដល់ការពង្រឹងការគ្រប់គ្រងពលករអន្តោប្រវេសន៍ដែលកំពុងបម្រើការងារនៅកម្ពុជា និង ការអនុវត្តច្បាប់ការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដែលមានថវិកាចំនួន៩៨៨លានរៀល
- ការបន្តគាំទ្រដល់ការងារកសាងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ ដោយផ្តោតទៅលើការងារដោះស្រាយកូដកម្ម និងបាតុកម្ម, សម្របសម្រួលដំណើរការសហជីព, គណៈកម្មការក្រុមប្រឹក្សា អាជ្ញាកណ្តាល និងគណៈកម្មការក្រុមប្រឹក្សាការងារ, ព្រមទាំងការរៀបចំសន្និបាតសហជីពប្រចាំឆ្នាំ ដែលមានថវិកាចំនួន៧ ២៩០លានរៀល
- *កញ្ចប់ថវិកាចំនួន១៣ ០០០លានរៀល ត្រូវបានវិភាជន៍សម្រាប់សកម្មភាពបន្តចុះសួរសុខទុក្ខកម្មករនិយោជិតរបស់រាជរដ្ឋាភិបាលតាមបណ្តារោងចក្រសហគ្រាសទូទាំងប្រទេស ដើម្បីស្វែងយល់ និងផ្តល់ដំណោះស្រាយសមស្របជូនដល់កម្មករនិយោជិត។*

- **ក្រសួងសុខាភិបាល** ត្រូវបានគ្រោងថវិកាចំនួន១ ៣៩៣ ៩៧៤លានរៀល, មានសមាមាត្រស្មើនឹង ៩,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា១,៤១%នៃ ផ.ស.ស. គឺមានកំណើន១៦,០%ធៀបនឹងច្បាប់ឆ្នាំ ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក មានចំនួន៣៣,៤%នៃចំណាយសរុបរបស់ក្រសួង និងមានកំណើនប្រមាណ១៦,២%ធៀបច្បាប់ឆ្នាំ២០១៧។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៦៦,៦%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងចំនួន៩២៧ ៨២៦លានរៀល មានកំណើន១៥,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាពិសេសលើការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាសុខាភិបាល ពិសេសសម្រាប់ប្រជាជនក្រីក្រ, ក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ តាមរយៈ៖

- ការបន្តគាំទ្រកម្មវិធីមូលនិធិសមធម៌ ដោយបង្កើនថវិកាឡើងទៅដល់៦០ ០០០លានរៀល នៅឆ្នាំ២០១៨ សម្រាប់ផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃជូនដល់ប្រជាជនក្រីក្រ នៅទូទាំងប្រទេស និងរក្សាថវិកាចំនួន១៨ ៨៦០លានរៀល សម្រាប់ការពង្រឹងការផ្តល់សេវាសុខាភិបាល (SDG) ដែលធ្វើឱ្យកញ្ចប់ថវិកាពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាលកើនឡើងដល់ចំនួន៧៨ ៨៦០លានរៀល
- ការបន្តបង្កើនកញ្ចប់ថវិកាប្រតិបត្តិការពីចំនួន៤២ ៨១០លានរៀល នៅឆ្នាំ២០១៧ ទៅដល់ចំនួន៥០ ៥០០លានរៀល នៅឆ្នាំ២០១៨ ជូនទៅមន្ទីរពេទ្យបង្អែកកម្រិត ១, ២ និង៣ ព្រមទាំង

មណ្ឌលសុខភាពដោយផ្ទាល់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវានៅនឹងកន្លែង ដោយក្នុងនោះ (១)-មន្ទីរពេទ្យបង្អែកកម្រិត១ចំនួន៥៩ ត្រូវបានបង្កើនថវិកាបន្ថែមចំនួន៥០លានរៀលក្នុងមួយឆ្នាំ ពោលគឺថវិការបស់មន្ទីរពេទ្យនីមួយៗ នឹងកើនឡើងពី១៥០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៧ ដល់២០០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៨, (២)-មន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន៣៦ ត្រូវបានបង្កើនថវិកាបន្ថែមចំនួន៥០លានរៀល ក្នុងមួយឆ្នាំ ពោលគឺថវិការបស់មន្ទីរពេទ្យនីមួយៗ នឹងកើនឡើងពី២០០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៧ ដល់២៥០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៨, (៣)-មន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន១៨ ត្រូវបានបង្កើនថវិកាបន្ថែមចំនួន៥០លានរៀល ក្នុងមួយឆ្នាំ ពោលគឺថវិការបស់មន្ទីរពេទ្យនីមួយៗ នឹងកើនឡើងពី២៥០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៧ ដល់៣០០លានរៀល ក្នុង១ឆ្នាំ នៅឆ្នាំ២០១៨ និង(៤)-ការរក្សាផ្តល់ថវិកាសម្រាប់មណ្ឌលសុខភាពចំនួន១ ២០០ ក្នុងនោះ មណ្ឌលសុខភាពចំនួន៣៧៥ដែលគ្របដណ្តប់ប្រជាជនក្រោម១ម៉ឺននាក់ ត្រូវបានផ្តល់ថវិកាចំនួន១២លានរៀល ក្នុង១ឆ្នាំ ក្នុង១មណ្ឌលសុខភាព។ ចំពោះមណ្ឌលសុខភាពចំនួន៨២៥ ដែលគ្របដណ្តប់ប្រជាជនលើសពី១ម៉ឺននាក់ឡើងទៅ ត្រូវបានថវិកាចំនួន២៤លានរៀល ក្នុង១ឆ្នាំ ក្នុង១មណ្ឌលសុខភាព

- ការបន្តបង្កើនកញ្ចប់ថវិកាពីចំនួន៩៧ ២៩៨លានរៀលនៅក្នុងឆ្នាំ២០១៧ ទៅដល់ចំនួន ១១៧ ៥៩៨លានរៀល នៅក្នុងឆ្នាំ២០១៨ សម្រាប់បំពាក់សម្ភារៈបរិក្ខារបច្ចេកទេសចាំបាច់ និងគ្រែពេទ្យ ព្រមទាំងការបន្តបង្កើនកញ្ចប់ថវិកាពីចំនួន២៨៥ ៨០៨លានរៀល នៅក្នុងឆ្នាំ ២០១៧ ទៅដល់ចំនួន២៨៩ ៥៧១លានរៀល សម្រាប់ទិញឱសថផ្គត់ផ្គង់ដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាព ក្នុងនោះ ថវិកាសម្រាប់ទិញឱសថអេដស៍មានចំនួន៦ ១៥០លានរៀល ក្នុងគោលបំណងពង្រឹងគុណភាពនៃសេវាសុខាភិបាលជូនប្រជាពលរដ្ឋ
- ការបន្តវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ជួសជុលឃ្លាំងសម្ភារៈចំនួន២ ដើម្បីធានាបាននូវសុវត្ថិភាព និងគុណភាពឱសថ និងសម្ភារបរិក្ខារ ដែលមានថវិកាចំនួន២ ៩៨០ លានរៀល
- ការបន្តគាំទ្រដល់ប្រតិបត្តិការរបស់មន្ទីរពេទ្យគន្ធបុប្ផា ដោយបន្តផ្តល់ថវិកាចំនួន៤០ ២៥៩ លានរៀល ក្នុងនោះ៖ មូលនិធិជាសាច់ប្រាក់ចំនួន ៦ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ សមមូលនឹងប្រមាណ២៤ ១៥០លានរៀល, ការផ្តល់ជាសម្ភារការិយាល័យ, ការចំណាយបង់ថ្លៃប្រើប្រាស់ទឹក អគ្គិសនី និងចំណាយប្រាក់បៀវត្សជូនបុគ្គលិកក្របខ័ណ្ឌចំនួន១៤០នាក់ សរុបចំនួន ១៦ ១០៩លានរៀល
- បានគ្រោងថវិកាចំនួន២០ ០០០លានរៀល ជា "**មូលនិធិទ្រទ្រង់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា**", បន្ថែមលើថវិកា៤០ ២៥៩លានរៀល ដែលត្រូវផ្តល់ជូនមន្ទីរពេទ្យគន្ធបុប្ផា នៅឆ្នាំ២០១៨, ដើម្បីធានាថា មន្ទីរពេទ្យនេះ នៅតែអាចរក្សាបាននូវស្តង់ដាគុណភាព និងការផ្តល់សេវាព្យាបាល

ដោយឥតគិតថ្លៃដដែល នៅពេលមានការផ្ទេរការគ្រប់គ្រងពីលោក Beat Richner ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលវិញនោះ

- ក្រៅពីថវិកាខាងលើនេះ ថវិកាត្រូវបានវិភាជន៍ជូនដល់មន្ទីរពេទ្យសំខាន់ៗក្នុងរាជធានីភ្នំពេញ ដូចជា មន្ទីរពេទ្យកុមារជាតិ, មន្ទីរពេទ្យព្រះអង្គឌួង, មន្ទីរពេទ្យព្រះកុសុមៈ, និងទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាលជាដើម សម្រាប់ការបន្តជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងចំណាយប្រតិបត្តិការ ដែលមានថវិកាសរុបចំនួន៤៧ ០៧២លានរៀល។

លើសពីនេះ កញ្ចប់ថវិកាត្រូវបានវិភាជជូនក្រសួងសុខាភិបាល សម្រាប់អនុវត្តគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមាន៖

- *ការគាំទ្រដល់ការពង្រីកមូលនិធិសមធម៌ សម្រាប់ពង្រីកការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃជូនដល់កម្មកររោងចក្រ (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) ដែលមិនទាន់ស្ថិតក្រោមបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ឱ្យទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌ដោយឥតគិតថ្លៃ ដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ,*
- *ការគាំទ្រដល់ការឧបត្ថម្ភមាតុភាព ដល់កម្មកររោងចក្រ ដោយបើកផ្តល់ថវិកាចំនួន៤០០ ០០០ រៀល ចំពោះការសម្រាលកូនមួយ និងថវិកាចំនួន៨០០ ០០០រៀល ចំពោះការសម្រាលបានកូនភ្លោះពីរ និងថវិកាចំនួន១ ២០០ ០០០រៀល បើសម្រាលបានកូនភ្លោះបី។*

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ត្រូវបានគ្រោងថវិកាចំនួន៨៨៧ ៣១២លានរៀល មានសមាមាត្រស្មើនឹង៥,៨%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,៩០%នៃ ផ.ស.ស. គឺមានកំណើន១៨,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានចំនួន៩១,៤%នៃចំណាយសរុបរបស់ក្រសួង និងមានកំណើន១៩,៧%ធៀបច្បាប់ឆ្នាំ២០១៧។ ចំណែកឯចំណាយមិនមែនបន្ទុកបុគ្គលិកដែល មានចំនួន៨,៦%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៧៦ ៧៥២លានរៀល មានកំណើន៥,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាពិសេសលើ៖

- ការឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន មានថវិកាចំនួន៤ ០០០លានរៀល និងការផ្តល់ថវិកាគាំទ្រដល់មជ្ឈមណ្ឌលជាតិថែទាំមនុស្សចាស់ នៅក្រាំងធ្នង់ មានថវិកាចំនួន១ ០០០លានរៀល ព្រមទាំងការផ្តល់ថវិកាគាំទ្រដល់មជ្ឈមណ្ឌលជនវិបល្លាសស្មារតីមានចំនួន១ ០៥០លានរៀល
- ការបង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ស្របតាមអនុក្រឹតលេខ ១៣៧ អនក្រ.បក.ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះ ជនពិការក្រីក្រនៅតាមសហគមន៍ ដោយអនុវត្តសាកល្បងនៅខេត្តមួយចំនួន ដើម្បីផ្តល់សេវាជូនជនពិការ ដែលមានថវិកាចំនួន២ ១០០លានរៀល
- ការបន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ នៅតាមសហគមន៍ចំនួន ១ ៥០០លានរៀល

- ការផ្តល់ថវិកាជាឧបត្ថម្ភធនចំនួន១ ៦៥៨លានរៀល ដើម្បីដំណើរការរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ដែលនៅក្នុងពេលកន្លងមកទទួលបាននូវការគាំទ្រពីគណៈកម្មការអន្តរជាតិ នៃកាកបាទក្រហម (ICRC)
- ការផ្តល់ថវិកាចំនួន៦០០លានរៀល ដើម្បីផ្តល់ថវិកាឧបត្ថម្ភដល់មជ្ឈមណ្ឌលចំនួន៣ ក្នុងនោះ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មគៀនឃ្លាំងនៅរាជធានីភ្នំពេញ, មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម នៅក្នុងខេត្តព្រៃវែង និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម នៅក្នុងខេត្តក្រចេះ ដែលនៅក្នុងពេលកន្លងមក មជ្ឈមណ្ឌលទាំង៣ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយអង្គការអតីតយុទ្ធជនអន្តរជាតិ (VIC)។

- **ក្រសួងបរិស្ថាន** ត្រូវបានគ្រោងថវិកាចំនួន៨២ ៣៥៧លានរៀល មានសមាមាត្រស្មើនឹង០,៥% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវដា០,០៨%នៃ ផ.ស.ស. គឺមានកំណើន៣៣,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៤២,០%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៣៤ ៥៧២លានរៀល មានកំណើន១៦,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាពិសេសលើការបន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ តាមរយៈ៖
  - ការបន្តបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន៥០០បង្គោល ក្នុងនោះ ដែនជម្រកសត្វព្រៃតាតៃចំនួន២០០បង្គោល នៅខេត្តកោះកុង, ដែនជម្រកសត្វស្រែពកចំនួន១០០បង្គោល, ដែនជម្រកសត្វព្រៃកែវសីមាចំនួន១០០បង្គោល និងដែនជម្រកសត្វព្រៃភ្នំព្រេច១០០បង្គោល នៅខេត្តមណ្ឌលគិរី ដែលមានថវិកាចំនួន៨៣៤លានរៀល
  - ការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈស្តីពីតួនាទី និងការកិច្ចរបស់ឧទ្យានុរក្ស និងមន្ត្រីនគរបាលយុត្តធម៌សម្រាប់ការងារការពារព្រៃឈើ ដែលមានថវិកាចំនួន២០០លានរៀល
  - ការបន្តឧបត្ថម្ភថវិកាជូនសហគមន៍ការពារព្រៃឈើចំនួន១០បន្ថែមទៀតតាមតំបន់អភិរក្ស ដើម្បីជួយដល់ពលរដ្ឋក្នុងដែនការពារព្រៃអភិរក្សបង្កើតមុខរបរ ដែលអាចមានសមត្ថភាពរកប្រាក់ចំណូល ក្រៅពីព្រៃឈើ ដែលមានថវិកាចំនួន១ ០០០លានរៀល
  - ការផ្តល់ប្រាក់ឧបត្ថម្ភដល់ឧទ្យានុរក្សចំនួន១ ២២១នាក់ សម្រាប់ប្រតិបត្តិការល្បាតការពារបរិស្ថាន និងព្រៃឈើ រួមទាំងនៅតាមបណ្តាកោះផងដែរ មានថវិកាចំនួន១ ៤៨៨លានរៀល
  - ការផ្តល់ថវិកាចំនួន៣ ៣៣៩លានរៀល សម្រាប់ទិញសម្ភារៈមន្ទីរពិសោធន៍ ដើម្បីពង្រឹង និងពង្រីកសមត្ថភាពមន្ទីរពិសោធន៍ ក្នុងការវិភាគជាតិពុលក្នុងទឹក ដី និងខ្យល់ ព្រមទាំងថវិកាចំនួន១៤០លានរៀល សម្រាប់ទិញឧបករណ៍ Drone សម្រាប់បម្រើឱ្យការងារថតរូបភាព និងតាមដានផ្ទៃដីព្រៃឈើដែលកំពុងទទួលបាននូវការអភិរក្ស។

**ក.២.៤-វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងថវិកាចំនួន១ ៣៧៩ ១៨៥លានរៀល មានសមាមាត្រស្មើនឹង ៩,១%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវដា១,៣៩%នៃ ផ.ស.ស. និងមានកំណើន៥,៦%ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ក្នុងនោះ៖

- **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានគ្រោងថវិកាចំនួន២៤៥ ០០៩លានរៀល មាន

សមាមាត្រស្មើនឹង១,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,២៥%នៃ ផ.ស.ស. មានកំណើន១១,៣% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៥០,៣%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន១២៣ ១៩២លានរៀល មានកំណើន៣,៥%ធៀបនឹងច្បាប់ឆ្នាំ ២០១៧ និង ត្រូវបានផ្តោតជាសំខាន់លើ៖

- កម្មវិធីបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មទទួលបានកំណើនថវិកាចំនួន៧៦១លានរៀលបន្ថែមទៀត, គឺកើនដល់ចំនួន២២ ៤៤៤លានរៀល
- កម្មវិធីជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ទទួលបានកំណើនថវិកាបន្ថែម៧៤២លានរៀល, គឺកើនដល់១៣ ៣៥៣លានរៀល
- កម្មវិធីការគ្រប់គ្រងធនធានដីលផលប្រកបដោយនិរន្តរភាព ដោយផ្តល់ទម្ងន់លើការការពារអភិរក្សធនធានដីលផល និងជំរុញវារីវប្បកម្ម ទទួលបានកំណើនថវិកាបន្ថែមចំនួន៨២៨លានរៀល, គឺកើនដល់១២ ២៥៨លានរៀល
- កម្មវិធីការគ្រប់ធនធានព្រៃឈើ និងសត្វព្រៃ ប្រកបដោយនិរន្តរភាព ដោយបន្តយកចិត្តទុក-ដាក់លើការការពារអភិរក្ស, ការបង្កើនការចូលរួមពីសហគមន៍, និងការស្តារព្រៃឈើឡើងវិញ ទទួលបានថវិកាចំនួន១២ ១៣៩លានរៀល
- កម្មវិធីពង្រឹងស្ថាប័ន និងបង្កើនប្រសិទ្ធភាពសេវាគាំទ្រទូទៅ ក្នុងការសម្របសម្រួលការងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងការលើកកម្ពស់ធនធានមនុស្ស ទទួលបានកំណើនថវិកាបន្ថែម៥៨៩លានរៀល, គឺកើនឡើងដល់ចំនួន២២ ៦០៦លានរៀល។

*ទន្ទឹមនឹងថវិកាចំណាយចរន្ត, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ទទួលបានថវិកាគម្រោងវិនិយោគ ផ្តាល់ចំនួន៤០ ០០០លានរៀល សម្រាប់ជំរុញផលិតកម្មស្បៀង ព្រមទាំងកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធកសិកម្ម។*

- **ក្រសួងសាធារណការ និងដឹកជញ្ជូន** ត្រូវបានគ្រោងថវិកាចំនួន៣៩៩ ៤៤៤លានរៀល មានសមាមាត្រស្មើនឹង២,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,៤០%នៃផ.ស.ស. មានកំណើន២,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៧៩,០%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន៣១៥ ៦៨០លានរៀល មានកំណើន១,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាសំខាន់លើការជួសជុល និងថែទាំផ្លូវ ដែលមានថវិកាចំនួន២៨០ ០០០លានរៀល។ ទន្ទឹមនឹងថវិកាចំណាយចរន្ត, ក្រសួងទទួលបានថវិកាគម្រោងវិនិយោគផ្តាល់ចំនួន៥៤០ ០០០លានរៀល សម្រាប់៖

- ជំរុញការស្តាបនាផ្លូវ និងស្ពានទូទាំងប្រទេស ដោយការបង្កើនថវិកាគម្រោងវិនិយោគផ្តាល់ពីចំនួន៣៩៥ ០០០លានរៀល ក្នុងឆ្នាំ២០១៧ ដល់៤៤០ ០០០លានរៀល ក្នុងឆ្នាំ២០១៨
- ជំរុញការស្តាបនាផ្លូវរថភ្លើងខ្សែភាគខាងជើង ដោយបន្តវិភាជន៍ថវិកាចំនួន៨០ ០០០លានរៀល និងជំរុញផែនការស្តាបនាកំពង់ផែទន្លេ ដោយបន្តវិភាជន៍ថវិកាចំនួន២០ ០០០លានរៀល។

- **ក្រសួងអភិវឌ្ឍន៍ជនបទ** ត្រូវបានគ្រោងថវិកាចំនួន១៦៩ ១៣៧លានរៀល មានសមាមាត្រស្មើនឹង ១,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,១៧%នៃ ផ.ស.ស. មានកំណើន៥,២%ធៀបនឹងច្បាប់ឆ្នាំ

២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៨៣,៥%នៃចំណាយសរុបរបស់ក្រសួង ត្រូវបានគ្រោងថវិកាចំនួន១៤១ ២៩៥លានរៀល មានកំណើន៣,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាសំខាន់លើ៖

- ការបន្តផ្តល់ថវិកាលើការថែទាំផ្លូវ និងស្ពានជនបទ ដែលត្រូវបានស្ថាបនារួចហើយ ដោយបង្កើនថវិកាពីចំនួន៧៨ ១០០លានរៀល នៅឆ្នាំ២០១៧ ទៅដល់៨២ ០០០លានរៀលសម្រាប់ឆ្នាំ២០១៨
- ការបន្តលើកកម្ពស់អនាម័យជនបទដោយរក្សាកញ្ចប់ថវិកា៤ ០៤៧លានរៀលសម្រាប់សាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋនៅទីជនបទ
- ការបន្តស្តារស្រះ ជីកស្រះ និងអណ្តូង ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត ដោយមានការវិភាជថវិកា៤ ៤៧៥លានរៀល នៅថ្នាក់កណ្តាល និង១ ២៥០លានរៀល នៅថ្នាក់ខេត្ត
- ការផ្តល់ថវិកាសម្រាប់សកម្មភាពបណ្តុះបណ្តាលជំនាញ តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលអភិវឌ្ឍន៍ជនបទកម្ពុជាកូរ៉េនៅខេត្តកំពង់ស្ពឺ (ចលនាភូមិថ្មី) ដែលមានថវិកាចំនួន២៨០ លានរៀល។

ទន្ទឹមនឹងថវិកាចំណាយចរន្ត, ក្រសួងអភិវឌ្ឍន៍ជនបទក៏ទទួលបានថវិកាគម្រោងវិនិយោគផ្តាល់សម្រាប់បន្តស្ថាបនាផ្លូវ ស្ពានជនបទ ដើម្បីបង្កើនការតភ្ជាប់នៅតាមតំបន់ជនបទ ដែលមានថវិកាចំនួន១៧០ ០០០ លានរៀល, មានកំណើនចំនួន ២០ ០០០លានរៀល ធៀបនឹងឆ្នាំ២០១៧។

- **ក្រសួងធនធានទឹកនិងឧតុនិយម** ត្រូវបានគ្រោងថវិកាចំនួន១៣០ ១៧៥លានរៀល មានសមាមាត្រស្មើនឹង០,៩%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា០,១៣%នៃ ផ.ស.ស. មានកំណើន១០,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងនោះ ចំណាយមិនមែនបន្ទុកបុគ្គលិកដែលមានចំនួន៧៩,២%នៃចំណាយសរុបរបស់ក្រសួង, ត្រូវបានគ្រោងថវិកាចំនួន១០៣ ០៦៦លានរៀល មានកំណើន៨,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និងត្រូវបានផ្តោតជាសំខាន់លើ៖

- ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ ដោយមានកំណើនថវិកា ពីចំនួន៥៧ ០០០លានរៀល ក្នុងឆ្នាំ២០១៧ ដល់៦២ ០០០លានរៀល ក្នុងឆ្នាំ២០១៨
- ការបន្តគាំទ្រដល់សកម្មភាពបូមទឹកសង្គ្រោះបន្ទាន់ ដោយបន្តផ្តល់ថវិកាចំនួន៣ ៧០០លានរៀល សម្រាប់ទិញប្រេងអន្តរាគមន៍បូមទឹកសង្គ្រោះបន្ទាន់ នៅពេលមានគ្រោះធម្មជាតិ និងផ្តល់ថវិកាចំនួន៨០០ លានរៀល សម្រាប់ជួសជុលម៉ាស៊ីនបូមទឹក និងស្ថានីយបូមទឹក
- ការបន្តគាំទ្រដល់ការអនុវត្តសកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប ដោយរក្សាការវិភាជថវិកាចំនួន៤ ០០០លានរៀល សម្រាប់សិក្សាស្រាវជ្រាវសក្តានុពល និងបញ្ហាប្រឈមរបស់បឹងទន្លេសាប, បោះបង្គោលកំណត់តំបន់ការពារព្រៃលិចទឹក និងបង្ក្រាបបទល្មើសកាប់ទន្ទ្រានព្រៃលិចទឹកយកដី និងបទល្មើសនេសាទ
- ការបន្តគាំទ្រដល់ការអនុវត្តសកម្មភាពការងាររបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដោយផ្តល់ថវិកាចំនួន២ ៦០០លានរៀល ក្នុងនោះ សម្រាប់ធ្វើការងារស្រាវជ្រាវ និងវិភាគទិន្នន័យ

ព័ត៌មានអាងទន្លេមេគង្គកម្ពុជា, ការងារសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការ-អនុវត្តគម្រោងកម្មវិធីនានា ក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគីចំនួន១ ៨០០ លានរៀល។

ទន្ទឹមនឹងថវិកាចំណាយចរន្ត, ក្រសួងធនធានទឹកនិងឧតុនិយមទទួលបានថវិកាគម្រោងវិនិយោគផ្ទាល់ដើម្បីបន្តស្ថាបនាប្រព័ន្ធធារាសាស្ត្រ មានថវិកាចំនួន១៥៥ ០០០លានរៀល, ក្នុងនោះ សម្រាប់អនុវត្តគម្រោងទំនប់ និងអាងស្តុកទឹកក្នុងតំបន់រដ្ឋបាលខេត្តត្បូងឃ្មុំ មានថវិកាចំនួន១៥ ០០០លានរៀល និងជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធតាមបណ្តាខេត្តមួយចំនួនទៀត ដែលមានថវិកាចំនួន១៤០ ០០០លានរៀល។

នៅក្នុងវិស័យសេដ្ឋកិច្ចនេះ ចំណាយចរន្តគឺមានទំហំតូច ក៏ប៉ុន្តែ ក្រសួងទាំង៤ ខាងលើ គឺជាស្ថាប័នដែលទទួលបានចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសច្រើនជាងគេ សម្រាប់កសាងហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវ ស្ពាន និង ប្រព័ន្ធធារាសាស្ត្រ។

**ក.២.៥-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា** ត្រូវបានគ្រោងចំនួន២ ០២២ ៣៤២លានរៀល មានសមាមាត្រស្មើនឹង១៣,៣%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ហើយត្រូវជា២,០៤%នៃ ផ.ស.ស.។ ចំណាយនេះត្រូវបានត្រៀមបម្រុងសម្រាប់ការផ្ទេរទៅមុខសញ្ញាមួយចំនួន ដូចខាងក្រោម៖

- ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ៧៣៧ ៨៧០លានរៀល
- ការសងការប្រាក់៣៨៧ ៤៨១លានរៀល
- ចំណាយចរន្តក្នុងការអនុវត្តគម្រោងចំនួន២២០ ៤៨៧លានរៀល
- ចំណាយអនុវត្តគម្រោងសាកល្បងយន្តការគ្រប់គ្រង **"មូលនិធិអភិវឌ្ឍន៍ជំនាញ"** ចំនួន ២០ ០០០លានរៀល
- មូលនិធិអភិរក្ស និងអភិវឌ្ឍន៍តំបន់អង្គរ ចំនួន៥៣ ០០០លានរៀល
- ត្រៀមជាបណ្តើរៗសម្រាប់ការរៀបចំ Sea Game ចំនួន៣០ ០០០លានរៀល
- មុខសញ្ញាផ្សេងៗទៀត ដូចជា៖ គ្រោះមហន្តរាយធម្មជាតិ, ការងារអធិបតេយ្យ, ស្បៀងបម្រុងកម្ពុជា និងការត្រៀមបម្រុងសម្រាប់ចំណាយអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច-សេដ្ឋកិច្ចជាដើម។

**ខ- <u>គម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ</u>**

ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ ឆ្នាំ (២០១៧-២០១៩) ចំណាយមូលធនថ្នាក់ជាតិឆ្នាំ២០១៨ ត្រូវបានគ្រោងចំនួន៨ ២១០ ១៣២លានរៀល មានសមាមាត្រស្មើនឹង ៣៥,០%នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា៨,២៨%នៃ ផ.ស.ស. មានកំណើន១៥,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ គម្រោងចំណាយមូលធននេះ ត្រូវបានបែងចែកដូចខាងក្រោម៖

- **គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន ២ ៩២៥ ៨០០លានរៀល ត្រូវជា២,៩៥%នៃ ផ.ស.ស. មានកំណើន៣៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ គម្រោងវិនិយោគនេះត្រូវបានបែងចែកជា៖

▪ គម្រោងវិនិយោគផ្ទាល់ចំនួន២ ០៧៥ ៨០០លានរៀល ដែលក្នុងនោះ បែងចែកជូន (១)-ក្រសួងអភិវឌ្ឍន៍ជនបទចំនួន១៧០ ០០០លានរៀល, (២)-ក្រសួងសាធារណការនិងដឹកជញ្ជូន

ចំនួន៥៤០ ០០០លានរៀល ក្នុងនោះ៨០ ០០០លានរៀល សម្រាប់សាងសង់ ផ្លូវថ្នល់ និង ២០ ០០០លានរៀល សម្រាប់សាងសង់កំពង់ផែទន្លេ, (៣)-ក្រសួងធនធានទឹក និងឧតុនិយម ចំនួន១៥៥ ០០០លានរៀល, (៤)-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៤០ ០០០ លានរៀល, (៥)-ក្រសួងអប់រំ យុវជន និងកីឡាចំនួន៤២០ ០០០លានរៀល, (៦)-ក្រសួង មហាផ្ទៃចំនួន៥៤ ៦០០លានរៀល, (៧)-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន១៦ ៥០០លានរៀល, (៨)- ចំណាយសម្រាប់ក្រសួង-ស្ថាប័នផ្សេងៗចំនួន១៧៩ ៧០០ លានរៀល, (៩)-ចំណាយសម្រាប់ទូទាត់គម្រោងឆ្នាំចាស់២៥០ ០០០លានរៀល និងចំណាយ ត្រៀមបម្រុងរបស់រាជរដ្ឋាភិបាល២០០ ០០០លានរៀល និងសាច់ប្រាក់សម្រាប់ពលកម្ម (Cash for Works) ចំនួន៧១ ០០០លានរៀល

- ថវិកាបដិភាគវិនិយោគគម្រោងហិរញ្ញប្បទានក្រៅប្រទេសចំនួន៦០០ ០០០លានរៀល,
- គម្រោងមូលនិធិទ្រទ្រង់ថវិកាចំនួន២៥០ ០០០លានរៀល ត្រូវជា០,២៥%នៃ ផ.ស.ស.។

- **ចំណាយលើការទូទាត់ប្រាក់ខ្ចី**ចំនួន៧៣៧ ៣៩៣លានរៀល មានកំណើន១០,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ត្រូវជា០,៧៤%នៃ ផ.ស.ស. សម្រាប់រំលស់បំណុលក្រៅប្រទេស

- **គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងចំនួន៤ ៥៤៦ ៩៣៩ លានរៀល ត្រូវជា៤,៥៩%នៃ ផ.ស.ស. មានកំណើន៦,១%ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៧។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និងមានទំហំកាន់តែធំឡើងៗ សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈដែលចេះតែរំកិលពីឆ្នាំមុនៗមក និងត្រូវរង់ចាំចុះហត្ថលេខារហូតដល់ជាង១ ៨៩៣ លានអេសដេអ៊ែរ ក្នុងវិស័យអាទិភាព តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង ជាពិសេសការសម្រេចឱ្យបាននូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិច១%ក្នុងមួយឆ្នាំ។ កំណើននៃសេចក្តីត្រូវការឥណទានសម្បទាននេះ គឺមួយផ្នែកធំបណ្តាលមកពីនិន្នាការកាន់តែច្រើនរបស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់នូវកម្ចីឥណទានសម្បទាន ជំនួសឱ្យហិរញ្ញប្បទានឥតសំណងដែលខ្លួនធ្លាប់ផ្តល់កន្លងមកដោយសារការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ច ក្នុងខណៈដែលកម្ពុជាកាន់តែមានសេចក្តីត្រូវការនៅក្នុងវិនិយោគសាធារណៈកាន់តែច្រើនថែមទៀត ស្របទៅតាមការវិវឌ្ឍឈានឡើងនៃសេដ្ឋកិច្ចរបស់ខ្លួន។ ជារួម ការបង្កើនទំហំនៃការខ្ចីនេះនឹងមិនបង្កើតជាបន្ទុកបំណុលវ៉ែ្លកវដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះសមត្ថភាពសងរបស់កម្ពុជាក៏ខ្ពស់ជាងមុនដែរ។ ជាក់ស្តែង បើផ្អែកទៅលើលទ្ធផលនៃការវិភាគចីរភាពបំណុលដោយឈរលើមូលដ្ឋានសន្មតិនៃការខ្ចីថ្មីបន្ថែម សម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ គឺបានបង្ហាញថា អនុបាតបំណុលគន្លឹះទាំង៥របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។ ដូចនេះផ្អែកតាមបទដ្ឋានបច្ចេកទេសអន្តរជាតិគឺកម្ពុជាអាចបង្កើនពិដាននៃការខ្ចីថ្មីរហូតដល់១ ០០០លានអេសដេអ៊ែរបាននៅឆ្នាំ២០១៨ ដោយមិនមានការប៉ះពាល់ដល់ចីរភាព បំណុលសាធារណៈឡើយ ពោលគឺស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមាន**ចីរភាព** និង**ហានិភ័យកម្រិតទាប** នៅក្នុងរយៈពេលមធ្យមដដែល។

ម្យ៉ាងវិញទៀត ការបង្កើនពិដានៃការខ្ចីនេះ គឺគ្រាន់តែជាការបំពេញនូវលទ្ធខ័ណ្ឌនីត្យានុកូលភាពក្នុងការខ្ចីប៉ុណ្ណោះ ក្នុងខណៈដែលការចុះហត្ថលេខាខ្ចីប្រាក់ជាក់ស្តែង អាចទាបជាងនេះដូចការអនុវត្តនៅបណ្តាឆ្នាំកន្លងទៅ។ ដោយឡែក ចំពោះការដកសាច់ប្រាក់សម្រាប់គម្រោងនីមួយៗវិញ គឺមានរយៈពេលជាមធ្យមប្រមាណពី៣ឆ្នាំ ទៅ៥ឆ្នាំឯណោះ។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេបានក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ **នៅក្នុងចំណោមគម្រោងសរុបចំនួន២៦ ដែលមានលក្ខណៈសម្បត្តិរួចរាល់ លើបេក្ខភាពគម្រោងដែលត្រូវរង់ចាំចុះហត្ថលេខាសរុបចំនួន៣១ គម្រោង ដែលមានទឹកប្រាក់សរុបសមមូលស្មើនឹង១ ៨៩៣លានអេសដេអ៊ែរ** ដែលរួមមាន៖ ធនាគារពិភពលោកចំនួន៤គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន១០គម្រោង សាធារណរដ្ឋប្រជាមានិតចិនចំនួន៤គម្រោង ប្រទេសជប៉ុនចំនួន២គម្រោង សាធារណរដ្ឋកូរ៉េចំនួន២គម្រោង សាធារណរដ្ឋបារាំងចំនួន២គម្រោង និងសាធារណរដ្ឋឥណ្ឌាចំនួន២គម្រោង **ក្នុងគោលដៅទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតជែង និងផលិតភាពសេដ្ឋកិច្ច ដែលរួមមាន៖**

- **វិស័យថាមពល៖** គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ជំហានទី២ គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញជំហានទី២ ដំណាក់កាលទី២កម្មវិធីថាមពលដើរដោយព្រះអាទិត្យសម្រាប់ការតភ្ជាប់ជាមួយថាមពលអគ្គិសនី គម្រោងសាងសង់ខ្សែបណ្តាញថាមពលអគ្គិសនីតង់ស្យុង ១១៥គីឡូវ៉ុល ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះតម្លៃអគ្គិសនីនៅជនបទ ដើម្បីរួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង

- **វិស័យធារាសាស្ត្រ៖** គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់ខេត្តកំពង់ស្ពឺ គម្រោងអភិវឌ្ឍន៍អាងទឹករក្សាខេត្តព្រះវិហារ គម្រោងអភិវឌ្ឍន៍វិស័យធារាសាស្ត្រនិងកសិកម្មដំណាក់កាលទី២

- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** គម្រោងកែលម្អផ្លូវជាតិលេខ៣ លេខ៤ លេខ៥ គម្រោងអភិវឌ្ឍន៍ផ្លូវពីសំឡូត វាលវែង ទៅដល់កោះកុង គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី៣ ពីផ្លូវជាតិលេខ៥ ទៅផ្លូវជាតិលេខ១ និងគម្រោងកែលម្អការថែទាំផ្លូវ។ល។ និង

- **វិស័យអាទិភាពផ្សេងទៀត៖** គម្រោងក្នុងវិស័យកសិកម្ម សុខាភិបាល ទេសចរណ៍ ការផ្គត់ផ្គង់ទឹកស្អាត និងអប់រំ។

## ២.៤-គម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៨

គម្រោងចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងដោយឈរលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ព្រមទាំងរាល់ក្របខ័ណ្ឌគតិយុត្តដែលមានជាធរមាន។ គម្រោងចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់) ឆ្នាំ ២០១៨ ត្រូវបានគ្រោងដូចខាងក្រោម៖

| សូចនាករថវិកាថ្នាក់ក្រោមជាតិ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលចរន្ត (% ផ.ស.ស.) | ១,០២ | ១,០២ | ១,០៨ | **០,៩៦** |
| ចំណាយសរុប (% ផ.ស.ស.) | ១,៦៦ | ១,៧១ | ១,៧៩ | **១,៧០** |
| ចំណាយចរន្ត (% ផ.ស.ស.) | ១,៤៧ | ១,៤៨ | ១,៥៥ | **១,៤៨** |
| ចំណាយមូលធន(% ផ.ស.ស.) | ០,១៩ | ០,២៣ | ០,២៤ | **០,២២** |

- **ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក** ត្រូវបានគ្រោងចំនួន៩៤៦ ៨០៤លានរៀល មានសមាមាត្រស្មើនឹង៥,១%នៃចំណូលចរន្តថវិការដ្ឋ, ត្រូវដា០,៩៦%នៃ ផ.ស.ស. មានការថយចុះ-២,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះរួមមាន៖
  - ចំណូលសារពើពន្ធត្រូវបានគ្រោងចំនួន៩១០ ៤៤៣លានរៀល ត្រូវដា០,៩២%នៃ ផ.ស.ស. មានការថយចុះ-១,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧
  - ចំណូលមិនមែនសារពើពន្ធត្រូវបានគ្រោងចំនួន៣៦ ៣៦១លានរៀលត្រូវដា០,០៤%នៃផ.ស.ស. មានការថយចុះ-១១,៨% ធៀបនឹងច្បាប់ឆ្នាំ២០១៧។
- **ចំណាយសរុបថវិការាជធានី-ខេត្ត ក្រុង-ស្រុក និងឃុំ-សង្កាត់** ត្រូវបានគ្រោងចំនួន១ ៦៨៤ ៦៧៤ លានរៀល មានសមាមាត្រស្មើនឹង៦,៩%នៃចំណាយថវិការដ្ឋសរុប, ត្រូវដា១,៧០%នៃ ផ.ស.ស. មានកំណើន ៤,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

**ក. ចំណាយចរន្ត** ត្រូវបានគ្រោងចំនួន១ ៤៦៥ ១២២លានរៀល មានសមាមាត្រស្មើនឹង៩,២%នៃចំណាយចរន្តថវិការដ្ឋសរុប ត្រូវដា១,៤៨%នៃ ផ.ស.ស. មានកំណើន៥,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការកើនឡើងនេះ បណ្តាលមកពីមានការដំឡើងប្រាក់បំណាច់ជូនដល់ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងមន្ត្រីភូមិ ដោយចាប់អនុវត្តពីខែ មេសា ឆ្នាំ២០១៨ ដែលក្នុងនោះ៖

- **ក្រុមប្រឹក្សារាជធានី-ខេត្ត**
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី១ ២១០ ០០០នៅឆ្នាំ២០១៧ ដល់១ ៣៦០ ០០០រៀល នៅឆ្នាំ ២០១៨ និង
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី៩៧០ ០០០រៀល នៅឆ្នាំ២០១៧ ដល់១ ០៨៥ ០០០រៀល នៅឆ្នាំ ២០១៨។
- **ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖**
  - ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី៩៣៥ ០០០រៀល នៅឆ្នាំ២០១៧ ដល់១ ០៧៥ ០០០រៀល នៅឆ្នាំ ២០១៨ និង
  - ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី៧៥០ ០០០រៀល នៅឆ្នាំ២០១៧ ដល់៨៦០ ០០០រៀល នៅឆ្នាំ ២០១៨។
- **ក្រុមប្រឹក្សាឃុំ សង្កាត់៖**

- ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ នឹងត្រូវបានដំឡើងពី៨៨០ ០០០រៀល នៅឆ្នាំ២០១៧ ដល់ ១ ០៣០ ០០០រៀល នៅឆ្នាំ២០១៨
- ប្រាក់បំណាច់ដំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវបានដំឡើងពី៦៥០ ០០០ រៀល នៅឆ្នាំ២០១៧ ដល់៨០០ ០០០រៀល នៅឆ្នាំ២០១៨
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបានដំឡើងពី៥៧០ ០០០រៀល នៅឆ្នាំ២០១៧ ដល់៧០០ ០០០រៀល នៅឆ្នាំ២០១៨
- ប្រាក់បំណាច់មេភូមិ នឹងត្រូវបានដំឡើងពី២២៥ ០០០រៀល នៅឆ្នាំ២០១៧ ដល់២៥០ ០០០រៀល នៅឆ្នាំ២០១៨
- ប្រាក់បំណាច់អនុប្រធានភូមិនឹងត្រូវបានដំឡើងពី១៨០ ០០០រៀល នៅឆ្នាំ២០១៧ ដល់២០០ ០០០រៀល នៅឆ្នាំ២០១៨
- ប្រាក់បំណាច់សមាជិកភូមិនឹងត្រូវបានដំឡើងពី១៦០ ០០០រៀល នៅឆ្នាំ២០១៧ ដល់១៨០ ០០០រៀល នៅឆ្នាំ២០១៨។

**ខ.ចំណាយមូលធន** ត្រូវបានគ្រោងចំនួន២១៩ ៥៥២លានរៀល មានសមាមាត្រ៧%នៃចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវជា០,២២%នៃ ផ.ស.ស.។

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និង ឃុំ-សង្កាត់ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន៧៣៧ ៨៧០លានរៀល ត្រូវជា០,៧៤%នៃ ផ.ស.ស. ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះមានកំណើន១៥,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖ (១)-ឧបត្ថម្ភរាជធានី-ខេត្ត ចំនួន១៤៨ ៨១៤លានរៀល, (២)-ឧបត្ថម្ភក្រុង-ស្រុក ចំនួន១៥៥ ០១៥លានរៀល និង(៣)-ឧបត្ថម្ភមូលនិធិឃុំ-សង្កាត់ ចំនួន៤៣៤ ០៤១លានរៀល។

## ២.៥-អំពីតុល្យភាពរួមនៃថវិកាឆ្នាំ ២០១៨

នៅក្នុងក្របខ័ណ្ឌថវិកាខាងលើ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ២,៤៨%នៃផ.ស.ស. នៅឆ្នាំ២០១៨ នេះ ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលមាន២,៩៨%នៃ ផ.ស.ស.។ ជាលទ្ធផល ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង-៥,៨៤%នៃ ផ.ស.ស. គឺកើនឡើងពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៧ ដែលស្មើនឹង-៥,០៧%នៃ ផ.ស.ស.។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ៤,៥៩%នៃ ផ.ស.ស. និងមូលនិធិទ្រទ្រង់ថវិកាប្រមាណជា០,២៥%នៃ ផ.ស.ស. និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលប្រមាណ ១,០០% នៃ ផ.ស.ស.។

## ៣. បញ្ហាប្រឈម និងវិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

### ៣.១ បញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលបន្តខិតខំជម្នះនូវបញ្ហាលំបាក និងបញ្ហាប្រឈម

មួយចំនួន ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ។ ជាក់ស្តែង រាជរដ្ឋាភិបាលនឹងត្រូវពុះពារជម្នះនូវការលំបាក ដែលកើតចេញពីបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

**ក-ផ្នែកចំណូល**

ទី១-ចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយនៅឡើយ ទោះបីមានការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូលគួរឱ្យកត់សម្គាល់យ៉ាងណាក្តី

ទី២-ការគ្រោងចំណូលសារពើពន្ធត្រូវបានធ្វើឡើងក្នុងសេណារីយ៉ូសុទិដ្ឋិនិយម ដោយឈរលើមូលដ្ឋាននៃកំណើនមួយក្នុងកម្រិតខ្ពស់ក្នុងបណ្តាឆ្នាំកន្លងទៅ ដែលនាំឱ្យការប្រមូលចំណូលឈានទៅកៀកនឹងពិដាននៃសក្តានុពល, ក្នុងខណៈដែលរាជរដ្ឋាភិបាលពុំមានគោលនយោបាយបង្កើតពន្ធថ្មី ឬដំឡើងអត្រាពន្ធ ក្រៅពីការពង្រឹងវិធានការខាងផ្នែករដ្ឋបាល និងអនុលោមភាពពន្ធ ហើយលើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/បរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

ទី៣- បញ្ហាប្រឈមមួយចំនួនដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណូលពន្ធដារ រួមមាន៖ កិច្ចសហការផ្តល់ព័ត៌មានរវាងអន្តរស្ថាប័នមិនបានទាន់ពេល វប្បធម៌នៃការបង់ពន្ធនៅមានកម្រិត អ្នកជាប់ពន្ធមួយចំនួនគេចវេះពន្ធឬមិនសហការជាមួយរដ្ឋបាលសារពើពន្ធ ការរីកដុះដាលនៃអាជីវកម្មតាមប្រព័ន្ធអេឡិកត្រូនិកដែលបង្កជាបញ្ហាស្មុគស្មាញក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធ ការកើនឡើងនៃប្រតិបត្តិការមានការរៀបចំដើម្បីផ្ទេរថ្លៃក្នុងចំណោមបុគ្គលទាក់ទិនដើម្បីចៀសវាងពន្ធ និងកង្វះខាតធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន

ទី៤-ចំណូលពន្ធគយក៏កាន់តែមានការធ្លាក់ចុះច្រើន ដោយសារ៖ (១)-ភាពតូចចង្អៀតនៃមូលដ្ឋានចំណូលគយ, (២)-កំណើនផលិតផលក្នុងស្រុកដំនួសការនាំចូល, (៣)-កំណើននៃការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេង, (៤)កំណើននៃការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (៥)-ការរត់ពន្ធ និងការគេចវេះពន្ធនៅមានវត្តមានខ្លះនៅឡើយ

ទី៦-ការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង-ស្ថាប័នផ្សេងៗគ្នាជាច្រើន នៅជួបបញ្ហាប្រឈមមួយចំនួន ដោយសារ៖ (១)-កិច្ចសហប្រតិបត្តិការនៅមានកម្រិតរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយភាគីឯកជនដែលជាប់កាតព្វកិច្ចបង់ចំណូល, (២)-ត្រូវការពេលវេលាច្រើនថែមទៀត ដើម្បីដំណើរការប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមដានការប្រមូលចំណូលគួរលេខបំណុលនិងប្រព័ន្ធរាយការណ៍តាមព័ត៌មានវិទ្យា, (៣)-បំណុលរ៉ាំរ៉ៃមួយចំនួនមិនទាន់បានដោះស្រាយ ជាពិសេស**បំណុលក្នុងវិស័យទូរគមនាគមន៍**, (៤)-ក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, (៥)-តម្រូវការនៃការត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជាពិសេសបញ្ហាតម្លាភាពនៃការបែងចែក និងប្រើប្រាស់ប្រាក់រង្វាន់ ក្នុងខណៈដែលក្រសួង-ស្ថាប័នមួយចំនួននៃរាជរដ្ឋាភិបាលមិនមានប្រាក់រង្វាន់ ដោយសារមិនមានកាតព្វកិច្ចប្រមូលចំណូល,

ទី៧-ដំណើរចាកចេញពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក៏នឹងធ្វើឱ្យកម្ពុជាបាត់បង់ជាបណ្តើរៗនូវលក្ខណៈសម្បត្តិ ក្នុងការបន្តទទួលបាននូវហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានសម្បទានខ្ពស់ ឬនិយាយតាមមួយបែបទៀតថា ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍជាប្រពៃណីនឹងមានទំហំមិនគ្រប់គ្រាន់ ឆ្លើយតបទៅនឹងតម្រូវការដ៏ធំធេងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ដែលកំពុងបន្តកើនឡើងក្នុងល្បឿនលឿននោះទេ។

**ខ-ផ្នែកចំណាយ**

ទី១- ការកើនឡើងយ៉ាងគំហុកនៃចំណាយបន្ទុកបុគ្គលិក បានដាក់ជាសម្ពាធដល់ចំណាយក្រៅបន្ទុកបុគ្គលិក ជាពិសេសចំពោះចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយ និងការអនុវត្តសកម្មភាពកែទម្រង់គ្រប់វិស័យរបស់រាជរដ្ឋាភិបាល។ ជាងនេះទៅទៀត បរិការណ៍ខាងលើនេះ ក៏បានបង្កើនសម្ពាធទៅលើចំណាយវិនិយោគសាធារណៈផងដែរ ដែលជាបច្ច័យនឹងធ្វើឱ្យមានការប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចជារួម

ទី២- ការឈានឡើងរបស់កម្ពុជាពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក៏កាន់តែធ្វើឱ្យដៃគូទាមទារឱ្យរាជរដ្ឋាភិបាលបង្កើននូវចំណែកទឹកប្រាក់បដិភាគកាន់តែធំទៅៗ ក្នុងខណៈកាតព្វកិច្ចទូទាត់សេវាបំណុលពីគម្រោងទាំងនោះក៏ចេះតែកើនឡើងច្រើនផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលក៏ត្រូវទទួលកាតព្វកិច្ចរ៉ាប់រងចំពោះកម្មវិធីធំៗមួយចំនួន ដែលត្រូវដល់ពេលត្រូវបញ្ចប់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ

ទី៣-កាតព្វកិច្ចទូទាត់ចំពោះគម្រោងចំណាយធំៗដែលមានថវិតពហុឆ្នាំ ទាំងនៅក្នុងក្របខ័ណ្ឌនៃចំណាយថវិកាចរន្ត និងវិនិយោគ បានដាក់ជាសម្ពាធដល់លទ្ធភាពថវិកាក្នុងឆ្នាំ និង

ទី៤-សមត្ថភាពស្ថាប័ននៅមានកម្រិត នៅតែជាបញ្ហាប្រឈម ក្នុងការសម្រេចឱ្យបាននូវការអនុវត្តក្របខ័ណ្ឌថវិកាមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ ទោះបីជាថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តដោយរំពឹងថាអាចជាដំណោះស្រាយដ៏មានស័ក្តិសិទ្ធិភាព ក្នុងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកា និងក្នុងការកំណត់ឱ្យមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ជាងមុនក្នុងការបំពេញភារកិច្ចរបស់អង្គភាពនានានៃក្រសួង-ស្ថាប័ន។

### ៣.២. វិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

ដើម្បីដម្នះបញ្ហាប្រឈមទាំងឡាយ ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកាខាងលើ ប្រកបដោយ-ប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងដាក់ចេញនូវវិធានការទាន់ពេលវេលា ព្រមទាំងនឹងបន្តជំរុញបន្ថែមទៀតការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ពិសេសបន្តជំរុញអនុវត្តនូវគោលនយោបាយកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់សំខាន់ៗ និងចាំបាច់មួយចំនួន ដូចខាងក្រោម៖

**ក- <u>ការពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល</u>**

ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាល ពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬ ដំឡើងពន្ធបន្ថែមដល់ប្រជាជន

និងធុរជន លើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ឬបរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូលពីអនុលោមភាពតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ ជាពិសេសការបន្តអនុវត្តបញ្ចប់ឱ្យមានប្រសិទ្ធភាពនូវ**យុទ្ធសាស្ត្រភៀសគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពនៃកំណើនចំណូល ដូចសម្រេចបាននៅបណ្តាឆ្នាំកន្លងមក ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ៖

**ក.១- ផ្នែកចំណូលគយ និងរដ្ឋាករ** រួមមាន៖

- <u>ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្តោតលើការប្រកាសគយ, ការកំណត់ និងធ្វើ-ចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ</u> តាមរយៈ ៖
    - ការបន្តលើកកម្ពស់អនុលោមភាព នៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយ ទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយ ដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធអត្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេស ជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក
    - ការចុះឃ្លាំមើល និងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនករមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន ជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ
    - ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងធុរជនលើនីតិវិធីគយជាពិសេស កាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត
    - ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការ លើជនសង្ស័យ ឬជនល្មើសដែលមិនរាងចាល
    - ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរូបវន្តលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យ និងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរូបវន្តដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កែន
    - ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការ-លើកកម្ពស់កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយជាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វេភាគី ឬច្រកវៀងខុសច្បាប់

- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជនតាមរូបភាពនៃការចូលរួមផ្តល់ព័ត៌មាន ព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយ តាមរយៈការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស។

- <u>ការបន្តការពង្រឹងយន្តការគាំទ្រ</u> តាមរយៈ៖
  - ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្សៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្ទុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋានដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្យដ្ឋានច្បាស់លាស់ ទាំងយានយន្តឯកជន, យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្នផ្សេងៗ
  - ការកសាង អនុវត្ត និងវាយតម្លៃនូវការអនុវត្តផែនការសកម្មភាព ឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើ (១)-រចនាសម្ព័ន្ធគ្រប់គ្រង, (២)-សមត្ថភាពនិងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)-ការបំពាក់មធ្យោបាយការងារ ទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរូបវន្តផ្សេងទៀតឱ្យបានសមស្របដូចជា៖ មធ្យោបាយប្រជេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយ មានស្នាដៃនិងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម
  - ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូលដោយបន្តផ្សព្វផ្សាយ និងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល, សន្និធិ និងចរាចរចែកចាយផលិតផលតេល-សិលា ជាពិសេសការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,
  - ការបន្តពង្រីកភាពគ្របដណ្តប់ និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិកវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ
  - ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានាសំដៅប៉ះប៉ូវចំណូលគយ ដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលា ជាពិសេស (១)-ការបន្តពិនិត្យលទ្ធភាពកែសម្រួលអត្រាអាករពិសេស (២)-ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស

និងការធ្វើវិចារណកម្ម ការលើកទឹកចិត្តផ្អែកលើឧត្តមានុវត្តក្នុងតំបន់ និង (៣)-ការចាត់វិធានការមុតស្រួចបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

**ក.២- ផ្នែកចំណូលពន្ធដារ រួមមាន៖**

- <u>បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្តោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា</u> តាមរយៈ៖
    - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី
    - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្គូផ្គងព័ត៌មានជាមួយស្ថាប័នផ្សេងៗ
    - ការផ្តល់សេវាជូនអ្នកជាប់ពន្ធធំចំនួន១៥០សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ
    - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment)
    - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យ ឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម
    - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្តានុពលមួយចំនួនដូចជា៖ វិស័យនាំចេញ-នាំចូល, វិស័យទេសចរណ៍ និងវិស័យសំណង់
    - ការបន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរប្លៃ
    - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្តីពីការផ្ទេរប្លៃ (Transfer Pricing) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ
    - ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។
- <u>បន្តការពង្រឹងមុខងារគាំទ្រ</u> តាមរយៈ៖
    - ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន
    - ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្គូផ្គងអាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ

- ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single Sign-on)។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ** រួមមាន៖

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន កត់ត្រា កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន ការទទួលខុសត្រូវច្បាស់លាស់ ការដាក់ទណ្ឌកម្ម សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលកំពុងត្រូវបានរៀបចំ ដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិ ឱ្យគ្រប់ចំនួន និងទាន់ពេលវេលា
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើ-ពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំ និងដាក់ឱ្យអនុវត្តនូវការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណកម្មពាណិជ្ជកម្ម ឱ្យចេញនៅឆ្នាំ ២០១៨

- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

ខ- <u>ការពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណាយ</u>

<u>ខ-១- ការបន្តពង្រឹង និងកែលម្អការរៀបចំថវិកា</u> ដោយ៖

- បន្តបង្កើនសុក្រឹតភាពនៃការព្យាករ និងការកសាងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយថវិកា តាមរយៈការពង្រឹងសមត្ថភាព និងបង្កើនសុក្រឹតភាពនៃការព្យាករចំណូលនិងចំណាយ
- តាមដានជាប្រចាំ អំពីសភាពការណ៍វិវត្តន៍នានា ព្រមទាំងបន្តកសាង និងពង្រឹងសមត្ថភាពមន្ត្រីទាំងក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ទាំងក្នុងក្របខ័ណ្ឌថវិកា ដែលរួមមានទាំងខាងផ្នែកចំណូល និងទាំងខាងផ្នែកចំណាយ សំដៅដាក់ចេញវិធានការដោះស្រាយ និងកែតម្រូវបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ក្នុងករណីមានការចាំបាច់ ឬក្នុងករណីមានវិបត្តិកើតឡើង
- បន្តបង្កើនការឆ្លើយតបនៃថវិកា ទៅនឹងគោលនយោបាយអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា
- បន្តជំរុញ និងលើកកម្ពស់ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសាច់ប្រាក់ ក្នុងគោលដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងធានាបានភាពជឿទុកចិត្តលើថវិកា
- បន្តជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់នានាពាក់ព័ន្ធចំណាយថវិកាថ្នាក់ជាតិ និងការអនុវត្តលទ្ធកម្មសាធារណៈ ក៏ដូចជា សម្រាប់ការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ និងបន្តជំរុញការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌវិមជ្ឈការហិរញ្ញវត្ថុរយៈពេលខ្លីនិងវែង ដើម្បីបន្តរួមចំណែកក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរាជធានី-ខេត្ត ក្រុង-ស្រុក ពិសេសកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ។

<u>ខ-២-ការពង្រឹង និងកែលម្អការអនុវត្តថវិកា</u> តាមរយៈវិធានការសំខាន់ៗ ដូចខាងក្រោម៖

- ក្នុងឆ្នាំ២០១៨ ការជ្រើសរើសក្របខ័ណ្ឌថ្មីសម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល (រួមទាំងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល) យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ត្រូវបានអនុញ្ញាតស្មើចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ដោយផ្អែកលើគោលការណ៍នៃការជ្រើសរើសក្របខ័ណ្ឌចូលថ្មីដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** ផ្តល់ការឯកភាពកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ដោយក្រសួង-ស្ថាប័នណាដែលមានមន្ត្រីចូលនិវត្តន៍ច្រើនជាង១៥០នាក់ អនុញ្ញាតឱ្យរើសក្របខ័ណ្ឌចូលថ្មីចំនួន៥០នាក់, មានមន្ត្រីចូលនិវត្តន៍ចាប់ពី១០១ដល់១៥០នាក់ អនុញ្ញាតឱ្យរើស

ក្របខ័ណ្ឌចូលថ្មីចំនួន៤០នាក់, មានមន្ត្រីចូលនិវត្តន៍ចាប់ពី៦១ដល់១០០នាក់ អនុញ្ញាតឱ្យរើសក្របខ័ណ្ឌចូលថ្មីចំនួន៣០នាក់, មានមន្ត្រីចូលនិវត្តន៍ចាប់ពី២០ដល់៦០នាក់ អនុញ្ញាតឱ្យរើសក្របខ័ណ្ឌចូលថ្មីចំនួន២០នាក់ និងមានមន្ត្រីចូលនិវត្តន៍ក្រោម២០នាក់ អនុញ្ញាតឱ្យរើសក្របខ័ណ្ឌចូលថ្មីយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្ត។ ការជ្រើសរើសមន្ត្រីរាជការបន្ថែមដើម្បីបម្រើការងារសម្រាប់គ្រប់ក្រសួង-ស្ថាប័ន ក៏នឹងត្រូវបានស្នើផ្អាកបណ្តោះអាសន្ន។ ក្រសួង-ស្ថាប័ន អង្គភាព ដែលបង្កើតថ្មី ត្រូវពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់មន្ត្រីរាជការដែលមានស្រាប់ឱ្យអស់លទ្ធភាព ហើយការជ្រើសរើសក្របខ័ណ្ឌថ្មីត្រូវមានលក្ខណៈរឹតត្បិតបំផុតនិងស្ថិតក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានកំណត់

- ការបន្តពង្រឹងការគ្រប់គ្រង និងកែសម្រួលរបបឧបត្ថម្ភនិវត្តជន ជនបាត់បង់សមត្ថភាពការងារពលី មរណៈ និងពិការនៃមន្ត្រីរាជការ កងទ័ព និងនគរបាល ជាពិសេសការឧបត្ថម្ភមួយលើកមុនពេលផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទន្ទឹមនឹងការបន្តពង្រឹងការគ្រប់គ្រងការបើកផ្តល់ប្រាក់ឧបត្ថម្ភទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសតាមរយៈការប្រើប្រាស់យន្តការរបស់បេឡាជាតិសន្តិសុខសង្គម និងប្រព័ន្ធព័ត៌មានវិទ្យា
- ការបង្កើនប្រសិទ្ធភាពចំណាយ តាមរយៈការបន្តកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ ទៅតាមអាទិភាពគោលនយោបាយ ទន្ទឹមនឹងការបន្តលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការបង្កើនតម្លៃនៃលុយ ដើម្បីធានាថា រាល់ចំណាយត្រូវបានធ្វើឡើងដោយមានតម្លាភាព និងគណនេយ្យភាព ក្នុងថ្លៃសមរម្យ និងគុណភាពសមស្របក្នុងបរិមាណដែលត្រូវការជាក់ស្តែង ព្រមទាំងក្នុងពេលវេលាដែលចាំបាច់ត្រូវការប្រើប្រាស់។ ដូច្នេះវិធានការមួយចំនួន អាចនឹងត្រូវដាក់ចេញ ដើម្បីពង្រឹងការគោរពគោលការណ៍ និងវិន័យថវិកា ព្រមទាំងការគោរពម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ព្រមទាំងវិធានការជាក់ស្តែងមួយចំនួនទៀត ដោយប្រទាក់ក្រឡា ជាមួយនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- ការបន្តជំរុញការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ តាមរយៈការផ្ទេរសិទ្ធិអំណាចក្នុងការ-ចាត់ចែងចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅក្រសួង-ស្ថាប័ន និងពីអង្គភាពហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ទៅអង្គភាពអនុវត្តការងារផ្ទាល់នៅតាមក្រសួង-ស្ថាប័ន
- ការបន្តកាត់បន្ថយនីតិវិធីចំណាយ ជាពិសេស បរិបថចំណាយថ្មីសម្រាប់ការអនុវត្តថវិកាកម្មវិធីតាមរយៈការបង្កើនការផ្ទេរពីការត្រួតពិនិត្យមុនចំណាយ ទៅត្រួតពិនិត្យក្រោយចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា (FMIS)
- ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវរាល់វិធានការនិងបទប្បញ្ញត្តិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងតម្លាភាពក្នុងចំណាយសាធារណៈ

- ការបន្តពិនិត្យការស្នើសុំបើកគណនីថ្មីរបស់ក្រសួង-ស្ថាប័ន ដែលនឹងត្រូវបានអនុញ្ញាតសម្រាប់តែការអនុវត្តគម្រោងនានាក្រៅពីកិច្ចប្រតិបត្តិការចំណូល-ចំណាយ ដើម្បីបន្តពង្រឹងគណនីទោលរតនាគារ
- ការបន្តកែលម្អ និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តថវិកា ជាមួយនឹងការកែលម្អការអនុវត្តប្លង់គណនេយ្យថ្មី
- ការបន្តដាក់អនុវត្តប្រព័ន្ធមាតិកាថវិកាថ្មីជាបណ្តើរៗនូវចំណាត់ថ្នាក់ទាំង ៧ រួមមាន ចំណាត់ថ្នាក់សេដ្ឋកិច្ច ភូមិសាស្ត្រ រដ្ឋបាល កម្មវិធី មុខងារ គម្រោង និងប្រភពហិរញ្ញប្បទាន តាមរយៈប្រព័ន្ធគ្រប់គ្រងតាមព័ត៌មានវិទ្យា (FMIS)
- ការបន្តពង្រឹង និងពង្រីកការអនុវត្តការទូទាត់ថវិកា និងការបើកប្រាក់បៀវត្ស តាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារ
- ការបន្តអនុវត្តវិធានការមុឺងម៉ាត់មិនអនុញ្ញាតឱ្យមានបុរេប្រទានថវិកាដោយគ្មានឥណទានចំណាយ,
- ការមិនអនុញ្ញាតឱ្យក្រសួង-ស្ថាប័នណាមួយ ចាយថវិកាលើសពីឥណទានដែលអនុញ្ញាតដោយច្បាប់ថវិកាប្រចាំឆ្នាំ
- ការពង្រឹងការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និងលើកកម្ពស់ការអនុវត្តវិធានការរដ្ឋបាល និងវិន័យហិរញ្ញវត្ថុតាមច្បាប់ជាធរមាន។

**គ.<u>ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ ក្នុងនោះមាន</u>៖**

- បន្តអនុវត្តដោយម៉ឺងម៉ាត់នូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ (២០១៦-២០២០) សំដៅផ្សារភ្ជាប់ថវិកាទៅនឹងរចនាសម្ព័ន្ធគោលនយោបាយ, កម្មវិធី និងផែនការសកម្មភាពរបស់ក្រសួងស្ថាប័ន ដោយផ្តោតលើការកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និងអង្គភាពថវិកា ព្រមទាំងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅកាន់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រង់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។ នៅក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវឯកសារយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាឆ្នាំ២០១៧-២០២៥ ដើម្បីកំណត់នូវយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវ ដើម្បីសម្រេចបាននូវប្រព័ន្ធថវិការួមមួយពីថវិកាកម្មវិធី ឆ្ពោះទៅថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្មកម្រិតឆ្នាំ២០២៥ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើការកសាងសមត្ថភាពមន្ត្រីរាជការពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបន្តបំពាក់ស្មារតី ការបង្កើនសុឆន្ទៈ ការលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៅក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ ជាពិសេសការធ្វើស្ថាប័នី-

យកម្មនៃការកែទម្រង់នេះឱ្យក្លាយទៅជាការងារប្រចាំថ្ងៃ ដើម្បីថែរក្សាចីរភាពលទ្ធផលនៃការកែទម្រង់ឱ្យនៅស្ថិតស្ថេរ

- បន្តជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ និងវិធានការកែទម្រង់បៀវត្សសម្រាប់រយៈពេលពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរៀបចំប្រព័ន្ធបៀវត្ស និងរបបតារាងកាលិកផ្សេងទៀតដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាព ធានាសង្គតិភាព និងប្រសិទ្ធភាពនៅក្នុងប្រព័ន្ធ និងក្នុងការគ្រប់គ្រងមន្ត្រីសាធារណៈ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពស្ថាប័នរដ្ឋ និងគុណភាពសេវាសាធារណៈ ដោយធានារក្សាបាននូវចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល
- បន្តជំរុញការអនុវត្តកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសបន្តពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូននូវការផ្ទេរអំណាច ការទទួលខុសត្រូវ មុខងារ និងធនធានពីថ្នាក់ជាតិ ក្នុងគោលដៅសម្រេចបាននូវការកែលម្អសេវាសាធារណៈនៅតាមមូលដ្ឋានប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពផង និងធានាឱ្យមានសង្គតិភាពជាមួយនឹងគោលដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ទន្ទឹមគ្នានឹងពង្រឹងយន្តការសម្របសម្រួលរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្ម នៃទំនាក់ទំនងការងារកែទម្រង់ទាំងបីរបស់រាជរដ្ឋាភិបាលទាំងមូល ដើម្បីអាចឈានទៅសម្រេចបាននូវប្រព័ន្ធអភិបាលកិច្ចមួយ ដែលមានប្រសិទ្ធភាពខ្ពស់ និងបម្រើឱ្យការអភិវឌ្ឍ
- បន្តជំរុញការអនុវត្តការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសការពង្រឹងសមត្ថភាពដឹកនាំជំនាញវិជ្ជាជីវៈ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពក្នុងបុព្វហេតុការពារជាតិ និងបូរណភាពទឹកដី ក៏ដូចជាការធានាសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម ដើម្បីផ្តល់ភាពសុខក្សេមក្សាន្តជូនប្រទេសជាតិ និងប្រជាជន
- បន្តពង្រឹងសមត្ថភាព និងតួនាទីរបស់សវនកម្ម រួមទាំងការងារអធិការកិច្ច ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចនៅក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលនឹងធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនូវការត្រួតពិនិត្យ និងអធិការកិច្ចរបស់ក្រសួងស្ថាប័នមួយចំនួន ដែលមានភាពជាន់គ្នា ឬមានការប្រទាញប្រទង់សមត្ថកិច្ចគ្នា ដើម្បីសន្សំសំចៃថវិកា និងធនធានផង និងមិនឱ្យបង្កការលំបាកដល់អ្នកអនុវត្តដោយសារមានស្តង់ដាច្រើនផង ក៏ដូចជាដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចការនេះកុំ

ឱ្យមានចន្លោះប្រហោង ដោយឥតរវាតពីការអនុវត្តច្បាប់ តែមិនឱ្យក្លាយទៅជាការបង្កើតបន្ទុកដែលរារាំងដល់សកម្មភាពសេដ្ឋកិច្ច ជាពិសេសការធ្វើធុរកិច្ច

- បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេសការបន្តរៀបចំ និងពង្រឹងសមត្ថភាពអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ
- បន្តជានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដូចជា៖ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ, ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ ធានាយុត្តិធម៌សង្គម និងធានាចីរភាពបរិស្ថាន។

## ៤. បទប្បញ្ញត្តិស្តីពីពន្ធដារ

ការកែសម្រួលបទប្បញ្ញត្តិមួយចំនួនស្តីពីពន្ធដារនេះ គឺត្រូវបានធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជួយសម្រាលបន្ទុកជីវភាពរបស់ប្រជាពលរដ្ឋ ពិសេសតាមរយៈការជួយកាត់បន្ថយចំណាយលើសាច់សត្វដែលជាអាហារមូលដ្ឋានចាំបាច់សម្រាប់ចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ
- លើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ កងកម្លាំងប្រដាប់អាវុធនិងកម្មករនិយោជិតថែមមួយកម្រិតទៀត តាមរយៈការសម្រួលឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្សទន្ទឹមនឹងការគិតគូររបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការ ឱ្យបានជាង១លានរៀល និងការដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងឱ្យបានដល់១៧០ដុល្លារអាមេរិក (ប្រមាណ៦៨០ ០០០រៀល) នៅឆ្នាំ២០១៨
- តម្រូវការជាចាំបាច់នូវបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ និងជានាបាននូវប្រសិទ្ធភាព និងតម្លាភាពដល់ការអនុវត្តកិច្ចព្រមព្រៀងប្រេងកាតរវាងរាជរដ្ឋាភិបាលជាមួយប្រតិបត្តិករដែលធ្វើប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ "A" ព្រមទាំងជំរុញឱ្យមានប្រតិបត្តិការប្រេងកាតឬធនធានរ៉ែនៅក្នុងតំបន់ដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្របតាមគោលបំណងសំខាន់ៗដូចបានជម្រាបជូនខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ នូវការកែសម្រួលបទប្បញ្ញត្តិស្តីពីពន្ធដារមួយចំនួន ដូចខាងក្រោម៖

### ៤.១-ការលុបពន្ធសត្តឃាត

ពន្ធសត្តឃាតត្រូវបានដាក់ឱ្យអនុវត្តអស់រយៈពេល២៦ឆ្នាំ មកហើយ ចាប់តាំងពីឆ្នាំ១៩៩១។ ក្នុងស្មារតីជួយកាត់បន្ថយបន្ទុកចំណាយលើ សាច់សត្វដែលជាអាហារមូលដ្ឋានសម្រាប់ចិញ្ចឹមជីវិត ក៏ដូចជាជួយសម្រាលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋបានមួយកម្រិតថែមទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើសុំលុបពន្ធសត្តឃាតនេះ ដោយនិវាករណ៍ ច្បាប់ស្តីពីការបង្កើតពន្ធសត្តឃាត ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ១៧ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១។

### ៤.២-ការកែសម្រួលកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ

ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ កងកម្លាំងប្រដាប់អាវុធ និងកម្មករនិយោជិត **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានយកចិត្តទុកដាក់ជាប្រចាំ ដោយដំឡើងប្រាក់បៀវត្ស និងប្រាក់ឈ្នួលអប្បបរមាជាបន្តបន្ទាប់ ហើយនៅឆ្នាំ២០១៨ ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ និងកងកម្លាំងប្រដាប់អាវុធនឹងត្រូវដំឡើងជាង១លានរៀល ចំណែកឯប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង នឹងត្រូវដំឡើងដល់ ១៧០ដុល្លារអាមេរិក (ប្រមាណ៦៨០ ០០០រៀល) ផងដែរ ប្រសិនបើបញ្ចូលទាំងបុព្វលាភ លាភការប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ប្រាក់ឈ្នួលនេះអាចលើស១លានរៀលផងដែរ។

ទន្ទឹមនឹងការដំឡើងប្រាក់បៀវត្ស និងប្រាក់ឈ្នួលអប្បបរមានេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគិតគូរបន្ថែមមួយកម្រិតទៀត ដោយផ្តល់ការអនុគ្រោះឱ្យរួចផុតពីកាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស តាមរយៈការធ្វើវិសោធនកម្មពន្ធលើប្រាក់បៀវត្ស។ ជាក់ស្តែង ករណីនេះបានអនុវត្តជាសរុបចំនួន៣លើក ទាំងលើកនេះ ដែលកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ ត្រូវបានដំឡើងលើកទី១ ពី៥០០ ០០០រៀល ដល់ ៨០០ ០០០រៀល នៅឆ្នាំ២០១៥, លើកទី២ ពី៨០០ ០០០រៀល ដល់១ ០០០ ០០០រៀល នៅឆ្នាំ២០១៧ និងលើកទី៣ នេះ ពី១ ០០០ ០០០ រៀល ដល់១ ២០០ ០០០ រៀល។

ដូច្នេះ ដើម្បីឱ្យមន្ត្រីរាជការស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ កងកម្លាំងប្រដាប់អាវុធ និងកម្មករនិយោជិត ដែលមានប្រាក់បៀវត្សជាង១ ០០០ ០០០រៀល អាចរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើសុំកែសម្រួលមាត្រា៤៧ថ្មី (មួយ) ដោយដំឡើងកម្រិតបៀវត្សអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធពី១ ០០០ ០០០រៀល ដល់១ ២០០ ០០០រៀល។ ការកែសម្រួលនេះ នឹងអនុញ្ញាតឱ្យមន្ត្រីរាជការ និងកម្មករនិយោជិតដែលទទួលបានប្រាក់បៀវត្សសរុប ឬប្រាក់ឈ្នួលសរុប១ ២០០ ០០០រៀល ឬតិចជាង មិនជាប់ពន្ធលើប្រាក់បៀវត្សទៀតទេ។

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

### ៤.៣-ការបញ្ចូលបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែទៅក្នុងច្បាប់ស្តីពីសារពើពន្ធ

ដើម្បីធានាបាននូវសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នាក្នុងច្បាប់ស្តីពីសារពើពន្ធ បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវបានបញ្ចូលទៅជាជំពូកទី៦ នៃច្បាប់ស្តីពីសារពើពន្ធ ហើយជំពូកទី ៦ ជាធរមាន ស្តីពីអវសានប្បញ្ញត្តិ ត្រូវបានប្តូរទៅជាជំពូកទី៧ ដែលក្នុងនោះមាត្រា១៤១ ត្រូវបានប្តូរជាមាត្រា

១៥៤ និងមាត្រា១៤២ ត្រូវបានប្តូរជាមាត្រា១៥៥។ ជំពូកទី៦ ដែលត្រូវបានបញ្ចូលថ្មី ចែកចេញជា៦ ផ្នែកមាន ១៣ មាត្រា ចាប់ពីមាត្រា១៤១ ដល់មាត្រា១៥៣ ដូចខាងក្រោម៖

**ផ្នែកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន២ មាត្រា** ក្នុងនោះ **មាត្រា១៤១** ចែងអំពីវិសាលភាព និង **មាត្រា ១៤២** ចែងអំពីវាក្យសព្ទនិងនិយមន័យ។

**ផ្នែកទី២ ស្តីពីអត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់ មាន១ មាត្រា** គឺមាត្រា១៤៣។

**ផ្នែកទី៣ ស្តីពីការកាត់កង មាន៦ មាត្រា** ក្នុងនោះ **មាត្រា១៤៤** ចែងអំពីចំណាយ ដែលអនុញ្ញាតឱ្យ កាត់កង **មាត្រា១៤៥** ចែងអំពីការអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់ **មាត្រា១៤៦** ចែងអំពីការអនុញ្ញាត ឱ្យអ្នកជាប់ពន្ធធ្វើសំវិធានធននៃប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬចំណាយស្តារបរិស្ថាន **មាត្រា ១៤៧** ចែងអំពីវិធីរំលស់ **មាត្រា១៤៨** ចែងអំពីអាយុកាលរំពឹងទុកសម្រាប់ការធ្វើរំលស់ និង **មាត្រា១៤៩** ចែងអំពីពេលធ្វើរំលស់ និងលក្ខខណ្ឌនានាក្នុងការធ្វើរំលស់។

**ផ្នែកទី៤ ស្តីពីការផ្ទេរអត្ថប្រយោជន៍ មាន១ មាត្រា** គឺមាត្រា**១៥០** ចែងអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ក្នុងករណីមានការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាប័ណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ។

**ផ្នែកទី៥ ស្តីពីកាតព្វកិច្ចអ្នកជាប់ពន្ធ មាន១ មាត្រា** គឺមាត្រា**១៥១** ចែងអំពីកាតព្វកិច្ចបន្ថែមសម្រាប់ អ្នកជាប់ពន្ធអនិវាសនជន និងកាតព្វកិច្ចសម្រាប់អ្នកជាប់ពន្ធទូទៅ ព្រមទាំងប្រតិបត្តិករដែលជាតំណាង អ្នកជាប់ពន្ធ។

**ផ្នែកទី៦ ស្តីពីអន្តរប្បញ្ញត្តិ មាន២ មាត្រា** ក្នុងនោះ **មាត្រា១៥២** ចែងអំពីការរៀបចំអនុក្រឹត្យស្តីពី ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាប័ណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ ណាមួយដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃជំពូកនេះ និង**មាត្រា១៥៣** ចែងអំពី ឧត្តមានុភាពនៃបទប្បញ្ញត្តិក្នុងជំពូកនេះ។

## ៥. សេចក្តីសន្និដ្ឋាន

ការរៀបចំថវិកាឆ្នាំ២០១៨ ទោះបីជាជួបប្រទះនឹងបញ្ហាច្រើន រួមទាំងបញ្ហាប្រឈម និងហានិភ័យមួយ ចំនួនយ៉ាងណាក្តី, ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជន៍សម្រាប់អនុវត្តអាទិភាព គោលនយោបាយសំខាន់ៗជាសារវ័ន្ត ដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងដែល អាចផ្តល់ផលភ្លាមៗនៅក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំដ៏សំខាន់បំផុតនៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា។ ជាទូទៅ ការរៀបចំថវិកាឆ្នាំ២០១៨ នេះ គឺទទួលបាននូវការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធ យ៉ាងសកម្ម ប្រកបដោយសុឆន្ទៈ និងការយោគយល់គ្នា ព្រមទាំងក្នុងស្មារតីនិងឆន្ទៈកែទម្រង់ដោយឈរលើ ស្មារតីរួម ដែលជាលក្ខខណ្ឌចាំបាច់ អាចឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចបាននូវកញ្ចប់ថវិកាមួយ ដែល អាចឆ្លើយតបបានកាន់តែល្អប្រសើរ ទៅនឹងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដូចបានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨**។ ដូច្នេះ ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ គឺត្រូវបានរៀបចំឡើងតាមគោលនយោបាយវិស្តារកម្ម

**ថវិកាដោយប្រយ័ត្នប្រយែង** ឆ្ពោះទៅរកការសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗជាសារវ័ន្ត នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ហើយដែលអាចហុចផលភ្លាមៗនៅឆ្នាំ២០១៨ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី៥ ក៏ដូចជាការធានានូវចលនការនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ហើយតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធីនិងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគាំទ្រដល់ដំណើរឈានឡើងរបស់កម្ពុជា នៅក្នុងបរិការណ៍ថ្មីទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ។ ក្របខ័ណ្ឌថវិកានេះ ក៏បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងមុឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាសន្តិភាព ស្ថិរភាពនយោបាយ ឯកភាពជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តលើកស្ទួយ កិត្យានុភាពកម្ពុជា ការការពារបានដោយឥតរារាំងនូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី ការបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងធានាបាន នូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅពន្លឿនសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ជាពិសេសការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្របខ័ណ្ឌថវិកាខាងលើនេះ ក៏មានគោលដៅធានារក្សានូវវឌ្ឍនភាព ឯករាជ្យភាព និងភាពជាម្ចាស់របស់កម្ពុជា ក្នុងការគ្រប់គ្រងជោគវាសនារបស់ខ្លួនដោយខ្លួនឯង នៅក្នុងរយៈពេលវែងផងដែរ។

**ថវិកាឆ្នាំ២០១៨ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងបានបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជា តទៅមុខទៀត។** អាទិភាពចំណាយថវិកាឆ្នាំ២០១៨ គឺជាការឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួងស្ថាប័ននានា ក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួន ក៏ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល ដែលរួមមាន៖ ការអភិវឌ្ឍធនធានមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម ការលើកកម្ពស់គុណភាពសេវាសុខាភិបាលឱ្យកាន់តែល្អប្រសើរ ការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាពខ្ពស់ ការពង្រឹងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសការជំរុញអនុវត្តកម្មវិធីថ្មីៗនៃគោលនយោបាយ ក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគាំពារសង្គមដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។ ទន្ទឹមនេះ ថវិកាឆ្នាំ២០១៨ ក៏បានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ ប្រកបដោយមហិច្ឆតា តាមរយៈការអនុវត្តវិធានការយ៉ាងមុឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ដែលមានចែងនៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ទន្ទឹមនឹងការបន្តគោលនយោបាយបន្ទុបន្ថយ និងអនុគ្រោះពន្ធដល់ប្រជាពលរដ្ឋមានចំណូលទាប និងអាជីវកម្មតូចតាច។

សរុបមក ថវិកាឆ្នាំ ២០១៨ អាចប្រសិទ្ធនាមបានថាជា "**ថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ**

**ដើម្បីបន្តរក្សាសន្តិភាព, ស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត។**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងខិតខំប្រឹងប្រែងធានាធ្វើឱ្យស្មារតី និងខ្លឹមសារនៃការចរចា ថវិកា ត្រូវបានគោរពយ៉ាងខ្ជាប់ខ្ជួននៅក្នុងការអនុវត្ត ដើម្បីធានាបាននូវភាពស័ក្តិសិទ្ធិពិតប្រាកដនៃថវិកា ព្រមទាំងបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពប្រតិបត្តិការ ដើម្បីធានាថា រាល់ចំណាយត្រូវធ្វើឡើងក្នុងថ្លៃសមរម្យ, មានគុណភាព, សមស្របតាមលទ្ធភាព, ក្នុងបរិមាណដែលត្រូវការជាក់ស្តែង ព្រមទាំងក្នុងពេលវេលាដែលចាំបាច់ត្រូវការប្រើប្រាស់។ ទន្ទឹមនេះ ក្រោមការដឹកនាំផ្ទាល់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងឋានៈជាអគ្គមេបញ្ជាការតែមួយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការបច្ចេកទេស នឹងបន្តប្រកាន់ភាពម៉ឺងម៉ាត់ក្នុងការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លទ្ធផលចុងក្រោយ គឺអាស្រ័យយ៉ាងខ្លាំងទៅលើសុឆន្ទៈ និងការទទួលខុសត្រូវព្រមទាំងសមត្ថភាពគ្រប់គ្រង និងចាត់ចែងថវិការបស់ក្រសួង-ស្ថាប័នសាមីផ្ទាល់។ ដូចនេះ ការបន្តចូលរួមរបស់ក្រសួង-ស្ថាប័ននៅក្នុងកិច្ចដំណើរការនៃការកែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមកន្លែងរបស់ខ្លួន គឺជាកត្តាចាំបាច់មិនអាចខ្វះបានឡើយ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្នើសុំការគាំទ្ររបស់រាជរដ្ឋាភិបាលដើម្បីសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានលើកឡើងខាងលើ ជាពិសេសការបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ៤ យ៉ាងគឺ **"ឆ្នុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល"**។ ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះដោគវាសនារបស់ប្រទេសជាតិ និងឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចតេជោនាយករដ្ឋមន្ត្រី និង គណៈរដ្ឋមន្ត្រីមេត្តាពិនិត្យ និងអនុម័តនូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដូចមានគោរពជូនភ្ជាប់មកជាមួយនេះ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ១១ ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ចរិតសកាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៧ សជណ.កប៩

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

**១**- ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលកើតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** និងការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍នៃលទ្ធិប្រជា-ធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ ព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវការអភិវឌ្ឍរីកចម្រើនលូតលាស់លើគ្រប់វិស័យ គួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ជាពិសេសការសម្រេចបាននូវបង្គោលចរមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន គឺការក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥កន្លងទៅ ក៏ដូចជាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត។ សមិទ្ធផលខាងលើនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជា ដោយចាប់ផ្តើមពីបាតដៃទទេ និងក្នុងដំណើរឆ្លងកាត់ដ៏វែងឆ្ងាយ បត់បែន និងលំបាកជាច្រើនរាប់មិនអស់ ហើយទទួលបាននូវការសាទរ និងការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើមុខ និងស្មើសិទ្ធិ ជាពិសេសបានផ្តល់នូវក្តីសង្ឃឹម និងភាពជឿជាក់ ចំពោះជោគវាសនាអនាគតរបស់ប្រជាជនគ្រប់រូប និងប្រទេសជាតិទាំងមូល នៅក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីទៀត គឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានសមធម៌សង្គម និងការថែរក្សាបរិស្ថានកាន់តែល្អប្រសើរ។ ឈរលើមូលដ្ឋាននេះ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានរៀបចំឡើង ក្នុងគោលដៅដើម្បីបង្ហាញអំពីលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន ព្រមទាំងវិធានការគោលនយោបាយសំខាន់ៗ នៅក្នុងឆ្នាំចុងក្រោយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ឆ្ពោះទៅរកការសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យដែលបាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ដើម្បីឆ្លើយតបទៅនឹងឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូរដោយចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជា នៅក្នុងបរិការណ៍ថ្មី ទាំងកម្រិតជាតិ និងអន្តរជាតិ។

២- ជាបរិការណ៍ទូទៅ ឆ្នាំ២០១៨ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ផង និងជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ផង។ ដូចនេះ រាជរដ្ឋាភិបាលត្រូវធានាឱ្យការបោះឆ្នោតទាំងពីរនេះ ប្រព្រឹត្តទៅដោយរលូន មានសណ្តាប់ធ្នាប់ និងប្រកបដោយតម្លាភាព ទន្ទឹមនឹងការធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាទូទៅ ជាពិសេសការធានារក្សាការពារឱ្យបានដាច់ខាតនូវសុខសន្តិភាព និងស្ថិរភាពសង្គម ដែលសម្រេចបានមកដោយលំបាក ឱ្យស្ថិតស្ថេរគង់វង្សចីរកាល ក៏ដូចជាការបន្តទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឱ្យប្រទេសជាតិធ្លាក់ទៅក្នុងសភាពវឹកវរ និងអស្ថេរភាព។ ម៉្យាងទៀត និន្នាការនៃការផ្លាស់ប្តូរថ្មីនៅក្នុងបរិការណ៍ពិភពលោក ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយ ទាំងក្នុងទិដ្ឋភាពភូមិសាស្ត្រសេដ្ឋកិច្ច និងទាំងក្នុងទិដ្ឋភាពចរន្តនយោបាយ-សង្គម រួមទាំងបញ្ហាសន្តិសុខនៅក្នុងតំបន់និងពិភពលោក អាចនឹងបង្កើនកម្រិតហានិភ័យដល់សេដ្ឋកិច្ចពិភពលោកឱ្យកាន់តែខ្ពស់ថែមទៀត ទោះបីស្ថានភាពសេដ្ឋកិច្ចពិភពលោកកំពុងមានលក្ខណៈប្រសើរជាងបណ្តាឆ្នាំកន្លងទៅក្តី។ ទោះបីជាយ៉ាងនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថា នឹងនៅតែអាចបន្តមានស្ថានភាពល្អប្រសើរ ហើយនៅតែអាចរក្សាបាននូវចីរភាពនៃកំណើន សម្រាប់រយៈពេលមធ្យមទៅមុខ។ ក៏ប៉ុន្តែសេដ្ឋកិច្ចកម្ពុជាកំពុងស្ថិតក្នុងរបត់ថ្មីមួយ ដែលទាមទារជាចាំបាច់នូវការជំរុញអនុវត្តឱ្យបានខ្លាំងក្លា និងឱ្យកាន់តែមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយទាំងឡាយ ដែលត្រូវបានដាក់ចេញកន្លងមក ព្រមពេលជាមួយគ្នានឹងការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីនៃសេដ្ឋកិច្ចដែលកាន់តែលូតលាស់ ហើយកាន់តែស្មុគស្មាញជាងមុន និងការប្រែប្រួលរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ជាពិសេសការចាប់យកកាលានុវត្តភាពពីផលលាភបច្ចេកវិទ្យាឌីជីថល និងផលលាភប្រជាសាស្ត្រ ក្នុងគោលដៅទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យសម្រេចបានក្នុងរង្វង់៧% ក្នុងមួយឆ្នាំប្រកបដោយបរិយាប័ន្ន ដែលជាមូលដ្ឋានមិនអាចខ្វះបាន ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣០ ដើម្បីអាចក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ហើយប្រជាជនកម្ពុជាគ្រប់រូបនឹងទទួលបាននូវឱកាសរកប្រាក់ចំណូលបានកាន់តែច្រើន ទទួលបានការអប់រំកាន់តែខ្ពស់ និងការងារធ្វើកាន់តែល្អ ព្រមទាំងជីវភាពកាន់តែធូរធា។ ជាមួយគ្នានេះ កម្ពុជាត្រូវខិតខំទ្វេដងថែមទៀត ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ហើយត្រូវមានភាពហ្មត់ចត់និងភាពប្រុងប្រយ័ត្ននៅក្នុងការគ្រប់គ្រងហានិភ័យផ្សេងៗជាប់ជាប្រចាំ។ នៅក្នុងក្របខ័ណ្ឌនេះ កម្ពុជាត្រូវបន្តជំរុញការអនុវត្ត**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ដែលជា **យុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ** ឱ្យកាន់តែខ្លាំងក្លា និងការធ្វើទំនើបកម្មវិស័យកសិកម្ម ព្រមទាំងត្រូវជំរុញការអភិវឌ្ឍវិស័យសេវាកម្ម ដូចជា៖ វិស័យទេសចរណ៍ វិស័យដឹកជញ្ជូននិងឡូជីស្ទីក និងវិស័យហិរញ្ញវត្ថុ ព្រមទាំងវិស័យឌីជីថលឱ្យកាន់តែខ្លាំងថែមទៀត ដើម្បីបង្កើតជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចថ្មី បន្ថែមលើកម្លាំងចលករអូសកំណើនចាស់ប្រពៃណីដូចជា៖ វិស័យកាត់ដេរ សំណង់ និងវិស័យកសិកម្ម ដែលកំពុងប្រឈមនឹងបញ្ហាផលិតភាពទាប និងហានិភ័យនៃការថមថយ ក៏ដូចជាកត្តាវិបត្តិពីខាងក្រៅ។ ទន្ទឹមនឹងនេះ កម្ពុជាក៏ត្រូវបន្តធ្វើការកែទម្រង់វិស័យសាធារណៈ និងបន្តលើកកម្ពស់សមត្ថភាពស្ថាប័ន ព្រមទាំងធនធានមនុស្ស ដើម្បីជាមូលដ្ឋានសម្រាប់ទ្រទ្រង់ដល់ដំណើរឈានឡើងរបស់កម្ពុជា ក៏ដូចជាដើម្បីលើកកម្ពស់បរិស្ថានវិនិយោគ និងធុរកិច្ចឱ្យកាន់តែប្រសើរឡើង។ ក្នុងន័យនេះ **ថវិកាឆ្នាំ២០១៨ ដែលជាឆ្នាំចុងក្រោយ** នៃនីតិកាលទី៥

នៃរដ្ឋសភា ត្រូវតែជាថវិកាយុទ្ធសាស្ត្រនៃការពង្គុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យ ខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព និងស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត។

**៣**-ជារួម រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ចាប់តាំងតែពីដើមនីតិកាលរបស់ខ្លួនរហូតមក ធានាបានជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា ជាពិសេសការធានានិង រក្សាបាននូវសន្តិភាព សន្តិសុខ អធិបតេយ្យភាព ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ព្រមទាំងលំនឹង ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ទោះបីត្រូវប្រឈមនឹងបញ្ហាគ្រប់បែបយ៉ាង ទាំងក្នុង និងក្រៅ ប្រទេសក៏ដោយ។ ទន្ទឹមនឹងនេះដែរ ការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ របស់រាជរដ្ឋាភិបាល បាននិងកំពុងចាប់ផ្តើមបង្កើតចេញជាលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់ ទោះបីល្បឿននៃ ការកែទម្រង់នេះនៅមានកម្រិតខុសៗគ្នាក៏ដោយ។ ប្រការនេះ បានបង្កើនការជឿជាក់មកលើសមត្ថភាព ដឹកនាំ និងគ្រប់គ្រងប្រទេសរបស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់។ ជាក់ស្តែង ទំហំសេដ្ឋកិច្ចជាតិ (ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន) បានកើនឡើងពី៦១ ៣២៦ ៩២៨លានរៀល ឬសមមូលនឹងប្រមាណជាង១៥ ២៣៧ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់៨៩ ៥០៩ ៤២២លានរៀល ឬសមមូលនឹងប្រមាណជាង ២២ ១៧២លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់៩៩ ១១៦ ០៤១លានរៀល ឬសមមូលនឹងប្រមាណជាង២៤ ៥៥២លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។ ចំណូលមនុស្សម្នាក់ ធៀបនឹង ផ.ស.ស. ក៏បានកើនឡើងពី១ ០៤២ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ១ ៤៣៥ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ១ ៥៦៨ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ក្នុងខណៈដែលអត្រាប្តូរប្រាក់ស្ថិតក្នុងរង្វង់៤ ០៥០រៀល ក្នុងមួយដុល្លារអាមេរិក ហើយអត្រាអតិផរណា ជាមធ្យមស្ថិតក្នុងរង្វង់៣% ដែលជាកម្រិតមួយទាប និងអាចគ្រប់គ្រងបាន នៅក្នុងរយៈពេលដូចគ្នា។ ទន្ទឹមនឹងនេះ ទុនបម្រុងអន្តរជាតិ ក៏បានកើនឡើងពី៣ ៦៤៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ ៩ ០៥០លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់១០ ៥១៨លានដុល្លារអាមេរិកនៅ ឆ្នាំ២០១៨។ គុណភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែល្អប្រសើរឡើងជាលំដាប់ ក្នុងខណៈដែលកម្រិត បំណុលសាធារណៈរបស់កម្ពុជាមានអនុបាតបំណុលទាបបំផុតនៅក្នុងតំបន់ ដែលឆ្លុះបញ្ចាំងពីហានិភ័យ ទាប និងចីរភាពនៃបំណុលសាធារណៈរបស់កម្ពុជា។ ជាមួយនឹងកំណើនខាងលើនេះ អត្រានៃភាពក្រីក្រ ដែលបានធ្លាក់ចុះពីប្រមាណ៥៣,៥%ក្នុងឆ្នាំ២០០៤ មកត្រឹមតែប្រមាណ១៣,៥%ក្នុងឆ្នាំ២០១៤នោះ នឹងបន្តកាន់តែធ្លាក់ចុះមកថែមទៀតនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយមេគុណជីនីដែលបានធ្លាក់ចុះ ពី០,៣៨០ក្នុងឆ្នាំ២០០៤ មកត្រឹម០,២៩៥ក្នុងឆ្នាំ២០១៤នោះ ក៏ត្រូវបានរំពឹងថាកាន់តែមានភាពប្រសើរ ឡើងថែមទៀតផងដែរ។ ប្រការនេះ បានគូសបញ្ជាក់ថា កម្ពុជាមិនត្រឹមតែសម្រេចបាននូវកំណើនសេដ្ឋកិច្ច ខ្ពស់ និងរឹងមាំប៉ុណ្ណោះទេ តែកំណើននេះក៏កាន់តែមានបរិយាប័ន្ន ហើយការបែងចែកផលនៃកំណើន ក៏កាន់តែសមធម៌ផងដែរ។ សមិទ្ធផលសង្គម-សេដ្ឋកិច្ចខាងលើនេះ បានធ្វើឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ចាត់ទុកកម្ពុជាជាប្រទេសមួយ នៅក្នុងចំណោមប្រទេសឯតទគ្គកំណើនចំណាត់ថ្នាក់ទី៦ នៅក្នុង

ពិភពលោក ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។ ជាងនេះទៅទៀត ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានចាត់ទុកកម្ពុជាជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ីផងដែរ។ ក្រៅពីនេះ កម្ពុជាក៏ទទួលបាននូវជ័យលាភីជាច្រើនទៀត ដូចជាការទទួលបានចំណាត់ថ្នាក់ជាប្រទេសជោគជ័យបំផុតទី៤ លើពិភពលោក ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រ និងទទួលបានការវាយតម្លៃខ្ពស់ពីអង្គការសហប្រជាជាតិ ចំពោះការកាត់បន្ថយអត្រានៃភាពអត់ឃ្លានជាងពាក់កណ្តាលមុនពេលកំណត់ និងជាប្រទេសឈានមុខគេទាំង៧ លើពិភពលោកក្នុងការកែលម្អសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស ក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥។

៤- ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិការណ៍អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាពខាងលើនេះ បានធ្វើឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់នៅទូទាំងប្រទេស កាន់តែមានឱកាសក្នុងការស្វែងរកការងារ និងក្នុងការបង្កើនប្រាក់ចំណូល ដោយក្នុងនោះ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ទទួលបាននូវប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការអនុវត្តនូវគោលនយោបាយដំឡើងប្រាក់បៀវត្សក្នុងគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល ចាប់តាំងពីដើមនីតិកាលមក។ ដូចគ្នានេះដែរ កម្មករនិយោជិតរាប់សែននាក់ទៀតដែលកំពុងតែបម្រើការងារក្នុងវិស័យឯកជន ក៏ទទួលបាននូវឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួនផងដែរ តាមរយៈការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងជារៀងរាល់ឆ្នាំ ដែលនឹងត្រូវកើនឡើងដល់ចំនួន១៧០ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀតពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ក្រៅពីការផ្តល់នូវឱកាសស្វែងរកការងារ និងឱកាសបង្កើនប្រាក់ចំណូលជូនដល់ប្រជាជនរាប់លាននាក់ខាងលើ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់នានាជាបន្តបន្ទាប់ ក្នុងគោលដៅដោះស្រាយការលំបាក ក្តីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាដោះស្រាយបញ្ហាប្រឈមរបស់ជាតិ ទាំងបញ្ហាសង្គម និងទាំងបញ្ហាសេដ្ឋកិច្ច។ ជាក់ស្តែង ការលុបចោលមិនយកកម្រៃពីសេវាសាធារណៈចាំបាច់មួយចំនួន បានជួយសម្រាលបន្ទុកចំណាយ និងលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ លើសពីនេះ ការដាក់ចេញនូវវិធានការបុរេសកម្មចាំបាច់នានាជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ទាំងក្នុងទិដ្ឋភាពនយោបាយ និងទាំងក្នុងទិដ្ឋភាពគោលនយោបាយពាក់ព័ន្ធនឹងការបញ្ចុះថ្លៃថាមពលអគ្គិសនី និងទឹកស្អាត ការបន្ធូរបន្ថយពន្ធ និងការអនុគ្រោះពន្ធលើប្រភេទពន្ធមួយចំនួន ដូចជា៖ ការលុបចោលរបបពន្ធម៉ៅការ ការដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ការលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តកម្លាំងក្រោម១៥០សេសេ និងការលើកលែងពន្ធប្រថាប់ត្រាក្នុងរង្វង់សាច់ញាតិជាដើម បាននិងកំពុងតែផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន និងគ្រូពេទ្យ កម្មករនិយោជិត ក៏ដូចជាដល់ការប្រកបអាជីវកម្មតូចតាចផងដែរ។ ទន្ទឹមនឹងនេះ ការលុបចោលការបង់ភាស៊ី និងថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង កញ្ជើ ល្ហុ នៅតាមទីផ្សារទូទាំងប្រទេស និងការអនុញ្ញាតឱ្យអាជីវករ ដែលមានតូប រាន ស្តង់ ឬកន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ហើយ

អាចផ្ទេរសិទ្ធិបាន ព្រមទាំងការលុបចោលពន្ធសត្តឃាត និងការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្ម សត្តឃាតដ្ឋាន បានចូលរួមចំណែកលើកកម្ពស់ជីវភាព និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ លើម្ហូបអាហារប្រចាំថ្ងៃបានមួយកម្រិតថែមទៀត ក៏ដូចជាបានជួយជំរុញធ្វើឱ្យសេដ្ឋកិច្ចជាតិ ជាពិសេស សេដ្ឋកិច្ចជនបទកាន់តែរីកចម្រើន។ ជារួម ការដាក់ចេញនូវវិធានការគោលនយោបាយពន្ធខាងលើ គឺដើម្បី ឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការជួយដោះស្រាយ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ ទោះយ៉ាងណាក្តី រាជរដ្ឋាភិបាលនៅតែអាចរក្សាបាននូវតួនាទីរបស់ប្រព័ន្ធពន្ធជាឃ្នាស់សម្រាប់ការការពារ បាននូវការប្រមូលចំណូល។ ម៉្យាងវិញទៀត ការសម្រេចទិញយកមកគ្រប់គ្រងវិញនូវគម្រោងផ្លូវ និងស្ពាន មួយចំនួនជាបន្តបន្ទាប់ពីវិស័យឯកជននៅក្នុងក្របខ័ណ្ឌនៃយន្តការភាពជាដៃគូ រវាងរដ្ឋនិងវិស័យឯកជន ក៏បានជួយដោះស្រាយការលំបាក និងជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋបន្ថែមទៀត ផងដែរ ក្រៅពីការសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បាន បង្កើនចំណាយយ៉ាងច្រើនទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃសេវាសាធារណៈ ទាំងតាមរយៈចំណាយចរន្តថវិកាជាតិ និងទាំងតាមរយៈចំណាយវិនិយោគសាធារណៈ ដើម្បីធ្វើឱ្យ ការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង និងកាន់តែខិតជិតដល់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់។

**៥**- ចាប់តាំងពីចុងឆ្នាំ២០១៣មក រាជរដ្ឋាភិបាលក៏បានគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ បានយ៉ាងល្អ ដែលធ្វើឱ្យវិស័យនេះ កាន់តែមានលក្ខណៈរឹងមាំ និងចីរភាព ទាំងនៅក្នុងផ្នែកចំណូល និង ទាំងនៅក្នុងផ្នែកចំណាយ ដែលនេះគឺជាការបោះជំហានឆ្ពោះទៅកាន់ជោគជ័យនៅលើវិថីនៃការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សំដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាជាជំហានៗ ឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបទដ្ឋានអន្តរជាតិ។ ជាក់ស្តែង ខាងផ្នែកចំណូលយើងសម្រេច បាននូវការបង្កើនទំហំចំណូលចរន្តថវិការដ្ឋសរុបពី៩ ១១០ ៨៤៨លានរៀល ឬសមមូលនឹង២ ២៦៤លាន ដុល្លារអាមេរិក ដែលត្រូវជា១៤,៨៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ១៦ ៤៦៨ ៩៩៧ លានរៀល ឬសមមូលនឹង៤ ០៨០លានដុល្លារអាមេរិក ដែលត្រូវជា១៨,៤០%នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៧ ហើយនឹងបន្តកើនឡើងដល់១៨ ៤០៦ ៨១០លានរៀល ឬសមមូលនឹង៤ ៥៦០លានដុល្លារ អាមេរិកនៅឆ្នាំ២០១៨ ដែលត្រូវជា១៨,៥៧%នៃ ផ.ស.ស. **ពោលគឺ ចំណូលចរន្តថវិការដ្ឋបានកើន ឡើងប្រមាណពីរដង**។ ប្រការនេះ គួសបញ្ជាក់ថា កម្ពុជាសម្រេចបាននូវកំណើននៃចំណូលប្រមាណ ជិត១ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ពោលគឺ លើសពីគោលដៅ០,៥០ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមប្រចាំឆ្នាំ និងលើសពីកម្រិត១៧,៣៥%នៃ ផ.ស.ស. សម្រាប់គោលដៅឆ្នាំ២០១៨ ដូចដែល មានកំណត់ក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨**។ ការសម្រេចបាននូវ កំណើនចំណូលដ៏ខ្ពស់ និងមិនធ្លាប់មាននៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ បាននាំកម្ពុជាដែលធ្លាប់ មានចំណូលថវិកាជាតិធៀបនឹង ផ.ស.ស. ទាបជាងគេក្នុងតំបន់ ឱ្យឡើងដល់កម្រិតកណ្តាលធៀបនឹង គេវិញ ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត ក៏បានផ្តល់ការវាយតម្លៃ ខ្ពស់លើសមិទ្ធផលនៃការខិតខំប្រឹងប្រែងនេះផងដែរថា **មិនធ្លាប់មានពីមុនមកនៅក្នុងបណ្តាប្រទេសក្នុង តំបន់ផងដែរ**។ គួរគូសបញ្ជាក់ផងដែរថា សមាមាត្រនៃចំណូលថវិកាពីប្រភពហិរញ្ញប្បទានក្រៅប្រទេស ក្នុងចំណែកថវិកាជាតិបានថយចុះពីប្រមាណជិត៧០%នៅក្នុងឆ្នាំ១៩៩៥ មកត្រឹមតែប្រមាណ២១,៤%

ប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៧ ហើយនឹងបន្តថយចុះមកទៀតមិនដល់២០%ផងនៅឆ្នាំ២០១៨។ ប្រការនេះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា សេដ្ឋកិច្ចកម្ពុជាកាន់តែមានឯករាជ្យភាពជាងមុន និងកាន់តែមានភាពជាម្ចាស់ជាងមុន ដែលនេះគឺជាផលផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងឆន្ទៈបូរផ្តៅចំតងាកអនុវិធានការមុតស្រួចទាំងឡាយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដែលបានចាប់ផ្តើមតាំងពីនីតិកាលមុនមក។ ទន្ទឹមនឹងនេះដែរ ខាងផ្នែកចំណាយវិញ គឺយើងបានបង្កើនទំហំចំណាយថវិការដ្ឋសរុបពី១៣ ៤៧៥ ៩២៣លានរៀល ឬសមមូលនឹង៣ ៣៤៨លានដុល្លារអាមេរិក ដែលត្រូវជា២១,៩៧%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់២១ ១៥១ ៩៨៥លានរៀល ឬសមមូលនឹង៥ ២៤០លានដុល្លារអាមេរិក ដែលត្រូវជា២៣,៦៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់២៤ ៣៧៥ ១០២លានរៀល ឬសមមូលនឹង៦ ០៣៨លានដុល្លារអាមេរិក ដែលត្រូវជា២៤,៥៩%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបថវិការដ្ឋត្រូវបានបង្កើនជិតពីរដង** សម្រាប់គាំទ្រដល់ការកែទម្រង់នានា និងសកម្មភាពការងារសំខាន់ៗចាំបាច់មួយចំនួនទៀតរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ ការអប់រំ សុខាភិបាល ព្រមទាំងការវិនិយោគលើការពង្រឹងការតភ្ជាប់ ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ព្រមទាំងការទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យសម្រេចបាន៧%។ ជាក់ស្តែង យើងបានបង្កើនចំណាយយ៉ាងច្រើនចំពោះវិស័យ និងក្រសួងអាទិភាពនានា ដោយក្នុងនោះ (១)-**ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានបង្កើនពីប្រមាណតែ១ ០៨១ ៦៦២លានរៀល ឬសមមូលនឹងប្រមាណ២៦៩លានដុល្លារអាមេរិក ដែលត្រូវជា១,៧៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ២ ៧៣៩ ៩១៣លានរៀល ឬសមមូលនឹងប្រមាណ៦៧៩លានដុល្លារអាមេរិក ដែលត្រូវជា៣,០៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ ៣ ៤៣៨ ០០៨លានរៀល ឬសមមូលនឹងប្រមាណ៨៥២លានដុល្លារអាមេរិក ដែលត្រូវជា៣,៤៧%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើនជាងបីដង** (២)-**ចំណាយសរុបរបស់ក្រសួងសុខាភិបាល**ត្រូវបានបង្កើនពីប្រមាណតែ៨៥៧ ៦៨២លានរៀល ឬសមមូលនឹងប្រមាណ២១៣លានដុល្លារអាមេរិក ដែលត្រូវជា១,៤០%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ១ ៦៩៧ ៦១៥លានរៀល ឬសមមូលនឹងប្រមាណ៤២១លានដុល្លារអាមេរិក ដែលត្រូវជា១,៩០%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ១ ៩៦៧ ៨៥១លានរៀល ឬសមមូលនឹងប្រមាណ៤៨៧លានដុល្លារអាមេរិក ដែលត្រូវជា១,៩៩%នៃ ផ.ស.ស. នៅឆ្នាំ២០១៨ **ពោលគឺ ចំណាយសរុបរបស់ក្រសួងសុខាភិបាលត្រូវបានបង្កើនជិតពីរដងកន្លះ** និង (៣)-**ចំណាយសរុបរបស់វិស័យកសិកម្មទាំងមូល** ត្រូវបានបង្កើនពីប្រមាណ១ ២៤៤ ៤២៧លានរៀល ឬសមមូលនឹងប្រមាណ៣០៩លានដុល្លារអាមេរិក ដែលត្រូវជា២,០៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ ១ ៤៥៧ ៩១៥លានរៀល ឬសមមូលនឹងប្រមាណ៣៦១លានដុល្លារអាមេរិក ដែលត្រូវជា១,៦៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ដោយក្នុងនោះ **ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានបង្កើនពីប្រមាណតែ១៤៣ ៣៤៩លានរៀល ឬសមមូលនឹងប្រមាណ៣៦លានដុល្លារអាមេរិក ដែលត្រូវជា០,២៣%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ៤៣៩ ៤៨០លានរៀល ឬសមមូលនឹងប្រមាណ១០៩លានដុល្លារអាមេរិក ដែលត្រូវជា០,៤៩%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយទំហំ

ចំណាយនេះនៅឆ្នាំ២០១៨ នឹងនៅបន្តស្ថិតក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៧ ពោលគឺ ចំណាយសរុបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានបង្កើនជិតបីដង។

**៦**- ក្រៅពីការបង្កើនទំហំនៃចំណាយ យើងក៏បានខិតខំបង្កើនគុណភាពចំណាយថែមទៀត តាមរយៈការបន្តបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា និងការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និងបច្ចេកទេស ដោយបានធ្វើឱ្យកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបាននូវទំនិញ សេវា និងសំណង់ ក្នុងបរិមាណច្រើនជាងមុន គុណភាពល្អជាងមុន និងតម្រង់ចំណាយឱ្យកាន់តែចំទិសដៅ និងអាទិភាពជាងមុន។ លើសពីនេះ យើងក៏សម្រេចបាននូវអតិរេកថវិកាចរន្តជាប់ជាប្រចាំនៅក្នុងឆ្នាំថវិកានីមួយៗ សម្រាប់យកទៅបង្កើនការវិនិយោគសាធារណៈ។ ជាក់ស្តែង ចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានបង្កើនពីប្រមាណតែ១ ២៥៩ ៧៩៣លានរៀល ឬសមមូលនឹងប្រមាណ៣១៣លានដុល្លារអាមេរិក ដែលត្រូវជា២,០៥%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ឡើងដល់ប្រមាណ២ ១៨៣ ៧០០លានរៀល ឬសមមូលនឹងប្រមាណ៥៤១លានដុល្លារអាមេរិក ដែលត្រូវជា ២,៤៤%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ២ ៩២៥ ៨០០លានរៀល ឬសមមូលនឹងប្រមាណ៧២៥លានដុល្លារអាមេរិក ដែលត្រូវជា២,៩៥ %នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៨ **ពោលគឺ ចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសត្រូវបានបង្កើនជិតពីរដងកន្លះ**។ ប្រការនេះគឺជាការឆ្លុះបញ្ចាំងពីសមត្ថភាព និងឯករាជ្យភាពខាងថវិការបស់កម្ពុជា និងជាលទ្ធផលនៃការប្រកាន់ខ្ជាប់នូវវិន័យថវិកា និងនិយាមថវិកា ព្រមទាំងបានផ្តល់លទ្ធភាពដល់ការបង្កើនប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលសម្រាប់ត្រៀមទប់ទល់បញ្ហាប្រឈម វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដាយថាហេតុ។ ជាមួយគ្នានេះដែរ ក្រៅពីបានដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធជារៀងរាល់ឆ្នាំ ដែលជាអាទិភាពសំខាន់បំផុតរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅ**ជាង១លានរៀលនៅឆ្នាំ២០១៨** និងបានបើកប្រាក់បៀវត្សទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ តាមប្រព័ន្ធធនាគារ រាជរដ្ឋាភិបាលក៏បានផ្តល់នូវការលើកទឹកចិត្ត និងមធ្យោបាយមួយចំនួនទៀត តាមរយៈ ការអនុវត្តនូវគោលនយោបាយផ្តោតការយកចិត្តទុកដាក់ដល់ធនធានមនុស្ស និងការផ្ទេរថវិកាឱ្យដល់អង្គភាពដែលអនុវត្តការងារផ្ទាល់ បន្ថែមពីលើអត្ថប្រយោជន៍ខាងហិរញ្ញវត្ថុមួយចំនួនទៀត ដូចជា៖ ការដំឡើងរបបប្រាក់បៃសកកម្ម និងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជាដើម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបង្កើនប្រាក់សោធននិវត្តន៍ និងរបបតាវកាលិកផ្សេងទៀត ជូននិវត្តជនជាបន្តបន្ទាប់ផងដែរ។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវកម្មវិធីអន្តរាគមន៍ផ្ទាល់របស់រដ្ឋក្នុងគោលដៅសង្គម-សេដ្ឋកិច្ចជាបន្តបន្ទាប់ ដូចជាកិច្ចអន្តរាគមន៍របស់រដ្ឋនៅក្នុងការប្រមូលទិញស្រូវពីកសិករ ដើម្បីទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះហួសពីថ្លៃទីផ្សារខ្លាំងពេក ដោយមិនសមហេតុផលជាដើម។

**៧**- សមិទ្ធផលខាងលើដែលសម្រេចបានមកនេះ គឺមិនអាចកាត់ផ្តាច់ពីការខិតខំប្រឹងប្រែងជាប់ជាប្រចាំ និងលទ្ធផលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះទេ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលទី២ **គណនេយ្យភាពហិរញ្ញវត្ថុ** និងបានចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ **គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ដែលនៅក្នុងដំណាក់កាលនេះ ការដាក់អនុវត្តសាកល្បងថវិកាកម្មវិធីពេញលេញ និងការដាក់ឱ្យអនុវត្ត

អង្គភាពថវិកា គឺជាស្នូលនៃការកែទម្រង់ប្រព័ន្ធថវិកា ដោយចាប់ផ្តើមជាដំហានៗ ពីឆ្នាំ២០១៥ ស្របតាមទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា២០១៣-២០២០ ក្នុងគោលដៅបោះដំហានឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកា ពីប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬ ធាតុចេញ និងវិមជ្ឈការ ។ ជាមួយនឹងទិសដៅនៃការពង្រឹង និងពង្រីកប្រព័ន្ធ ថវិកាកម្មវិធី ដែលគ្រប់ក្រសួងស្ថាប័ន នឹងអនុវត្តថវិកាកម្មវិធីនៅឆ្នាំ២០១៨ និងជាពិសេសផ្អែកលើបទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធីកន្លងមកនេះ រាជរដ្ឋាភិបាលកំពុងរៀបចំនូវ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៧-២០២៥ ដើម្បីឈានទៅដាក់អនុវត្ត ប្រព័ន្ធថវិកាផ្អែកលើពត៌មានសមិទ្ធកម្ម ឬ ហៅកាត់ថា ថវិកាសមិទ្ធកម្ម នៅឆ្នាំ២០២៥ នៅកម្ពុជា ស្របតាមឧត្តមានុវត្តតំបន់ និងអន្តរជាតិ។

ជារួម មកដល់ពេលនេះ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើនក្នុងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន៖

(១)-ការពង្រឹងភាពទុកចិត្តនៃថវិកាសម្រេចបាន តាមរយៈការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ជាពិសេសការផ្តោតលើការពង្រឹងរដ្ឋបាលចំណូល និងការព្យាករណ៍ចំណូល យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធអនុវត្តថវិកា ព្រមទាំងការពង្រីកវិសាលភាពនៃប្រព័ន្ធគណនីទោលរតនាគារ និងការគ្រប់គ្រងសាច់ប្រាក់តាមគេហទំព័រ

(២)-ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុបានផ្តោតជាសំខាន់លើការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំហានទី១ និងឈានទៅអនុវត្តដំហានទី២ ដែលនឹងគ្របដណ្តប់ដល់ក្រសួងអាទិភាពសំខាន់ៗ ស្របនឹងការរៀបចំ និងការដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកា និងមាតិកាគណនេយ្យថ្មី ដែលរួមចំណែកដល់ការលើកកម្ពស់ប្រព័ន្ធរបាយការណ៍ និងតម្លាភាពនៃការអនុវត្តថវិកា និង

(៣)-ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ តាមរយៈការដាក់អនុវត្តថវិកាកម្មវិធី និងការត្រៀមលក្ខណៈទៅមុខមួយដំហានទៀតឆ្ពោះទៅដាក់អនុវត្តថវិកាសមិទ្ធកម្ម ដែលប្រការនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចធ្វើការវិភាជធនធានកាន់តែមានប្រសិទ្ធភាពខ្ពស់ តម្រង់ឆ្ពោះទៅអាទិភាពគោលនយោបាយសំខាន់ៗ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

ជាលទ្ធផល តាមរយៈការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ការអនុវត្តថវិកាមានភាពប្រសើរឡើង ដោយគម្លាតនៃការអនុវត្តចំណូលនិងចំណាយនៃថវិកាជាតិធៀបនឹងច្បាប់ថវិកាដែលបានអនុម័តកាន់តែតូចទៅៗ លំហូរចំណូលនិងចំណាយកាន់តែមានភាពរលូន ដោយជំរុញការទូទាត់សាច់ប្រាក់បានទាន់ពេលវេលា ព្រមទាំងកាត់បន្ថយបានទាំងស្រុងនូវបំណុលកកស្ទះដ៏ពុំរ៉ៃ។ លើសពីនេះទៀត ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានរួមចំណែកដល់ការពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពហិរញ្ញវត្ថុ សំដៅបង្កើនភាពច្បាស់លាស់សុក្រឹតភាព ភាពទាន់ពេលនៃប្រព័ន្ធកត់ត្រា និងរបាយការណ៍ ជាមួយគ្នានឹងចំណាត់ថ្នាក់ថវិកាទាំង៧ ដែលត្រូវបានរៀបចំរួចរាល់ សម្រាប់ដាក់ចូលក្នុងប្រព័ន្ធ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាបន្តបន្ទាប់ តាមរយៈការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តិដោយបានបញ្ចប់អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌ សារាចរណែនាំស្តីពី

ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបន្តបញ្ចប់ការរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។ ក្នុងក្របខ័ណ្ឌនៃការវាយតម្លៃវិញ ស្ថាប័នអន្តរជាតិ ជាច្រើនបានវាយតម្លៃខ្ពស់ ចំពោះវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍ផ្សេងៗ។ ទន្ទឹមនឹងនេះ កម្ពុជាក៏មានភាពជាម្ចាស់ក្នុងការរៀបចំ វាយតម្លៃដោយខ្លួនឯង តាម **ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ** (PEFA) ដើម្បីវាស់វែងអំពីសុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលឈរលើមូលដ្ឋានគ្រឹះ៣ យ៉ាង គឺ ការគោរពវិន័យថវិកា ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ។

**៨**- ឈរលើមូលដ្ឋានខាងលើនេះ ថវិកាឆ្នាំ២០១៨ ត្រូវបានគិតគូរ និងរៀបចំ ដើម្បីជានាចលនការ នៃការកែទម្រង់របស់ខ្លួន ដែលរាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើម នីតិកាលមក ហើយក៏កំពុងបន្តតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោល-នយោបាយសំខាន់ៗ ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគិតគូរផងដែរទៅដល់ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ និងការត្រៀមខ្លួនទប់ទល់នឹងវិបត្តិដែលអាចកើតមានឡើងជាយថាហេតុ ក៏ដូចជាផ្តល់ការឆ្លើយតបទៅ នឹងបរិការណ៍ថ្មីរបស់កម្ពុជា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស ទាំងក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក ជាពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវ **គោលដៅជាយុទ្ធសាស្ត្រទាំង៤** ដូចមានចែង ក្នុង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាពនៅកម្ពុជា** ដែលជា **រង្វើបទារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** នៃ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា**។

## I - ក្របខ័ណ្ឌនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

### I.១.ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨

**៩**- តាមការព្យាករ កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៨ នឹងអាចបន្តសម្រេចបានប្រមាណ ៦,៩%ដូចឆ្នាំ២០១៧ ដែលធ្វើឱ្យ ផ.ស.ស. ថ្លៃបច្ចុប្បន្នកើនឡើងដល់៩៩ ១១៦ ០៤១លានរៀល ប្រមាណជា២៤ ៥៥២លានដុល្លារអាមេរិក ខណៈដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថា នឹងកើនឡើងដល់១ ៥៦៨ដុល្លារអាមេរិក ធៀបនឹងត្រឹមតែ១ ០៤២ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣។ កំណើននេះ ត្រូវបានទ្រទ្រង់ដោយ៖ (ទី១)-កំណើននៃវិស័យឧស្សាហកម្មប្រមាណ៨,៦% ដែលគាំទ្រ ដោយអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ជាពិសេសលើផលិតកម្មគ្រឿងបង្គុំអេឡិចត្រូនិច ម្ហូបអាហារ និងភេសជ្ជៈ ដែលជួយបំពេញបន្ថែមឱ្យការថមថយនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់។ ថ្វីត្បិតតែអនុវិស័យសំណង់មានកំណើនថមថយបន្តិច ប៉ុន្តែកំណើននេះនៅតែខ្ពស់ដោយសារសំណង់ប្រភេទ ពាណិជ្ជកម្ម និងការងាកទៅរកសំណង់លំនៅឋានតម្លៃសមរម្យ ចំណែកឯការបន្តថមថយនៃអនុវិស័យ កាត់ដេរ គឺបណ្តាលមកពីការកើនឡើងប្រាក់ឈ្នួលអប្បបរមាដែលធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែង របស់កម្ពុជា និងភាពស្ងាត់ស្ងៀរនៃការបញ្ជាទិញក្នុងអំឡុងឆ្នាំបោះឆ្នោតសកល (ទី២)-វិស័យសេវាកម្ម

បន្តកំណើនប្រមាណ៧,៦% ដែលគាំទ្រដោយកំណើនខ្ពស់នៃអនុវិស័យលក់ដុំ-រាយ អនុវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ព្រមទាំងអនុវិស័យសេវាកម្មផ្សេងៗ តាមរយៈការកើនឡើងការប្រើប្រាស់ក្នុងស្រុក ដោយសារការកើនឡើងប្រាក់ឈ្នួលអប្បបរមា និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ ស្របនឹងការបន្តគោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាលដែលជួយជំរុញដល់សកម្មភាពសេដ្ឋកិច្ច។ ជាមួយគ្នានេះដែរ អនុវិស័យអចលនទ្រព្យនៅតែបន្តកំណើនរឹងមាំ ស្របតាមនិន្នាការនៃអនុវិស័យសំណង់ ខណៈដែលអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបានរំពឹងថា មានកំណើនថមថយបន្តិច និង (ទី៣)-វិស័យកសិកម្មអាចសម្រេចបានកំណើនក្នុងរង្វង់២,០% ទ្រទ្រង់ដោយអនុវិស័យដំណាំ និងជលផល ដោយសារភាពប្រសើរឡើងនៃប្រព័ន្ធស្រោចស្រព និងការរំពឹងទុកលក្ខខណ្ឌអំណោយផលនៃកត្តាអាកាសធាតុ។

**១០**- អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថា នឹងមានការកើនឡើងបន្តិចក្នុងអត្រា៣,៨%ក្នុងឆ្នាំ២០១៧ និង៣,៥%ក្នុងឆ្នាំ ២០១៨ ដោយសារការងើបឡើងវិញជាបណ្តើរៗនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងថ្លៃកសិផលមួយចំនួន។ ចំណែកឯអត្រាប្តូរប្រាក់រៀល គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់៤ ០៣៧រៀលក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង២០១៨ ដែលជាអត្រាមួយអាចរក្សាស្ថិរភាពអតិផរណា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេសត្រូវបានរំពឹងថានឹងកើនឡើងជាងមុនបន្តិចពី៧,៩%នៃ ផ.ស.ស. នៅឆ្នាំ២០១៧ មក៨,៤% នៃ ផ.ស.ស. នៅឆ្នាំ២០១៨ ដោយសារការរំពឹងទុកនៃការថមថយ នៃឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណង ក្រោមហេតុផលថាកម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ខណៈដែលឱនភាពពាណិជ្ជកម្មបានធ្លាក់ចុះពី១៥,៤%នៃ ផ.ស.ស. នៅក្នុងឆ្នាំ២០១៧ មកត្រឹម១៥%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៨ ដែលឆ្លុះបញ្ចាំងនូវពិពិធកម្មផលិតផលនាំចេញ។ ដោយឡែក ទុនបម្រុងអន្តរជាតិត្រូវបានប៉ាន់ស្មានថា នឹងបន្តកើនឡើងពី៦ ៧៣១លានដុល្លារអាមេរិកនៅឆ្នាំ២០១៦ ដល់៩ ០៥០លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៧ និងបន្តឡើងដល់១០ ៥១៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨ ដោយសារការវិនិយោគផ្ទាល់ពីបរទេសនឹងនៅបន្តមានកំណើនល្អ ដែលនឹងជានាបាននូវការនាំចូលប្រមាណ៦,៥ខែ ក្នុងឆ្នាំ២០១៨ ដែលជាកម្រិតមួយល្អ សម្រាប់ការរក្សាបាននូវស្ថិរភាពជញ្ជីងទូទាត់។

**១១**- ក្នុងន័យនេះ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៨ ត្រូវបានកំណត់តាមសូចនាករសំខាន់ៗ ដូចខាងក្រោម៖

| **សូចនាករសេដ្ឋកិច្ច** | **២០១៦** | **២០១៧** | **២០១៨** |
|---|---|---|---|
| | ប៉ាន់ស្មាន | ព្យាករ | ព្យាករ |
| ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន (លានរៀល) | ៨០ ៥៥៨ ៥៣២ | ៨៩ ៥០៩ ៤២២ | ៩៩ ១១៦ ០៤១ |
| កំណើននៃ ផ.ស.ស. តាមថ្លៃថេរ (%) | ៧,០ | ៦,៩ | ៦,៩ |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | ១ ៣០២ | ១ ៤៣៥ | ១ ៥៦៨ |

| | | | |
|---|---|---|---|
| អតិផរណា (អត្រាមធ្យមប្រចាំឆ្នាំ) | ៣,០ | ៣,៨ | ៣,៥ |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/រៀល) | ៤ ០៥៦ | ៤ ០៣៧ | ៤ ០៣៧ |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស.) | -៩,០ | -៧,៩ | -៨,៤ |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | ៦ ៧៣១ | ៩ ០៥០ | ១០ ៥១៨ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | ៥,៥ | ៦ | ៦,៥ |

**១២**- និយាយជារួម ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និងមធ្យមខាងមុខនេះ ខណៈដែលបញ្ហាប្រឈម និងហានិភ័យកាន់តែកើនឡើង ទាំងខាងក្នុង ទាំងខាងក្រៅ ដែលអាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើននេះ និងបង្កភាពអាក់អន្លួលដល់កិច្ចអភិវឌ្ឍន៍ ដូចជា៖

**ទី១**-ផ្នែកក្រៅប្រទេស សេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងកំណើនយឺតនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហគមន៍អឺរ៉ុប និងភាពស្រពិចស្រពិលនៃសេដ្ឋកិច្ចអឺរ៉ុប ការថមថយកំណើនសេដ្ឋកិច្ចរបស់ចិន ការតឹងតែងគោលនយោបាយរូបិយវត្ថុ និងភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក ព្រមទាំងស្ថានការណ៍វិវត្តន៍ទៅរកភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចនៅក្នុងពិភពលោក ជាពិសេសការឡើងកម្តៅនៃវិាទនៅតាមតំបន់មួយចំនួន ដែលបញ្ហាទាំងនេះជាហានិភ័យសេដ្ឋកិច្ចសម្រាប់កម្ពុជាដែលមានសេដ្ឋកិច្ចបើកចំហខ្លាំង ជាពិសេសសម្រាប់វិស័យពាណិជ្ជកម្មអន្តរជាតិ និងលំហូរទុនវិនិយោគផ្ទាល់ពីបរទេស ព្រមទាំងវិស័យទេសចរណ៍។

**ទី២**-ផ្នែកក្នុងស្រុក កម្ពុជាកំពុងប្រឈមនឹងបញ្ហាចម្បងៗមួយចំនួននៅក្នុងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចដូចជា៖ បញ្ហាថ្លៃអគ្គិសនីនៅខ្ពស់ ប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីកនៅទន់ខ្សោយ និងនិន្នាការនៃកំណើនប្រាក់ឈ្នួលអប្បបរមាលឿនជាងកំណើននៃផលិតភាពការងារ ព្រមទាំងការយកកម្រៃក្រៅផ្លូវការដែលនៅមានខ្លះ គួបផ្សំនឹងបែបបទនីតិវិធីមួយចំនួនដែលនៅតែស្មុគស្មាញនៅឡើយ។ បញ្ហាប្រឈមទាំងនេះ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងរបស់កម្ពុជាប៉ុណ្ណោះទេ តែប៉ះពាល់ផងដែរដល់ប្រសិទ្ធភាពនៃសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល ហើយជាឧបសគ្គរារាំងដល់ការបង្កើនសក្តានុពលវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា ជាពិសេសការប្រែក្លាយកម្ពុជាឱ្យទៅជាគោលដៅនៃការវិនិយោគលើឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់។

**ទី៣**-និន្នាការកើនឡើងនៃថ្លៃប្រេង ក៏អាចនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាដែលជាប្រទេសប្រើប្រាស់ប្រេងនាំចូល១០០%។ ទន្ទឹមនឹងនេះ សម្ពាធនៃការបន្តឡើងថ្លៃម្ហូបអាហារក៏នឹងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋផងដែរ ជាពិសេសអ្នកដែលមានចំណូលទាប។ ការកើនឡើងនៃថ្លៃទំនិញទាំងពីរប្រភេទនេះ នឹងអាចធ្វើឱ្យអត្រាអតិផរណាមានការកើនឡើង។

ទី៤-ជាងនេះទៅទៀត កម្ពុជាកំពុងទទួលសម្ពាធនៃតម្រូវការចំណាយថវិការដ្ឋកាន់តែកើនឡើង ឥតឈប់ឈរដោពិសេសចំណាយបន្ទុកបុគ្គលិក ក្នុងខណៈដែលកំណើនចំណូលថវិកាបានឈានទៅកៀកនឹងពិដាននៃសក្តានុពលទៅហើយ។ ដូចនេះ កំណើនចំណូលនៅឆ្នាំ២០១៨ និងបណ្តាឆ្នាំខាងមុខ អាចប្រឈមនឹងការថមថយ ទន្ទឹមនឹងឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានឥតសំណងក៏កាន់តែរឹងស្ងួតទៅៗ ទៅតាមដំណាក់កាលនៃការវិឌ្ឍរីកចម្រើនខាងសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ។

ក្នុងន័យនេះ កម្ពុជាត្រូវដាក់ចេញនូវវិធានការគោលនយោបាយមុតស្រួចមួយចំនួនឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅជម្នះ និងដោះស្រាយនូវាល់បញ្ហាប្រឈម និងហានិភ័យខាងលើ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំ និងប្រកបដោយចីរភាពក្នុងរង្វង់៧% ដូចខាងក្រោម៖

(ក)-**ការបន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** តាមរយៈ៖ (១)-ការពង្រឹងបន្ថែមទៀតនូវយន្តការគ្រប់គ្រងវិបត្តិនិងហានិភ័យ ទាំងយន្តការបញ្ជៀសវិបត្តិ និងទាំងយន្តការដោះស្រាយវិបត្តិ ព្រមទាំងត្រូវធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលាក្នុងការរក្សាស្ថិរភាពថ្លៃនៅលើទីផ្សារ (២)-ការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែខ្លាំងក្លា តាមរយៈការជំរុញការអនុវត្ត**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥** ដោយបន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតជាពិសេសការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ និងទីផ្សាររូបិយប័ណ្ណ ព្រមទាំងការបន្តពង្រឹងវិស័យមិនមែនធនាគារ រួមមាន៖ វិស័យធានារ៉ាប់រង និងទីផ្សារមូលបត្រ (៣)-ការបន្តរក្សាស្ថិរភាពនៃកំណើនឥណទានស្របទៅតាមស្ថានភាពនៃសេដ្ឋកិច្ច តែត្រូវជំរុញបន្ថែមទៀតនូវការផ្តល់ឥណទាន ទាំងបរិមាណ និងគុណភាពទៅលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម រួមទាំងសហគ្រាសធុនតូចនិងមធ្យម ជាពិសេសវិស័យស្រូវ-អង្ករ (៤)-ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងការប្រើប្រាស់កម្ចីនេះឱ្យមានប្រសិទ្ធភាព និងផលិតភាពខ្ពស់ ទន្ទឹមនឹងការបន្តគ្រប់គ្រងការអនុវត្តគោលនយោបាយកំណត់ពិដានអត្រាការប្រាក់ឱ្យបានរលូន និងមានប្រសិទ្ធភាព និង (៥)-ការបន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យឱ្យកាន់តែល្អ រួមទាំងការឃ្លាំមើលនៃការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

(ខ)- **ការបន្តជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព** តាមរយៈ៖ (១)-ការខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ដើម្បីបំពេញបន្ថែមការវិនិយោគក្នុងស្រុក ដែលអាចនឹងថមថយដោយកត្តាចិត្តសាស្ត្រឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោត តាមរយៈការបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ហើយជំរុញការអនុម័ត និងការអនុវត្តច្បាប់នេះ រួមទាំងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍនិងតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗក្នុងប្រទេសទៅនឹងប្រទេសជិតខាង ក៏ដូចជាដើម្បីបន្តជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ច ទាំងនៅក្នុងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ អាស៊ាន និងពិភពលោក (២)-ការជំរុញអនុវត្តគោលនយោបាយ**អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ឱ្យមានសន្ទុះកាន់តែខ្លាំងក្លា ទន្ទឹមនឹងការខិតខំអនុវត្តបញ្ចប់នូវកិច្ចការមួយចំនួនដែលនៅមិនទាន់ចេញជាផ្លែផ្កា សំដៅជំរុញល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មកម្ពុជាឱ្យបានកាន់តែឆាប់រហ័ស ក្នុងគោល

ដៅបង្កើនភាពប្រកួតប្រជែង ការបង្កើនតម្លៃបន្ថែមឱ្យកាន់តែខ្ពស់ក្នុងខ្សែចង្វាក់ផលិតកម្មនៃឧស្សាហកម្ម កាត់ដេរ ការកែច្នៃម្ហូបអាហារ ការដំឡើងគ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិច និងគ្រឿងបន្លាស់ ព្រមទាំងឧស្សាហកម្មថ្មីៗផ្សេងទៀត ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និង (៣)-ការបង្កើនចំណាយលើវិស័យអាទិភាពសំខាន់ៗដូចជា៖ ការអប់រំ ការអភិវឌ្ឍជំនាញ សុខាភិបាល កសិកម្ម ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ រួមទាំងការបង្កើនប្រសិទ្ធភាពចំណាយនៅក្នុងវិស័យទាំងនោះ ហើយត្រូវផ្អែកលើផែនការមេមួយច្បាស់លាស់ ជាពិសេសចំពោះវិស័យទូរគមនាគមន៍ ដឹកជញ្ជូន និងវិស័យថាមពល ដើម្បីជំរុញកំណើន លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពនៃសេដ្ឋកិច្ច ព្រមទាំងភាពប្រកួត-ប្រជែងរបស់កម្ពុជា ក៏ដូចជាសម្រាប់ឈានទៅអនុវត្តនូវសេដ្ឋកិច្ចឌីជីថល នៅក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។

(គ)- **ការពន្លឿនកិច្ចការកែទម្រង់រចនាសម្ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស** តាមរយៈ៖ (១)-ការគិតគូរឡើងវិញនូវគោលនយោបាយរយៈពេលវែង និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីចំពោះវិស័យសំខាន់ៗមួយចំនួននៅក្នុងសេដ្ឋកិច្ច និងធ្វើពិពិធកម្មវិស័យទាំងនោះឱ្យកាន់តែខ្លាំងក្លា ជាពិសេសវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដើម្បីជំរុញសន្ទុះនៃកំណើនផង និងរក្សាចីរភាពនៃកំណើនផង (២)-ការចាត់វិធានការមុតស្រួចមួយចំនួន សំដៅកាត់បន្ថយថ្លៃម្ហូបអាហារផង និងរក្សាស្ថិរភាពថ្លៃម្ហូបអាហារនៅលើទីផ្សារផង (៣)-ការបន្តដោះស្រាយបញ្ហាថ្លៃធ្វើធុរកិច្ចនៅខ្ពស់នៅកម្ពុជា ដោយធ្វើការពិនិត្យទៅលើបញ្ហាបទប្បញ្ញត្តិ និងនីតិវិធីនៃការអនុវត្ត រួមទាំងគុណភាព និងចំណាយលើសេវាសាធារណៈ ដើម្បីកែលម្អបរិស្ថានវិនិយោគនិងធុរកិច្ចឱ្យកាន់តែប្រសើរឡើង ដើម្បីការទាក់ទាញបន្ថែមទៀតនូវការវិនិយោគថ្មីៗពីបរទេស ក៏ដូចជាដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគក្នុងស្រុក និង (៤)-ការបន្តកែទម្រង់វិស័យសាធារណៈ និងពន្លឿនការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍជំនាញកម្រិតទាប មធ្យម និងខ្ពស់ សំដៅគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មឱ្យកាន់តែខ្លាំងក្លាជាងមុន និងការជំរុញការបែងចែកផ្លែផ្កាពីកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបរិយាប័ន្ន តាមរយៈ**ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥** ដើម្បីឈានទៅកសាងប្រព័ន្ធគាំពារសង្គមមួយដែលមានប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ សម្រាប់បម្រើឱ្យគោលនយោបាយកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សឱ្យកាន់តែរឹងមាំ និងទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## I.២.ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ២០១៨

**១៣**- ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ២០១៨ មានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តពង្រឹងយ៉ាងមុឺងម៉ាត់ និងដាច់ខាតនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងភាពសុខដុមរមនាក្នុងសង្គម ក៏ដូចជាភាពសុខក្សេមក្សាន្តរបស់ប្រជាជន

- បន្តជានានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ ដល់ប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់
- បន្តជានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% ប្រកបដោយបរិយាប័ន្ន និងចីរភាព ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេសសម្រាប់ស្រទាប់យុវជន និងដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ និងបង្កើនចំណូលថវិកាជាតិផងដែរ
- បន្តជានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងឱ្យបាននូវអតិផរណា និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ
- បន្តផ្តល់អាទិភាពដល់ការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីសម្រេចឱ្យបាននូវគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (២០១៥-២០១៨) ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- គាំទ្រដល់ការអនុវត្តកម្មវិធីថ្មីៗមួយចំនួនលើវិស័យសង្គមកិច្ច ក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ឱ្យចេញជាលទ្ធផលផ្លែផ្កាបណ្តើរៗ ជាពិសេសពាក់ព័ន្ធនឹងការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ការផ្តល់និងបង្កើនប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាស្ត្រីនៅពេលសម្រាលកូន និងសម្រាកលំហែមាតុភាព ការបង្កើនប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ការផ្តល់ការថែទាំសុខភាពសម្រាប់កម្មករ និងការផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី ស្របពេលជាមួយគ្នានឹងការអនុវត្តគោលនយោបាយជាតិមនុស្សចាស់ឆ្នាំ២០១៧-២០៣០
- បន្តកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល តាមរយៈការជំរុញអនុវត្តវិធានការនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ជាពិសេសគឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ ដូចសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទន្ទឹមនឹងបន្តការកែសម្រួលនីតិវិធី និងសេវាពាក់ព័ន្ធនឹងការបង់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ និងកាន់តែងាយស្រួល មានយុត្តិធម៌ និងកាន់តែមានអភិបាលកិច្ចខ្ពស់
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងដោយថាហេតុ និងបង្កើនចំណាយវិនិយោគផ្ទាល់ដោយថវិកាជាតិ ដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល និងអាហារូបត្ថម្ភ

- បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់ សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេសផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យជាដើម ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ជាពិសេសទូរគមនាគមន៍ សម្រាប់កសាងមូលដ្ឋានគ្រឹះក្នុងការឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា
- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញផលិតផលកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងសកម្មភាពអភិវឌ្ឍន៍វិស័យកសិកម្ម ដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាៈ ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជម្ងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច
- បន្តជំរុញការអនុវត្តគោលនយោបាយ**អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥**
- បន្តអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ**ឆ្នាំ២០១៥-២០១៨** ដើម្បីរក្សាចីរភាពនៃបំណុលសាធារណៈផង ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់គាំទ្រដល់កំណើន ផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា ដែលមានទំហំកាន់តែធំស្របទៅតាមដំណាក់កាលនៃភាពរីកចម្រើនលូតលាស់របស់សេដ្ឋកិច្ចជាតិ
- គាំទ្រដល់ការអនុវត្តកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល២០១៨-២០២០
- គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងទទួលបានលទ្ធផលផ្លែផ្កាជាក់ស្តែងកាន់តែច្រើនថែមទៀត រួមទាំងការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ជាពិសេសការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជាដើម្បីផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជនទូទៅ និង
- ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦។

**១៤**- ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗ នៃក្របខ័ណ្ឌគោលនយោបាយខាងលើនេះ ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយឈរលើ**អភិក្រម** និង**គោលការណ៍** ដូចខាងក្រោម៖

*ទី១.* គោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានកំណត់ និងធានាឱ្យបាននូវនិរន្តរភាពនៃកិច្ចប្រតិបត្តិការរបស់រដ្ឋ ក៏ដូចជាទ្រទ្រង់ដល់ដំណើរឈានឡើងឥតឈប់ឈររបស់កម្ពុជា ក្នុងរយៈពេលមធ្យម និងវែងតទៅមុខ

*ទី២.* បន្តប្រឹងប្រែងប្រមូលចំណូលឱ្យអស់លទ្ធភាព និងអស់សក្តានុពល តាមរយៈការជំរុញអនុវត្តបញ្ចប់នូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨** ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីបន្តធានាចីរភាព និងសមិទ្ធកម្មនៃចំណូល ទន្ទឹមនឹងការបន្តគោលនយោបាយលុបពន្ធ និងបន្ធូរបន្ថយពន្ធ សម្រាប់អ្នកមានចំណូលទាប និងអ្នករកស៊ីតូចតាច ដោយផ្អែកទៅលើសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ស្របតាមស្ថានភាពជាក់ស្តែងនៃសង្គម-សេដ្ឋកិច្ចកម្ពុជា តែមិនឱ្យរាតពីការអនុវត្តអនុលោមភាពពន្ធ

*ទី៣.* **បន្តរក្សាតុល្យភាព និងចីរភាពថវិកា** តាមរយៈការរៀបចំក្របខ័ណ្ឌចំណាយផ្អែកលើលទ្ធភាពថវិកា ដោយផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព និងកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ជាពិសេសលើសកម្មភាពការងារណាដែលផ្តល់ផលភ្លាមៗ ដើម្បីផ្តល់ការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាការពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ

*ទី៤.* បន្តបង្កើនប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសតាមរយៈការដាក់ឱ្យអនុវត្តនូវថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួងស្ថាប័នរបស់រដ្ឋ ដោយក្នុងនោះ រួមទាំងការបន្តការយកចិត្តទុកដាក់លើមនុស្ស និងការបង្កើនការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្តការងារផ្ទាល់នៅក្រោមឱវាទក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ទាំងលើការអនុវត្តចំណាយ ទាំងលើសមិទ្ធកម្មការងារ ក៏ដូចជាដើម្បីពង្រឹងគុណភាពសេវាសាធារណៈដែលផ្តល់នូវអត្ថប្រយោជន៍និងផលប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋទូទៅ

*ទី៥.* **បន្តអនុវត្តគោលនយោបាយវិត្តារកម្មថវិកាដោយប្រយ័ត្នប្រយែង ដោយបន្តធ្វើវិចារណកម្ម និងវិតត្ថិតចំណាយ** តាមរយៈការបន្តនូវភាពម៉ឺងម៉ាត់ និងការសម្រួចលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ហើយការបង្កើនកំណើនថវិកាត្រូវបានផ្តល់លំដាប់អាទិភាពខ្ពស់បំផុតទៅលើកម្មវិធី/អនុកម្មវិធី/សកម្មភាពណាដែលរំពឹងថា នឹងសម្រេចបានលទ្ធផលជាក់លាក់ នៅក្នុងរយៈពេលខ្លី និងមានប្រសិទ្ធភាពអនុវត្តខ្ពស់ ក្នុងការឆ្លើយតបទៅនឹងអាទិភាពគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល នៅក្នុងឆ្នាំចុងក្រោយ នៃនីតិកាលទី៥ ក៏ដូចជាការកសាងមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរយៈពេលវែង នៅក្នុងនីតិកាលបន្តបន្ទាប់ទៀត

*ទី៦.* **បន្តខិតខំសន្សំសំចៃថវិកា និងលុបបំបាត់ភាពខ្ជះខ្ជាយថវិកា** តាមរយៈការបន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ បរិមាណ គុណភាព និងពេលវេលា នៅក្នុងការ-អនុវត្តកម្មវិធី/អនុកម្មវិធី/សកម្មភាពនានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពចំណាយផង

និងដើម្បីបង្កើតបានជាលម្ហថវិកាខ្លះ សម្រាប់ផ្តល់ការគាំទ្របន្ថែមទៀតដល់សកម្មភាពការងារចាំបាច់មួយចំនួនរបស់រាជរដ្ឋាភិបាលផង

*ទី៧.* ផ្សារភ្ជាប់ការដំឡើងបៀវត្សនិងការកែទម្រង់ប្រព័ន្ធបៀវត្ស ទៅនឹងការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

*ទី៨.* ផ្សារភ្ជាប់រវាងការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ភាពបុរេសកម្ម និងសមិទ្ធកម្មការងារ និងការវិភាជថវិកា តាមរយៈការតឹតតឹតលើការស្នើសុំបង្កើនថវិកា ចំពោះក្រសួងស្ថាប័នណា ដែលការប្រមូលចំណូលមិនអាចសម្រេចបានលទ្ធផលល្អតាមការរំពឹងទុកសមស្របតាមសក្តានុពលជាក់ស្តែង ឬ មានទំហំចំណែកប្រាក់រង្វាន់ធំ ឬ មិនបានផ្តល់ការយកចិត្តទុកដាក់ហ្មត់ចត់ពេញលេញដល់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬ មានការគ្រប់គ្រងធូរលុង ឬ ពុំសម្រេចបាននូវឱ្យនភាពល្អប្រសើរនៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ មិនមានភាពបុរេសកម្មក្នុងការងារ ហើយមិនសម្រេចបាននូវសមិទ្ធកម្មការងារល្អប្រសើរ និង

*ទី៩.* បន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានាចីរភាពថវិកា តាមរយៈការអនុវត្តដោយម៉ឺងម៉ាត់នូវ **យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៥-២០១៨**។

**១៥**- ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម៖

| **សូចនាករថវិកា** | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលក្នុងប្រទេសថវិការដ្ឋ (% ផ.ស.ស.) | ១៧,៨២ | ១៨,៨៩ | ១៨,៥៧ | **១៨,៧៥** |
| - *ចំណូលចរន្ត (% ផ.ស.ស.)* | ១៧,៦៦ | ១៨,៧៤ | ១៨,៤០ | **១៨,៥៧** |
| ចំណាយសរុបថវិការដ្ឋ (% ផ.ស.ស.) | ២២,៧០ | ២២,០៣ | ២៣,៦៣ | **២៤,៥៩** |
| - *ចំណាយចរន្ត (% ផ.ស.ស.)* | ១៤,៦៨ | ១៤,២៨ | ១៥,៤២ | **១៦,០៩** |
| **អតិរេកចរន្ត (% ផ.ស.ស.)** | ២,៩៨ | ៤,៤៦ | ២,៩៨ | **២,៤៨** |
| **ឱនភាពសរុប (% ផ.ស.ស.)** | -៤,៨៧ | -៣,១៣ | -៥,០៧ | **-៥,៨៤** |

តាមក្របខ័ណ្ឌថវិកាខាងលើនេះ ចំណូលក្នុងប្រទេសថវិការដ្ឋ ត្រូវបានគ្រោងចំនួន១៨ ៥៨៧ ០០៣ លានរៀល ត្រូវជា១៨,៧៥%នៃ ផ.ស.ស. និងមានកំណើន១១,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដោយក្នុងនោះ ចំណូលចរន្តថវិការដ្ឋត្រូវបានគ្រោងស្មើនឹង១៨,៥៧%នៃ ផ.ស.ស. ដែលមានកំណើន ០,១៧ពិន្ទុភាគរយនៃ ផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ថ្វីត្បិតតែកំណើននៃចំណូលចរន្តថវិការដ្ឋបង្ហាញថាមិនដល់គោលដៅដែលត្រូវកើន០,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ តែផ្ទុយទៅវិញទំហំចំណូលឆ្នាំ២០១៨ គឺលើសពីគោលដៅចំណូលដែលបានកំណត់ត្រឹមតែ១៧,៣៥%នៃ ផ.ស.ស.

សម្រាប់ឆ្នាំ២០១៨ នៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨**។ ម៉្យាងវិញទៀត ការបង្កើនកំណើននៃចំណូលស្មើនឹង០,១៧ ពិន្ទុភាគរយនៃ ផ.ស.ស. សម្រាប់ឆ្នាំ២០១៨ អាចនិយាយបានថា **នៅតែជាគោលដៅប្រកបដោយសុទិដ្ឋិនិយម** ដោយសារកំណើននេះឈរលើមូលដ្ឋាននៃចំណូលដ៏ខ្ពស់ក្នុងបណ្តាឆ្នាំកន្លងទៅ ដែលកម្រិតនៃចំណូលនេះហាក់ដូចជាបានឈានទៅកៀកនឹងពិដានៃសក្តានុពលទៅហើយ ហើយរាជរដ្ឋាភិបាលពុំមានគោលនយោបាយក្នុងការបង្កើតពន្ធថ្មី ឬបង្កើនអត្រាពន្ធ ក្រៅតែពីការពង្រឹងការអនុវត្តនូវវិធានការខាងផ្នែករដ្ឋបាល និងវិធានការខាងគោលនយោបាយមួយចំនួន មានជាអាទិ៍ ការកែសម្រួលអាករពិសេស សម្រាប់ប៉ះប៉ូវការបាត់បង់ចំណូល ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់។ ទន្ទឹមនឹងនេះ ការដាក់ចេញនូវវិធានការគោលនយោបាយជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ក្នុងគោលដៅកាត់បន្ថយបន្ទុកចំណាយ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ក៏បានធ្វើឱ្យមានការសឹករេចរឹលផងដែរនូវប្រភពចំណូលមួយចំនួន ទាំងចំណូលសារពើពន្ធ និងទាំងចំណូលមិនមែនសារពើពន្ធ ដោយមិនទាន់គិតទៅដល់ការធ្លាក់ចុះចំណូលពន្ធ ដោយសារកាតព្វកិច្ចនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ជាមួយគ្នានេះ គួរកត់សម្គាល់ថា កម្រិតចំណូលឆ្នាំ២០១៨ បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការសម្រេចលុបកម្រៃគ្រប់គ្រងការនាំចេញដែលតាមការប៉ាន់ស្មានមានចំនួន៨២ ៥៤២លានរៀល ឬសមមូលនឹងប្រមាណ២០លានដុល្លារអាមេរិក។ ការលុបកម្រៃគ្រប់គ្រងការនាំចេញនេះ នឹងជួយ៖ (១)-បង្កើនការទាក់ទាញនូវការវិនិយោគថ្មីៗបន្ថែមទៀតនៅកម្ពុជា ដើម្បីរួមចំណែកបន្តលើកស្ទួយកំណើនសេដ្ឋកិច្ច និងបង្កើតការងារកាន់តែច្រើនជូនពលករកម្ពុជា និង (២)-ផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់ក្រុមហ៊ុនវិនិយោគនានាដែលកំពុងតែប្រតិបត្តិការរោងចក្រ/សហគ្រាសនៅកម្ពុជា ក្នុងការដំឡើងប្រាក់ឈ្នួលជូនកម្មករ-កម្មការិនី ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**១៦**- គម្រោងចំណូលថវិកាថ្នាក់ជាតិ មានសមាសធាតុដូចខាងក្រោម ៖

| សូចនាករ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណូលថវិកាថ្នាក់ជាតិសរុប(% ផ.ស.ស.) | ២១,៨៦ | ២២,៩៨ | ២២,៥៥ | ២២,៦៤ |
| ចំណូលក្នុងប្រទេសថ្នាក់ជាតិ(% ផ.ស.ស.) | ១៦,៨១ | ១៧,៨៧ | ១៧,៤៨ | ១៧,៨០ |
| ចំណូលចរន្តថវិកាថ្នាក់ជាតិ(% ផ.ស.ស.) | ១៦,៦៤ | ១៧,៧២ | ១៧,៣២ | ១៧,៦២ |
| ចំណូលមូលធន(% ផ.ស.ស.) | ៥,២២ | ៥,២៦ | ៥,២៣ | ៥,០២ |
| ចំណូលមូលធនក្នុងប្រទេស(% ផ.ស.ស.) | ០,១៦ | ០,១៥ | ០,១៧ | ០,១៨ |
| ចំណូលមូលធនក្រៅប្រទេស(% ផ.ស.ស.) | ៥,០៦ | ៥,១១ | ៥,០៧ | ៤,៨៤ |

ថវិកាឆ្នាំ២០១៨ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង១៧,៨០%នៃ ផ.ស.ស. គឺស្មើនឹង១៧ ៦៤០ ១៩៩លានរៀល ដែលមានកំណើន១២,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ តាមគោលដៅនេះ៖

ក-<u>ចំណូលចរន្តថ្នាក់ជាតិ</u> ត្រូវសម្រេចឱ្យបានចំនួន១៧ ៤៦០ ០០៦លានរៀល ត្រូវជា ១៧,៦២%នៃ ផ.ស.ស. គឺមានកំណើន១២,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

• **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន១៥ ០៧៥ ៥៦២លានរៀល ត្រូវជា១៥,២១% នៃ ផ.ស.ស. គឺមានកំណើន១៤,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនេះ៖

- ចំណូលគយ និងរដ្ឋាករ ត្រូវបានគ្រោងចំនួន៨ ៣៣០ ០០៤លានរៀល ត្រូវជា៨,៤០% នៃ ផ.ស.ស. គឺមានកំណើន១៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន៦ ៧៤៥ ៥៥៨លានរៀល ត្រូវជា៦,៨១%នៃ ផ.ស.ស. គឺមានកំណើន១៤,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

• **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន២ ៣៨៤ ៤៤៤លានរៀល ត្រូវជា២,៤១%នៃ ផ.ស.ស. គឺមានកំណើន៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

- ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន២ ១១៦ ១១១លានរៀល គឺមានកំណើន៦,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧
- ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត និងអាជ្ញាបណ្ណ ត្រូវបានគ្រោងចំនួន ២២៤ ៨៧៥លានរៀល គឺមានកំណើន២៥,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ដោយ-ឡែក កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ ដែលត្រូវបានគ្រោងចំនួន៤៣ ៤៥៨លានរៀលនោះ មានការថយចុះ-៦៥,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧វិញ ដោយសារការលុបចំណូលពីកម្រៃគ្រប់គ្រងការនាំចេញ ក្នុងគោលដៅដូចបានគូសបញ្ជាក់ខាងលើ។

ខ- <u>ចំណូលមូលធន</u> ត្រូវបានគ្រោងចំនួន៤ ៩៧៧ ១៣២លានរៀល ត្រូវជា៥,០២%នៃ ផ.ស.ស. មានកំណើន៦,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

• **ចំណូលមូលធនក្នុងប្រទេស** ដែលជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវសម្រេចឱ្យបានចំនួន១៨០ ១៩៣លានរៀល ត្រូវជា០,១៨% នៃ ផ.ស.ស. គឺមានកំណើន២១,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

• **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន៤ ៧៩៦ ៩៣៩លានរៀល ត្រូវជា ៤,៨៤%នៃ ផ.ស.ស. គឺមានកំណើន៥,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

- មូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន២៥០ ០០០លានរៀល ត្រូវជា០,២៥%នៃ ផ.ស.ស. គឺស្មើនឹងច្បាប់ឆ្នាំ២០១៧
- ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណងនិងពីការខ្ចី ត្រូវបានគ្រោងចំនួន៤ ៥៤៦ ៩៣៩លានរៀល ត្រូវជា៤,៥៩%នៃ ផ.ស.ស. គឺមានកំណើន៦,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

**១៧**- ចំណាយសរុបថវិកាថ្នាក់ជាតិនៅឆ្នាំ២០១៨ ត្រូវបានគ្រោងក្នុងទឹកប្រាក់២៣ ៤២៨ ២៩៨ លានរៀល ស្មើនឹង២៣,៦៤%នៃ ផ.ស.ស. គឺមានកំណើន១៦,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

| សូចនាករ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណាយថវិកាថ្នាក់ជាតិសរុប(% ផ.ស.ស.) | ២១,៦៨ | ២១,០១ | ២២,៥៥ | ២៣,៦៤ |
| ចំណាយចរន្តថ្នាក់ជាតិ(% ផ.ស.ស.) | ១៣,៨៥ | ១៣,៥០ | ១៤,៥៨ | ១៥,៣៥ |
| ចំណាយមូលធនថវិកាថ្នាក់ជាតិ(% ផ.ស.ស.) | ២,៣៩ | ២,១៨ | ២,៤៤ | ២,៩៥ |
| គម្រោងវិនិយោគ | ១,៥២ | ១,៤៤ | ១,៦១ | ២,០៩ |
| បដិភាគវិនិយោគ | ០,៥៦ | ០,៥៨ | ០,៥៥ | ០,៦១ |
| មូលនិធិទ្រទ្រង់ថវិកា | ០,៣១ | ០,១៧ | ០,២៨ | ០,២៥ |
| ការទូទាត់ប្រាក់ខ្ចី | ០,៦៣ | ០,៥៧ | ០,៧៤ | ០,៧៤ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤,៨១ | ៤,៧៦ | ៤,៧៩ | ៤,៥៩ |

**១៨**- ចំណាយចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៨ ត្រូវបានកំណត់ឱ្យស្ថិតក្នុងកម្រិតចំនួន ១៥ ២១៨ ១៦៦លានរៀល ត្រូវជា១៥,៣៥%នៃ ផ.ស.ស. គឺមានកំណើន១៦,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលក្នុងនោះ៖

**ក-ចំណាយលើបន្ទុកបុគ្គលិក** រួមមាន៖ បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភនិវត្តជន លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់ថ្នាក់ដឹកនាំនៃស្ថាប័នសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ មន្ត្រីជាប់កិច្ចសន្យា ត្រូវបានគ្រោងចំនួន៧ ៩១៤ ៩២៤លានរៀល មានសមាមាត្រស្មើនឹង៥២,០%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៧,៩៩%នៃ ផ.ស.ស. គឺមានកំណើន ១៦,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ បានគ្រោងសម្រាប់៖ (១)-ការដំឡើងបៀវត្សមូលដ្ឋាន ក្នុងអត្រា១២,០%ដោយដំឡើងបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍២ ១៣០រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ និង (២)-ការដំឡើងប្រាក់បំណាច់មុខងារនឹងត្រូវអនុវត្តចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០១៨ ទៅតាមកម្រិតនៃប្រាក់បំណាច់មុខងារ ដូចតទៅ៖

- **មន្ត្រីរាជការ នៃក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទ នៃវិស័យរដ្ឋបាល ការទូត បច្ចេកទេស និងផ្សេងៗ៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៣៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥០០ ០០០រៀល និង
  - ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០រៀលឡើងទៅ។
- **មន្ត្រីរាជការ នៃក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលបម្រើការងារក្នុងវិស័យអប់រំ៖**
  - ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥៤០ ០០០រៀល
  - ផ្តល់បន្ថែម៩០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៤០ ០០០រៀល ទៅដល់កម្រិតក្រោម៧៥០ ០០០រៀល និង

- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧៥០ ០០០រៀលឡើងទៅ។

• **មន្ត្រីរាជការ នៃក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទ ដែលបម្រើការងារក្នុងវិស័យសុខាភិបាល៖**

- ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៤៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥៩០ ០០០រៀល
- ផ្តល់បន្ថែម៩០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥៩០ ០០០រៀល ទៅដល់កម្រិតក្រោម៧០០ ០០០រៀល និង
- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៧០០ ០០០រៀលឡើងទៅ។

• **យោធិន៖**

- ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ២៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥០០ ០០០រៀល
- ផ្តល់បន្ថែម៨០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៥០០ ០០០រៀល ទៅដល់កម្រិតក្រោម៦៥០ ០០០រៀល
- ផ្តល់បន្ថែម៦០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ៦៥០ ០០០រៀល ទៅដល់កម្រិតក្រោម១ ៣៤០ ០០០រៀល និង
- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់យោធិនដែលមានប្រាក់បំណាច់មុខងារ ចាប់ពី ១ ៣៤០ ០០០រៀលឡើងទៅ។

• **នគរបាលជាតិ និងអនុរក្សពន្ធនាគារ៖**

- ផ្តល់បន្ថែម១០០ ០០០រៀល សម្រាប់នគរបាលជាតិនិងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី២៥០ ០០០រៀល ទៅដល់កម្រិតក្រោម៥០០ ០០០រៀល
- ផ្តល់បន្ថែម៨០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី៥០០ ០០០រៀល ទៅដល់កម្រិតក្រោម៦៥០ ០០០រៀល
- ផ្តល់បន្ថែម៦០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី៦៥០ ០០០រៀល ទៅដល់កម្រិតក្រោម១ ៤៤០ ០០០ រៀល និង
- ផ្តល់បន្ថែម៤០ ០០០រៀល សម្រាប់នគរបាលជាតិ និងអនុរក្សពន្ធនាគារដែលមានប្រាក់បំណាច់មុខងារ ចាប់ពី១ ៤៤០ ០០០រៀលឡើងទៅ។

ដូច្នេះ តាមរយៈការដំឡើងប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារខាងលើនេះ នឹងធ្វើឱ្យរាជរដ្ឋាភិបាលអាចសម្រេចបាននូវអាទិភាពគោលនយោបាយខ្ពស់បំផុតរបស់ខ្លួន ក្នុងការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យបានជាង១លានរៀលនៅឆ្នាំ២០១៨ ទៅតាមការគ្រោងទុកតាំងពីដើមនីតិកាលមក ដោយអាចធានាមិនឱ្យមានបច្ច័យប៉ះពាល់ដល់ចីរភាពថវិកា និងស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ចជារួម។ កំណើនប្រាក់បៀវត្សនេះ មិនត្រឹមតែបានជួយលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធតែមួយមុខទេ តែថែមទាំងបានលើកកម្ពស់ប្រសិទ្ធភាព

នៃសេវាធារណៈឱ្យកាន់តែប្រសើរឡើងផងដែរ។ នៅក្នុងក្របខ័ណ្ឌនេះ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៅក្នុងឆ្នាំ២០១៨ នឹងត្រូវបានដំឡើងដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវដំឡើងពីចំនួន៨៥៣ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ៩១៤ ៤៥០រៀល នៅខែមករា ឆ្នាំ២០១៨ ហើយចាប់ពីខែមេសា ឆ្នាំ ២០១៨ នឹងត្រូវដំឡើងដល់ប្រមាណ១ ០១៤ **៤៥០រៀល** ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែប្រមាណ៣៤៤ ០០០រៀល
- **បៀវត្សគ្រូបង្រៀន** នឹងត្រូវដំឡើងពីចំនួន៩៥៣ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ១ ០១៤ ៤៥០រៀល នៅខែមករា ឆ្នាំ២០១៨ ហើយចាប់ពីខែមេសា ឆ្នាំ ២០១៨ នឹងត្រូវដំឡើងដល់ប្រមាណ១ ១១៤ **៤៥០រៀល** ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែប្រមាណ៤០០ ០០០រៀល
- **បៀវត្សគ្រូពេទ្យ** នឹងត្រូវដំឡើងពីចំនួន៩៥៣ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ១ ០១៤ ៤៥០រៀល នៅខែមករា ឆ្នាំ២០១៨ ហើយចាប់ពីខែមេសា ឆ្នាំ ២០១៨ នឹងត្រូវដំឡើងដល់ប្រមាណ១ ១១៤ **៤៥០រៀល** ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែប្រមាណ៣៦០ ០០០រៀល
- **បៀវត្សនគរបាល** (ពលបាលត្រី) នឹងត្រូវដំឡើងពីចំនួន៩៣៧ ៩៧៧រៀល នៅឆ្នាំ ២០១៧ ដល់ប្រមាណ៩៩៨ ៩២៧រៀល នៅខែមករា ឆ្នាំ២០១៨ (ដោយគិតបញ្ចូលរបបអង្ករ) ហើយចាប់ពីខែមេសា ឆ្នាំ២០១៨ នឹងត្រូវដំឡើងដល់**១ ០៩៨ ៩២៧រៀល** (ដោយគិតបញ្ចូលរបបអង្ករ) ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៣៨០ ០០០ រៀល និង
- **បៀវត្សយោធិន** (ពលទោ) នឹងត្រូវដំឡើងពីចំនួន៨២២ ៥០០រៀល នៅឆ្នាំ២០១៧ ដល់ប្រមាណ៨៧៦ ៥៥០រៀល នៅខែមករា ឆ្នាំ២០១៨ (មិនគិតបញ្ចូលរបបអង្ករ) ហើយចាប់ពីខែមេសា ឆ្នាំ២០១៨ នឹងត្រូវដំឡើងដល់ប្រមាណ៩៧៦ ៥៥០រៀល (មិនគិតបញ្ចូលរបបអង្ករ) ហើយបើគិតបញ្ចូលរបបអង្ករត្រូវជាប្រមាណ**១ ០៣៥ ០២៧ រៀល** ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែប្រមាណ៣១៦ ០០០រៀល។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធជាង១លានរៀល **រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន៣០ ០០០លានរៀល សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន**។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន២ទៀត ដោយអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៨ ដែលរួមមាន៖

- **ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាព ដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រី** ដោយបង្កើនពី៦០០ ០០០រៀលទៅចំនួន៨០០ ០០០រៀល សម្រាប់ការសម្រាលបានកូនមួយ និងចំនួន១ ៦០០ ០០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះពីរ និងចំនួន២ ៤០០ ០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះបី។

- ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ដោយក្នុងម្នាក់ៗ ត្រូវបានដំឡើងពីចំនួន១ ២០០ ០០០រៀល ទៅ២ ០០០ ០០០រៀល ចំពោះមរណភាពដោយជម្ងឺធម្មតា និងដំឡើងពីចំនួន១ ៥០០ ០០០រៀល ទៅ៤ ០០០ ០០០រៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ។

ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន៣៥ ០០០លានរៀលផងដែរ សម្រាប់បន្ថែមជូនដល់និវត្តជន ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយដំឡើងរបបសោធនប្រចាំខែទាបបំផុតពី៤២០ ០០០រៀល ឱ្យឡើងដល់៤៨០ ០០០រៀលក្នុងមួយខែ ព្រមទាំងគ្រោងផ្តល់បន្ថែមចន្លោះពី២០ ០០០រៀល ទៅ៤០ ០០០រៀល ជូននិវត្តជន ដោយផ្អែកលើកម្រិតរបបសោធនប្រចាំខែ ហើយគ្រោងអនុវត្តចាប់ពីខែមេសា ឆ្នាំ២០១៨ ។ ប្រការនេះនឹងជួយកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់។

ក្រៅពីការដំឡើងប្រាក់សោធននិវត្តន៍ជូននិវត្តជន ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា ក៏នឹងត្រូវបានដំឡើងពីចំនួន៥០០ ០០០រៀល នៅឆ្នាំ២០១៧ ដល់ចំនួន៦០០ ០០០រៀល នៅឆ្នាំ២០១៨ ផងដែរ។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន៧ ៣០៣ ២៤៣លានរៀល មានសមាមាត្រ៤៨,0%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៧,៣៧%នៃ ផ.ស.ស. គឺមានកំណើន ១៦,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

**១៩- ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជន៍តាមវិស័យ គ្របដណ្តប់លើក្រសួងស្ថាប័នទាំង ៣៩ ហើយនៅកម្រិតក្រសួងស្ថាប័ននីមួយៗវិញ ត្រូវបានធ្វើការវិភាជបន្តទៅតាមកម្មវិធី អនុកម្មវិធី រហូតដល់ចង្កោមសកម្មភាព តាមរយៈការឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិការសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ ដូចតទៅ៖**

**១-វិស័យរដ្ឋបាលទូទៅ:** ត្រូវបានគ្រោងចំនួន២ ២៦៣ ៣០៤លានរៀល មានសមាមាត្រស្មើនឹង១៤,៩%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា២,២៨%នៃ ផ.ស.ស. គឺមានកំណើន១៣,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ (១)-**សម្រាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** ត្រូវបានគ្រោងចំនួន២០៨ ៥២៤លានរៀល មានសមាមាត្រស្មើនឹង១,៤%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ គឺមានកំណើន១៥,២%ធៀបនឹងច្បាប់ឆ្នាំ២០១៧ និង (២)-**សម្រាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ត្រូវបានគ្រោងចំនួន១៥០ ១០៣លានរៀល មានសមាមាត្រស្មើនឹង១,0%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា0,១៥%នៃ ផ.ស.ស. គឺមានកំណើន ១១,៤% ធៀបនឹងច្បាប់ឆ្នាំ២០១៧។

*អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើ៖*

- *ការគាំទ្រដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឱ្យប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌ ។*

- *ការបន្តគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ:២០១៥-២០១៨ ជាពិសេសការបណ្តុះបណ្តាលមន្ត្រីរាជការ ដើម្បីកសាងរដ្ឋបាលសាធារណៈឱ្យកាន់តែមានភាពឆ្លើយតប មានប្រសិទ្ធភាព ប្រសិទ្ធផល និងជឿទុកចិត្ត*
- *ការគាំទ្រដល់អន្តរាគមន៍ដោយផ្ទាល់របស់រដ្ឋ ទាំងក្នុងវិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច*
- *ការបន្តគាំទ្រដល់ការបែងចែកដីសម្បទានសង្គមកិច្ច និងការដោះស្រាយទំនាស់ដីធ្លី*
- *ការជំរុញការបន្តចុះបញ្ជី និងការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ជនជាតិដើមភាគតិច*
- *ការបន្តគាំទ្រនិងពង្រឹងការងារសម្របសម្រួលតាមដាននិងត្រួតពិនិត្យការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥*
- *ការបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ*
- *ការបន្តគាំទ្រដល់អគ្គលេខាធិការដ្ឋសភា និងព្រឹទ្ធសភា សម្រាប់អនុវត្តនូវមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព*
- *ការបន្តគាំទ្រដល់សវនកម្មផ្ទៃក្រៅ ដើម្បីរួមចំណែកលើកស្ទួយអភិបាលកិច្ច និងការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និង*
- *ការគាំទ្រដល់កិច្ចដំណើរការរបស់វិទ្យាស្ថានការទូតនិងការសិក្សាអន្តរជាតិ ក៏ដូចជាការបន្តគាំទ្រដល់កិច្ចការពារ និងជួយសង្គ្រោះពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស ជាពិសេសស្ត្រីខ្មែរដែលត្រូវរងគ្រោះដោយការឆបោក និងការជួញដូរផ្លូវភេទ។*

**២-វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងចំនួន៣ ៨៩៤ ៣៧៦ លានរៀល មានសមាមាត្រស្មើនឹង២៥,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៣,៩៣%នៃ ផ.ស.ស. គឺមានកំណើន១៦,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ (១)-**សម្រាប់ក្រសួងការពារជាតិ** ត្រូវបានគ្រោងចំនួន២ ១៩៨ ៣៧៨លានរៀល មានសមាមាត្រស្មើនឹង១៤,៤%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា២,២២%នៃ ផ.ស.ស. គឺមានកំណើន១៨,៤%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ សមាមាត្រនៃចំណាយបន្ទុកបុគ្គលិកមានចំនួនរហូតទៅដល់៨៤,៨%នៃចំណាយសរុបរបស់ក្រសួង ហើយចំណែកនៃចំណាយមិនមែនបន្ទុកបុគ្គលិកវិញ មានត្រឹមតែចំនួន១៥,២% (២)-**សម្រាប់ក្រសួងមហាផ្ទៃ** ត្រូវបានគ្រោងចំនួន១ ៥៥៧ ៦៧៧លានរៀល មានសមាមាត្រស្មើនឹង១០,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៥៧%នៃ ផ.ស.ស. គឺមានកំណើន១៤,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ **ផ្នែកសន្តិសុខសាធារណៈ** ត្រូវបានគ្រោងចំនួន១ ៣៩៤ ០៩៥លានរៀល មានសមាមាត្រស្មើនឹង៩,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៤១%នៃ ផ.ស.ស. គឺមានកំណើន១២,៥%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ សមាមាត្រនៃចំណាយបន្ទុកបុគ្គលិកមានចំនួនរហូតទៅដល់៦៦,៧%នៃចំណាយសរុប និងមានកំណើនប្រមាណ១១,១%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ហើយចំណែកនៃចំណាយមិនមែនបន្ទុកបុគ្គលិកវិញ មានត្រឹមតែចំនួន២២,៧% និង (៣)-**សម្រាប់ក្រសួងយុត្តិធម៌** ត្រូវបានគ្រោងចំនួន ១៣៨ ៣២១លានរៀល មានសមាមាត្រស្មើនឹង០,៩%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា០,១៤% នៃ ផ.ស.ស. គឺមានកំណើន១៨,៥%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

*អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើ៖*

- *ការបន្តបង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ ក្នុងគោលដៅធានាឱ្យបាននូវប្រព័ន្ធយុត្តិធម៌មួយ ដែលអាចជឿទុកចិត្តបាន និងមានស្ថិរភាព សម្រាប់ការលើកស្ទួយការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការពង្រឹងគោលការណ៍នីតិរដ្ឋក្នុងលទ្ធិប្រជាធិបតេយ្យសេរី ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្ត សម្រាប់ទាក់ទាញការវិនិយោគ*
- *ការបន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគាត់ តាមផ្លូវតុលាការ*
- *ការបង្កើនការគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ*
- *ការបន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខមាលភាពកងកម្លាំងប្រដាប់អាវុធ រួមទាំងការហ្វឹកហ្វឺន និងការបំពាក់មធ្យោបាយចាំបាច់នានា ក្នុងបុព្វហេតុបន្តធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាពនូវអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខក្សេមក្សាន្តរបស់ប្រជាជន*
- *ការគាំទ្រដល់ការសាងសង់ទីលានហ្វឹកហ្វឺន សម្រាប់បម្រើឱ្យការហ្វឹកហ្វឺនផង និងសម្រាប់ត្រៀមទទួលធ្វើជាម្ចាស់ផ្ទះនូវព្រឹត្តិការណ៍បាញ់គ្រាប់ពិត ទាំងកម្រិតតំបន់ និងអន្តរជាតិផង*
- *ការបន្តបង្កើនការគាំទ្រដល់ការបណ្តុះបណ្តាលមន្ត្រីនគរបាល និងមន្ត្រីពន្ធនាគារ*
- *ការបន្តគាំទ្រដល់ការផលិតលិខិតឆ្លងដែន និងប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋ*
- *ការបន្តគាំទ្រដល់កិច្ចការសន្តិសុខជាតិ សកម្មភាពការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងការគាំទ្រដល់ការរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន នៅតាមគ្រប់មាត់ច្រកព្រំដែននៅទូទាំងប្រទេស*
- *ការបន្តគាំទ្រដល់ការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព និង*
- *ការបង្កើនការគាំទ្រដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការផ្តល់ការគាំទ្រដល់ការពង្រឹងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន។*

**៣-វិស័យសង្គមកិច្ច:** ត្រូវបានគ្រោងចំនួន៥ ៦៥៨ ៩៥៩លានរៀល មានសមាមាត្រស្មើនឹង ៣៧,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា៥,៧១%នៃ ផ.ស.ស. គឺមានកំណើន១៧,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ **ពោលគឺ វិស័យនេះនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី១ នៅក្នុងការវិភាជថវិកាជាតិឆ្នាំ២០១៨** ក្នុងនោះ (១)-**សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានគ្រោងចំនួន ២ ៧០៥ ៤៥៧លានរៀល មានសមាមាត្រស្មើនឹង១៧,៨%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ២,៧៣%នៃ ផ.ស.ស. គឺមានកំណើន១៣,៥%ធៀបនឹងច្បាប់ឆ្នាំ២០១៧ **ដែលនឹងធ្វើឱ្យចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០១៨ ឡើងដល់ប្រមាណ៣ ៤៣៨ ០០៨លានរៀល ត្រូវជា** ៣,៤៧%នៃ ផ.ស.ស. (២)-**សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ត្រូវបានគ្រោងចំនួន ២០៩ ៣៥៩លានរៀល មានសមាមាត្រស្មើនឹង១,៤%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា០,២១%

នៃ ផ.ស.ស. គឺមានកំណើន១០,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧ (៣)-សម្រាប់ក្រសួងសុខាភិបាល ត្រូវបានគ្រោងចំនួន១ ៣៩៣ ៩៧៤លានរៀល មានសមាមាត្រស្មើនឹង៩,២%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៤១%នៃ ផ.ស.ស. គឺមានកំណើន១៦,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលនឹងធ្វើឱ្យចំណាយសរុបរបស់ក្រសួងសុខាភិបាលនៅឆ្នាំ២០១៨ ឡើងដល់ប្រមាណ១ ៩៦៧ ៨៥១លានរៀល ត្រូវជា១,៩៩%នៃ ផ.ស.ស. និង (៤)-សម្រាប់ក្រសួងបរិស្ថាន ត្រូវបានគ្រោងចំនួន៨២ ៣៥៧លានរៀល មានសមាមាត្រស្មើនឹង០,៥%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា០,០៨%នៃ ផ.ស.ស. គឺមានកំណើន៣៣,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ដូចនេះ ជានិន្នាការ គឺទំហំចំណាយរបស់វិស័យសង្គមកិច្ចមានការកើនឡើងខ្លាំងជាងគេ ធៀបជាមួយនឹងវិស័យផ្សេងៗទៀត។

*អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើ៖*

*ទី១- ការបន្តគាំទ្រដល់ការពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ ព្រមទាំងការអប់រំកាយ និងកីឡា ជាពិសេសការបន្តកែទម្រង់ក្នុងវិស័យអប់រំ និងការពន្លឿនការអភិវឌ្ឍវិស័យអប់រំ តាមរយៈ៖*

- *ការបន្តផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ(ដោយក្នុងម្នាក់ទទួលបានថវិកាចំនួន២៤០ ០០០រៀលក្នុង១ឆ្នាំ) ព្រមទាំងនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ដោយក្នុងម្នាក់ទទួលបានថវិកាចំនួន៣៦០ ០០០ រៀលក្នុង១ឆ្នាំ) ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស និងសម្រាលបន្ទុកចំណាយរបស់មាតាបិតា និងអាណាព្យាបាលសិស្ស ជាពិសេសដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រឱ្យទទួលបាននូវការអប់រំ ដោយស្មើភាព*
- *ការគាំទ្រដល់ការសិក្សារបស់សិស្សពិការ គ ថ្លង់ និងខ្វាក់*
- *ការគាំទ្រដល់ចំណាយប្រតិបត្តិការមត្តេយ្យសហគមន៍ ដើម្បីជំនួសហិរញ្ញប្បទានដែលធ្លាប់ផ្តល់ដោយដៃគូអភិវឌ្ឍន៍*
- *ការបន្តគាំទ្រដល់ការសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀន ដើម្បីបន្តលើកកម្ពស់អនាម័យរបស់សិស្សានុសិស្សទូទៅ ជាពិសេសជួយសម្រួលដល់ការសិក្សារបស់សិស្សស្រី*
- *ការបន្តវិនិយោគលើការកសាងអគារសិក្សា និងការជួសជុលថែទាំអគារសិក្សា ជាពិសេសនៅតាមមណ្ឌលប្រលងនានាទូទាំងប្រទេស រួមទាំងការបំពាក់តុ កៅអី តាមសាលារៀន*
- *ការបន្តគាំទ្រដល់កិច្ចដំណើរការរបស់សាលារៀន និងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនៅតាមសាលារៀន តាមរយៈ៖ (១)-ការបន្តផ្តល់ថវិកាដំណើរការដល់ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ចំនួន២៤លានរៀល ក្នុង១ឆ្នាំ (២)-ការបន្តលើកកម្ពស់ប្រសិទ្ធភាពការងាររដ្ឋបាលនៅតាមសាលារៀន និង (៣)-ការបង្កើនថវិកាដំណើរការសាលារៀនចំនួន១ ៥០០ពាន់រៀល ក្នុង១សាលារៀន ដែលធ្វើឱ្យថវិកាដំណើរការសាលារៀនកើនឡើងដល់ប្រមាណ៨០ប៊ីលានរៀលនៅឆ្នាំ២០១៨*
- *ការបន្តគាំទ្រដល់ការលើកកម្ពស់គុណភាពគ្រូឧទ្ទេស តាមរយៈការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ចំពោះមុខជំនាញចាំបាច់មួយចំនួន*

- *ការគាំទ្រដល់កម្មវិធីបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀន*
- *ការគាំទ្រដល់ការកែលម្អ និងការសាងសង់សាលាគរុកោសល្យភូមិភាគនៅតាមខេត្ត*
- *ការបន្តគាំទ្រដល់ការកែទម្រង់ការប្រឡង ការកែទម្រង់កម្មវិធីសិក្សា និងការបោះពុម្ពសៀវភៅសិក្សាគោល រួមទាំងការពង្រឹងប្រសិទ្ធភាពនៃការចែកចាយ*
- *ការបន្តបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដើម្បីផ្តល់ជម្រើសដល់សិស្សដែលរៀនចប់មធ្យមសិក្សាបឋមភូមិ អាចមានលទ្ធភាពបន្តការសិក្សាជំនាញបច្ចេកទេស ដែលអាចរកការងារធ្វើបានសមរម្យ*
- *ការបន្តពង្រីកសាលារៀនជំនាន់ថ្មី*
- *ការបន្តលើកកម្ពស់គុណភាពឧត្តមសិក្សា ជាពិសេសការគាំទ្រដល់ការសិក្សា និងស្រាវជ្រាវលើមុខជំនាញវិជ្ជាវិទ្យាសាស្ត្រពិត បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM) និង*
- *ការបន្តលើកកម្ពស់កីឡា ការរៀបចំការប្រកួតកីឡាជាតិលើកទី២ ពិសេសការហ្វឹកហាត់សម្រាប់ត្រៀមក្នុងការទទួលធ្វើម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមនៅឆ្នាំ២០២៣។*

*ទី២- ការបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ជាពិសេសការជំរុញអនុវត្តនូវគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ជាពិសេសនៅក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការអភិវឌ្ឍវិស័យការងារ ស្របតាមគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ តាមរយៈ៖*

- *ការបន្តគាំទ្រដល់ការបណ្តុះបណ្តាលបច្ចេកទេសជំនាញរយៈពេលពី១ឆ្នាំ ដល់៣ឆ្នាំ (C1, C2, & C3) ជូនដល់យុវជន ដោយក្នុងនោះ រួមទាំងមានការផ្តល់អាហារូបករណ៍ដល់សិក្ខាកាមមកពីគ្រួសារក្រីក្រ លើមុខជំនាញដែលមានតម្រូវការទីផ្សារ និងចាំបាច់មួយចំនួន*
- *ការគាំទ្រដល់ការសាងសង់អគារសិក្សាអភិវឌ្ឍន៍ជំនាញឧស្សាហកម្ម (IDP Building) ដើម្បីផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព ក្នុងការឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយឧស្សាហកម្មនៅកម្ពុជា រួមទាំងការពង្រឹងសមត្ថភាពគ្រូបង្រៀនជំនាញវិជ្ជាជីវៈ និងការកែលម្អកម្មវិធីសិក្សា*
- *ការបន្តគាំទ្រដល់ការបណ្តុះបណ្តាលរយៈពេលខ្លីជូនដល់យុវជន ដើម្បីជួយពួកគេឱ្យអាចបង្កើតមុខរបរដោយខ្លួនឯងផង និងដើម្បីបង្កើនផលិតភាពផង*
- *ការបន្តផ្តល់សេវាស្វែងរកការងារធ្វើជូនយុវជន ទាំងក្នុង និងក្រៅប្រទេស*
- *ការគាំទ្រដល់ពលករខ្មែរ ដែលកំពុងតែធ្វើការនៅក្រៅប្រទេស ទាំងស្របច្បាប់ និងទាំងមិនទាន់បានចុះបញ្ជី*
- *ការគាំទ្រដល់ការពង្រឹងការគ្រប់គ្រងពលកររដ្ឋាភិបាលលើវិស័យ និងការអនុវត្តច្បាប់ការងារឱ្យមានប្រសិទ្ធភាពខ្ពស់ជាង*

- *ការបន្តគាំទ្រដល់ការកសាងសុខដុមនីយកម្មនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ រួមទាំងការផ្តល់ការគាំទ្រដល់សហជីព ការបង្កើតតុលាការការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងគណៈកម្មការប្រឹក្សាការងារ និង*
- *ការបន្តសកម្មភាពការងាររបស់រាជរដ្ឋាភិបាល ក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី តាមបណ្តាពេងចក្រសហគ្រាសនៅទូទាំងប្រទេស ដើម្បីស្វែងយល់ និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី។*

*ទី៣- ការបន្តលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាសុខាភិបាល តាមរយៈ៖*

- *ការបន្តបង្កើនថវិកាដល់មូលនិធិសមធម៌ ដើម្បីផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃជូនដល់ប្រជាជនក្រីក្រ*
- *ការគាំទ្រដល់ការពង្រីកមូលនិធិសមធម៌ សម្រាប់ពង្រីកការផ្តល់សេវាសុខាភិបាលដោយឥតគិតថ្លៃជូនដល់កម្មករ-កម្មការិនី (ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ) ដែលមិនទាន់ស្ថិតក្រោមបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)*
- *ការគាំទ្រដល់ការឧបត្ថម្ភមាតុភាព ដល់កម្មការនិយោជិត ដោយបើកផ្តល់ថវិកាចំនួន ៤០០ ០០០រៀល ចំពោះការសម្រាលកូនមួយ និងថវិកាចំនួន៨០០ ០០០រៀល ចំពោះការសម្រាលបានកូនភ្លោះពីរ និងថវិកាចំនួន១ ២០០ ០០០រៀល បើសម្រាលបានកូនភ្លោះបី*
- *ការបន្តបង្កើនកញ្ចប់ថវិកាប្រតិបត្តិការជូនទៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដោយផ្ទាល់ សម្រាប់បង់ថ្លៃសេវាព្យាបាលជូនប្រជាពលរដ្ឋ ដែលគ្មានលទ្ធភាពបង់ថ្លៃសេវាព្យាបាល និងដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវានៅទីតាំងកន្លែង ដោយក្នុងនោះ (១)-មន្ទីរពេទ្យបង្អែកកម្រិត១ ទទួលបានការបង្កើនថវិកាពីចំនួន១៥០លានរៀល ទៅ២០០លានរៀលក្នុងមួយឆ្នាំ (២)-មន្ទីរពេទ្យបង្អែកកម្រិត២ ទទួលបានការបង្កើនថវិកាពីចំនួន២០០លានរៀល ទៅ២៥០លានរៀលក្នុងមួយឆ្នាំ (៣)-មន្ទីរពេទ្យបង្អែកកម្រិត៣ ទទួលបានការបង្កើនថវិកាពីចំនួន២៥០លានរៀល ទៅ៣០០លានរៀលក្នុងមួយឆ្នាំ និង (៤)-មណ្ឌលសុខភាពទាំងអស់ បន្តទទួលបាននូវថវិកាចំនួន ១២លានរៀល ក្នុងមួយឆ្នាំ។ ដោយឡែក ចំពោះមណ្ឌលសុខភាព ដែលគ្របដណ្តប់ប្រជាជនលើសពី១០០ពាន់នាក់ឡើងទៅ ទទួលបានការបង្កើនថវិកាបន្ថែមចំនួន១២លានរៀល ក្នុងមួយឆ្នាំបន្ថែមទៀត*
- *ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការបំពាក់សម្ភារៈបរិក្ខារបច្ចេកទេសចាំបាច់នានា និងបង្កើនការផ្តត់ផ្តង់ឱសថដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាព ដើម្បីពង្រឹងគុណភាពនៃសេវាសុខាភិបាលជូនប្រជាពលរដ្ឋ និង*
- *ការផ្តល់ថវិកាចំនួន២០ ០០០លានរៀល ជាមូលនិធិទ្រទ្រង់និរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា បន្ថែមលើកញ្ចប់ថវិកាចំនួន៤០ ២៥៩លានរៀល ដែលត្រូវផ្តល់ជូនមន្ទីរពេទ្យគន្ធបុប្ផានៅឆ្នាំ២០១៨ ដើម្បីធានាបានថា មន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវ*

*ស្តង់ដាគុណភាព និងការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃដដែល នៅពេលដែលត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋពេញលេញ។ ប្រការនេះនឹងធ្វើឱ្យការឧបត្ថម្ភសរុបពីថវិការដ្ឋជូនដល់មន្ទីរពេទ្យគន្ធបុប្ផា មានការកើនឡើងជាលំដាប់ដោយមិនទាន់គិតបញ្ចូលនូវទឹកប្រាក់ ដែលទទួលបានពីការលក់សំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ ពីភ្ញៀវទេសចរបរទេសម្នាក់ចំនួន២ដុល្លារអាមេរិក ដែលទឹកប្រាក់សរុបទទួលបានពីការលក់សំបុត្រនេះនឹងកើនឡើងរាល់ឆ្នាំ ស្របទៅតាមកំណើននៃចំនួនភ្ញៀវទេសចរ។*

*ទី៤- អាទិភាពផ្សេងទៀត ក្នុងវិស័យសង្គមកិច្ច រួមមាន៖*

- *ការបន្តផ្តល់ការគាំទ្រដល់ការងារទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ពិសេសការជួយស្ត្រីមានវិបត្តិ ព្រមទាំងគាំទ្រដល់ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ*
- *ការឧបត្ថម្ភគាំទ្រដល់មជ្ឈមណ្ឌលជាតិថែទាំមនុស្សចាស់ មជ្ឈមណ្ឌលជនវិបល្លាសស្មារតី និងការបន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន*
- *ការឧបត្ថម្ភគាំទ្រដល់កិច្ចដំណើរការរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ដែលដៃគូឈប់បន្តផ្តល់ហិរញ្ញប្បទាន និងការបង្កើនការគាំទ្រដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា ដើម្បីបន្តនិរន្តរភាពក្នុងការផ្តល់សេវាជូនជនពិការ រួមទាំងការពង្រីកសកម្មភាពជួយជនពិការក្រីក្រនៅតាមសហគមន៍*
- *ការបន្តគាំទ្រដល់កិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយផ្តោតលើការបន្តឧបត្ថម្ភថវិកាជូនសហគមន៍ការពារព្រៃឈើ និងការបង្កើនការឧបត្ថម្ភគាំទ្រដល់ប្រតិបត្តិការល្បាតការពារបរិស្ថាននិងព្រៃឈើរបស់ឧទ្យានុរក្ស ព្រមទាំងការពង្រឹងនិងពង្រីកសមត្ថភាពមន្ទីរពិសោធន៍ ក្នុងការរីកាគជាតិពុលក្នុងទឹក ដី និងខ្យល់*
- *ការបន្តគាំទ្រដល់ការអភិរក្ស និងការអភិវឌ្ឍប្រាសាទបុរាណនានាដែលបានចុះបញ្ជីជាបេតិកភ័ណ្ឌពិភពលោកួច និងការត្រៀមដាក់បញ្ចូលនូវប្រាសាទបុរាណមួយចំនួនទៀតទៅក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោកបន្ថែមទៀត រួមទាំងការជួសជុលប្រាសាទបុរាណ ដែលជិតដួលរលំ*
- *ការគាំទ្រដល់ការសិក្សាស្រាវជ្រាវ និងការចងក្រងឯកសារស្តីពីសម្បត្តិវប្បធម៌អរូបីដូចជាល្ខោនខោល និងតម្បាញសូត្រខ្មែរ ដើម្បីស្នើសុំដាក់បញ្ចូលក្នុងបញ្ជីបេតិកភ័ណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ រួមទាំងការបន្តគាំទ្រដល់ការបណ្តុះបណ្តាល និងការអភិរក្សវិស័យសិល្បៈបុរាណដល់សិស្សជំនាន់ក្រោយ និង*
- *ការបន្តលើកស្ទួយសុខដុមនីយកម្មសាសនានៅកម្ពុជា។*

**៤-វិស័យសេដ្ឋកិច្ច**: ត្រូវបានគ្រោងចំនួន១ ៣៧៩ ១៨៥លានរៀល មានសមាមាត្រស្មើនឹង ៩,១%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា១,៣៩%នៃ ផ.ស.ស. គឺមានកំណើន៥,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ **សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានគ្រោងចំនួន

២៤៥ ០០៩លានរៀល មានសមាមាត្រស្មើនឹង១,៦%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា០,២៥% នៃ ផ.ស.ស. គឺមានកំណើន១១,៣%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ទន្ទឹមនឹងថវិកាចំណាយចរន្ត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ទទួលបានថវិកាគម្រោងវិនិយោគផ្ទាល់ចំនួន៤០ ០០០លានរៀល សម្រាប់ជំរុញផលិតកម្មស្បៀង និងហេដ្ឋារចនាសម្ព័ន្ធកសិកម្ម។ គួរគូសបញ្ជាក់ផងដែរថា ទោះបីជាក្រសួងសំខាន់ៗនៅក្នុងវិស័យសេដ្ឋកិច្ចនេះ មិនបានទទួលនូវកំណើនចំណាយចរន្តថវិកាថ្នាក់ជាតិច្រើន និងនៅមានទំហំតូចក្តី តែក្រសួងសំខាន់ៗទាំងនេះ ដូចជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសាធារណការនិងដឹកជញ្ជូន រួមទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផង គឺជាស្តាប័នដែលបានស្រូបយកចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស រហូតទៅដល់ជាង៧០% សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា៖ ផ្លូវ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ។

*អាទិភាពសំខាន់ក្នុងវិស័យនេះ គឺផ្តោតទៅលើ៖*

- *ការបន្តលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ និងកសិផលដែលមានសក្តានុពលមួយចំនួនទៀត រួមទាំងការបន្តជំរុញការផលិតពូជស្រូវដែលមានគុណភាព ហើយឆ្លើយតបទៅនឹងតម្រូវការទីផ្សារ*
- *ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត*
- *ការជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម ព្រមទាំងការបន្តជំរុញការដាំដុះបន្លែនៅក្នុងស្រុក ជំនួសឱ្យការនាំចូលជាបណ្តើរៗ*
- *ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងដលផលឱ្យមានប្រសិទ្ធភាព រួមទាំងការឧបត្ថម្ភថវិកាជូនដល់សហគមន៍ព្រៃឈើក្នុងការចូលរួមការពារព្រៃឈើ ក៏ដូចជាការចូលរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ទាំងនោះ*
- *ការជំរុញការស្តារព្រៃឈើឡើងវិញ*
- *ការបង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានវ៉ែគ្រប់ប្រភេទ រួមទាំងអាជីវកម្មខ្នាច់ ត្បូងថ្ម និងលោហធាតុមានតម្លៃ*
- *ការគាំទ្រដល់ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរមៃ ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីកនៅកម្ពុជា*
- *ការជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ*
- *ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ រួមទាំងការបង្កើនកិច្ចអន្តរាគមន៍របស់រដ្ឋ ពេលមានគ្រោះរាំងស្ងួត និងទឹកជំនន់*
- *ការជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍ ព្រមទាំងការឃោសនាផ្សព្វផ្សាយ ដើម្បីទាក់ទាញផង និងជួយបង្កើនតម្លៃបន្ថែមរបស់វិស័យនេះផង*
- *ការបន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា*
- *ការបន្តពង្រឹងការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ*
- *ការបន្តពង្រឹងនូវយន្តការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម។*

- *ការបន្តអភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ រួមទាំងពង្រឹងការអនុវត្ត និង*
- *ការបន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទូរគមនាគមន៍ ជាពិសេសការលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃសេវាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ឈានទៅអនុវត្តសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។*

**៥-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា** ត្រូវបានគ្រោងចំនួន២ ០២២ ៣៤២លានរៀល មានសមាមាត្រស្មើនឹង១៣,៣%នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ហើយត្រូវជា២,០៤%នៃ ផ.ស.ស.។

ចំណាយនេះមួយភាគធំ គឺមានមុខសញ្ញាចំណាយច្បាស់លាស់រួចហើយ តែតម្រូវឱ្យកត់ត្រាក្នុងខ្នង់ចំណាយមិនទាន់បែងចែកនេះសិន ដោយសារការតម្រូវខាងទិដ្ឋភាពបច្ចេកទេស ដែលកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន លើកលែងតែចំណាយត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងមុខចំណាយដូចរៀបរាប់ក្នុងមុខសញ្ញាផ្សេងៗទៀត។ ក៏ប៉ុន្តែចំណាយមានមុខសញ្ញាច្បាស់លាស់នេះ នឹងត្រូវធ្វើការផ្ទេរភ្លាមទៅតាមមុខសញ្ញាចំណាយដែលបានគ្រោងទុក តាមនីតិវិធីហិរញ្ញវត្ថុ ក្រោយពេលដែលច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំចូលជាធរមាន។ ចំណាយមានមុខសញ្ញាទាំងនេះ រួមមានដូចខាងក្រោម៖

- *ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ*
- *ការសងការប្រាក់*
- *ចំណាយចរន្តក្នុងការអនុវត្តគម្រោង*
- *ការត្រៀមបម្រុងសម្រាប់ចំណាយអន្តរាគមន៍របស់រដ្ឋ ក្នុងវិស័យសង្គមកិច្ច-សេដ្ឋកិច្ច*
- *ការដំឡើងប្រាក់ឧបត្ថម្ភជូននិវត្តជន និង*
- *មុខសញ្ញាផ្សេងៗទៀត ដូចជា គ្រោះមហន្តរាយធម្មជាតិ ការងារអធិបតេយ្យ ស្បៀងបម្រុងកម្ពុជា មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ មូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងការងារសន្តិសុខការបោះឆ្នោតជាដើម។ល។*

**២០- ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន៨ ២១០ ១៣២លានរៀល មានសមាមាត្រស្មើនឹង៣៥,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា៨,២៨%នៃ ផ.ស.ស. គឺមានកំណើន១៥,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដោយក្នុងនោះ៖

**១-គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន២ ៩២៥ ៨០០លានរៀល ត្រូវជា២,៩៥%នៃ ផ.ស.ស. គឺមានកំណើន៣៤,០%ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការបង្កើនចំណាយនេះ គឺដើម្បីទ្រទ្រង់ចលនការនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ហើយឱ្យផលប្រយោជន៍ដល់ប្រជាពលរដ្ឋដោយផ្ទាល់ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបំពេញបន្ថែមការវិនិយោគឯកជន ដែលរំពឹងថានឹងមិនមានកំណើនខ្លាំងក្លាដូចបណ្តាឆ្នាំកន្លងទៅ។

*អាទិភាពនៃចំណាយគម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសផ្តោតអាទិភាពទៅលើ៖* ⇘

- *ការកសាង និងជួសជុលផ្លូវថ្នល់ ព្រមទាំងការបន្តស្ពានផ្លូវដែកទិសខាងជើង និងកសាងកំពង់ផែទន្លេ ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្តទាំងនេះ ក្លាយទៅជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ក្នុងគោលដៅលើកកម្ពស់ការប្រកួតប្រជែង និងប្រសិទ្ធភាពសេដ្ឋកិច្ច*
- *ការបន្តស្តារ និងកសាងប្រព័ន្ធជាតសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងជាតសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់ ព្រមទាំងការស្ថាបនាប្រឡាយជើងក្អែប ដើម្បីនាំទឹកពីប្រឡាយមេ មកបញ្ចូលស្រែ*
- *ការជំរុញផលិតកម្មស្បៀង ជាពិសេសការផលិតពូជស្រូវ និងពូជបន្លែ*
- *ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត និង*
- *ការបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលនឹងចូលរួមបង្កើនជំនាញទប់ស្កាត់ចំណាកស្រុក និងចំណាកប្រទេស បង្កើនផលិតភាព និងលើកកម្ពស់ជីវភាពរបស់ប្រជាជននៅជនបទ។*

**២-គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានគ្រោងចំនួន ៤ ៥៤៦ ៩៣៩លានរៀល ត្រូវជា៤,៥៩%នៃ ផ.ស.ស. គឺមានកំណើន៦,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត ១ ០០០លានអេសដេអ៊ែរ ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និងមានទំហំកាន់តែធំឡើងៗ សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ដែលចេះតែរំកិលពីឆ្នាំមុនៗមក និងត្រូវរង់ចាំចុះហត្ថលេខារហូតដល់ជាង១ ៨៩៣លានអេសដេអ៊ែរ ក្នុងវិស័យអាទិភាព តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង ជាពិសេសការសម្រេចឱ្យបាននូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិច១%ក្នុងមួយឆ្នាំ។ កំណើននៃសេចក្តីត្រូវការឥណទានសម្បទាននេះ គឺមួយផ្នែកធំបណ្តាលមកពីនិន្នាការកាន់តែច្រើនរបស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់នូវកម្ចីឥណទានសម្បទាន ជំនួសឱ្យហិរញ្ញប្បទានឥតសំណងដែលខ្លួនធ្លាប់ផ្តល់កន្លងមក ដោយសារការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ច ក្នុងខណៈដែលកម្ពុជាកាន់តែមានសេចក្តីត្រូវការនៅក្នុងវិនិយោគសាធារណៈកាន់តែច្រើនថែមទៀត ស្របទៅតាមការវិឌ្ឍឈានឡើងនៃសេដ្ឋកិច្ចរបស់ខ្លួន។ ជារួមការបង្កើនទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះសមត្ថភាពសងរបស់កម្ពុជាក៏ខ្ពស់ជាងមុនដែរ។ ជាក់ស្តែងបើផ្អែកទៅលើលទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្ទតិនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ គឺបានបង្ហាញថា អនុបាតបំណុលគន្លឹះទាំង៥របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។ ដូចនេះ ផ្អែកតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ គឺកម្ពុជាអាចបង្កើនពិដាននៃការខ្ចីថ្មីរហូតដល់១ ០០០លានអេសដេអ៊ែរបាននៅឆ្នាំ២០១៨ ដោយមិនមានការប៉ះពាល់ដល់ចីរភាពបំណុលសាធារណៈឡើយ ពោលគឺស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមាន **ចីរភាព** និង**ហានិភ័យកម្រិតទាប** នៅក្នុងរយៈពេលមធ្យមដដែល។ ម្យ៉ាងវិញទៀត ការបង្កើន

ពិដានៃការខ្ចីនេះ គឺគ្រាន់តែជាការបំពេញនូវលក្ខខ័ណ្ឌនីតានុកូលភាពក្នុងការខ្ចីប៉ុណ្ណោះ ក្នុងខណៈដែលការចុះហត្ថលេខាខ្ចីប្រាក់ជាក់ស្តែង អាចទាបជាងនេះដូចការអនុវត្តក្នុងបណ្តាឆ្នាំកន្លងទៅ។ ដោយឡែក ចំពោះការដកសាច់ប្រាក់សម្រាប់គម្រោងនីមួយៗវិញ គឺមានរយៈពេលជាមធ្យមប្រមាណពី៣ឆ្នាំ ទៅ៥ឆ្នាំឯណោះ។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីសម្រាប់ឆ្នាំ២០១៨ ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ គឺដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេបាន ក្នុងកម្រិត១ ០០០លានអេសដេអ៊ែរ **នៅក្នុងចំណោមគម្រោងសរុបចំនួន២៦ ដែលមានលក្ខណៈសម្បត្តិរួចរាល់ លើបេក្ខភាពគម្រោងដែលត្រូវរង់ចាំចុះហត្ថលេខាសរុបចំនួន៣១ គម្រោង ដែលមានទឹកប្រាក់សរុបសមមូលនឹង១ ៨៩៣លានអេសដេអ៊ែរ** ដែលរួមមាន៖ ធនាគារពិភពលោកចំនួន៤គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន១០គម្រោង សាធារណរដ្ឋប្រជាមានិតចិនចំនួន៤គម្រោង ប្រទេសជប៉ុនចំនួន២គម្រោង សាធារណរដ្ឋកូរ៉េចំនួន២គម្រោង សាធារណរដ្ឋបារាំងចំនួន២គម្រោង និងសាធារណរដ្ឋឥណ្ឌាចំនួន២គម្រោង **ក្នុងគោលដៅទ្រទ្រង់កំណើនសេដ្ឋកិច្ច ការលើកកម្ពស់ភាពប្រកួតប្រជែង និងផលិតភាពសេដ្ឋកិច្ច ដែលរួមមាន៖**

- **វិស័យថាមពល៖** គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ជំហានទី២ គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញជំហានទី២ ដំណាក់កាលទី២ កម្មវិធីថាមពលដើរ ដោយពន្លឺព្រះអាទិត្យ សម្រាប់ការតភ្ជាប់ជាមួយថាមពលអគ្គិសនី គម្រោងសាងសង់ខ្សែបណ្តាញថាមពលអគ្គិសនីតង់ស្យុង១១៥គីឡូវ៉ុល ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះតម្លៃអគ្គិសនីនៅជនបទ ដើម្បីរួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង
- **វិស័យធារាសាស្ត្រ៖** គម្រោងអភិវឌ្ឍន៍ធនធានទឹកស្ទឹងស្វាហាប់ខេត្តកំពង់ស្ពឺ គម្រោងអភិវឌ្ឍន៍អាងទឹករក្សាខេត្តព្រះវិហារ គម្រោងអភិវឌ្ឍន៍វិស័យធារាសាស្ត្រនិងកសិកម្ម ដំណាក់កាលទី២
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** គម្រោងកែលម្អផ្លូវជាតិលេខ៣ លេខ៤ លេខ៥ គម្រោងអភិវឌ្ឍន៍ផ្លូវពីសំឡូត វាលវែង ទៅដល់កោះកុង គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី៣ ពីផ្លូវជាតិលេខ៥ ទៅផ្លូវជាតិលេខ១ និងគម្រោងកែលម្អការថែទាំផ្លូវ។ល។ និង
- **វិស័យអាទិភាពផ្សេងទៀត៖** គម្រោងក្នុងវិស័យកសិកម្ម សុខាភិបាល ទេសចរណ៍ ការផ្គត់ផ្គង់ទឹកស្អាត និងអប់រំ។

ចំណាយលើការទូទាត់ប្រាក់ខ្ចីនៅក្នុងឆ្នាំ២០១៨ ត្រូវបានគ្រោងមានចំនួន៧៣៧ ៣៩៣លានរៀល ត្រូវដា០,៧៤%នៃ ផ.ស.ស. គឺមានកំណើន១០,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧ សម្រាប់រំលស់បំណុលក្រៅប្រទេស។

**២១**- **គម្រោងចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** (រាជធានី ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់) ឆ្នាំ២០១៨ ត្រូវបានគ្រោងដូចខាងក្រោម៖

| សូចនាករថវិកាថ្នាក់ក្រោមជាតិ | ២០១៦ | | ២០១៧ | ២០១៨ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| ចំណូលចរន្ត (% ផ.ស.ស.) | ១,០២ | ១,០២ | ១,០៨ | ០,៩៦ |
| ចំណាយសរុប (% ផ.ស.ស.) | ១,៦៦ | ១,៧១ | ១,៧៩ | ១,៧០ |
| ចំណាយចរន្ត (% ផ.ស.ស.) | ១,៤៧ | ១,៤៨ | ១,៥៥ | ១,៤៨ |
| ចំណាយមូលធន(% ផ.ស.ស.) | ០,១៩ | ០,២៣ | ០,២៤ | ០,២២ |

• **ចំណូលចរន្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក** ត្រូវបានគ្រោងចំនួន៩៤៦ ៨០៤ លានរៀល មានសមាមាត្រស្មើនឹង៥,១%នៃចំណូលចរន្តថវិការដ្ឋ ត្រូវជា០,៩៦%នៃ ផ.ស.ស. គឺមានការថយចុះ-២,១% ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

- ចំណូលសារពើពន្ធត្រូវបានគ្រោងចំនួន៩១០ ៤៤៣លានរៀល ត្រូវជា០,៩២%នៃ ផ.ស.ស. គឺមានការថយចុះ-១,៧%ធៀបនឹងច្បាប់ឆ្នាំ២០១៧
- ចំណូលមិនមែនសារពើពន្ធត្រូវបានគ្រោងចំនួន៣៦ ៣៦១លានរៀល ត្រូវជា០,០៤% នៃ ផ.ស.ស. គឺមានការថយចុះ-១១,៨%ធៀបនឹងច្បាប់ឆ្នាំ២០១៧។

• **ចំណាយថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់** ត្រូវបានគ្រោងចំនួន១ ៦៨៤ ៦៧៤ លានរៀល មានសមាមាត្រស្មើនឹង៦,៩%នៃចំណាយថវិការដ្ឋសរុប ដែលត្រូវជា១,៧០%នៃ ផ.ស.ស. គឺមានកំណើន៤,៩%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖

ក.**ចំណាយចរន្ត** ត្រូវបានគ្រោងចំនួន១ ៤៦៥ ១២២លានរៀល មានសមាមាត្រស្មើនឹង ៩,២% នៃចំណាយចរន្តថវិការដ្ឋសរុប ដែលត្រូវជា១,៤៨%នៃ ផ.ស.ស. គឺមានកំណើន៥,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ការបង្កើនចំណាយ ដើម្បីអនុវត្តនូវគោលនយោបាយដំឡើងប្រាក់បំណាច់ជូនដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ដែលនឹងធ្វើឱ្យប្រាក់បំណាច់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ចាប់ពីខែមេសា ឆ្នាំ ២០១៨ ត្រូវបានដំឡើង ដូចខាងក្រោម៖

• **ក្រុមប្រឹក្សារាជធានី ខេត្ត៖**

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី១ ២១០ ០០០ រៀល នៅឆ្នាំ២០១៧ ដល់១ ៣៦០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ១ ០០០ ០០០រៀល និង
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នឹងត្រូវបានដំឡើងពី៩៧០ ០០០ រៀល នៅឆ្នាំ២០១៧ ដល់១ ០៨៥ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៨០០ ០០០រៀល។

• **ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖**

- ប្រាក់បំណាច់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី៩៣៥ ០០០ រៀល នៅឆ្នាំ២០១៧ ដល់១ ០៧៥ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៧០០ ០០០រៀល និង
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងត្រូវបានដំឡើងពី៧៥០ ០០០ រៀល នៅឆ្នាំ២០១៧ ដល់៨៦០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៥០០ ០០០រៀល។

• ក្រុមប្រឹក្សាឃុំ សង្កាត់៖

- ប្រាក់បំណាច់មេឃុំ ចៅសង្កាត់ នឹងត្រូវបានដំឡើងពី៨៨០ ០០០រៀល នៅឆ្នាំ ២០១៧ ដល់១ ០៣០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ១៥០ ០០០រៀល
- ប្រាក់បំណាច់ជំទប់ទី១ ទី ២ ចៅសង្កាត់រងទី១ ទី២ នឹងត្រូវបានដំឡើងពី៦៥០ ០០០ រៀល នៅឆ្នាំ២០១៧ ដល់៨០០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ១២០ ០០០រៀល
- ប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវបានដំឡើងពី៥៧០ ០០០រៀល នៅឆ្នាំ២០១៧ ដល់៧០០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ១០០ ០០០រៀល
- ប្រាក់បំណាច់មេភូមិ នឹងត្រូវបានដំឡើងពី២២៥ ០០០រៀល នៅឆ្នាំ២០១៧ ដល់ ២៥០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៦០ ០០០ រៀល
- ប្រាក់បំណាច់អនុប្រធានភូមិនឹងត្រូវបានដំឡើងពី១៨០ ០០០រៀល នៅឆ្នាំ២០១៧ ដល់២០០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៥០ ០០០ រៀល និង
- ប្រាក់បំណាច់សមាជិកភូមិនឹងត្រូវបានដំឡើងពី១៦០ ០០០រៀល នៅឆ្នាំ២០១៧ ដល់ ១៨០ ០០០រៀល នៅឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៤០ ០០០ រៀល។

**ខ.ចំណាយមូលធន** ត្រូវបានគ្រោងចំនួន២១៩ ៥៥២លានរៀល មានសមាមាត្រ៧,០%នៃចំណាយមូលធនដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវជា០,២២%នៃ ផ.ស.ស.។

គម្រោងចំណូលនិងចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ខាងលើបានធ្វើឱ្យមានឱនភាពថវិកាចំនួន៧៣៧ ៨៧០លានរៀល ត្រូវជា០,៧៤%នៃ ផ.ស.ស. ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះមានកំណើន១៥,៦%ធៀបនឹងច្បាប់ឆ្នាំ២០១៧ ក្នុងនោះ៖ (១)-ឧបត្ថម្ភរាជធានី ខេត្ត ចំនួន១៤៨ ៨១៤លានរៀល ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ៧០ ២៧០លានរៀល (២)-ឧបត្ថម្ភក្រុង ស្រុក ចំនួន១៥៥ ០១៥លានរៀល ធៀបនឹងឆ្នាំ

២០១៣ ដែលមានត្រឹមតែ៥៨ ៤០៥លានរៀល និង (៣)-ឧបត្ថម្ភមូលនិធិឃុំ សង្កាត់ ចំនួន ៤៣៤ ០៤១លានរៀល ធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ២០៤ ៤១៨លានរៀល ។

ជារួម ក្របខ័ណ្ឌថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិខាងលើនេះ ត្រូវបានរៀបចំឡើងដោយមានការគិតគូរយ៉ាងល្អិតល្អន់ ឈរលើគោលការណ៍គ្រឹះនៃការបែងចែកថវិកា ហើយកាន់តែមានភាពគ្រប់-ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាជាមួយនឹងក្របខ័ណ្ឌថវិកាថ្នាក់ជាតិ ទាំងក្នុងទិដ្ឋភាពមុខងារ ទាំងក្នុងទិដ្ឋភាពសមត្ថភាព និងរចនាសម្ព័ន្ធស្ថាប័ន ដើម្បីធានាបាននូវចីរភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។ ថ្វីត្បិតតែទំហំថវិកានេះ នៅមានកម្រិតទាបនៅឡើយ ប៉ុន្តែទំហំថវិកានេះបានកើនឡើងយ៉ាងឆាប់រហ័ស ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ និងការផ្តល់អាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលដល់ថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់រដ្ឋបាលឃុំសង្កាត់ ក្នុងទិសដៅធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងប្រសិទ្ធភាព ដោយផ្សារភ្ជាប់ការគិតគូរទៅដល់តុល្យភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ និងគ្រប់ទិសទីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២២**- នៅក្នុងក្របខ័ណ្ឌថវិកាខាងលើ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលនឹងអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ២,៤៨%នៃផ.ស.ស. នៅឆ្នាំ២០១៨ ធៀបនឹងច្បាប់ឆ្នាំ២០១៧ ដែលមាន២,៩៨%នៃ ផ.ស.ស.។ ជាលទ្ធផល ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង-៥,៨៤%នៃ ផ.ស.ស. គឺកើនឡើងពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៧ ដែលស្មើនឹង-៥,០៧%នៃ ផ.ស.ស.។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ៤,៥៩%នៃ ផ.ស.ស. មូលនិធិទ្រទ្រង់ថវិកាប្រមាណជា០,២៥%នៃ ផ.ស.ស. និងប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលប្រមាណ១,០០%នៃ ផ.ស.ស.។

## II- បញ្ហាប្រឈម និងវិធានការក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨

**២៣**- ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួន ទាំងផ្នែកចំណូល ទាំងផ្នែកចំណាយ។ បញ្ហាប្រឈមចម្បងពាក់ព័ន្ធនឹងផ្នែកចំណូល គឺចំណូលនៅមិនទាន់អាចឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការផ្នែកចំណាយនៅឡើយ ទោះបីលទ្ធផលនៃការកៀរគរចំណូលមានការកើនឡើងយ៉ាងខ្លាំង គួរឱ្យកត់សម្គាល់យ៉ាងណាក្តី។ ម្យ៉ាងវិញទៀត ការគ្រោងចំណូលសារពើពន្ធត្រូវបានធ្វើឡើងក្នុងសេណារីយ៉ូសុទិដ្ឋិនិយម ដោយឈរលើមូលដ្ឋាននៃកំណើនមួយក្នុងកម្រិតខ្ពស់ក្នុងបណ្តាឆ្នាំកន្លងទៅ ដែលនាំឱ្យការប្រមូលចំណូលឈានទៅកៀកនឹងពិដានៃសក្តានុពល ក្នុងខណៈដែលរាជរដ្ឋាភិបាលពុំមានគោលនយោបាយបង្កើតពន្ធថ្មី ឬដំឡើងអត្រាពន្ធ ក្រៅពីការពង្រឹងវិធានការខាងផ្នែករដ្ឋបាល និងអនុលោមភាពពន្ធ ដោយលើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ឬ បរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូលពន្ធគយពីការអនុ-វត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ទន្ទឹមនឹងនេះ នៅមានបញ្ហាប្រឈមមួយចំនួនដែលអាចធ្វើឱ្យប៉ះពាល់ដល់ចំណូលពន្ធដារ ដូចជា៖ កិច្ចសហការផ្តល់ព័ត៌មានរវាងអន្តរស្ថាប័នមិនបានទាន់ពេល វប្បធម៌នៃការបង់ពន្ធនៅមានកម្រិត អ្នកជាប់ពន្ធមួយចំនួនគេចវេះពន្ធឬមិនសហការជាមួយរដ្ឋបាលសារពើពន្ធ ការរីកដុះដាល

នៃអាជីវកម្មតាមប្រព័ន្ធអេឡិកត្រូនិក ដែលបង្កជាបញ្ហាស្មុគស្មាញក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធ និងការកើនឡើងនៃប្រតិបត្តិការមានការរៀបចំដើម្បីផ្ទេរថ្លៃក្នុងចំណោមបុគ្គលទាក់ទិនដើម្បីចៀសវាងពន្ធ ព្រមទាំងកង្វះខាតធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។ ជាមួយគ្នានេះ ចំណូលពន្ធគយក៏កាន់តែមានការធ្លាក់ចុះច្រើនដោយសារភាពតូចចង្អៀតនៃមូលដ្ឋានចំណូលគយ កំណើនផលិតផលក្នុងស្រុកជំនួសការនាំចូល និងកំណើននៃការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេង ព្រមទាំងកំណើននៃការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ខណៈអំពើរត់ពន្ធ និងការគេចវេះពន្ធនៅមានវត្តមានខ្លះនៅឡើយ។ លើសពីនេះ ការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធនៅជួបប្រទះនឹងបញ្ហាប្រឈមច្រើននៅឡើយ ដោយសារមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងស្ថាប័នផ្សេងគ្នាច្រើន។ ម៉្យាងវិញទៀត ការសម្រួលផ្តល់នូវការអនុគ្រោះបន្ថែមមួយចំនួនរបស់រាជរដ្ឋាភិបាល ក្នុងពេលកន្លងមក ដើម្បីសមធម៌សង្គម និងជួយគាំពារជីវភាពមន្ត្រីរាជការ ប្រជាពលរដ្ឋទូទៅ និងជំរុញសកម្មភាពសេដ្ឋកិច្ច ក៏បានធ្វើឱ្យមានការសឹករេចរឹលនូវប្រភពចំណូលមួយចំនួនថែមទៀត ទាំងចំណូលសារពើពន្ធ និងទាំងចំណូលមិនមែនសារពើពន្ធ។ រីឯផ្នែកចំណាយវិញ គឺសម្ភាធនៃចំណាយ ទាំងចំណាយបន្ទុកបុគ្គលិក ទាំងចំណាយក្រៅបន្ទុកបុគ្គលិកបានកើនឡើងឥតឈប់ឈរ ដោយសារម្ខាងការផ្តល់អាទិភាពចាំបាច់បំផុតដល់ការដំឡើងបៀវត្សជូនមន្ត្រីរាជការឱ្យបានជាង១លានរៀលនៅឆ្នាំ២០១៨ និងម្ខាងទៀត គឺការបង្កើនចំណាយមួយចំនួនដែលមានភាពចាំបាច់ខ្លាំង ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តសកម្មភាពកែទម្រង់គ្រប់វិស័យ និងការលើកកម្ពស់ជីវភាពប្រជាជន ព្រមទាំងការអនុវត្តកម្មវិធីថ្មីៗនៃគោលនយោបាយគាំពារសង្គមជាដើម។ កត្តាខាងលើនេះ ក៏បានបង្កើនសម្ពាធទៅលើចំណាយវិនិយោគសាធារណៈមិនឱ្យមានសន្ទុះខ្លាំង ដែលជាបច្ច័យនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចជារួម ហើយការធ្លាក់ចុះជាយថាហេតុនៃកំណើននេះអាចនឹងមានបច្ច័យធ្វើឱ្យប៉ះពាល់ដល់ការប្រមូលចំណូលថវិកាសម្រាប់បង្កើនចំណាយវិញ ទៅតាមវដ្តនៃសេដ្ឋកិច្ច។ ជាមួយគ្នានេះ ដំណើរឈានឡើងរបស់កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតទាបមិនត្រឹមតែធ្វើឱ្យដៃគូកាន់តែច្រើនមាននិន្នាការផ្តល់នូវកម្ចីសម្បទាន ជំនួសហិរញ្ញប្បទានឥតសំណងប៉ុណ្ណោះទេ តែកម្ពុជាត្រូវទទួលរែកពន់កាន់តែច្រើនឡើងៗដោយបន្ទុកចំណាយថវិកាជាតិ ក្នុងការបន្តគាំទ្រដល់គម្រោង និងកម្មវិធីមួយចំនួន ក្រោយបានបញ្ចប់ ហើយដៃគូបានចាកចេញទៅ ក្នុងខណៈដែលកម្ពុជាត្រូវបង្កើននូវចំណែកថវិកាបដិភាគរបស់ខ្លួននៅក្នុងការអនុវត្តគម្រោងថែមទៀត។ ទន្ទឹមនឹងនេះ សមត្ថភាពស្ថាប័នរដ្ឋនៅមានកម្រិតនៅឡើយ ដែលនឹងធ្វើឱ្យគោលដៅក្នុងការសម្រេចបាននូវការអនុវត្តក្របខ័ណ្ឌថវិកាមួយប្រកបដោយប្រសិទ្ធភាព អាចនឹងមិនដូចការរំពឹងទុកនៅឡើយ ទោះបីមានការដាក់ឱ្យអនុវត្តនូវថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួងស្ថាប័នរដ្ឋទាំង៣៩ក្តី។

**២៤**- ដើម្បីជម្នះបញ្ហាប្រឈមទាំងឡាយ ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងថវិកាខាងលើប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងដាក់ចេញនូវវិធានការទាន់ពេលវេលា ព្រមទាំងនឹងបន្តជំរុញបន្ថែមទៀតការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវ

ការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេសបន្តជំរុញអនុវត្តនូវគោលនយោបាយ កម្មវិធីអភិវឌ្ឍន៍ និង កម្មវិធីកែទម្រង់សំខាន់ៗ និងចាំបាច់មួយចំនួនដូចជា៖

ទី១. បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈបុរេសកម្ម សម្របសម្រួល និងប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយរូបិយវត្ថុ ដ៏សមស្រប និងការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា ជាពិសេសការជំរុញអនុវត្តឱ្យបានខ្លាំងក្លា និងឱ្យ កាន់តែមានប្រសិទ្ធភាពនូវយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយទាំងឡាយ ដែលត្រូវបានដាក់ចេញ កន្លងមក ព្រមពេលជាមួយគ្នានឹងការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្មីៗ បន្ថែមទៀត ដើម្បីបន្តធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ចាប់ពីពេលនេះតទៅ ដើម្បីអាចឈានទៅសម្រេចបាននូវចក្ខុវិស័យជាប្រទេសមាន ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ជាមួយគ្នា នេះ រាជរដ្ឋាភិបាលក៏នឹងធ្វើការតាមដានជាប់ជាប្រចាំនូវសកាពការណ៍វិត្តន៍ទាំងឡាយ ទាំងខាងផ្នែក ម៉ាក្រូសេដ្ឋកិច្ច និងទាំងខាងផ្នែកថវិកា ក៏ដូចជាការរៀបចំខ្លួនឱ្យបានល្អ ក្នុងការត្រៀមដាក់ចេញនូវ វិធានការដោះស្រាយ និងធ្វើការកែតម្រូវឱ្យបានសមស្រប ទាន់ពេលវេលា និងមានប្រសិទ្ធភាព ក្នុង ករណីមានការចាំបាច់ ឬ ក្នុងករណីមានវិបត្តិកើតឡើងជាយថាហេតុ។

ទី២. បន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែខ្លាំងក្លាថែមទៀត តាមរយៈការជំរុញអនុវត្ត **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥"** ដោយក្នុងនោះ ផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើការស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀត ការបន្តពង្រឹងការគ្រប់គ្រងអលចនទ្រព្យ ការជំរុញ ការអភិវឌ្ឍលំនៅឋានដែលមានថ្លៃសមរម្យ និងការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹង កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយកំណត់ពិដាន អត្រាការប្រាក់ ទន្ទឹមគ្នានឹងការជំរុញការផ្តល់ឥណទានឱ្យច្រើនដល់វិស័យផលិតកម្ម សហគ្រាសធុនតូច និងមធ្យម និងវិស័យកសិកម្ម ជាពិសេសការបង្កើនការផ្តល់ឥណទានដល់វិស័យស្រូវអង្ករ ទាំងសម្រាប់ ប្រជាកសិករ និងទាំងសម្រាប់រោងម៉ាស៊ីនកិនស្រូវ ដើម្បីអាចធ្វើការប្រមូលទិញស្រូវពីប្រជាកសិករបាន ក្នុងបរិមាណកាន់តែច្រើនជាងមុន ក្នុងខណៈដែលរាជរដ្ឋាភិបាលនឹងបន្តធ្វើអន្តរាគមន៍ក្នុងការប្រមូល ទិញស្រូវពីកសិករ ដើម្បីទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះហួសពីថ្លៃទីផ្សារខ្លាំងពេក ដោយមិនសមហេតុផល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការគ្រប់គ្រង និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការធានារ៉ាប់រង បញ្ចាំ និងទីផ្សារមូលបត្រ ដើម្បីទប់ស្កាត់រាល់អាជីវកម្មមិនស្របច្បាប់ទាំងឡាយដែលមានហានិភ័យ ខ្ពស់ដល់ចំណូល និងនាំឱ្យមានការខាតបង់ប្រយោជន៍ដល់ប្រជាជន។

ទី៣. បន្តអនុវត្តបញ្ចប់ឱ្យមានប្រសិទ្ធភាពនូវ **"យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨"** ដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពនៃកំណើនចំណូល ដូចសម្រេចបាននៅបណ្តាឆ្នាំកន្លងមក ទន្ទឹមនឹងការបន្តការកែសម្រួលនីតិវិធី និងសេវាបង់ពន្ធឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួល យុត្តិធម៌ និងកាន់តែមានអភិបាលកិច្ចខ្ពស់ តែមិនឱ្យវារាតពីការអនុវត្តអនុលោមភាពពន្ធ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទឱ្យ កាន់តែមានប្រសិទ្ធភាព រួមទាំងការពិនិត្យឡើងវិញផងដែរនូវគោលការណ៍នៃការប្រើប្រាស់ប្រាក់រង្វាន់ និង ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងសេចក្តី-

ព្រោងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធ្វើការត្រួត-ពិនិត្យឡើងវិញនូវប្រព័ន្ធសារពើពន្ធជាបណ្តើរៗ សំដៅធ្វើឱ្យប្រព័ន្ធនេះក្លាយទៅជាឃ្នាស់សេដ្ឋកិច្ចមួយ យ៉ាងពិតប្រាកដ ដោយមានការគិតគូរច្បាស់លាស់ពីទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ដោយឈរលើគោលការណ៍សមធម៌ យុត្តិធម៌សង្គម ប្រសិទ្ធភាពសេដ្ឋកិច្ច តម្លាភាព និងគណនេយ្យភាព នៅក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបាននិងបន្តដាក់ចេញនូវវិធានការបន្ធូរបន្ថយពន្ធ និងអនុគ្រោះពន្ធដល់ប្រជាពលរដ្ឋទូទៅ ដែលមានប្រាក់ចំណូលទាប រួមទាំងមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យ កម្មករនិយោជិត ក៏ដូចជាដល់ការប្រកបអាជីវកម្មតូចតាច។

**ទី៤.** នៅក្នុងផ្នែកចំណាយ រាជរដ្ឋាភិបាលនឹងបន្តចាត់វិធានការបង្កើនប្រសិទ្ធភាពចំណាយ តាមរយៈការបន្តកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ ទៅតាមអាទិភាពគោលនយោបាយ ទន្ទឹមនឹងការបន្តលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការបង្កើនតម្លៃនៃលុយ ដើម្បីធានាថា រាល់ចំណាយត្រូវបានធ្វើឡើងដោយមានតម្លាភាព និងគណនេយ្យភាព ក្នុងថ្លៃសមរម្យ និងគុណភាពសមស្រប ក្នុងបរិមាណដែលត្រូវការដាក់ស្តែង ព្រមទាំងក្នុងពេលវេលាដែលចាំបាច់ត្រូវការប្រើប្រាស់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការមុតស្រួចបន្ថែមទៀត ដើម្បីពង្រឹងការគោរពគោលការណ៍ និងវិន័យថវិកា ព្រមទាំងការគោរពឱ្យម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនិងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលនឹងចាត់វិធានការដាក់ស្តែងមួយចំនួនទៀត ដោយប្រទាក់ក្រឡាជាមួយនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

**ទី៥.** អនុវត្តដោយម៉ឺងម៉ាត់នូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ (២០១៦-២០២០) សំដៅផ្សារភ្ជាប់ថវិកាទៅនឹងរចនាសម្ព័ន្ធគោលនយោបាយ កម្មវិធី និងផែនការសកម្មភាពរបស់ក្រសួងស្ថាប័ន ដោយផ្តោតលើការកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា ព្រមទាំងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅផ្លាស់ប្តូរជាបណ្តើរៗ **ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅកាន់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រង់គ្រងថវិកាផ្អែកលើលទ្ធផល ឬ ធាតុចេញ និងវិមជ្ឈការ**។ នៅក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវឯកសារយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធ**ថវិកាកម្ពុជាឆ្នាំ២០១៧-២០២៥** ដើម្បីកំណត់នូវយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវ ដើម្បីសម្រេចបាននូវប្រព័ន្ធថវិការួមមួយពី **ថវិកាកម្មវិធី** ឆ្ពោះទៅ**ថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម** ត្រឹមឆ្នាំ២០២៥ ស្របតាមឧត្តមានុវត្តតំបន់និងអន្តរជាតិ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើការកសាងសមត្ថភាពមន្ត្រីរាជការ ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបន្តបំពាក់ស្មារតី ការបង្កើនសុឆន្ទៈ ការលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវនៅក្នុងកិច្ចការកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ ជាពិសេសការធ្វើស្ថាប័នីយកម្មនៃការកែទម្រង់នេះ ឱ្យក្លាយទៅជាការងារប្រចាំថ្ងៃ ដើម្បីថែរក្សាចីរភាពលទ្ធផលនៃការកែទម្រង់ឱ្យនៅស្ថិតស្ថេរ។

**ទី៦.** បង្កើនការវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមទាំងការបង្កើនការយកចិត្តទុកដាក់កាន់តែខ្ពស់លើប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោង ព្រមទាំងការខិតខំកសាង

នូវបរិស្ថានអនុគ្រោះសម្រាប់ការអភិវឌ្ឍវិស័យឯកជនឱ្យខ្លាំងក្លា ក្នុងនោះ រួមទាំងការជំរុញអនុវត្តនូវយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីបង្កើនទំនុកចិត្ត លើកទឹកចិត្ត និងជំរុញទាក់ទាញសកម្មភាពវិនិយោគ និងពាណិជ្ជកម្មឱ្យកាន់តែខ្លាំងក្លា ទោះបីវិនិយោគិន និងធុរជនជាទូទៅអាចស្ថិតក្នុងស្ថានភាពរង់ចាំដោយសារបរិការណ៍ក្នុងឆ្នាំបោះឆ្នោតក្តី ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងការដោះស្រាយជីវភាពប្រជាជន ក៏ដូចជាដើម្បីលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា។

**ទី៧.** បន្តជំរុញការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ និងវិធានការកែទម្រង់បៀវត្សសម្រាប់រយៈពេលពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរៀបចំប្រព័ន្ធបៀវត្ស និងរបបតារាំកាលិកផ្សេងទៀត ដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាព ធានាសង្គតិភាព និងប្រសិទ្ធភាពនៅក្នុងប្រព័ន្ធ និងក្នុងការគ្រប់គ្រងមន្ត្រីសាធារណៈ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពស្ថាប័នរដ្ឋ និងគុណភាពសេវាសាធារណៈ ដោយធានារក្សាបាននូវចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល។

**ទី៨.** បន្តជំរុញការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសបន្តពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ននិងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន នូវការផ្ទេរអំណាច ការទទួលខុសត្រូវ មុខងារ និងធនធានពីថ្នាក់ជាតិ ក្នុងគោលដៅសម្រេចបាននូវការកែលម្អសេវាសាធារណៈនៅតាមមូលដ្ឋានប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពផង និងធានាឱ្យមានសង្គតិភាពជាមួយនឹងគោលដៅនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងយន្តការសម្របសម្រួល រវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្ម នៃទំនាក់ទំនងការងារកែទម្រង់ទាំងបីរបស់រាជរដ្ឋាភិបាលទាំងមូល ដើម្បីអាចឈានទៅសម្រេចបាននូវប្រព័ន្ធអភិបាលកិច្ចមួយ ដែលមានប្រសិទ្ធភាពខ្ពស់ និងបម្រើឱ្យការអភិវឌ្ឍ។

**ទី៩.** បន្តជំរុញការអនុវត្តការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសការពង្រឹងសមត្ថភាពដឹកនាំ ដំនាញវិជ្ជាជីវៈ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ក្នុងបុព្វហេតុការពារជាតិ និងបូរណភាពទឹកដី ក៏ដូចជាការធានាសុខសន្តិភាព និងសណ្តាប់ធ្នាប់សង្គម ដើម្បីផ្តល់ភាពសុខក្សេមក្សាន្តជូនប្រទេសជាតិ និងប្រជាជន។

**ទី១០.** បន្តពង្រឹងសមត្ថភាព និងតួនាទីរបស់សវនកម្ម រួមទាំងការងារអធិការកិច្ច ដើម្បីរួមចំណែកទប់ស្កាត់កំហុសឆ្គង និងពង្រឹងអភិបាលកិច្ចនៅក្នុងការគ្រប់គ្រង និងការអនុវត្តហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាដើម្បីបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលនឹងធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនូវការត្រួតពិនិត្យ និងអធិការកិច្ចរបស់ក្រសួងស្ថាប័នមួយចំនួន ដែលមានភាពជាន់គ្នា ឬមានការប្រទាញប្រទង់សមត្ថកិច្ចគ្នា ដើម្បីសន្សំសំចៃថវិកា និងធនធានផង និងមិនឱ្យបង្កការលំបាកដល់អ្នក

អនុវត្តដោយសារមានស្តង់ដាច្រើនផង ក៏ដូចជាដើម្បីពង្រឹងប្រសិទ្ធភាពនៃកិច្ចការនេះ កុំឱ្យមានចន្លោះប្រហោង ដោយឥតរារាតពីការអនុវត្តច្បាប់ តែមិនឱ្យក្លាយទៅជាការបង្កើតបន្ទុកដែលរារាំងដល់សកម្មភាពសេដ្ឋកិច្ច ជាពិសេសការធ្វើធុរកិច្ច។

ទី១១. បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេសការបន្តរៀបចំ និងពង្រឹងសមត្ថភាពអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ។

## III- **វិធានការបន្ថែមខាងផ្នែកពន្ធដារសម្រាប់ឆ្នាំ២០១៨**

**២៥**- ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរបស់មន្ត្រីរាជការ និងកម្មកររនិយោជិត រួមទាំងប្រជាពលរដ្ឋទូទៅផង ក៏ដូចជាក្នុងគោលបំណងជំរុញកៀរគរចំណូលឆ្នាំ២០១៨ ឱ្យទទួលបានលទ្ធផលតាមគោលដៅដែលបានគ្រោងទុក ជាពិសេសដើម្បីធានាបាននូវចីរភាពក្នុងការប្រមូលចំណូល ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពផងដែរ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចខាងក្រោម៖

**ទី១.ធ្វើការលុបចោលពន្ធសត្តឃាត** ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ១៧ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដើម្បីសម្រាលបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើសាច់សត្វដែលជាអាហារមូលដ្ឋានសម្រាប់ចិញ្ចឹមជីវិត ក៏ដូចជាដើម្បីជួយលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងថែមទៀត និងបន្ធូរបន្ថយសម្ពាធលើថ្លៃម្ហូបអាហារជារួមផងដែរ។

**ទី២.ធ្វើការកែសម្រួលមាត្រា៤៧ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដើម្បីដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធឱ្យឡើងដល់១ ២០០ ០០០រៀល** ដើម្បីផ្តល់ការលើកទឹកចិត្ត និងលើកកម្ពស់កម្រិតជីវភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យ ព្រមទាំងកម្មកររនិយោជិត ដែលមានប្រាក់បៀវត្សទាប។ យោងតាមស្មារតីនៃមាត្រា៤៧ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ គឺមន្ត្រីរាជការ កម្មកររនិយោជិត ដែលមានប្រាក់បៀវត្ស១ ០០០ ០០០រៀល ឬ តិចជាងមិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សទេ។ ប៉ុន្តែតាមរយៈការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការជាង១ ០០០ ០០០រៀលនៅឆ្នាំ២០១៨ នឹងធ្វើឱ្យប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យ នឹងត្រូវជាប់ពន្ធលើប្រាក់បៀវត្សនៅឆ្នាំ២០១៨ ហើយកាន់តែនឹងជាប់ពន្ធលើប្រាក់បៀវត្សច្រើនថែមទៀត ទៅតាមកម្រិតនៃការដំឡើងប្រាក់បៀវត្សនាបណ្តាឆ្នាំខាងមុខទៀត។ ទន្ទឹមនឹងនេះ ការអនុវត្តគោល-នយោបាយដំឡើងប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មកររនិយោជិត ក្នុងផ្នែកវាយនកណ្តាកាត់ដេរ និងផលិតស្បែកជើងជារៀងរាល់ឆ្នាំ ហើយដែលនឹងកើនឡើងដល់ចំនួន១៧០ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ក៏នឹងអាចធ្វើឱ្យប្រាក់ឈ្នួលអប្បបរមា បូកបន្ថែមបុព្វលាភ លាភការ ប្រាក់ម៉ោងបន្ថែម និងប្រាក់ប៉ះប៉ូវនានាអាចនឹងឡើងជិតដល់កម្រិតត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ឬអាចនឹងត្រូវជាប់ពន្ធលើប្រាក់បៀវត្សនៅក្នុងឆ្នាំ២០១៨តែម្តង បើទោះបីជាស្ថិតក្នុងកម្រិតតិចតួចក៏ដោយ។ លើសពីនេះទៀត ចាប់ពីឆ្នាំ២០១៩ តទៅ កម្មកររនិយោជិតក៏នឹងត្រូវបង់ពន្ធលើប្រាក់បៀវត្សកាន់តែច្រើនថែមទៀតទៅតាមនោះ។ ក្នុងន័យ-នេះ ការដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធពី១ ០០០ ០០០រៀល ដល់

១ ២០០ ០០០រៀល នឹងផ្តល់ការអនុគ្រោះដល់មន្ត្រីរាជការ និងកម្មករនិយោជិត ដែលមានប្រាក់បៀវត្ស ១ ២០០ ០០០រៀល ឬ តិចជាង ដោយមិនជាប់ពន្ធលើប្រាក់បៀវត្ស។ ម៉្យាងវិញទៀត ការដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធនេះ នឹងអាចរក្សាបាននូវអត្ថប្រយោជន៍ពេញលេញពីការដំឡើងប្រាក់បៀវត្សនេះជូនមន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ ជាពិសេសពីការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិត។ គួរបញ្ជាក់ដែរថា ករណីនេះធ្លាប់បានអនុវត្តជាសរុបចំនួន៣ លើក ទាំងលើកនេះ ដែលកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធ ត្រូវបានដំឡើងលើកទី១ ពី ៥០០ ០០០រៀល ដល់៨០០ ០០០រៀលនៅឆ្នាំ២០១៥ និងលើកទី២ ពី៨០០ ០០០រៀល ដល់ ១ ០០០ ០០០លានរៀលនៅឆ្នាំ២០១៧ និងលើកទី៣នេះ ពី១ ០០០ ០០០រៀល ដល់១ ២០០ ០០០ រៀល។ **ដូច្នេះ ជារួម ការកែសម្រួលកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធនេះ នឹងបានជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅគ្រប់ៗគ្នា ទាំងសម្រាប់មន្ត្រីរាជការ កម្មករនិយោជិតទូទៅ ក៏ដូចជាចូលរួមចំណែកលើកកម្ពស់សេវាអប់រំ និងសុខាភិបាលផងដែរ។**

**ទី៣.ការបញ្ចូលបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែក្នុងច្បាប់ស្តីពីសារពើពន្ធ** ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាចាំបាច់នូវបទប្បញ្ញត្តិ សម្រាប់គ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ជាពិសេសដើម្បីធានាបាននូវប្រសិទ្ធភាព និងតម្លាភាពនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងប្រេងកាត រវាងរាជរដ្ឋាភិបាលជាមួយនឹងប្រតិបត្តិករធ្វើប្រតិបត្តិការប្រេងកាតក្នុងប្លុកអេ (A) ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ក៏ដូចជាដើម្បីធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាក្នុងច្បាប់ស្តីពីសារពើពន្ធ តាមរយៈការច្របាច់បញ្ចូលគ្នានូវសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ និងសេចក្តីព្រាងបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត បន្ទាប់ពីបានដាក់ឆ្លងការពិភាក្សាយ៉ាងទូលំទូលាយជាងមួយទសវត្សរ្សចមក។ ការបញ្ចូលបទប្បញ្ញត្តិនេះ ក៏នឹងជួយពង្រឹងការគ្រប់គ្រងវិស័យប្រេងកាត និងធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព ហើយអាចធានាបាននូវការការពារបរិស្ថាន ទន្ទឹមគ្នានឹងការជំរុញឱ្យមានប្រតិបត្តិការធនធានរ៉ែ ជាពិសេសប្រតិបត្តិការប្រេងកាតក្នុងតំបន់ដទៃទៀត ក្នុងខណៈដែលកម្ពុជានឹងមានដំណាក់ប្រេងពីប្លុកអេ (A) ជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនក្នុងពេលខាងមុខ។ ក្នុងន័យនេះ បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវបានបញ្ចូលទៅជាជំពូកទី៦ នៃច្បាប់ស្តីពីសារពើពន្ធ ហើយជំពូកទី៦ ជាធរមាន ស្តីពីអវសានប្បញ្ញត្តិ ត្រូវបានប្តូរទៅជាជំពូកទី៧ ដែលក្នុងនោះមាត្រា១៤១ ត្រូវបានប្តូរជាមាត្រា១៥៤ និងមាត្រា១៤២ ត្រូវបានប្តូរជាមាត្រា១៥៥។ ជំពូកទី៦ ដែលត្រូវបានបញ្ចូលថ្មីចែកចេញជា ៦ផ្នែក មាន ១៣ មាត្រា ចាប់ពីមាត្រា១៤១ ដល់មាត្រា១៥៣ ដូចខាងក្រោម៖

**ផ្នែកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ** មាន ២ មាត្រា ក្នុងនោះ មាត្រា១៤១ ចែងអំពីវិសាលភាព និងមាត្រា១៤២ ចែងអំពីវាក្យសព្ទនិងនិយមន័យ។

**ផ្នែកទី២ ស្តីពីអត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់** មាន ១ មាត្រា គឺមាត្រា១៤៣។

**ផ្នែកទី៣ ស្តីពីការកាត់កង** មាន ៦ មាត្រា ក្នុងនោះ មាត្រា១៤៤ ចែងអំពីចំណាយដែលអនុញ្ញាតឱ្យកាត់កង មាត្រា១៤៥ ចែងអំពីការអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់ មាត្រា១៤៦ ចែងអំពីការអនុញ្ញាតឱ្យអ្នកជាប់ពន្ធធ្វើសំវិធានធននៃប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬ

ចំណាយស្តារបរិស្ថាន មាត្រា១៤៧ ចែងអំពីវិធីរំលស់ មាត្រា១៤៨ ចែងអំពីអាយុកាលរំពឹងទុកសម្រាប់ការធ្វើរំលស់ និងមាត្រា១៤៩ ចែងអំពីពេលធ្វើរំលស់ និងលក្ខខណ្ឌនានាក្នុងការធ្វើរំលស់។

**ផ្នែកទី៤ ស្តីពីការផ្ទេរអត្ថប្រយោជន៍** មាន ១ មាត្រា គឺមាត្រា១៥០ ចែងអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ក្នុងករណីមានការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬ អាជ្ញាបណ្ណ ឬ កិច្ចព្រមព្រៀងធនធានរ៉ែ។

**ផ្នែកទី៥ ស្តីពីកាតព្វកិច្ចអ្នកជាប់ពន្ធ** មាន ១ មាត្រា គឺមាត្រា១៥១ ចែងអំពីកាតព្វកិច្ចបន្ថែមសម្រាប់អ្នកជាប់ពន្ធអនិវាសនជន និងកាតព្វកិច្ចសម្រាប់អ្នកជាប់ពន្ធទូទៅ ព្រមទាំងប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធ។

**ផ្នែកទី៦ ស្តីពីអន្តរប្បញ្ញត្តិ** មាន ២ មាត្រា ក្នុងនោះ មាត្រា១៥២ ចែងអំពីការរៀបចំអនុក្រឹត្យស្តីពីការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាត ឬ អាជ្ញាបណ្ណ ឬកិច្ចព្រម-ព្រៀងធនធានរ៉ែណាមួយដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃជំពូកនេះ និងមាត្រា១៥៣ ចែងអំពីឧត្តមានុភាពនៃបទប្បញ្ញត្តិក្នុងជំពូកនេះ។

## IV- សេចក្តីសន្និដ្ឋាន

**២៦- ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ គឺត្រូវបានរៀបចំឡើងតាមគោលនយោបាយវិស្តារកម្មថវិកាដោយប្រយ័ត្នប្រយែង** ឆ្ពោះទៅរកការសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗជាសារវន្ត នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ហើយដែលអាចហុចផលភ្លាមៗនៅឆ្នាំ២០១៨ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី៥ ក៏ដូចជាការជានានូវចលនការនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ហើយតម្រង់ តម្រឹម និងពន្លឿនការអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ព្រមទាំងគាំទ្រដល់ដំណើរឈានឡើងរបស់កម្ពុជា នៅក្នុងបរិការណ៍ថ្មីទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ។ ក្របខ័ណ្ឌថវិកានេះ ក៏បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងមុឹងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាលក្នុងការបន្តរក្សាសន្តិភាព ស្ថិរភាពនយោបាយ ឯកភាពជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តលើកស្ទួយកិត្យានុភាពកម្ពុជា ការការពារបានដោយឥតរវាតនូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី ការបន្តពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងជានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅពន្លឿនសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា ជាពិសេសការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្របខ័ណ្ឌថវិកាខាងលើនេះ ក៏មានគោលដៅជានារក្សានូវឥទ្ធិពលភាព ឯករាជ្យភាព និងភាពជាម្ចាស់របស់កម្ពុជា ក្នុងការគ្រប់គ្រងដោគវាសនារបស់ខ្លួនដោយខ្លួនឯង នៅក្នុងរយៈពេលវែងផងដែរ។

**២៧- ថវិកាឆ្នាំ២០១៨ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងបានបុកគ្រឹះសម្រាប់បម្រើឱ្យការអភិវឌ្ឍរបស់កម្ពុជាតទៅមុខទៀត។** អាទិភាពចំណាយថវិកាឆ្នាំ២០១៨ គឺជាការឆ្លើយតបទៅនឹងអាទិភាព និងតម្រូវការចាំបាច់របស់ក្រសួងស្ថាប័ននានា ក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួន ក៏

ដូចជាគោលនយោបាយជាអាទិភាពរួមរបស់រាជរដ្ឋាភិបាល ដែលរួមមាន៖ ការអភិវឌ្ឍធនធានមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម ការលើកកម្ពស់គុណភាពសេវាសុខាភិបាលឱ្យកាន់តែល្អប្រសើរ ការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាពខ្ពស់ ការពង្រឹងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសការជំរុញអនុវត្តកម្មវិធីថ្មីៗនៃគោលនយោបាយក្នុងវិស័យសង្គមកិច្ចពាក់ព័ន្ធនឹងការគាំពារសង្គម ដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៨ ក៏បានគូសបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូលគ្រប់ប្រភេទ ប្រកបដោយមហិច្ឆតា តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ដែលមានចែងនៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨** ទន្ទឹមនឹងការបន្តគោលនយោបាយបន្ធូរបន្ថយនិងអនុគ្រោះពន្ធដល់ប្រជាពលរដ្ឋមានចំណូលទាប និងអាជីវកម្មតូចតាច។

**២៨**- សរុបមក ថវិកាឆ្នាំ២០១៨ អាចប្រសិទ្ធនាមបានថាជា "**ថវិកាយុទ្ធសាស្ត្រនៃការពូនផ្តុំកម្លាំង និងធនធានជាអតិបរមា ដើម្បីសម្រេចឱ្យខាងតែបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងសភាពការណ៍តំបន់ និងពិភពលោក ដែលកាន់តែមានសភាពស្មុគស្មាញ ដើម្បីបន្តរក្សាសន្តិភាព និងស្ថេរភាព ក៏ដូចជាការទ្រទ្រង់នូវដំណើរការវិវឌ្ឍន៍ឈានឡើងរបស់កម្ពុជាលើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរក្នុងនីតិកាលបន្តបន្ទាប់ទៀត**"។

**២៩**- ក្នុងន័យនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តមុតមាំក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើ ជាពិសេសការបន្តជំរុញអនុវត្តបញ្ចប់នូវកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗ នៃកម្មវិធីនយោបាយ និងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យមានល្បឿនកាន់តែលឿនជាងមុន និងកាន់តែស្រុះដៃគ្នាជាងមុន ដើម្បីជំរុញការបញ្ចេញលទ្ធផលជាក់ស្តែងឱ្យបានជាអតិបរមាជូនដល់ដៃប្រជាជន ក៏ដូចជាប្រទេសជាតិទាំងមូល នៅក្នុងឆ្នាំចុងក្រោយនៃនីតិកាលទី៥ ដោយបន្តប្រកាន់ខ្ជាប់នូវអភិក្រមការងារ៤ យ៉ាង គឺ "*ស្ទុះកញ្ចាក់ ដូតទឹក ជុសក្បែល និងព្យាបាល*"។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្ម ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះដោគវាសនារបស់ប្រទេសជាតិ និងឈរលើគោលការណ៍តម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំ ដើម្បីជម្នះបាននូវបញ្ហាប្រឈម និងឧបសគ្គទាំងឡាយ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងភាពថ្កុំថ្កើង រុងរឿងរបស់កម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ដើម្បីបញ្ជូនទៅសុំការពិនិត្យ និងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន៦ជំពូក និងមាន១៥ មាត្រា ដែលមានខ្លឹមសារសំខាន់ដូចខាងក្រោម៖

- ជំពូកទី១ មាន ៦ មាត្រា (ពីមាត្រា១ ដល់មាត្រា៦)
  ជំពូកទី១ នេះ កំណត់អំពីថវិកាថ្នាក់ជាតិ
- ជំពូកទី២ មាន ២ មាត្រា (ពីមាត្រា៧ ដល់មាត្រា៨)
  ជំពូកទី២ នេះ កំណត់អំពីការខ្ចីនិងការធានារបស់រដ្ឋ
- ជំពូកទី៣ មាន ៣ មាត្រា (ពីមាត្រា៩ ដល់មាត្រា១១)
  ជំពូកទី៣ នេះ កំណត់អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ
- ជំពូកទី៤ មាន ១ មាត្រា (មាត្រា១២)
  ជំពូកទី៤ នេះ កំណត់អំពីនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
  ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- ជំពូកទី៥ មាន ១ មាត្រា (មាត្រា១៣)
  ជំពូកទី៥ នេះ កំណត់អំពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំពូកទី៦ មាន ២ មាត្រា (ពីមាត្រា១៤ ដល់មាត្រា១៥)
  ជំពូកទី៦ នេះ កំណត់អំពីអវសានប្បញ្ញត្តិ

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងផ្តល់ការអនុម័តលើសេចក្តីព្រាង-ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨នេះ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ភ្ជុំ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជក្រម

នស/រកម/១២១៧/០១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**
**ខេមរាជនា សម្ងហោតាស អម្ពុជឯករាជ្យបូរណសន្តិ សុតមន្តណា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់
# ការគ្រប់គ្រងឆ្នាំ២០១៨

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
## ថវិកាថ្នាក់ជាតិ

**មាត្រា១ ៖**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធននិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន២២ ៤៣៧ ១៣៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត..... ១៧ ៤៦០ ០០៦លានរៀល
- ចំណូលមូលធន.....៤ ៩៧៧ ១៣២លានរៀល
  - + ចំណូលមូលធនក្នុងប្រទេស.....១៨០ ១៩៣លានរៀល
  - + ចំណូលមូលធនក្រៅប្រទេស.....៤ ៧៩៦ ៩៣៩លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ .....២៥០ ០០០លានរៀល
    - និយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស .....៤ ៥៤៦ ៩៣៩លានរៀល។

**មាត្រា២ ៖**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង២៣ ៤២៨ ២៩៨លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត..... ១៥ ២១៨ ១៦៦លានរៀល
- ចំណាយមូលធន.....៨ ២១០ ១៣២លានរៀល

ក- និយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

..... ២ ៩២៥ ៨០០លានរៀល

- ដោយថវិកាថ្នាក់ជាតិ.....២ ៦៧៥ ៨០០លានរៀល
  - ▪ គម្រោងវិនិយោគផ្ទាល់.....២ ០៧៥ ៨០០លានរៀល

▪ បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស
..... ៦០០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ
..... ២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
.....៤ ៥៤៦ ៩៣៩លានរៀល

គ- ការទូទាត់ការខ្វី.....៧៣៧ ៣៩៣លានរៀល។

**មាត្រា៣ ..**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ស្មើនឹង១៥ ២១៨ ១៦៦លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ ..**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង២១ ៣៤១ ៥៩៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ ..**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា..... ៨ ២១០ ១៣២លានរៀល
- ឥណទានទូទាត់..... ៨ ២១០ ១៣២លានរៀល។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា.....២ ៩២៥ ៨០០លានរៀល
- ឥណទានទូទាត់.....២ ៩២៥ ៨០០លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា..... ៤ ៥៤៦ ៩៣៩លានរៀល
- ឥណទានទូទាត់..... ៤ ៥៤៦ ៩៣៩លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា.....៧៣៧ ៣៩៣លានរៀល
- ឥណទានទូទាត់.....៧៣៧ ៣៩៣លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**ក២**" និង"**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦** ..

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| **I. ចំណូលក្នុងប្រទេសសរុប** | **<u>១៧ ៦៤០ ១៩៩</u>** | |
| ១. ចំណូលចរន្ត | ១៧ ៤៦០ ០០៦ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៨០ ១៩៣ | |
| **II. ចំណាយថវិកាសរុប** | **<u>២២ ៦៩០ ៩០៥</u>** | |
| ១. ចំណាយចរន្ត | ១៥ ២១៨ ១៦៦ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៧ ៤៧២ ៧៣៩ | |
| • និយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ២ ៩២៥ ៨០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ២ ៦៧៥ ៨០០ | |
| - គម្រោងនិយោគផ្ទាល់ | ២ ០៧៥ ៨០០ | |
| - បដិភាគនិយោគ | ៦០០ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • និយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ៥៤៦ ៩៣៩ | |
| **អតិរេកនៃថវិកាចរន្ត ( I.១ -II.១ )** | | **<u>+២ ២៤១ ៨៤០</u>** |
| **ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II )** | | **<u>-៥ ០៥០ ៧០៦</u>** |
| **III. ហិរញ្ញប្បទាននៃឱនភាព** | | **<u>+៥ ០៥០ ៧០៦</u>** |
| **១. ហិរញ្ញប្បទានក្រៅប្រទេស** | | **+៤ ០៥៩ ៥៤៦** |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២៥០ ០០០ |
| • និយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៤ ៥៤៦ ៩៣៩ |
| • ការទូទាត់ការខ្ចី | | - ៧៣៧ ៣៩៣ |
| **២. ហិរញ្ញប្បទានក្នុងប្រទេស** | | **+៩៩១ ១៦០** |
| • បញ្ជីរាជរដ្ឋាភិបាល | | +៩៩១ ១៦០ |

# ជំពូកទី២

## ការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា៧ ..**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ០០០ ០០០ ០០០ SDR(មួយប៊ីលានអេសដេអ៊ែរ)។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសែងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិដាលាយលក្ខណ៍អក្សរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្តង។

**មាត្រា៨ ..**

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្រយៈពេលវែង មធ្យម ខ្លី ឬតំណាងអ្នកផ្តត់ផ្តង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសែងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

# ជំពូកទី៣

## បទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា៩ ..**

ច្បាប់ស្តីពីការបង្កើតពន្ធសត្តឃាត ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ១៧ ក្រ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ ..**

មាត្រា៤៧ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលត្រូវបានកែសម្រួលដោយ មាត្រា១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានកែប្រែ ដូចខាងក្រោម ៖

**មាត្រា៤៧ ..ថ្មី (ពីរ)**

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធ ប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ ៖

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០៛ | ០% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០៛ | ២០% |

**មាត្រា១១ ..**

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ ត្រូវបានធ្វើវិសោធនកម្មបំពេញ បន្ថែមដូចខាងក្រោម ៖

១- ជំពូកទី៦ នៃច្បាប់ស្តីពីសារពើពន្ធ ស្តីពីអវិសាន្តប្បញ្ញត្តិ ត្រូវបានប្តូរជា ជំពូកទី៧ ដែលក្នុងនោះមាត្រា១៤១ ត្រូវបានប្តូរជា មាត្រា១៥៤ និងមាត្រា១៤២ ត្រូវបានប្តូរជា មាត្រា១៥៥។

២- ត្រូវបានជំនួស ជំពូកទី៦ បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ ដែលចែកចេញជា ៦ ផ្នែក មានចំនួន ១៣ មាត្រា ចាប់ពីមាត្រា១៤១ ដល់មាត្រា១៥៣ ដូចតទៅ ៖

## << ជំពូកទី ៦
## បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៤១ ..**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែនេះ អនុវត្តចំពោះប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

**មាត្រា១៤២ ..**

វាក្យសព្ទនិងនិយមន័យសំខាន់ៗសម្រាប់ប្រើប្រាស់ក្នុងជំពូកនេះ មានដូចខាងក្រោម ៖

១- សម្រាប់គោលដៅនៃប្រតិបត្តិការប្រេងកាត ៖

ក. ពាក្យ "ប្រេងកាត" សំដៅដល់ប្រេងឆៅ ឧស្ម័នធម្មជាតិ ឬអ៊ីដ្រូកាបួរផ្សេងទៀត ទោះជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ក្នុងស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបួរនោះ

ខ. ពាក្យ "កិច្ចព្រមព្រៀងប្រេងកាត" សំដៅដល់កិច្ចព្រមព្រៀង ឬការអនុញ្ញាតដែលត្រូវបានផ្តល់ឱ្យក្រោមច្បាប់និងបទប្បញ្ញត្តិស្តីពីប្រេងកាត រវាងរាជរដ្ឋាភិបាលកម្ពុជា និងអ្នកជាប់ពន្ធពាក់ព័ន្ធដើម្បីធ្វើប្រតិបត្តិការប្រេងកាត

គ. ពាក្យ "ប្រតិបត្តិការប្រេងកាត" សំដៅដល់សកម្មភាពស្វែងរកេរក អភិវឌ្ឍនិងផលិតប្រេងកាត ដែលបានធ្វើឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមកិច្ចព្រមព្រៀងប្រេងកាត

ឃ. ពាក្យ "តំបន់ចុះកិច្ចសន្យា" សំដៅដល់តំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង

ប្រេងកាត ដែលបានអនុញ្ញាតផ្តល់ឱ្យពីដំបូង រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់នោះដែលត្រូវបានបោះបង់ចោល ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងប្រេងកាត

ង. ពាក្យ "គម្រោងអភិវឌ្ឍន៍" សំដៅដល់កម្មវិធីការងារអភិវឌ្ឍន៍ ដើម្បីអភិវឌ្ឍ និងធ្វើផលិតកម្មធនធានប្រេងកាតនៅក្នុងតំបន់ចុះកិច្ចសន្យា ដែលបានយល់ព្រមដោយស្ថាប័ន

ច. ពាក្យ "គម្រោងរុះរើបោសសម្អាត" សំដៅដល់គម្រោងរុះរើបោសសម្អាតរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមកិច្ចព្រមព្រៀងប្រេងកាត

ឆ. ពាក្យ "ចំណាយបុរេសនា" សំដៅដល់ចំណាយក្នុងការស្វែងរុករកដើម្បីកំណត់សក្តានុពលកូគព្តសាស្ត្រប្រេងកាតជំហានដំបូង ដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម

ជ. ពាក្យ "ចំណាយស្វែងរុករក" សំដៅដល់ចំណាយក្នុងការអង្កេតផ្នែកភូគព្តសាស្ត្រ រូបភូគព្តសាស្ត្រ គីមីភូគព្តសាស្ត្រ ចំណាយវិភាគទិន្នន័យ ចំណាយទស្សនទានស្វែកម្មមុនពេលអភិវឌ្ឍន៍ ចំណាយលើការខួងស្វែងរុករក ខួងវាយតម្លៃ ការសិក្សាលើសមិទ្ធិលទ្ធភាពផលប៉ះពាល់បរិស្ថាន ចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងការស្វែងរុករក

ឈ. ពាក្យ "ចំណាយអភិវឌ្ឍន៍" សំដៅដល់ចំណាយដែលបានកើតឡើងបន្ទាប់ពីស្ថាប័នបានយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ ដើម្បីសាងសង់មធ្យោបាយផលិតកម្មសម្រាប់ប្រតិបត្តិការប្រេងកាត ជាអាទិ៍មាន ការរៀបចំទីតាំង ការខួងអណ្តូង ការសាងសង់អណ្តូងសម្រាប់ផលិតកម្ម និងការសាងសង់បំពង់បង្ហូរប្រេងកាតដែលជាមធ្យោបាយផលិតកម្ម ព្រមទាំងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងការអភិវឌ្ឍស្របតាមកិច្ចព្រមព្រៀងប្រេងកាត

ញ. ពាក្យ "ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត" សំដៅដល់ប្រាក់បម្រុងដែលត្រូវបានអនុញ្ញាតឱ្យកាត់កងជាមុន សម្រាប់ចំណាយរុះរើបោសសម្អាតដែលនឹងកើតឡើងស្របតាមគម្រោងរុះរើបោសសម្អាត

ដ. ពាក្យ "ចំណាយសរុបដែលបានយល់ព្រមសម្រាប់រុះរើបោសសម្អាត" សំដៅដល់ចំណាយសរុបសម្រាប់រុះរើបោសសម្អាតនៅក្នុងតំបន់ចុះកិច្ចសន្យា ដែលបានយល់ព្រមដោយស្ថាប័ន តាមគម្រោងរុះរើបោសសម្អាតរបស់អ្នកជាប់ពន្ធ ស្របតាមកិច្ចព្រមព្រៀងប្រេងកាត ដូចដែលបានកែប្រែទៅតាមពេលវេលានីមួយៗ

ប. ពាក្យ "ផលិតកម្មពាណិជ្ជកម្ម" សំដៅដល់សកម្មភាពផលិតប្រេងកាតដែលអាចកើតឡើងនៅពេលដែលមធ្យោបាយផលិតកម្មចាប់ផ្តើមដំណើរការផលិតជាលើកដំបូង ឬនៅពេលដឹកជញ្ជូនផលិតផលប្រេងកាតចេញពីតំបន់ចុះកិច្ចសន្យាដើម្បីលក់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២- សម្រាប់គោលដៅនៃប្រតិបត្តិការធនធានរ៉ែ ៖

ក. ពាក្យ "ធនធានរ៉ែ" សំដៅដល់សារធាតុទាំងឡាយ ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ធ្យូងថ្ម រ៉ែអរលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ។ ពាក្យ "ធនធានរ៉ែ" មិនរាប់បញ្ចូលប្រេងកាតដូចមានចែងក្នុងវាក្យខណ្ឌក នៃកថាខណ្ឌ១ នៃមាត្រានេះទេ

ខ. ពាក្យ "អាជ្ញាបណ្ណ" សំដៅដល់លិខិតអនុញ្ញាតដែលផ្តល់សិទ្ធិឱ្យអ្នកជាប់ពន្ធ ដោយស្ថាប័នដើម្បីធ្វើប្រតិបត្តិការធនធានរ៉ែ

គ. ពាក្យ "កិច្ចព្រមព្រៀងធនធានរ៉ែ" សំដៅដល់កិច្ចព្រមព្រៀង ដែលតម្រូវឱ្យធ្វើបន្ថែមលើអាជ្ញាបណ្ណ ក្នុងករណីដែលអាជីវកម្មធនធានរ៉ែជាគម្រោងមានទ្រង់ទ្រាយធំ និងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ

ឃ. ពាក្យ "ប្រតិបត្តិការធនធានរ៉ែ" សំដៅដល់សកម្មភាពទាំងឡាយដែលបានអនុញ្ញាតក្រោមអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែ។ ប្រតិបត្តិការធនធានរ៉ែត្រូវបានបែងចែកជាដំណាក់កាលបុរេសនា ដំណាក់កាលស្វែងរុករក ដំណាក់កាលអភិវឌ្ឍន៍ និងដំណាក់កាលផលិតកម្ម

ង. ពាក្យ "តំបន់ទទួលអាជ្ញាបណ្ណ" សំដៅដល់តំបន់ដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែនិងជាកម្មវត្ថុនៃអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់ដែលត្រូវបានបោះបង់ចោល ដោយអនុលោមទៅតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែនោះ

ច. ពាក្យ "ផែនការស្តារបរិស្ថាន" សំដៅដល់ផែនការស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័ន ក្រោមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ។ ការស្តារបរិស្ថាន រួមបញ្ចូលទាំងការលុបអណ្តូងរ៉ែ ការដាំដើមឈើឡើងវិញ ការសម្អាតនានាក្នុងតំបន់ទទួលអាជ្ញាបណ្ណ

ឆ. ពាក្យ "ចំណាយបុរេសនា" សំដៅដល់ចំណាយដែលទាក់ទិននឹងការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ដែលមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ

ជ. ពាក្យ "ចំណាយស្វែងរុករក" សំដៅដល់ចំណាយនានាទាក់ទិនទៅនឹងការសិក្សាស្រាវជ្រាវនិងធ្វើតេស្តសន្ទស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ និងទាំងសម្បទាភាព សេដ្ឋកិច្ចអាជីវកម្ម តាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ

រូបកូគព្ភសាស្ត្រ និងគីមីកូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត

ឈ. ពាក្យ "ចំណាយអភិវឌ្ឍន៍" សំដៅដល់ចំណាយនានាទាក់ទិនទៅនឹងការរៀបចំទីតាំងសម្រាប់ប្រតិបត្តិការធនធានរ៉ែ ជាអាទិ៍មាន ការសាងសង់ផ្លូវចេញចូល ផ្លូវដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធឬមធ្យោបាយផ្សេងៗ ក្នុងគោលបំណងជីកយក ចម្រាញ់ បន្សុទ្ធ ធ្វើប្រព្រឹត្តិកម្ម កែច្នៃ ផលិតកម្ម ស្តុកទុក ដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មផលិតផលរ៉ែ

ញ. ពាក្យ "ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន" សំដៅដល់ប្រាក់បម្រុងដែលអនុញ្ញាតឱ្យកាត់កងជាមុន សម្រាប់ចំណាយស្តារបរិស្ថានឡើងវិញដែលនឹងត្រូវបានធ្វើឡើងស្របតាមផែនការស្តារបរិស្ថាន

ដ. ពាក្យ "ចំណាយសរុបដែលបានយល់ព្រមសម្រាប់ស្តារបរិស្ថាន" សំដៅដល់ចំណាយសរុបសម្រាប់ស្តារបរិស្ថានឡើងវិញនៅក្នុងតំបន់ទទួលអាជ្ញាបណ្ណ ដែលបានយល់ព្រមដោយស្ថាប័នតាមផែនការស្តារបរិស្ថានរបស់អ្នកជាប់ពន្ធ ស្របតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ និងច្បាប់និងបទប្បញ្ញត្តិស្តីពីធនធានរ៉ែ

ឋ. ពាក្យ "ផលិតកម្មពាណិជ្ជកម្ម" សំដៅដល់សកម្មភាពប្រព្រឹត្តិកម្មធនធានរ៉ែដែលអាចកើតឡើងនៅពេលដែលមធ្យោបាយផលិតកម្មចាប់ផ្តើមដំណើរការផលិតជាលើកដំបូង ឬនៅពេលដែលការចាប់ផ្តើមដឹកជញ្ជូនចេញដើម្បីលក់ពីតំបន់ទទួលអាជ្ញាបណ្ណ។

៣- សម្រាប់គោលដៅនៃជំពូកនេះ ៖

ក. ពាក្យ "អ្នកជាប់ពន្ធ" សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយរាជរដ្ឋាភិបាលកម្ពុជា ឬដែលទទួលបានអាជ្ញាបណ្ណឬបានចុះកិច្ចព្រមព្រៀងធនធានរ៉ែឱ្យធ្វើប្រតិបត្តិការធនធានរ៉ែ រួមទាំងអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ

ខ. ពាក្យ "ស្ថាប័ន" សំដៅដល់ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យប្រេងកាត ឬគ្រប់គ្រងវិស័យធនធានរ៉ែ។

## ផ្នែកទី២
## អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់

### មាត្រា១៤៣ .-



១- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា

៣០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធ" សំដៅដល់ ប្រាក់ចំណូលសុទ្ធដែលបានមកពីការយកចំណូលដុល សម្រេចបានពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ ដកចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ។

២- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិត តាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រានេះ ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត។ សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែករវាងទឹកប្រាក់បូកបង្គរនៃចំណូល និងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ មកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣- អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត មានដូចក្នុងតារាងខាងក្រោម ៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | | | | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|---|---|---|
| ១ | | | ដល់ | ១,៣ | ០ % |
| ២ | លើសពី | ១,៣ | ដល់ | ១,៦ | ១០ % |
| ៣ | លើសពី | ១,៦ | ដល់ | ២ | ២០ % |
| ៤ | លើសពី | ២ | ឡើងទៅ | | ៣០ % |

វិធីគណនាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត ប្រាក់ចំណូលលើសកម្រិតពន្ធលើប្រាក់ចំណូលលើសកម្រិត និងវិធាននិងនីតិវិធីនៃការគ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- អ្នកជាប់ពន្ធត្រូវបានលើកលែងពីការបង់ពន្ធអប្បបរមាដែលមានចែងក្នុងមាត្រា ២៤ថ្មី (ពីរ) នៃច្បាប់នេះ។

## ផ្នែកទី៣
## ការកាត់កង

### មាត្រា១៤៤ .-

ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កងដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធរបស់អ្នកជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំហិតដូចខាងក្រោម ៖



១- សម្រាប់ប្រតិបត្តិការប្រេងកាត ៖

ក. ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រែងកាតនៅក្នុងតំបន់ចុះកិច្ចសន្យាណាមួយ សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រែងកាតក្នុងតំបន់ចុះកិច្ចសន្យានៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ

ខ. ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការប្រែងកាតនៅក្នុងតំបន់ចុះកិច្ចសន្យា លើសពីចំណូលដុលសរុប ដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី១០។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ ៖

ក. ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ នៅក្នុងតំបន់ទទួលអាជ្ញាបណ្ណណាមួយសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាបណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ

ខ. ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទទួលអាជ្ញាបណ្ណ លើសពីចំណូលដុលសរុប ដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៣- ការខាតបង់ដែលកើតមានឡើងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណដទៃទៀតឡើយ។

**មាត្រា១៤៥ ..**

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់តាមវិធានសមាមាត្រ ... ៣ ធៀបនឹងដើមទុន ១។

មាត្រា១៤៦ ..

ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬចំណាយស្តារបរិស្ថាន ត្រូវបានកំណត់ដូចតទៅ ៖

១- ដោយមិនគិតពីបទប្បញ្ញត្តិនៃកថាខណ្ឌ២ និងកថាខណ្ឌ៤ នៃមាត្រា៦ថ្មី នៃច្បាប់នេះ ប្រសិនបើអ្នកជាប់ពន្ធមានគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថានដែលបានយល់ព្រមដោយស្ថាប័ន អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យបង្កើតប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតឬធនធានរ៉ែ។ ចំណាយសម្រាប់ប្រាក់បម្រុងទាំងនេះ ត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថាន ដែលបានយល់ព្រមដោយស្ថាប័នទេ ការកាត់កងតាមមាត្រានេះមិនត្រូវបានអនុញ្ញាតឡើយ។

២- ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័ន សម្រាប់រុះរើបោសសម្អាត ឬស្តារបរិស្ថាន។ ប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមគម្រោងរុះរើបោសសម្អាត ឬស្តារបរិស្ថាន។

៣- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន មានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

៤- ប្រសិនបើនៅចុងបញ្ចប់នៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំណាយសរុបជាក់ស្តែងនៃការរុះរើបោសសម្អាត ឬស្តារបរិស្ថាន មានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការរុះរើបោសសម្អាត ឬស្តារបរិស្ថាននោះបានបញ្ចប់។

៥- នីតិវិធីគ្រប់គ្រងប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬស្តារបរិស្ថាន ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័ន។

មាត្រា១៤៧ ..

វិធីរំលស់ត្រូវបានកំណត់ ដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមមាត្រា១៤៨ នៃច្បាប់នេះ។ អ្នកជាប់ពន្ធមិនត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមមាត្រា១៥ នៃច្បាប់នេះទេ។

២- ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្ម ក្នុងតំបន់ចុះកិច្ចសន្យា ឬក្នុងតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីតាមវាក្យខណ្ឌក ដល់វាក្យខណ្ឌឃ នៃកថាខណ្ឌ១ នៃមាត្រា១៣ថ្មី នៃច្បាប់នេះ និងធ្វើរំលស់ទ្រព្យអរូបីតាមមាត្រា១៤ នៃច្បាប់នេះ។

**មាត្រា១៤៨ .-**

រំលស់ស្មើភាគសម្រាប់ប្រតិបត្តិការប្រែងកាតនិងប្រតិបត្តិការធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- សម្រាប់ប្រតិបត្តិការប្រែងកាត ៖

ក. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ខ. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រែងកាត ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

គ. ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មណាមួយក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែថ្មី ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌក និងវាក្យខណ្ឌខ នៃកថាខណ្ឌនេះឡើយ។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ ៖

ក. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគ តាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ខ. អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

គ. ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែថ្មី ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌក និងវាក្យខណ្ឌខ នៃកថាខណ្ឌនេះឡើយ

ឃ. ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាងមួយឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនា និងចំណាយស្វែងរុករក។

**មាត្រា១៤៩ .-**

ពេលធ្វើរំលស់ត្រូវបានកំណត់ដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូង នៅដំណាច់ឆ្នាំជាប់ពន្ធដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ។

២- ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនាឬស្វែងរុករក ឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមពេលដូចខាងក្រោម ៖

ក. នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករក ទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង

ខ. នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ ចំពោះចំណាយអភិវឌ្ឍន៍។

រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នាសម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ស្របតាមមាត្រា១៤៨ នៃច្បាប់នេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់គណនាតំកល់ក្នុងឆ្នាំជាប់ពន្ធ។

៣- ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្ម ក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធ ដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

## ផ្នែកទី៤

## ការផ្ទេរអត្ថប្រយោជន៍

**មាត្រា១៥០ .-**

ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែ តាមរូបភាពលក់ទិញដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ត្រូវអនុវត្តដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរត្រូវកត់ត្រាចំណូលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ ជាចំណូលពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែ ដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

២- បុគ្គលជាអ្នកទទួលបន្តត្រូវ ៖

ក. បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកដែលបានទទួល

ខ. បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធាននិងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបានធ្វើរំលស់កន្លងមក

គ. ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែមានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្តត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង ៧ឆ្នាំ សម្រាប់ប្រតិបត្តិការធនធានរ៉ែ ដោយជ្រើសរើសយករយៈពេលមួយដែលតិចជាង

ឃ. ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែមានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្តត្រូវកែត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង ៧ឆ្នាំ សម្រាប់ប្រតិបត្តិការធនធានរ៉ែ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

## ផ្នែកទី៥
## ភាគព្វកិច្ចអ្នកជាប់ពន្ធ

### មាត្រា១៥១ ..

អ្នកជាប់ពន្ធអនិវាសនជនដែលចុះកិច្ចព្រមព្រៀងប្រេងកាតឬកិច្ចព្រមព្រៀងធនធានរ៉ែជាមួយរាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវបង្កើតជាក្រុមហ៊ុនក្នុងស្រុកមួយសម្រាប់តំបន់ចុះកិច្ចសន្យាមួយ ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃ មុនពេលចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច។

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធ ទៅតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។

ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ចុះកិច្ចសន្យា ឬតំបន់ទទួលអាជ្ញាបណ្ណត្រូវផ្តល់របាយការណ៍ និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ចុះកិច្ចសន្យាឬតំបន់ទទួលអាជ្ញាបណ្ណ តាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

## ផ្នែកទី៦
## អន្តរប្បញ្ញត្តិ

### មាត្រា១៥២ ..

ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែណាមួយដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា១៤២ នៃច្បាប់នេះ ត្រូវអនុវត្តបទប្បញ្ញត្តិក្នុងជំពូកនេះនិងបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។ ក្នុងករណីដែលមានភាពមិនស្របគ្នា បទប្បញ្ញត្តិនៃជំពូកនេះមានឧត្តមានុភាពលើបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។>>

# ជំពូកទី ៤

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

**មាត្រា១២ ..**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ទឹកប្រាក់ចំនួន៣៧១ ៣៩៧ ០០០ ០០០រៀល(បីរយចិតសិបមួយប៊ីលានបីរយកៅសិបប្រាំពីរលានរៀលគត់) ដែលត្រូវបានបែងចែកដូចតទៅ៖

១- ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់ការសាងសង់ឃ្លាំង និងឡសម្ងួត ទឹកប្រាក់ចំនួន១២០ ៧៨០ ០០០ ០០០រៀល(មួយរយម្ភៃប៊ីលានប្រាំពីរយប៉ែតសិបលានរៀលគត់)។

២- ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទ សម្រាប់ជំរុញស្ថិរភាពការបែនីយកម្មថ្លៃស្រូវ និងជំរុញការទិញស្រូវក្នុងស្រុក ទឹកប្រាក់ចំនួន៩៣ ៧៧១ ០០០ ០០០រៀល(កៅសិបបីប៊ីលានប្រាំពីររយចិតសិបមួយលានរៀលគត់)។

៣- ទូទាត់ការបង្វិលសងអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុន ស្ថានទូត អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ទឹកប្រាក់ចំនួន ១៥០ ០០០ ០០០ ០០០រៀល(មួយរយហាសិបប៊ីលានរៀលគត់)។

៤- ទូទាត់ចំណាយរៀបចំមហាសន្និបាតតំបន់អាស៊ីលើកទី ៩ (APA-9) ទឹកប្រាក់ចំនួន៦ ៨៤៦ ០០០ ០០០រៀល(ប្រាំមួយប៊ីលានប្រាំបីរយសែសិបប្រាំមួយលានរៀលគត់)។

# ជំពូកទី ៥

## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១៣ .-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា៣៥ និងមាត្រា៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ សរុបចំនួន១ ៦៨៤ ៦៧៤លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប.....១ ០៩០ ២៣៣លានរៀល
  - +ចំណូលចរន្តសរុប.....៩៤១ ៤១៩លានរៀល
    - -ចំណូលសារពើពន្ធ..... ៩១០ ៤៤៣លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ.....៣០ ៩៧៦លានរៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..... ១៤៨ ៨១៤លានរៀល
    - -ឧបត្ថម្ភរាជធានី ខេត្ត..... ១៤០ ៨១៤លានរៀល
    - -ឧបត្ថម្ភសេវាអនាម័យបរិស្ថាន..... ៨ ០០០លានរៀល។
- ចំណាយថវិកាសរុប..... ១ ០៩០ ២៣៣លានរៀល
  - +ចំណាយចរន្ត..... ៧៤៤ ៧២៨លានរៀល
  - +ចំណាយមូលធន..... ២១៩ ៥០៥លានរៀល
  - +អតិរេករាជធានី ខេត្ត.....១២៦ ០០០លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- ចំណូលថវិកាសរុប..... ១៦០ ៤០០លានរៀល

  +ចំណូលចរន្តសរុប..... ៥ ៣៨៥លានរៀល

  -ចំណូលមិនមែនសារពើពន្ធ..... ៥ ៣៨៥លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..... ១៥៥ ០១៥លានរៀល។

- ចំណាយថវិកាសរុប..... ១៦០ ៤០០លានរៀល

  +ចំណាយចរន្ត.....១៦០ ៣៥៣លានរៀល

  +ចំណាយមូលធន..... ៤៧លានរៀល។

**គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់**

- ចំណូលថវិកាសរុប..... ៤៣៤ ០៤១លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិសរុប..... ៤៣៤ ០៤១លានរៀល

  -ចំណូលសង្កាត់ចំណុះរាជធានី..... ៣០ ៧៥២លានរៀល

  -ចំណូលសង្កាត់ចំណុះក្រុង..... ៣៣ ៩៩៧,៤៧លានរៀល

  -ចំណូលឃុំ.....៣៦៩ ២៩១,៥៣លានរៀល។

- ចំណាយថវិកាសរុប.....៤៣៤ ០៤១លានរៀល

  +ចំណាយសរុប..... ៤៣៤ ០៤១លានរៀល

  -ចំណាយសង្កាត់ចំណុះរាជធានី.....៣០ ៧៥២លានរៀល

  -ចំណាយសង្កាត់ចំណុះក្រុង.....៣៣ ៩៩៧,៤៧លានរៀល

  -ចំណាយឃុំ..... ៣៦៩ ២៩១,៥៣លានរៀល។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្នែកក្នុងថវិកាជាដំបូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

# ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦ រោច ខែ មិគសិរ ឆ្នាំរកា ព.ស.២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ ធ្នូ គ.ស.២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករណ.៣៧១២.១៧៤៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

**លេខ:១១៨៤ ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ១៤ រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| **សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II)** | | | | 20.184.457,0 | 22.437.138,0 | 2.252.681,0 | 11,2% |
| **I. សរុបចំណូលស្លឹងកាត់រតនាគារជាតិ (ក+ខ)** | | | | 15.899.900,0 | 17.890.199,0 | 1.990.299,0 | 12,5% |
| **ក្នុងនោះចំណូលក្នុងប្រទេស** | | | | 15.649.900,0 | 17.640.199,0 | 1.990.299,0 | 12,7% |
| **ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២)** | | | | 15.501.469,0 | 17.460.006,0 | 1.958.537,0 | 12,6% |
| **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | | | | 15.501.469,0 | 17.460.006,0 | 1.958.537,0 | 12,6% |
| **ប្រភេទទី១: ចំណូលសារពើពន្ធ** | | | | 13.209.100,0 | 15.075.562,0 | 1.866.462,0 | 14,1% |
| 70 | | | **ចំណូលសារពើពន្ធក្នុងស្រុក** | 11.009.500,0 | 12.934.062,0 | 1.924.562,0 | 17,5% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 3.276.600,0 | 3.899.300,0 | 622.700,0 | 19,0% |
| | | 70011 | ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) | 210.000,0 | 210.000,0 | 0,0 | 0,0% |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 2.190.000,0 | 2.662.000,0 | 472.000,0 | 21,6% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 620.600,0 | 724.000,0 | 103.400,0 | 16,7% |
| | | 70014 | ពន្ធលើឈ្នួលចលនទ្រព្យនិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 200.000,0 | 236.000,0 | 36.000,0 | 18,0% |
| | | 70015 | ពន្ធលើឈ្នួលចលនទ្រព្យនិងអចលនទ្រព្យ (នីតិបុគ្គល) | 56.000,0 | 67.300,0 | 11.300,0 | 20,2% |
| | 7002 | | ពន្ធប្រយោល | 4.574.400,0 | 4.962.262,0 | 387.862,0 | 8,5% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1.745.000,0 | 1.938.758,0 | 193.758,0 | 11,1% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រើងតន្ទន:) | 750.000,0 | 590.000,0 | -160.000,0 | -21,3% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.835.000,0 | 2.150.000,0 | 315.000,0 | 17,2% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល (ជាបន្ទុករបស់រដ្ឋ) | 244.400,0 | 283.504,0 | 39.104,0 | 16,0% |
| | 7003 | | អាករពិសេស | 3.060.000,0 | 3.974.000,0 | 914.000,0 | 29,9% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 700.000,0 | 729.000,0 | 29.000,0 | 4,1% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រើងតន្ទន:) | 360.000,0 | 760.000,0 | 400.000,0 | 111,1% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.920.000,0 | 2.405.000,0 | 485.000,0 | 25,3% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 80.000,0 | 80.000,0 | 0,0 | 0,0% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 98.500,0 | 98.500,0 | 0,0 | 0,0% |
| | | 70081 | ពន្ធតែមប្រ៊ី | 8.500,0 | 8.500,0 | 0,0 | 0,0% |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 90.000,0 | 90.000,0 | 0,0 | 0,0% |
| 71 | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | 2.199.600,0 | 2.141.500,0 | -58.100,0 | -2,6% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.149.800,0 | 2.095.700,0 | -54.100,0 | -2,5% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.430.000,0 | 1.450.000,0 | 20.000,0 | 1,4% |
| | | 71002 | តម្រៃពីការងារគយ | 72.600,0 | 83.000,0 | 10.400,0 | 14,3% |
| | | 71003 | ពន្ធគយលើផលិតផលតេលសិលា | 320.000,0 | 220.000,0 | -100.000,0 | -31,3% |
| | | 71004 | អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 288.000,0 | 320.000,0 | 32.000,0 | 11,1% |
| | | 71005 | ផលពីការលក់ទំនិញបែអូស និងទំនិញគ្មានការទាមទារ | 1.000,0 | 500,0 | -500,0 | -50,0% |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 36.000,0 | 20.000,0 | -16.000,0 | -44,4% |
| | | 71007 | ការនាំចូល (ជាបន្ទុករបស់រដ្ឋ) | 2.200,0 | 2.200,0 | 0,0 | 0,0% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 49.800,0 | 45.800,0 | -4.000,0 | -8,0% |
| | | 71011 | ឈើនៅលើការនាំចេញឈើ | 14.000,0 | 10.000,0 | -4.000,0 | -28,6% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 33.000,0 | 33.000,0 | 0,0 | 0,0% |

# ការត្រួតត្រាឆ្នាំ២០១៨

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 2.300,0 | 2.300,0 | 0,0 | 0,0% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500,0 | 500,0 | 0,0 | 0,0% |
| | **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | 2.292.369,0 | 2.384.444,0 | 92.075,0 | 4,0% |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | 100.999,3 | 104.515,9 | 3.516,6 | 3,5% |
| | 7200 | | ផលសម្បទាន | 82.353,3 | 85.065,9 | 2.712,6 | 3,3% |
| | | 72001 | ផលពីនេសាទ | 2.650,0 | 2.650,0 | 0,0 | 0,0% |
| | | 72002 | ផលពីព្រៃឈើ | 17.678,0 | 17.412,6 | -265,4 | -1,5% |
| | | 72003 | សម្បទានប្រេងកាត | 400,0 | 6.787,0 | 6.387,0 | 1596,8% |
| | | 72004 | សម្បទានរ៉ែ | 55.625,3 | 50.358,3 | -5.267,0 | -9,5% |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 6.000,0 | 6.500,0 | 500,0 | 8,3% |
| | | 72006 | ចំណតយានជំនិះ | 0,0 | 8,0 | 8,0 | |
| | | 72008 | ផលសម្បទានផ្សេងៗ | 0,0 | 1.350,0 | 1.350,0 | |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ: | 18.646,0 | 19.450,0 | 804,0 | 4,3% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ: | 18.545,0 | 19.450,0 | 905,0 | 4,9% |
| | | 72014 | ប្រាក់ធានារ៉ាប់រងសង្គម | 101,0 | 0,0 | -101,0 | -100,0% |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | 1.957.104,0 | 2.036.610,3 | 79.506,3 | 4,1% |
| | 7300 | | ផលទុនតាមវិស័យ | 722.454,6 | 804.024,4 | 81.569,8 | 11,3% |
| | | 73001 | ផលទុនអាកាសចរស៊ីវិល | 120.110,0 | 134.440,0 | 14.330,0 | 11,9% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 398.090,9 | 438.363,7 | 40.272,8 | 10,1% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 43.131,0 | 45.562,0 | 2.431,0 | 5,6% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូគមនាគមន៍ | 155.565,8 | 181.503,2 | 25.937,4 | 16,7% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 1.233,0 | 1.226,6 | -6,4 | -0,5% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 32,0 | 33,1 | 1,1 | 3,4% |
| | | 73008 | ផលទុនផ្សេងៗទៀត | 4.291,9 | 2.895,8 | -1.396,1 | -32,5% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ: | 85.310,1 | 88.047,9 | 2.737,8 | 3,2% |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 124,0 | 118,0 | -6,0 | -4,8% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 84.598,4 | 87.588,9 | 2.990,5 | 3,5% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 0,0 | 5,0 | 5,0 | |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 470,7 | 270,0 | -200,7 | -42,6% |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬ ខូច | 0,0 | 23,0 | 23,0 | |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬ ខូច | 0,0 | 3,0 | 3,0 | |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬ ខូច | 0,0 | 2,0 | 2,0 | |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ: ផ្សេងៗទៀត | 117,0 | 38,0 | -79,0 | -67,5% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 28.855,5 | 29.385,5 | 530,0 | 1,8% |
| | | 73022 | ផលពីការបង្កើតសហគ្រាស | 23.274,2 | 21.478,4 | -1.795,8 | -7,7% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 443,3 | 2.437,5 | 1.994,2 | 449,9% |
| | | 73026 | ផលពីប្រាក់ពិន័យ | 3.635,6 | 3.903,0 | 267,4 | 7,4% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.502,4 | 1.566,6 | 64,2 | 4,3% |
| | 7304 | | ផលប្រយោជន៍សេវាកម្ម | 79.451,2 | 65.925,0 | -13.526,2 | -17,0% |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| | | 73042 | កម្រៃនៃការថែទាំ | 8.614,5 | 9.270,8 | 656,3 | 7,6% |
| | | 73043 | សេវាសុរិយោដី | 30.550,0 | 36.099,7 | 5.549,7 | 18,2% |
| | | 73044 | សេវាសំណង់ | 9.800,0 | 11.004,4 | 1.204,4 | 12,3% |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 1.918,8 | 2.376,0 | 457,2 | 23,8% |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 500,0 | 1.000,0 | 500,0 | 100,0% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 28.067,9 | 6.174,1 | -21.893,8 | -78,0% |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 304.080,1 | 268.332,6 | -35.747,5 | -11,8% |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 151.750,0 | 186.511,0 | 34.761,0 | 22,9% |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 1.430,0 | 1.930,5 | 500,5 | 35,0% |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 0,0 | 30,0 | 30,0 | |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 25.400,1 | 36.403,1 | 11.003,0 | 43,3% |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 125.500,0 | 43.458,0 | -82.042,0 | -65,4% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 30.200,0 | 28.182,1 | -2.017,9 | -6,7% |
| | | 73071 | ការជួលដីទំនេរ | 12.663,5 | 11.122,1 | -1.541,4 | -12,2% |
| | | 73072 | ការជួលដីមានអគារ | 13.182,6 | 13.393,9 | 211,3 | 1,6% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 4.154,7 | 3.278,9 | -875,8 | -21,1% |
| | | 73074 | ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 102,5 | 297,2 | 194,7 | 190,0% |
| | | 73078 | ផលពីការជួលផ្សេងៗ | 96,7 | 90,0 | -6,7 | -6,9% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 706.752,5 | 752.712,8 | 45.960,3 | 6,5% |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 158.000,0 | 182.499,2 | 24.499,2 | 15,5% |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 413.906,0 | 428.208,9 | 14.302,9 | 3,5% |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 0,0 | 3.500,0 | 3.500,0 | |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 8.100,0 | 7.036,3 | -1.063,7 | -13,1% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 9.732,7 | 9.185,0 | -547,7 | -5,6% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 4.974,9 | 5.368,9 | 394,0 | 7,9% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 112.038,9 | 116.914,5 | 4.875,6 | 4,4% |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **29.905,9** | **36.049,8** | **6.143,9** | **20,5%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 25.902,9 | 23.837,8 | -2.065,1 | -8,0% |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 17.500,0 | 14.000,0 | -3.500,0 | -20,0% |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 8.402,9 | 9.837,8 | 1.434,9 | 17,1% |
| | 7403 | | ចំណូលពីការរឹបអូស | 4.000,0 | 12.150,0 | 8.150,0 | 203,8% |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 4.000,0 | 12.150,0 | 8.150,0 | 203,8% |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 3,0 | 62,0 | 59,0 | 1966,7% |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 3,0 | 62,0 | 59,0 | 1966,7% |
| | | | **ការឧបត្ថម្ភ និង អំណោយ** | **131.938,8** | **124.733,0** | **-7.205,8** | **-5,5%** |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 131.938,8 | 124.733,0 | -7.205,8 | -5,5% |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | 1.504,3 | 1.853,0 | 348,7 | 23,2% |
| | | 76082 | ផលពីការរួមចំណែកការពារព្រៃឈើ | 85,5 | 80,0 | -5,5 | -6,4% |
| | | 75088 | ចំណូលពីប្រភពផ្សេងៗទៀត | 130.349,0 | 122.800,0 | -7.549,0 | -5,8% |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| 76 | | | **ផលហិរញ្ញវត្ថុ** | 72.421,0 | 82.526,0 | 10.105,0 | 14,0% |
| | 7601 | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | 72.421,0 | 82.526,0 | 10.105,0 | 14,0% |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 72.421,0 | 82.526,0 | 10.105,0 | 14,0% |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | 0,0 | 9,0 | 9,0 | |
| | 7704 | | ចំណូលពីការលក់អគារដម្រះបញ្ជីសារពើភណ្ឌ | 0,0 | 3,0 | 3,0 | |
| | | 77041 | ចំណូលពីការលក់អគារដម្រះបញ្ជីសារពើភណ្ឌ | 0,0 | 3,0 | 3,0 | |
| | 7705 | | ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារ ជាអចលនវត្ថុ | 0,0 | 6,0 | 6,0 | |
| | | 77052 | ចំណូលពីការលក់រថយន្ត | 0,0 | 3,0 | 3,0 | |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | 0,0 | 3,0 | 3,0 | |
| **ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២)** | | | | 398.431,0 | 430.193,0 | 31.762,0 | 8,0% |
| **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | | | | 398.431,0 | 430.193,0 | 31.762,0 | 8,0% |
| **ប្រភេទទី១ : ចំណូលពីប្រភពថ្លាល់** | | | | 148.431,0 | 180.193,0 | 31.762,0 | 21,4% |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | 148.431,0 | 180.193,0 | 31.762,0 | 21,4% |
| | 2701 | | ការឱ្យខ្ចី (ការសងវិញនូវមូលធន) | 148.431,0 | 180.193,0 | 31.762,0 | 21,4% |
| | | 27011 | ការឱ្យខ្ចី ទៅសហគ្រាសសាធារណៈ | 148.431,0 | 180.193,0 | 31.762,0 | 21,4% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | 250.000,0 | 250.000,0 | 0,0 | 0,0% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 88.000,0 | 125.000,0 | 37.000,0 | 42,0% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយនិយោគ | 88.000,0 | 125.000,0 | 37.000,0 | 42,0% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយនិយោគ | 88.000,0 | 125.000,0 | 37.000,0 | 42,0% |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | 162.000,0 | 125.000,0 | -37.000,0 | -22,8% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 162.000,0 | 125.000,0 | -37.000,0 | -22,8% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 162.000,0 | 125.000,0 | -37.000,0 | -22,8% |
| **II. សរុបចំណូលអនុវត្តក្រៅតេឌាគារជាតិ** | | | | 4.284.557,0 | 4.546.939,0 | 262.382,0 | 6,1% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | 4.284.557,0 | 4.546.939,0 | 262.382,0 | 6,1% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 599.838,0 | 591.102,0 | -8.736,0 | -1,5% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយនិយោគ | 599.838,0 | 591.102,0 | -8.736,0 | -1,5% |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយនិយោគ | 599.838,0 | 295.551,0 | -304.287,0 | -50,7% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយនិយោគ | 0,0 | 295.551,0 | 295.551,0 | |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | 3.684.719,0 | 3.955.837,0 | 271.118,0 | 7,4% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 3.684.719,0 | 3.955.837,0 | 271.118,0 | 7,4% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 3.684.719,0 | 2.373.503,0 | -1.311.216,0 | -35,6% |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | 0,0 | 1.582.334,0 | 1.582.334,0 | |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ចំណុច | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| **សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II)** | | | | 1.085.239,0 | 1.090.233,0 | 4.994,0 | 0,5% |
| **I. សរុបចំណូលឆ្លងកាត់រតនាគារជាតិ (ក+ខ)** | | | | 1.085.239,0 | 1.090.233,0 | 4.994,0 | 0,5% |
| **ក្នុងនោះចំណូលក្នុងប្រទេស** | | | | 1.085.239,0 | 1.090.233,0 | 4.994,0 | 0,5% |
| **ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២)** | | | | 1.085.239,0 | 1.090.233,0 | 4.994,0 | 0,5% |
| **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | | | | 1.085.239,0 | 1.090.233,0 | 4.994,0 | 0,5% |
| **ប្រភេទទី១: ចំណូលសារពើពន្ធ** | | | | 926.300,0 | 910.443,0 | -15.857,0 | -1,7% |
| 70 | | | **ចំណូលសារពើពន្ធក្នុងស្រុក** | 926.300,0 | 910.443,0 | -15.857,0 | -1,7% |
| | 7003 | | អាករពិសេស | 161.205,0 | 167.922,0 | 6.717,0 | 4,2% |
| | | 70035 | អាកសម្រាប់បំភ្លឺសាធារណៈ | 161.205,0 | 167.922,0 | 6.717,0 | 4,2% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 19.329,0 | 19.218,0 | -111,0 | -0,6% |
| | | 70045 | អាករលើការស្នាក់នៅ | 17.369,0 | 19.218,0 | 1.849,0 | 10,6% |
| | | 70046 | ពន្ធសត្តឃាត | 1.960,0 | 0,0 | -1.960,0 | -100,0% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 230.057,0 | 250.913,0 | 20.856,0 | 9,1% |
| | | 70053 | ពន្ធប៉ាតង់ | 43.788,0 | 46.541,0 | 2.753,0 | 6,3% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 186.269,0 | 204.372,0 | 18.103,0 | 9,7% |
| | 7006 | | ពន្ធប្រថាប់ត្រា | 401.645,0 | 367.998,0 | -33.647,0 | -8,4% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 383.630,0 | 349.029,0 | -34.601,0 | -9,0% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 7.453,0 | 7.415,0 | -38,0 | -0,5% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 562,0 | 740,0 | 178,0 | 31,7% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្តត់ផ្តង់ទំនិញ ឬ សេវា | 6.296,0 | 6.144,0 | -152,0 | -2,4% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 3.704,0 | 4.670,0 | 966,0 | 26,1% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 114.064,0 | 104.392,0 | -9.672,0 | -8,5% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 103.524,0 | 93.032,0 | -10.492,0 | -10,1% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 5.658,0 | 6.940,0 | 1.282,0 | 22,7% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 4.882,0 | 4.420,0 | -462,0 | -9,5% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | 158.939,0 | 179.790,0 | 20.851,0 | 13,1% |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | 6.918,9 | 18.007,4 | 11.088,5 | 160,3% |
| | 7200 | | ផលសម្បទាន | 6.918,9 | 18.007,4 | 11.088,5 | 160,3% |
| | | 72004 | សម្បទានរ៉ែ | 5.009,0 | 5.377,1 | 368,1 | 7,3% |
| | | 72006 | ចំណតយានជំនិះ | 1.657,1 | 1.860,0 | 202,9 | 12,2% |
| | | 72007 | ចំណតផលយាន | 249,3 | 261,8 | 12,5 | 5,0% |
| | | 72008 | ផលសម្បទានផ្សេងៗ | 3,5 | 10.508,5 | 10.505,0 | 300142,9% |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | 23.307,1 | 12.956,6 | -10.350,5 | -44,4% |
| | 7300 | | ផលទុនតាមវិស័យ | 11.526,4 | 18,0 | -11.508,4 | -99,8% |
| | | 73008 | ផលទុនផ្សេងៗទៀត | 11.526,4 | 18,0 | -11.508,4 | -99,8% |
| | 7301 | | តារាលើទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 0,0 | 10,0 | 10,0 | |
| | | 73011 | ការប្រគល់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | | 10,0 | 10,0 | |
| | 7302 | | ផ្សេងៗការគ្រប់គ្រងរដ្ឋបាល (1) | 1.863,0 | 1.982,3 | 119,3 | 6,4% |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ទឹកប្រាក់ | ភាគរយ |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.863,0 | 1.982,3 | 119,3 | 6,4% |
| | 7304 | | ការផ្តល់សេវាកម្ម | 1.035,0 | 1.088,0 | 53,0 | 5,1% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 1.035,0 | 1.088,0 | 53,0 | 5,1% |
| | 7305 | | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងទៀត | 7.459,0 | 8.133,2 | 674,2 | 9,0% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 937,5 | 1.013,9 | 76,4 | 8,1% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 1.631,5 | 1.716,6 | 85,1 | 5,2% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 982,3 | 948,5 | -33,8 | -3,4% |
| | | 73054 | ចំណូលពីឃ្មៀត្រី និងកន្លែងបែងចែកផលិតផល | 119,3 | 322,7 | 203,4 | 170,5% |
| | | 73055 | ចំណូលពីកាស៊ីផ្សារ | 3.605,6 | 3.618,7 | 13,1 | 0,4% |
| | | 73058 | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងៗ | 182,8 | 512,8 | 330,0 | 180,5% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 57,0 | 59,4 | 2,4 | 4,2% |
| | | 73071 | ការជួលដីទំនេរ | | 2,4 | 2,4 | |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 57,0 | 57,0 | 0,0 | 0,0% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 1.366,7 | 1.665,7 | 299,0 | 21,9% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 1.366,7 | 1.665,7 | 299,0 | 21,9% |
| 74 | | | **ចំណូលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម** | 3,0 | 12,0 | 9,0 | 300,0% |
| | 7401 | | ផលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម | 3,0 | 0,0 | -3,0 | -100,0% |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 3,0 | 0,0 | -3,0 | -100,0% |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 0,0 | 12,0 | 12,0 | |
| | | 74081 | ផលពីការពិន័យផ្សេងៗ | | 12,0 | 12,0 | |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 128.710,0 | 148.814,0 | 20.104,0 | 15,6% |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | 128.710,0 | 148.814,0 | 20.104,0 | 15,6% |
| | | 75011 | ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន | 128.710,0 | 148.814,0 | 20.104,0 | 15,6% |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ខ១"

## ចំណាយថវិកាជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ការខ្ចី | ប្រភេទទី២ អចលកម្ម |
| សរុបរួមចំណាយ | 23.428.298,0 | 15.218.166,0 | 11.207.810,2 | 387.481,0 | 2.469.998,0 | 476.372,8 | 676.504,0 | 8.210.132,0 | 737.393,0 | 7.472.739,0 |
| រដ្ឋបាលកណ្តាល | 14.300.122,8 | 10.636.929,8 | 6.821.519,2 | 387.481,0 | 2.276.434,6 | 474.991,0 | 676.504,0 | 3.663.193,0 | 737.393,0 | 2.925.800,0 |
| -ក្នុងនោះ:គ្រឹះស្ថានសាធារណៈរដ្ឋបាល | 203.959,3 | 203.959,3 | | | 203.959,3 | | | 0 | | 0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 4.581.236,2 | 4.581.236,2 | 4.386.291,0 | | 193.563,4 | 1.381,8 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.546.939,0 | | | | | | | 4.546.939,0 | | 4.546.939,0 |
| ក. វិស័យរដ្ឋបាលទូទៅ | 2.453.007,5 | 2.263.303,9 | 1.398.880,0 | | 391.353,0 | 473.070,9 | | 189.703,6 | | 189.703,6 |
| រដ្ឋបាលកណ្តាល | 2.105.613,9 | 2.089.113,9 | 1.224.806,3 | | 391.353,0 | 472.954,6 | | 16.500,0 | | 16.500,0 |
| -ក្នុងនោះ:គ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.357,0 | 8.357,0 | | | 8.357,0 | | | 0,0 | | 0,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 174.190,0 | 174.190,0 | 174.073,7 | | | 116,3 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 173.203,6 | | | | | | | 173.203,6 | | 173.203,6 |
| ០១. ព្រះបរមរាជវាំង | 94.699,0 | 94.699,0 | 74.610,0 | | 19.880,0 | 209,0 | | 0,0 | | 0,0 |
| ០២. ផ្នែសភា | 180.887,7 | 180.887,7 | 175.469,9 | | 5.302,0 | 115,8 | | 0,0 | | 0,0 |
| ០៣. ព្រឹទ្ធសភា | 73.617,0 | 73.617,0 | 68.537,0 | | 5.000,0 | 80,0 | | 0,0 | | 0,0 |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 11.695,0 | 11.695,0 | 11.577,0 | | 98,0 | 20,0 | | 0,0 | | 0,0 |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 553.973,1 | 409.132,0 | 132.119,0 | | 276.863,0 | 150,0 | | 144.841,1 | | 144.841,1 |
| -ក្នុងនោះ:គ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.357,0 | 8.357,0 | | | 8.357,0 | | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 144.841,1 | | | | | | | 144.841,1 | | 144.841,1 |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 15.040,0 | 15.040,0 | 15.020,0 | | | 20,0 | | 0,0 | | 0,0 |
| ០៨. ក្រសួងទំនាក់ទំនងផ្នែសភា ព្រឹទ្ធសភា និងអធិការកិច្ច | 38.956,0 | 38.956,0 | 38.889,0 | | 25,0 | 42,0 | | 0,0 | | 0,0 |
| ១. រដ្ឋបាលកណ្តាល | 23.278,0 | 23.278,0 | 23.233,0 | | 25,0 | 20,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 15.678,0 | 15.678,0 | 15.656,0 | | | 22,0 | | 0,0 | | 0,0 |
| ០៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 123.854,0 | 123.854,0 | 116.849,0 | | 5.730,0 | 1.275,0 | | 0,0 | | 0,0 |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 788.393,8 | 772.539,7 | 259.281,7 | | 42.545,0 | 470.713,0 | | 15.854,1 | | 15.854,1 |
| ១. រដ្ឋបាលកណ្តាល | 745.916,7 | 745.916,7 | 232.691,7 | | 42.545,0 | 470.680,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 26.623,0 | 26.623,0 | 26.590,0 | | | 33,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 15.854,1 | | | | | | | 15.854,1 | | 15.854,1 |
| ១៤. ក្រសួងផែនការ | 79.886,0 | 79.886,0 | 79.750,3 | | 60,0 | 75,7 | | 0,0 | | 0,0 |
| ១. រដ្ឋបាលកណ្តាល | 40.678,0 | 40.678,0 | 40.568,0 | | 60,0 | 50,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 39.208,0 | 39.208,0 | 39.182,3 | | | 25,7 | | 0,0 | | 0,0 |
| ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 177.803,0 | 150.103,0 | 125.002,4 | | 25.047,0 | 53,6 | | 27.700,0 | | 27.700,0 |
| ១. រដ្ឋបាលកណ្តាល | 90.925,0 | 74.425,0 | 49.353,0 | | 25.047,0 | 25,0 | | 16.500,0 | | 16.500,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 75.678,0 | 75.678,0 | 75.649,4 | | | 28,6 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 11.200,0 | | | | | | | 11.200,0 | | 11.200,0 |
| ៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 208.524,0 | 208.524,0 | 208.352,2 | | 2,0 | 169,8 | | 0,0 | | 0,0 |
| ៣១. អាជ្ញាធរសវនកម្មជាតិ | 13.810,0 | 13.810,0 | 13.781,0 | | 9,0 | 20,0 | | 0,0 | | 0,0 |
| ៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ | 43.504,4 | 42.600,0 | 42.470,0 | | 30,0 | 100,0 | | 904,4 | | 904,4 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 904,4 | | | | | | | 904,4 | | 904,4 |
| ៣៤. ក្រសួងមុខងារសាធារណៈ | 48.364,5 | 47.960,5 | 37.171,5 | | 10.762,0 | 27,0 | | 404,0 | | 404,0 |
| ១. រដ្ឋបាលកណ្តាល | 30.957,5 | 30.957,5 | 20.175,5 | | 10.762,0 | 20,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 17.003,0 | 17.003,0 | 16.996,0 | | | 7,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 404,0 | | | | | | | 404,0 | | 404,0 |
| ខ. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 4.005.664,5 | 3.894.376,0 | 3.839.131,0 | | 55.188,0 | 57,0 | | 111.288,5 | | 111.288,5 |
| រដ្ឋបាលកណ្តាល | 3.873.749,0 | 3.819.149,0 | 3.763.918,0 | | 55.188,0 | 43,0 | | 54.600,0 | | 54.600,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 75.227,0 | 75.227,0 | 75.213,0 | | | 14,0 | | 0,0 | | 0,0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 56.688,5 | | | | | | | 56.688,5 | | 56.688,5 |
| ០៦. [illegible] | 2.198.378,0 | 2.198.378,0 | 2.177.640,0 | | 20.738,0 | | | 0,0 | | 0,0 |
| ០៧. [illegible] | 1.407.095,0 | 1.394.095,0 | 1.364.451,0 | | 29.644,0 | | | 13.000,0 | | 13.000,0 |
| [illegible] | 252.624,8 | 163.582,0 | 161.549,0 | | 2.020,0 | 13,0 | | 89.042,8 | | 89.042,8 |
| [illegible] | 205.182,0 | 163.582,0 | 161.549,0 | | 2.020,0 | 13,0 | | 41.600,0 | | 41.600,0 |
| [illegible] | 47.442,8 | | | | | | | 47.442,8 | | 47.442,8 |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប ចំណាយ ចរន្ត | ប្រភេទទី១ មធ្យោបាយ និងសេវា | ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ប្រភេទទី៤ ចំណាយ ផ្សេងៗ | ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | សរុប ចំណាយ មូលធន | ប្រភេទទី១ ការទូទាត់ ការខ្ចី | ប្រភេទទី២ អចលករម្ម |
| ២៦. ក្រសួងយុត្តិធម៌ | 147.566,7 | 138.321,0 | 135.491,0 | | 2.786,0 | 44,0 | | 9.245,7 | | 9.245,7 |
| ១. យុត្តិធម៌ | 42.312,0 | 42.312,0 | 39.528,0 | | 2.764,0 | 20,0 | | 0,0 | | 0,0 |
| ២. តុលាការកំពូល | 7.826,0 | 7.826,0 | 7.798,0 | | 22,0 | 6,0 | | 0,0 | | 0,0 |
| ៣. សាលាឧទ្ធរណ៍ | 7.220,0 | 7.220,0 | 7.220,0 | | | | | 0,0 | | 0,0 |
| ៤. ក្រុមប្រឹក្សានៃអង្គចៅក្រម | 5.736,0 | 5.736,0 | 5.732,0 | | | 4,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 75.227,0 | 75.227,0 | 75.213,0 | | | 14,0 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 9.245,7 | | | | | | | 9.245,7 | | 9.245,7 |
| **គ. វិស័យសង្គមកិច្ច** | **7.014.099,8** | **5.658.959,4** | **4.662.067,0** | | **995.548,0** | **1.344,4** | | **1.355.140,4** | | **1.355.140,4** |
| រដ្ឋបាលកណ្តាល | 2.095.371,2 | 1.675.371,2 | 864.052,0 | | 810.656,1 | 663,1 | | 420.000,0 | | 420.000,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 165.552,5 | 165.552,5 | | | 165.552,5 | | | 0,0 | | 0,0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 3.983.588,2 | 3.983.588,2 | 3.798.015,0 | | 184.891,9 | 681,3 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 935.140,4 | | | | | | | 935.140,4 | | 935.140,4 |
| ១១. ក្រសួងព័ត៌មាន | 82.163,2 | 78.294,2 | 77.988,9 | | 276,0 | 29,3 | | 3.869,0 | | 3.869,0 |
| ១. រដ្ឋបាលកណ្តាល | 53.613,2 | 53.613,2 | 53.314,2 | | 276,0 | 23,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 24.681,0 | 24.681,0 | 24.674,7 | | | 6,3 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 3.869,0 | | | | | | | 3.869,0 | | 3.869,0 |
| ១២. ក្រសួងសុខាភិបាល | 1.967.851,0 | 1.393.974,0 | 771.634,0 | | 621.791,0 | 549,0 | | 573.877,0 | | 573.877,0 |
| ១. រដ្ឋបាលកណ្តាល | 820.304,0 | 820.304,0 | 289.498,0 | | 530.560,0 | 246,0 | | 0,0 | | 0,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 47.072,0 | 47.072,0 | | | 47.072,0 | | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 573.670,0 | 573.670,0 | 482.136,0 | | 91.231,0 | 303,0 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 573.877,0 | | | | | | | 573.877,0 | | 573.877,0 |
| ១៦. ក្រសួងអប់រំ យុវជន និងកីឡា | 3.438.007,5 | 2.705.456,5 | 2.544.628,3 | | 160.426,2 | 402,0 | | 732.551,0 | | 732.551,0 |
| ១. អប់រំ | 658.160,2 | 238.160,2 | 195.735,5 | | 42.302,3 | 122,4 | | 420.000,0 | | 420.000,0 |
| ២. ឧត្តមសិក្សា | 42.512,0 | 42.512,0 | 37.433,5 | | 5.072,8 | 5,7 | | 0,0 | | 0,0 |
| ៣. យុវជននិងកីឡា | 55.150,7 | 55.150,7 | 20.194,5 | | 34.956,2 | | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 2.369.633,6 | 2.369.633,6 | 2.291.264,8 | | 78.094,9 | 273,9 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 312.551,0 | | | | | | | 312.551,0 | | 312.551,0 |
| ១៨. ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | 190.719,3 | 190.101,4 | 86.188,6 | | 103.861,3 | 51,5 | | 617,9 | | 617,9 |
| ១. រដ្ឋបាលកណ្តាល | 160.601,7 | 160.601,7 | 56.951,4 | | 103.605,3 | 45,0 | | 0,0 | | 0,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 98.381,0 | 98.381,0 | | | 98.381,0 | | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 29.499,7 | 29.499,7 | 29.237,2 | | 256,0 | 6,5 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 617,9 | | | | | | | 617,9 | | 617,9 |
| ១៩. ក្រសួងបរិស្ថាន | 110.075,4 | 82.357,0 | 79.825,0 | | 2.426,0 | 106,0 | | 27.718,4 | | 27.718,4 |
| ១. រដ្ឋបាលកណ្តាល | 41.951,0 | 41.951,0 | 39.450,0 | | 2.426,0 | 75,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 40.406,0 | 40.406,0 | 40.375,0 | | | 31,0 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 27.718,4 | | | | | | | 27.718,4 | | 27.718,4 |
| ២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 890.826,4 | 887.312,0 | 833.677,0 | | 53.579,5 | 55,5 | | 3.514,4 | | 3.514,4 |
| ១. រដ្ឋបាលកណ្តាល | 65.811,5 | 65.811,5 | 25.092,0 | | 40.684,5 | 35,0 | | 0,0 | | 0,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 14.426,6 | 14.426,6 | | | 14.426,6 | | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានី ខេត្ត | 821.500,5 | 821.500,5 | 808.585,0 | | 12.895,0 | 20,5 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 3.514,4 | | | | | | | 3.514,4 | | 3.514,4 |
| ២៣. ក្រសួងធម្មការនិងសាសនា | 64.935,0 | 64.504,3 | 62.814,2 | | 1.678,0 | 12,1 | | 430,7 | | 430,7 |
| ១. រដ្ឋបាលកណ្តាល | 24.556,5 | 24.556,5 | 23.218,5 | | 1.328,0 | 10,0 | | 0,0 | | 0,0 |
| ៩. មន្ទីរជំនាញរាជធានីខេត្ត | 39.947,8 | 39.947,8 | 39.595,7 | | 350,0 | 2,1 | | 0,0 | | 0,0 |
| ថវិកាយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 430,7 | | | | | | | 430,7 | | 430,7 |

# ការគ្រប់គ្រងឆ្នាំ២០១៨

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត | | | | | | ចំណាយមូលធន | | |
|---|---|---|---|---|---|---|---|---|---|---|
